

# មេរៀនជ្រមុជទឹក

ដោយ ប៊ូ ឈុំ

មាតិកា ទំព័រ

ព្រះបន្ទូលនៃព្រះ ........................................ I
សេចក្តីណែនាំ........................................ III
ការត្រាស់ហៅ........................................ ១
ព្រះអម្ចាស់ផ្ទាល់ត្រាស់ហៅអ្នក........................................ ២៨
ការត្រាស់ហៅរបស់ព្រះអម្ចាស់........................................ ៤១
មើលការត្រាស់ហៅរបស់អ្នក........................................ ៧០

បទគម្ពីរចម្លងក្នុងខិត្តប័ណ្ណនេះ
ដកស្រង់ចេញពីគម្ពីរបោះពុម្ព ឆ្នាំ១៩៥៤

«...ឯសេចក្ដីពិត គឺជាព្រះបន្ទូលរបស់ទ្រង់»
(យ៉ូហាន១៧:១៧)
«អ្នករាល់គ្នានឹងស្គាល់សេចក្ដីពិត ហើយសេចក្ដីពិតនោះ នឹងប្រោសឲ្យអ្នករាល់គ្នាបានរួច»
(យ៉ូហាន៨:៣២)


**ខ្មែរស្ទួនគ្នាហៅសំរាប់ព្រះ**

*Khmer Brethren Called for God*

sabbathreflections.org

**Chumbou2020@gmail.com**

***016 509 779/ 097 990 6244***

***011 435 441***

# ព្រះបន្ទូលរបស់ព្រះ

«ឱព្រះយេហូវ៉ាអើយ ព្រះបន្ទូលទ្រង់បានតាំង នៅស្ថានសួគ៌ ដរាបដល់អស់កល្បជានិច្ច»
( ទំនុក ដំកើង១១៩:៨៩)

«ផ្ទៃមេឃ ហើយផែនដីនឹងកន្លងបាត់ទៅ តែពាក្យខ្ញុំមិនដែលបាត់ឡើយ» (ម៉ាថាយ២៤:៣៥)

«ដ្បិតទ្រង់បានដំកើងព្រះបន្ទូលទ្រង់ ឲ្យធំលើព្រះនាមទ្រង់ទៅទៀត»( ទំនុកដំកើង១៣៨:២)

«ឯព្រះបន្ទូលនៃព្រះយេហូវ៉ា នោះសុទ្ធស្អាតទាំងអស់ គឺដូចប្រាក់ដែលគេសាកក្នុងបាវធ្វើពីដី ហើយបានសំរង់អស់៧ដងផង»( ទំនុកដំកើង១២:៦)

«គ្រប់ទាំងព្រះបន្ទូលនៃព្រះ សុទ្ធតែបរិសុទ្ធ ទ្រង់ជាខែល ដល់អស់អ្នកដែលពឹងជ្រកក្នុងទ្រង់ កុំឲ្យបន្ថែម បញ្ចូលក្នុងព្រះបន្ទូលទ្រង់ឡើយ ក្រែងទ្រង់បន្ទោសដល់ឯង ហើយឃើញថា ឯងជាមនុស្សភូតភរ» (សុភាសិត៣០:៥-៦)

«សូមញែកគេចេញជាបរិសុទ្ធ ដោយសារសេចក្តីពិតរបស់ទ្រង់ ឯសេចក្តីពិត គឺជាព្រះបន្ទូលរបស់ទ្រង់» (យ៉ូហាន១៧:១៧)

«សេចក្តីសុចរិតរបស់ទ្រង់ ជាសេចក្តីសុចរិតដ៏នៅអស់កល្បជានិច្ច ហើយក្រិត្យវិន័យទ្រង់ជាសេចក្តីពិត» ( ទំនុកដំកើង១១៩:១៤២)

«ឯទ្រង់ ឱព្រះយេហូវ៉ាអើយ ទ្រង់គង់នៅជិតដែរ ហើយគ្រប់ទាំងសេចក្តីបង្គាប់របស់ទ្រង់ សុទ្ធតែពិតត្រង់» ( ទំនុកដំកើង១១៩:១៥១)

# ព្រះបន្ទូលរបស់ព្រះ(គ)

«ព្រះបន្ទូលនៃទ្រង់ជាចង្កៀងដល់ជើងទូលបង្គំ ហើយជាពន្លឺបំភ្លឺផ្លូវរបស់ទូលបង្គំផង»
( ទំនុកដំកើង១១៩:១០៥)

«ទូលបង្គំបានកំណត់ចាំព្រះបន្ទូលទុកនៅក្នុងចិត្ត ប្រយោជន៍កុំឲ្យទូលបង្គំធ្វើបាបនឹងទ្រង់ឡើយ»
( ទំនុកដំកើង១១៩:១១)

«ទូលបង្គំរង់ចាំព្រះយេហូវ៉ា គឺព្រលឹងទូលបង្គំរង់ចាំទ្រង់ ទូលបង្គំសង្ឃឹមដល់ព្រះបន្ទូលនៃទ្រង់»
( ទំនុកដំកើង១៣០:៥)

«ហេតុនោះបានជាទូលបង្គំស្រឡាញ់ ដល់សេចក្ដីបង្គាប់របស់ទ្រង់លើសជាងមាស អើ ក៏ស្រឡាញ់ ច្រើនជាងមាសសុទ្ធផង ដូច្នេះ ទូលបង្គំរាប់អស់ទាំងបញ្ញត្តិទ្រង់ថា ជាត្រឹមត្រូវគ្រប់ប្រការ តែទូលបង្គំ ស្អប់ដល់គ្រប់ទាំងផ្លូវកំភូតវិញ» ( ទំនុកដំកើង១១៩:១២៧-២៨)

«ពីព្រោះ ឯព្រះបន្ទូលនៃព្រះនោះរស់នៅ ហើយពូកែផង ក៏មុតជាងដាវណាមានមុខ២ ទាំងធ្លុះចូល ទៅ ទាល់តែកាត់ព្រលឹងនឹងវិញ្ញាណ ហើយសន្លាក់ នឹងខួរឆ្អឹងដាច់ពីគ្នា ទាំងពិចារណាអស់ទាំងគំនិត ដែលចិត្តគិត ហើយដែលសំរេចដែរ» ( ហេព្រើរ៤:១២)

«ដ្បិតព្រះអង្គ ដែលព្រះបានចាត់ឲ្យមក ទ្រង់មានបន្ទូលតាមព្រះបន្ទូលនៃព្រះ ពីព្រោះព្រះទ្រង់មិន ប្រទានវិញ្ញាណបរិសុទ្ធមកឲ្យមានកំរិតទេ» ( យ៉ូហាន៣:៣៤)

«គឺជាវិញ្ញាណដែលឲ្យមានជីវិត រូបសាច់គ្មានប្រយោជន៍អ្វីទេ ឯពាក្យដែលខ្ញុំនិយាយនឹងអ្នករាល់ គ្នា នោះត្រូវខាងវិញ្ញាណ នឹងជីវិតវិញ» ( យ៉ូហាន៦:៦៣)

# សេចក្តីណែនាំ

សព្វថ្ងៃនេះ មានគ្រីស្ទានតិចតួចណាស់ ដែលធ្វើបុណ្យជ្រមុជទឹកដោយពន្លិចខ្លួនទាំងស្រុងទៅក្នុងទឹក។ ទោះជាយ៉ាងណាក្តី ព្រះគម្ពីរសញ្ញាថ្មី បង្រៀនថា ពិធីជ្រមុជទឹកគឺជាការចុះសេចក្តីសន្យានៃសញ្ញាថ្មី។ គ្រឹះរបស់អ្នកជឿ ត្រូវតែធ្វើពិធីជ្រមុជទឹក ដែលជាការចាំបាច់សំរាប់ការអត់ទោសបាប នឹងការទទួលវិញ្ញាណបរិសុទ្ធរបស់ព្រះ តាមរយៈព្រះគុណ អំពីព្រះអម្ចាស់ ការរីកចំរើនឡើងក្នុងព្រះគុណ នឹងការស្គាល់ដល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង ក្នុងការដែលទ្រង់រៀបចំសំរាប់ជីវិតអស់កល្បជានិច្ច ដល់យើងរាល់គ្នា។

គម្ពីរសញ្ញាថ្មី ឬសេចក្តីសញ្ញាថ្មី ពីពិធីជ្រមុជទឹក មានអត្ថន័យយ៉ាងសំខាន់អស្ចារ្យ ចំពោះព្រះដ៏ជាព្រះវរបិតា នឹងចំពោះព្រះអម្ចាស់យេស៊ូវគ្រីស្ទ ហើយនឹងចំពោះអស់អ្នកដែលបានទទួលបុណ្យជ្រមុជទឹក។ គឺជានិមិត្តរូបនៃការបង្ហាញជាសាធារណៈនៃសេចក្តីជំនឿ ដែលមានអត្ថន័យធំធេង នឹងជ្រាលជ្រៅបំផុត។ ពិធីបុណ្យជ្រមុជទឹក គឺជាពិធីចុះសេចក្តីសន្យាថ្មីផ្ទាល់ខ្លួន រវាងអ្នកជឿដែលបានប្រែចិត្តពីអំពើបាប ទៅឯព្រះយេស៊ូវគ្រីស្ទ នឹងព្រះដ៏ជាព្រះវរបិតា។

ការទទួលបុណ្យជ្រមុជទឹក គឺជាការបញ្ចប់នៃការរស់នៅខុសឆ្គង ហើយនឹងចាប់ផ្តើមនៃរបៀបរស់នៅខាងឯវិញ្ញាណថ្មី។ អ្នកត្រូវយល់ពីអំពើបាប ដែលជាការរំលងបញ្ញត្តិ នឹងរំលងច្បាប់របស់ព្រះ។ អ្នកត្រូវតែដឹងថា យញ្ញបូជា នឹងលោហិតរបស់ព្រះយេស៊ូវគ្រីស្ទ តែមួយគត់ សំរាប់លោះអំពើបាបរបស់អ្នក ហើយអ្នកក៏ត្រូវយល់ថា អំពើបាប គឺជាការរំលងបញ្ញត្តិ នឹងច្បាប់របស់ព្រះ។

បន្ទាប់មកនៅពេលមានការប្រែចិត្តពីអំពើបាប នឹងទទួលព្រះយេស៊ូវគ្រីស្ទជាព្រះអង្គសង្គ្រោះផ្ទាល់ខ្លួនរបស់អ្នក សំរាប់ការអត់ទោសបាប។ ក្នុងនាមជាអ្នកជឿថ្មី អ្នកត្រូវតែទទួលបុណ្យជ្រមុជទឹកដោយពន្លិចខ្លួនទាំងស្រុងទៅក្នុងទឹក សំរាប់ការអត់ទោសបាបរបស់អ្នក។ ពិធីបុណ្យជ្រមុជទឹក ជានិមិត្តរូបនៃការស្លាប់របស់អ្នកជឿ ដែលប្រែចិត្តពីអំពើបាប ហើយក៏ជានិមិត្តរូបនៃការទទួលសេចក្តីសុគតរបស់ព្រះយេស៊ូវគ្រីស្ទ។

តាមរយៈបុណ្យជ្រមុជទឹក ដែលសំដែងពីសេចក្តីស្លាប់ អ្នកបានក្លាយជាអ្នកចូលរួមក្នុងសេចក្តី

# សេចក្តីណែនាំ

សញ្ញាថ្មី នៃការឆ្លង នឹងការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ។ ដោយសារព្រះគុណរបស់ព្រះដ៏ជាព្រះវរបិតា នឹងព្រះលោហិតនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ បានសងថ្លៃលោះបាបរបស់អ្នក។ ពេលអ្នកងើបពីទឹក គឺជានិមិត្តរូបនៃការរស់ពីសុគតឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ។ នៅពេលអ្នកជឿងើបពីទឹកឡើងវិញ អ្នកត្រូវដើរក្នុងជីវិតបែបថ្មី ដើម្បីបានរីកចំរើនក្នុងព្រះគុណ នឹងការស្គាល់ដល់ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់។ ដើម្បីក្លាយជាមនុស្សថ្មីនៅក្នុងព្រះអម្ចាស់យេស៊ូវគ្រីស្ទ អ្នកជឿដែលបានទទួលបុណ្យជ្រមុជទឹក ដើម្បីឲ្យបានទទួលអំណោយទានជាវិញ្ញាណបរិសុទ្ធពីព្រះវរបិតា តាមរយៈការអធិស្ឋានដាក់ដៃលើ។ បន្ទាប់មកអ្នកត្រូវបានដឹកនាំដោយវិញ្ញាណបរិសុទ្ធរបស់ព្រះ ឲ្យបានដើរក្នុងការគោរពប្រតិបត្តិដល់ព្រះវរបិតា នឹងមានសេចក្តីជំនឿជឿព្រះយេស៊ូវគ្រីស្ទ ដើម្បីបានចំរើនគំនិតរបស់ព្រះយេស៊ូវគ្រីស្ទដោយរក្សាបញ្ញត្តិ នឹងច្បាប់ទាំងប៉ុន្មានរបស់ព្រះ ដោយអំណាចនៃវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ដើម្បីចំរើនក្នុងព្រះគុណ នឹងចំណេះដឹងរបស់ព្រះយេស៊ូវគ្រីស្ទ ហើយនឹងការស្មោះត្រង់រហូតដល់ចុងបំផុត។ ពិធីជ្រមុជទឹក គឺជាការចុះសន្យានៃសញ្ញាថ្មី ដែលមិនអាចបដិសេធបាន រវាងអ្នក នឹងព្រះដ៏ជាព្រះវរបិតា ហើយនឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

ព្រមព្រៀងទទួលបុណ្យជ្រមុជទឹក គឺព្រមព្រៀងទទួលសេចក្តីសុគតរបស់ព្រះយេស៊ូវគ្រីស្ទ នឹងរស់នៅនៃជីវិតបែបថ្មីរបស់អ្នក នៅក្នុងព្រះគ្រីស្ទយេស៊ូវ ដូចដែលព្រះយេស៊ូវគ្រីស្ទបានសុគតសំរាប់អត់ទោសបាបឲ្យអ្នក ហើយអំពើបាបរបស់អ្នកក៏កប់ទៅក្នុងទឹកនៅក្នុងពិធីជ្រមុជទឹកនោះ ដោយសន្យាថាជីវិតរបស់អ្នកនឹងស្មោះត្រង់រហូតដល់ទីបញ្ចប់។ ប្រសិនបើអ្នកស្មោះត្រង់រហូតដល់ទីបញ្ចប់ នោះអ្នកនឹងទទួលបានជីវិតអស់កល្បជានិច្ច ដោយភាពរុងរឿង នឹងសិរីល្អ ក្នុងកាលបានរស់ពីស្លាប់ឡើងវិញ ពេលព្រះយេស៊ូវគ្រីស្ទទ្រង់យាងត្រឡប់មកផែនដីនេះម្តងទៀត។ សំបុត្ររបស់សាវកប៉ុល លោកសរសេរទៅពួកជំនុំនៅក្រុងរ៉ូម លោកបានបញ្ជាក់យ៉ាងច្បាស់ពីអត្ថន័យពេញលេញនៃពិធីជ្រមុជទឹកដោយពន្លិចខ្លួនទៅក្នុងទឹកទាំងស្រុង- អត្ថន័យនៃពិធីជ្រមុជទឹកៈ

**គម្ពីររ៉ូម៦:១-១៨**

១. «ដូច្នេះ យើងនឹងថាដូចម្តេច តើត្រូវឲ្យយើងចេះតែប្រព្រឹត្តអំពើបាបទៅទៀត ដើម្បីឲ្យព្រះគុណ

# សេចក្ដីណែនាំ

បានចំរើនឡើង ឬអី ២. ទេ មិនត្រូវឡើយ ធ្វើដូចម្ដេចឲ្យយើងដែលស្លាប់ខាងឯអំពើបាបហើយ បាននៅរស់ក្នុងអំពើបាបទៀតបាន ៣. តើអ្នករាល់គ្នាមិនដឹងទេឬអី ថា យើងទាំងប៉ុន្មានដែលបានទទួលបុណ្យជ្រមុជក្នុងព្រះយេស៊ូវគ្រីស្ទ នោះគឺបានទទួលបុណ្យក្នុងសេចក្ដីសុគតនៃទ្រង់ដែរ ៤. ដូច្នេះ យើងបានត្រូវកប់ជាមួយនឹងទ្រង់ហើយ ដោយទទួលជ្រមុជក្នុងសេចក្ដីស្លាប់ ដើម្បីឲ្យយើងបានដើរក្នុងជីវិតបែបថ្មី ដូចជាព្រះគ្រីស្ទបានរស់ពីស្លាប់ឡើងវិញ ដោយសារសិរីល្អនៃព្រះវរបិតាដែរ ៥. ដ្បិតយើងបានជាប់ជាមួយនឹងទ្រង់ ក្នុងកាលដែលជាគំរូពីសេចក្ដីសុគតរបស់ទ្រង់ នោះក៏បានជាប់ក្នុងសេចក្ដីរស់ឡើងវិញរបស់ទ្រង់ដែរ ៦. ដោយដឹងសេចក្ដីនេះថា មនុស្សចាស់របស់យើង បានត្រូវឆ្កាងជាមួយនឹងទ្រង់ហើយ ដើម្បីឲ្យតួអំពើបាបបានត្រូវសូន្យទៅ ប្រយោជន៍កុំឲ្យយើងនៅបំរើអំពើបាបទៀតឡើយ ៧. ដ្បិតអ្នកណាដែលស្លាប់ នោះក៏បានរាប់ជាសុចរិតរួចពីបាបហើយ ៨. បើសិនជាយើងស្លាប់ជាមួយនឹងព្រះគ្រីស្ទ នោះយើងជឿថា យើងនឹងរស់ជាមួយនឹងទ្រង់ដែរ ៩. ដោយដឹងថា ដែលព្រះគ្រីស្ទមានព្រះជន្មរស់ពីស្លាប់ឡើងវិញ នោះទ្រង់មិនចេះសុគតទៀតឡើយ ព្រោះសេចក្ដីស្លាប់គ្មានអំណាចលើទ្រង់ទៀត ១០. ដ្បិតដែលទ្រង់សុគត នោះគឺបានសុគតខាងឯបាប១ដងជាសំរេច ហើយដែលទ្រង់មានព្រះព្រះជន្មរស់ នោះទ្រង់រស់ខាងឯព្រះវិញ ១១. ដូច្នេះ ចូរអ្នករាល់គ្នារាប់ខ្លួនទុកជាស្លាប់ខាងឯបាបដែរ តែរស់ខាងឯព្រះវិញចុះ ដោយនូវព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នា។

១២. ហេតុនេះ កុំឲ្យបាបសោយរាជ្យក្នុងរូបកាយរបស់អ្នករាល់គ្នា ដែលតែងតែស្លាប់ ដើម្បីនឹងស្ដាប់តាមសេចក្ដីប៉ងប្រាថ្នារបស់បាននោះឡើយ ១៣. ក៏កុំឲ្យប្រគល់អវយវៈទាំងប៉ុន្មាន របស់អ្នករាល់គ្នាទៅក្នុងអំពើបាប ទុកដូចជាប្រដាប់ប្រដាទុច្ចរិតនោះឡើយ គឺត្រូវប្រគល់ទៅព្រះ ដូចជាបានរស់ពីស្លាប់ឡើងវិញ ហើយថ្វាយអវយវៈរបស់អ្នករាល់គ្នាទៅព្រះ ទុកដូចជាប្រដាប់ប្រដាសុចរិតផង ១៤. ដ្បិតបាបមិនត្រូវមានអំណាចលើអ្នករាល់គ្នាទៀតឡើយ ដោយព្រោះអ្នករាល់គ្នាមិននៅក្រោមក្រិត្យវិន័យ គឺនៅក្រោមព្រះគុណវិញ។

១៥. ដូច្នេះ ធ្វើដូចម្ដេច តើគួរឲ្យយើងប្រព្រឹត្តអំពើបាប ដោយព្រោះនៅក្រោមព្រះគុណ មិននៅក្រោមក្រិត្យវិន័យឬអី ទេ មិនគួរឡើយ ១៦. តើអ្នករាល់គ្នាមិនដឹងទេឬអី ថាអ្នករាល់គ្នាប្រគល់ខ្លួនទៅ

# សេចក្ដីណែនាំ

ធ្វើជាបាវបំរើនឹងស្ដាប់តាមចៅហ្វាយណា នោះអ្នកជាបាវរបស់ចៅហ្វាយនោះឯង ដែលអ្នកស្ដាប់តាម
ទោះជារបស់ផងអំពើបាប ឲ្យបានសេចក្ដីស្លាប់ ឬជារបស់ផងសេចក្ដីស្ដាប់បង្គាប់ ឲ្យបានសុចរិតក្ដី
១៧. ឯអ្នករាល់គ្នា ពីដើមជាបាវបំរើរបស់អំពើបាបមែន ប៉ុន្តែអរព្រះគុណដល់ព្រះអង្គ ឥឡូវនេះ
បានស្ដាប់ដោយស្មោះត្រង់ពីចិត្ត តាមក្បួននៃលទ្ធិ ដែលបានប្រគល់មកអ្នករាល់គ្នា ១៨. ហើយអ្នក
រាល់គ្នាបានត្រឡប់ជាបាវបំរើនៃសេចក្ដីសុចរិតវិញ ដោយទ្រង់បានប្រោសឲ្យរួចពីអំពើបាបហើយ»

(រ៉ូម៦:១-១៨)

Chum A. Bou

Email:chumbou2020@gmail.com

016 509 779/ 011 435 441/ 097 990 6244/ 010 228 199

# ការត្រាស់ហៅ

នៅពេលថ្មីៗនេះ មានការប្រជុំដ៏សំខាន់មួយ នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក។ មានពួកអ្នកដឹកនាំសាសនាមួយចំនួន ដែលមកពីគ្រប់ទឹកទ្វីបក្នុងលោកីយ ប្រជុំគ្នារកដំណោះស្រាយ ដើម្បីបង្រួបបង្រួមសាសនាទាំងអស់ ឲ្យធ្វើជាស្ពានជួយដល់រដ្ឋាភិបាលរបស់លោកីយ បង្កើតឲ្យមានសន្តិភាពនៅលើពិភពលោក។ អ្នកដឹកនាំទាំងនោះ ក៏បានជួបប្រជុំជាមួយប្រមុខរដ្ឋាភិបាល មួយចំនួនទៀត ហើយមានផែនការយកអង្គការសហប្រជាជាតិជាចម្បង ក្នុងការនាំមុខ ដើម្បីសំរេចតាមផែនការណ៍នេះ។ នៅបច្ចុប្បន្ននេះ អ្នកដឹកនាំទាំងនោះ ក៏ដឹងថា គេមិនអាចនឹងសំរេចអ្វីៗ ឲ្យរហ័សទៅតាមចិត្តដែលគេចង់បាននោះទេ។ ពួកគេមានប្រធានាធិបតីមួយរូប ដែលមិនល្បីឈ្មោះ គឺប្រធានាធិបតី បៀល គ្លិនតុន លោកគ្លិនតុនបានមានប្រសាសន៍ថា អង្គការសហប្រជាជាតិ មិនត្រូវឈរនៅជាកណ្តាលទៀតទេ លោកបន្តមានប្រសាសន៍ទៅទៀតថា អង្គការសហប្រជាជាតិ ត្រូវងើបឈរឡើង នេះមានន័យថា អង្គការសហប្រជាជាតិ ត្រូវប្រើកម្លាំងទ័ពរបស់រដ្ឋាភិបាលនានា ដើម្បីធ្វើឲ្យមានសន្តិភាពនៅលើពិភពលោកនេះ។ ខ្ញុំចង់ដឹងថា ការប្រកាសរបស់ពួកគេដែលបានធ្វើនៅពេលនោះ គឺគេបាននិយាយថាច្បាប់ ឬ ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ អាចជម្រុញចិត្ត របស់មនុស្សគ្រប់សាសន៍ឲ្យជួយសំរេចការនេះបាន។ ពួកអ្នកដឹកនាំទាំងនោះ បាននិយាយថា គេមានបំណងដឹកនាំប្រទេសដែលមានការរីកចំរើនចូលរួមធ្វើសហការជាមួយគ្នា ហើយគេនឹងចែកចំណែស្មើៗគ្នា ដោយយកពីអ្នកមាន ចែកឲ្យដល់ពួកអ្នកក្រ នេះមានន័យថា ជាកុម្មុយនិស្ត។ លោកប្រធានាធិបតី គ្លិនតុន បានមានប្រសាសន៍នៅក្នុងបន្ទប់ប្រជុំពេញអង្គមួយរបស់អង្គការសហប្រជាជាតិ ដោយមានប្រមុខអ្នកដឹកនាំរបស់រដ្ឋាភិបាលនៃលោកីយនេះជាច្រើនបានចូលរួមផង។ ពួកអ្នកដឹកនាំទាំងនោះ ដឹងថា គេអាចនឹងធ្វើអ្វីៗឲ្យសំរេចបានពីព្រោះគេមានមនុស្សសំខាន់ៗជាច្រើននាក់ បានធ្វើការនោះ ហើយផែនការដែលគេចង់ធ្វើ គេអាចនឹងធ្វើការនោះ ឲ្យសំរេចបានផង ទំនុកដំកើង ២:១ «ហេតុអ្វីបានជាអស់ទាំងសាសន៍ជ្រួលជ្រើមឡើង

ហើយជនជាតិទាំងពួងមានគំនិតជាឥតសារដូច្នេះ» នេះជាការដែលប្រមុខរដ្ឋាភិបាលរបស់លោកីនេះ គឺមានគំនិតជាឥតប្រយោជន៍ ដោយគិតថា គេអាចនឹងនាំឲ្យលោកីយនេះមានសន្តិភាពបាន។ អារក្សសាតាំងប្រកាសប្រាប់ភិពភលោក ថាវាអាចនឹងធ្វើឲ្យលោកីយនេះមានសន្តិភាពបាន នេះជាការប្រកាសប្រឆាំងនឹងព្រះយេស៊ូវគ្រីស្ទ អារក្សសាតាំងបាន «...តាំងសំដែងខ្លួនថា វាជាព្រះផង»(២ថែស្សាឡូនីច២:៤)។ ការប្រជុំនៅញីវយ៉ក សហរដ្ឋអាមេរិក អ្នកដឹកនាំទាំងអស់នោះ គេមិនបានប្រកាសខ្លួនគេ ថាជាអ្នកប្រឆាំងនឹងព្រះយេស៊ូវគ្រីស្ទទេ ប៉ុន្តែ ការប្រជុំទាំងប៉ុន្មានរបស់ពួកមេសាសនានឹងរដ្ឋាភិបាលទាំងអស់នោះ បានបញ្ជាក់យ៉ាងច្បាស់ពីគោលបំណងរបស់ពួកគេ ហើយអ្នកទាំងនោះគេអាចនឹងធ្វើឲ្យសំរេចពីគោលបំណងរបស់គេបានផង។ ២២. «ពួកមហាក្សត្រនៅផែនដីលើកគ្នាឡើង...» នេះជាការដែលពួកគេព្យាយាមនឹងធ្វើ គេមិនគ្រាន់តែព្យាយាមប៉ុណ្ណោះទេ គេនឹងធ្វើការនោះទៀតផង ...ពួកគ្រប់គ្រងទាំងប៉ុន្មានក៏ប្រឹក្សាគ្នាទាស់នឹងព្រះយេហូវ៉ា ហើយទាស់នឹងព្រះអង្គ...[ព្រះគ្រីស្ទ]... តាមគំរោងការរបស់មេសាសនានឹងរដ្ឋាភិបាលទាំងនោះ មានតែព្រះយេស៊ូវគ្រីស្ទមួយអង្គគត់ ដែលទ្រង់អាចធ្វើបាន ពីព្រោះព្រះយេស៊ូវគ្រីស្ទទ្រង់ «...ជាស្តេចលើអស់ទាំងស្តេចជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់ ...»(វិវរណៈ១៩:១៦) ពួកមេសាសនា នឹងរដ្ឋាភិបាលទាំងអស់នោះចង់បានពរ ប៉ុន្តែ មានតែព្រះវរបិតា នឹងព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ ដែលមានពរ។ ព្រះគម្ពីរបានចែងយ៉ាងច្បាស់ថា ព្រះទ្រង់មិនបានសង្គ្រោះយើងនៅក្នុងអំពើបាបរបស់យើងរាល់គ្នានោះទេ គឺទ្រង់បានសង្គ្រោះយើងចេញពីអំពើបាបរបស់យើងរាល់គ្នាវិញ ចូរឲ្យយើងរាល់គ្នាយល់សេចក្តីនេះ ពីព្រោះវាមានសារៈសំខាន់ណាស់ ២៣. «ចូរយើងផ្តាច់ចំណងទ្រង់ ... [នេះមានន័យថា ពួកគេបានបោះបង់ចោលអ្វីៗ ដែលត្រូវធ្វើជាមួយនឹងព្រះវរបិតា ហើយនឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទ]... ហើយបោះខ្សែចងរបស់ទ្រង់ពីយើងចេញ» [នេះមានន័យ គេផ្តាច់ចំណងទំនាក់ទំនងពីព្រះវរបិតា ហើយពីព្រះអម្ចាស់យេស៊ូវគ្រីស្ទចេញ ដោយខ្លួនគេ] បងប្អូនអើយ ការដ៏អាក្រក់ដែលគួរឲ្យខ្លាចទាំងនោះ នឹងកើតឡើងដល់លោកីយនេះ ហើយនឹងកើតដល់យើងរាល់គ្នាដែរ ដោយព្រោះមនុស្សបានបោះបង់ចោលព្រះដ៏ពិត ហើយនឹងបញ្ញត្តិ ច្បាប់ ដ៏បរិសុទ្ធរបស់ផងព្រះចេញ។

នៅពេលដែលព្រះដ៏ជាព្រះវរបិតា ទ្រង់ចាត់ព្រះយេស៊ូវគ្រីស្ទមកផែនដីនេះ ជាលើកទី២វិញ នោះទ្រង់នឹងប្រោសអស់អ្នកដែលទទួលការត្រាស់របស់ព្រះវរបិតា ឲ្យរស់ពីស្លាប់ឡើងវិញ ជាលើកជាលើកទី១ គម្ពីរម៉ាថាយ២៤:១៣ «តែអ្នកណាដែលកាន់ខ្ជាប់ ដរាបដល់ចុងបំផុតវិញ អ្នកនោះនឹងបានសង្គ្រោះ» លោកសាវកយ៉ូហាន ក៏សរសេរពីការត្រាស់ហៅរបស់ព្រះថា ....ហើយខ្ញុំ...[ព្រះគ្រីស្ទ]...នឹងឲ្យអ្នកនោះរស់ឡើងវិញនៅថ្ងៃចុងបំផុតដែរ» (យ៉ូហាន៦:៤៤) ហើយព្រះយេស៊ូវគ្រីស្ទទ្រង់ «ក៏នឹងតាំងយើងរាល់គ្នាឡើងជានគរ... [តាំងឡើងជាស្តេច]...ហើយជាសង្ឃ ថ្វាយដល់ព្រះនៃយើងរាល់គ្នា ឲ្យយើងបានសោយរាជ្យលើផែនដី» (វិវរណៈ៥:១០)។ ខ្ញុំចង់ដឹងថា តើបងប្អូនអាចចាប់យកឬទទួលយកបាន ហើយយល់ពីការដ៏អស្ចារ្យរបស់ព្រះអម្ចាស់ ដែលទ្រង់បានត្រាស់ហៅយើងម្នាក់ៗបានដែរឬទេ? ព្រះអម្ចាស់ទ្រង់ត្រាស់ហៅយើង គឺផ្ទុយពីលោកីយ ដែលគេហៅយើង ឧទាហរណ៍. បើបងប្អូនជាប្រធានសហគ្រាស ឬ ជាប្រធានរោងចក្រណាមួយ បងប្អូនពិតជាចង់ឲ្យសហគ្រាស ឬរោងចក្ររបស់បងប្អូនទទួលបានជោគជ័យ ដើម្បីទទួលបានជោគជ័យ បងប្អូនត្រូវស្វែងរកអ្នកធ្វើការដែលមានចំណេះដឹង នឹងមានសមត្ថភាព ដូចខាងក្រោមនេះ

- ជាអ្នកមានចំណេះដឹងក្នុងវិស័យការងារ
- ជាអ្នកធ្លាប់បានទទួលជោគជ័យក្នុងការងារ
- ជាអ្នកយកចិត្តទុកដាក់ក្នុងការងារ
- បុរស ឬស្ត្រីក្តី គឺជាអ្នកខំប្រឹងប្រែងគ្រប់វិស័យការងារ

បើសិនជាអាចរកបានអ្នកមានស្តុកស្តម ប្រាកដជាគេអាចនឹងជួយសហគ្រាស ឬរោងចក្ររបស់បងប្អូន ឲ្យអាចទទួលជោគជ័យបាន ដោយព្រោះដំរិះប្រាជ្ញារបស់គេៗ ចំណែកអារក្ស សាតាំងវិញ វាចូលចិត្តហៅរកមនុស្សខ្លាំងពូកែ ឆ្លាតវាងវៃ មានសម្រស់ស្រស់ រាងសង្ហារ ហើយវានឹងឲ្យលោកីយដល់គេ ពីព្រោះអារក្ស សាតាំង វាបាននិយាយថា «...ខ្ញុំ...[អារក្សសាតាំង]...នឹងឲ្យអំណាច នឹងសិរីល្អនៃនគរទាំងនេះដល់អ្នក ដ្បិតបានប្រគល់មកខ្ញុំហើយ ខ្ញុំនឹងឲ្យដល់អ្នកណាស្រេចនឹងចិត្តខ្ញុំ ដូច្នេះ បើអ្នកក្រាបថ្វាយបង្គំខ្ញុំ នោះទាំងអស់នេះ នឹងបានជារបស់អ្នក» (លូកា៤:៦-៧)

យើងឃើញថាលោកីយ ទាំងមូលកំពុងថ្វាយបង្គំអារក្ស សាតាំង ពួកសាសនាទាំងអស់គេថ្វាយបង្គំអារក្ស សាតាំង ដូចជាពួកកាតូលិក ពួកប្រូតេស្តង់ នឹងគ្រីស្តបរិស័ទនិកាយផ្សេងៗ ដែលថ្វាយបង្គំព្រះថ្ងៃអាទិត្យ ពីព្រោះថ្ងៃអាទិត្យ ជាថ្ងៃដែលកាតូលិកបង្កើតឡើង លោកសាវកយ៉ូហានបានសរសេរថា កាតូលិកវា «ជាស្រីសំផឹង» (វិវរណៈ ជំពូក១៧ នឹង ១៨)

នេះជាការអស្ចារ្យណាស់ ដែលព្រះអម្ចាស់ទ្រង់ត្រាស់ហៅយើងៗ លោកីយបដិសេធយើង ពីព្រោះយើងគ្មានដំរិះប្រាជ្ញា ទ្រព្យសម្បត្តិ ឋានៈខ្ពង់ខ្ពស់ នឹងកេរ្តិ៍ឈ្មោះល្បីនោះទេ ប៉ុន្តែព្រះអម្ចាស់ទ្រង់បានធ្វើការយ៉ាងអស្ចារ្យ ដោយបានត្រាស់ហៅយើង ឲ្យយើងមានចំណែកជាកេរ្តិ៍អាករ ឲ្យយើងបានហៅ ជាកូនរបស់ព្រះអង្គ ហើយនឹងរស់នៅក្នុងនគរដ៏នៅអស់កល្បជានិច្ចរបស់ព្រះអង្គផងៗ លោកសាវកប៉ុល សរសេរ «បងប្អូនអើយ ខ្ញុំចង់ប្រាប់ឲ្យអ្នករាល់គ្នាដឹង ពីដំណឹងល្អ ដែលខ្ញុំបានផ្សាយរួចមកហើយ ជាដំណឹងដែលអ្នករាល់គ្នាបានទទួល ក៏ឈរជាប់ក្នុងនោះផង គឺបើសិនជាកាន់ខ្ជាប់តាមព្រះបន្ទូល ដែលខ្ញុំបានថ្លែងប្រាប់...យើងឃើញពាក្យ «បើសិន» ពាក្យ «បើសិន» ពាក្យនេះមិនសំដៅទៅលើព្រះទេ ហេតុអ្វី? ពីព្រោះព្រះទ្រង់សុចរិត ហើយគ្រប់លក្ខណ៍! ពាក្យ «បើសិន» នេះគឺសំដៅចំពោះយើងរាល់គ្នា ហើយព្រះទ្រង់ក៏ប្រទានឲ្យយើងរាល់គ្នាមានសិទ្ធិសិរីភាពក្នុងការជ្រើសរើស ...គឺបើសិនជាកាន់ខ្ជាប់តាមព្រះបន្ទូល...» នោះយើងរាល់គ្នានឹងបាន សង្គ្រោះ (១កូរិនថូស១៥:១-២)

យើងអាចនឹងគិតដល់មនុស្សជាច្រើនដែលយើងបានស្គាល់ អ្នកទាំងនោះ មិនកាន់ខ្ជាប់តាមព្រះបន្ទូលរបស់ព្រះទេ ហើយគេក៏ជាអ្នកភ្លេចបញ្ញត្តិ១០ប្រការរបស់ព្រះអង្គផងដែរៗ ជាពិសេសបញ្ញត្តិទី៤ «ចូរឲ្យនឹកចាំពីថ្ងៃឈប់សំរាក ឬថ្ងៃសប្ប័ទ ដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ...»(និក្ខមនំ២០:៨) ត្រូវហើយ! យើងរាល់គ្នាត្រូវតែកាន់ខ្ជាប់តាមព្រះបន្ទូល ពីព្រោះព្រះអម្ចាស់ទ្រង់បង្គាប់ឲ្យយើងកាន់ លោកសាវកប៉ុល សរសេរទៅពួកជំនុំនៅរ៉ូម «ដូច្នេះ ដែលយើងបានរាប់ជាសុចរិត ដោយការជឿ...» (រ៉ូម៥:១) យើងជឿ ហើយប្រព្រឹត្តិតាមបញ្ញត្តិ១០ប្រការ ជាបង្គាប់របស់ព្រះអម្ចាស់ ដើម្បីឲ្យបានរាប់ជាសុចរិត (រ៉ូម២:១៣)ៗ បញ្ញត្តិ១០ប្រការ គឺជាបញ្ញត្តិដ៏សំខាន់ ពីព្រោះគ្មានអ្នករំលង

បញ្ញត្តិ ឬទទឹងនឹងបញ្ញត្តិណាម្នាក់ នឹងអាចចូលទៅក្នុងនគរព្រះបានឡើយ (ម៉ាថាយ ៧:២៣) ព្រះអម្ចាស់ទ្រង់ត្រាស់ហៅយើង ឲ្យចេញពីអំពើបាប ហើយទ្រង់ក៏បានអត់ទោសបាបឲ្យយើង ដូច្នេះ យើងរាល់គ្នាបានទទួលសេចក្តីសង្គ្រោះឲ្យរួចពីបាប ដោយសារព្រះលោហិតដ៏បរិសុទ្ធនៃព្រះយេស៊ូវគ្រីស្ទដែលខ្ចាយនៅលើឈើឆ្កាង ហើយសុគត ត្រូវគេបញ្ចុះក្នុងផ្នូរ ៣យប់ ៣ថ្ងៃ ហើយព្រះវរបិតាទ្រង់ប្រោស ឲ្យព្រះយេស៊ូវគ្រីស្ទមានព្រះជន្មរស់ពីសុគតឡើងវិញ រស់ឡើងវិញជាវិញ្ញាណ (គម្ពីរម៉ាថាយ ១២:៤០) គម្ពីររ៉ូម៥:១-២ «...យើងបានមេត្រីនឹងព្រះ...[ព្រះវរបិតា]...ដោយសារព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើងរាល់គ្នាហើយ ក៏ដោយសារទ្រង់ យើងមានផ្លូវចូលក្នុងព្រះគុណនេះ ជាទីដែលយើងកំពុងឈរនៅដោយសេចក្តីជំនឿ...» ព្រះគុណនៃព្រះដែលទ្រង់ប្រទានមកយើងរាល់គ្នា បានគ្របបាំងយើងដូចជាឆ័ត្រ ដោយ-

- សេចក្តីស្រឡាញ់របស់ព្រះ
- សេចក្តីសង្ឃឹមនៃព្រះ
- សេចក្តីជំនឿនៃព្រះ
- សេចក្តីប្រោសលោះរបស់ព្រះ
- ការញែកចេញជាបរិសុទ្ធបំផុត
- ទទួលវិញ្ញាណបរិសុទ្ធរបស់ព្រះ

ទាំងអស់នេះ ជាអំណោយទានរបស់ព្រះអម្ចាស់ ដែលទ្រង់ប្រទានមកយើង គឺជាព្រះគុណរបស់ទ្រង់ ដែលយើងរាល់គ្នាត្រូវការជានិច្ច ជារៀងរាល់ថ្ងៃ... «ជាទីដែលយើងកំពុងឈរ...» ម្តងទៀត យើងកំពុងតែឈរលើដំណឹងល្អពិត ពីព្រោះដំណឹងល្អពិត គឺជាគ្រឹះនៃសេចក្តីជំនឿរបស់យើងរាល់គ្នា។ លោកសាវកប៉ុល បានដាស់តឿនយើងរាល់គ្នាថា «...ជាដំណឹងល្អដែលអ្នករាល់គ្នាបានទទួល ក៏ឈរជាប់ក្នុងនោះផង» (១កូរិនថូស ១៥:១) សូមគិត ពីការដែលយើងរាល់គ្នាឈរសំរាប់ដំណឹងល្អពិតរបស់ព្រះ នឹងគិតពីគ្រប់ការទាំងអស់ដែលយើងត្រូវធ្វើថ្វាយព្រះ។ លោកសាវកប៉ុលបានសរសេរទៅពួកជំនុំរ៉ូមថា ២. «...ហើយយើងនឹងអួតពីសេចក្តីសង្ឃឹមដល់សិរីល្អនៃព្រះផង ៣. មិន

តែប៉ុណ្ណោះសោត យើងនៅតែអួតក្នុងកាលមានទុក្ខលំបាកដែរ ដោយដឹងថា សេចក្ដីទុក្ខលំបាកបង្កើតឲ្យមានសេចក្ដីទ្រាំទ្រ ៤. សេចក្ដីទ្រាំទ្របង្កើតឲ្យមានសេចក្ដីសាំថ្មីក សេចក្ដីសាំថ្មីកបង្កើតឲ្យមានសេចក្ដីសង្ឃឹម» (រ៉ូម៥:២-៤) ខ្ញុំគិតថា យើងទាំងអស់គ្នា មានសម្លេងតែមួយដូចគ្នា ដោយយើងធ្លាប់ឆ្លងកាត់ការលំបាក ការបៀតបៀន នឹងការបោកប្រាស់ ទាំងអស់នោះវាជាការពិសោធន៍របស់យើងរាល់គ្នាវិញ ដោយយើងបានរៀនពីការទាំងនោះ ហើយក៏ដឹងថា ការទាំងអស់នោះបានកើតមកតែពីលោកីយនេះទេ។ យើងត្រូវតែដឹង ពីការដ៏សំខាន់នេះ ពីព្រោះយើងក៏រស់នៅលើលោកីយនេះដែរ ហើយយើងក៏តែងតែទទួលរងទុក្ខវេទនា សូម្បីតែនៅក្នុងគ្រួសាររបស់យើង ក៏មានអ្នកប្រឆាំងនឹងយើងដែរ (ម៉ាថាយ១០:២១-២២)។ ព្រះអម្ចាស់យេស៊ូវគ្រីស្ទទ្រង់បានពន្យល់យ៉ាងច្បាស់ ២១. «បងប្អូននឹងបញ្ជូនគ្នាឲ្យត្រូវស្លាប់ ឪពុកនឹងបញ្ជូនកូន ហើយកូននឹងលើកគ្នាទាស់នឹងឪពុក ម្ដាយព្រមទាំងសម្លាប់គាត់ផង ២២. មនុស្សទាំងអស់នឹងស្អប់អ្នករាល់គ្នាដោយព្រោះឈ្មោះខ្ញុំ...[ព្រះគ្រីស្ទ...ប៉ុន្តែអ្នកណាដែលកាន់ខ្ជាប់ ដរាបដល់ចុងបំផុត អ្នកនោះនឹងបានសង្គ្រោះ» យើងទាំងអស់គ្នាមានសេចក្ដីកំសោយគ្រប់យ៉ាង។ យើងនឹងស្វែងយល់ថា មានផ្លូវតែមួយគត់ដែលអាចឲ្យយើងឈរជាប់លើជំណឿងល្អពិតបាន គឺដោយសារតែព្រះគុណនៃព្រះអម្ចាស់ប៉ុណ្ណោះ។ ពេលអ្នកចូលរួមធ្វើបុណ្យព្រះពន្លា ឬ បុណ្យបាពាំ នោះអ្នកនឹងឃើញ មានមនុស្សចាស់ ក្មេង ជនជាពិការ ជាច្រើននាក់ចូលរួម តើនោះ មិនមែនជាទីសព្វព្រះហឫទ័យនៃព្រះអម្ចាស់ទេ ឬអី? ព្រះអង្គទ្រង់សព្វព្រះហឫទ័យនឹងការទាំងនោះណាស់ តើដោយហេតុអ្វី បានជាព្រះអង្គទ្រង់សព្វព្រះហឫទ័យ នឹងបុណ្យទាំងនោះ? ពីព្រោះយើងធ្វើបុណ្យទាំងអស់នោះ ដោយស្ដាប់តាមបង្គាប់ព្រះអង្គ ហើយមានសេចក្ដីសង្ឃឹមលើព្រះបន្ទូលសន្យារបស់ទ្រង់ផង។ លោកសាវកប៉ុលសរសេរថា «ឯសេចក្ដីសង្ឃឹម ក៏មិនមែននាំឲ្យមានសេចក្ដីខ្មាសឡើយ ពីព្រោះសេចក្ដីស្រឡាញ់របស់ព្រះ បានផ្សាយមកសព្វក្នុងចិត្តយើងរាល់គ្នា ដោយសារវិញ្ញាណបរិសុទ្ធរបស់ព្រះ ដែលព្រះបានប្រទានមកយើងហើយ» (រ៉ូម៥:៥) ដូច្នេះ យើងមានសេចក្ដីស្រឡាញ់របស់ព្រះ ដោយសារវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ដែលជាអំណោយទានដែលព្រះវរបិតាប្រទានមកយើង។ អស់អ្នកណាដែល

ទទួលវិញ្ញាណបរិសុទ្ធរបស់ព្រះវរបិតា អ្នកនោះជាមនុស្សវៃឆ្លាត មានអំណាចខ្លាំងក្លា ភាពសង្ហារ មានសោភ័ណភាពល្អ ជាគំរូល្អខាងសាច់ឈាម ហើយអ្នកនោះក៏ជាមនុស្សដ៏អស្ចារ្យ។

លោកសាវកប៉ុលសរសេរថា «ដ្បិតដំណឹងពីឈើឆ្កាង...ជាព្រះចេស្តានៃព្រះដល់យើងរាល់គ្នាដែលកំពុងតែបានសង្គ្រោះ...» (១កូរិនថូស ១:១៨) ឱ បងប្អូនស្ងួនភ្ងាអើយ គឺយ៉ាងនោះដែលយើងរាល់គ្នាអាចនឹងចូលទៅក្នុងនគរនៃព្រះបាន ដោយសារវិញ្ញាណបរិសុទ្ធរបស់ទ្រង់។ ហោរាសាការី សរសេរថា «...មិនមែនដោយឥទ្ធិឫទ្ធិ ឬដោយអំណាចទេ គឺដោយសារវិញ្ញាណរបស់អញវិញ» (សាការី ៤:៦) លោកសាវកប៉ុល ក៏បានសរសេរថា «ព្រោះមានសេចក្តីចែងទុកមកថា អញនឹងបំផ្លាញប្រាជ្ញារបស់ពួកអ្នកប្រាជ្ញ...» (១កូរិនថូស១:១៩) តើនេះ មិនមែនជាការដែលព្រះអម្ចាស់កំពុងធ្វើទេ ឬអី? មនុស្សបានគិតថា គេមានចំណេះ អាចនឹងស្គាល់ពីលក្ខណៈរបស់ព្រះបាន គេអាចស្គាល់ទស្សនៈវិជ្ជា ហើយនឹងអត្ថន័យនៃជីវិតបាន! ប៉ុន្តែ គេមិនអាចស្គាល់លក្ខណៈរបស់ព្រះបាន ដោយសារជំរិះប្រាជ្ញារបស់មនុស្សនោះទេ ពីព្រោះព្រះអម្ចាស់ទ្រង់មានបន្ទូលថា «...អញនឹងបំផ្លាញប្រាជ្ញារបស់ពួកអ្នកប្រាជ្ញ ហើយនឹងលើកចំណេះរបស់ពួកអ្នក ដែលចេះចោលចេញ ២០. តើអ្នកប្រាជ្ញនៅឯណា? តើពួកអាចារ្យនៅឯណា? តើអ្នកដេញដោលនៃសម័យនេះនៅឯណា? ...» យើងអាចនឹងឃើញគេ នៅលើកញ្ចក់ទូរទស្សន៍ ឬនៅឯអង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក ២០. «...ព្រះទ្រង់បានធ្វើឲ្យប្រាជ្ញារបស់លោកីយនេះ ទៅជាសេចក្តីល្ងង់ល្ងើវិញ ទេតើ ២១. ដ្បិតដោយព្រោះព្រះទ្រង់បានសំរេចតាមប្រាជ្ញានៃទ្រង់ថា មនុស្សលោកនឹងរកស្គាល់ព្រះដោយអាងប្រាជ្ញាខ្លួនមិនបានទេ» (១កូរិនថូស១:២០-២១) គ្មានអ្នកដឹកនាំណាម្នាក់ ឬអ្នកមានជំរិះប្រាជ្ញារបស់លោកីយនេះ ដែលអាចស្គាល់ព្រះពិតបានទេ! តើជំរិះប្រាជ្ញារបស់អ្នកនោះ អាចនឹងស្គាល់ព្រះពិតឬ? ចម្លើយៈ គឺថាគេមិនអាចនឹងស្គាល់ព្រះពិតបានដោយសារជំរិះប្រាជ្ញារបស់មនុស្សលោកនោះបានទេ។ គេអាចនឹងស្គាល់ព្រះពិតបាន ដោយមានសេចក្តីជំនឿ ដូចលោកសាវកប៉ុល សរសេរថា «... ដ្បិតអ្នកណាដែលចូលទៅឯព្រះ នោះត្រូវតែជឿថាមានព្រះមែន ហើយថាទ្រង់នឹងប្រទានរង្វាន់ ដល់អស់អ្នកដែលស្វែងរកទ្រង់»

(ហេព្រើរ ១១:៦)។ ព្រះអម្ចាស់យេស៊ូវគ្រីស្ទទ្រង់នឹងយាងមកកាន់ផែនដីនេះវិញ ទ្រង់នឹងសោយរាជ្យ ហើយទ្រង់នឹងគ្រប់គ្រងផែនដីនេះ តែមនុស្ស គេគិតមិនដែលដល់ទេ ហើយព្រះអម្ចាស់ទ្រង់នឹងរំលាយរំលីង គ្រប់ការដែលមនុស្សធ្វើទាំងអស់ឲ្យទៅជាឥតប្រយោជន៍ទទេ។ សូមយើងពិចារណាមើល តើអារ្យធម៌បុរាណរបស់ជនជាតិក្រេក នៅឯណា? បាត់អស់ហើយ តើអារ្យធម៌បុរាណរបស់សាសន៍អេស៊ីព្ទនៅឯណា?គឺបាត់បង់អស់ តើចំណែកបាប៊ីឡូនវិញ នៅឯណា? បាត់បង់អស់ហើយ! ចូរយើងមើលមកសម័យឥឡូវនេះវិញ តើសហភាពសូវៀតនៅឯណា? បាត់បង់អស់ហើយ បាត់បង់គ្រប់ទាំងអស់! តើដោយហេតុអ្វី? លោកសាវកប៉ុលសរសេរថា «ពីព្រោះសេចក្តីក្រោធរបស់ព្រះបានសំដែងមកពីស្ថានសួគ៌ ទាស់នឹងគ្រប់ទាំងសេចក្តីទមិលល្មើស នឹងសេចក្តីទុច្ចរិតរបស់មនុស្សដែលគេបង្ខាំងសេចក្តីពិត ដោយសេចក្តីទុច្ចរិត» (រ៉ូម១:១៨) តើអ្នកប្រាជ្ញសម័យនេះ នៅឯណា? ឯកសារដើមរបស់អង្គការសហប្រជាជាតិ សរសេរថា «យើងបានផ្លាស់ប្តូរ ហើយនឹងផ្លាស់ប្តូរតទៅទៀត នូវការនេះមួយ ហើយនឹងការនោះមួយទៀត ហើយយើងនឹងយកទាំងអស់ចេញ» (គេនឹងយកសេចក្តីពិតរបស់ព្រះ នឹងផែនការណ៍នៃសេចក្តីសង្គ្រោះរបស់ព្រះចេញ) ពួកមេដឹកនាំទាំងនោះ យកព្រះគម្ពីរចេញពីសាលារៀន ចេញពីមន្ទីរពេទ្យ ចេញពីកន្លែងសាធារណៈ នឹងយកចេញពីអាគាររបស់តុលាការគ្រប់ជាន់ថ្នាក់។

រ៉ូម១:១៩ «ព្រោះការអ្វីដែលអាចនឹងស្គាល់ពីព្រះបាន នោះបានសំដែងមកក្នុងពួកគេហើយ ដោយព្រះទ្រង់សំដែងការនោះឲ្យគេឃើញជាក់» ពេលព្រះអម្ចាស់ទ្រង់សំដែងការអ្វីមួយដល់អ្នក ទ្រង់ចាត់ទុកថា អ្នកនឹងទទួលខុសត្រូវចំពោះការនោះ។ ខ្ញុំគិតថា មនុស្សជាច្រើននឹងទូលទៅព្រះអម្ចាស់យេស៊ូវគ្រីស្ទថា ឱព្រះអម្ចាស់អើយ ទ្រង់មិនដែលមានព្រះបន្ទូលមកទូលបង្គំទេ នោះព្រះយេស៊ូវគ្រីស្ទ ទ្រង់នឹងឆ្លើយតបទៅអ្នកនោះថា តើមានព្រះគម្ពីរនៅផ្ទះអ្នកឬទេ? ពិតហើយ គ្រប់គ្នាមានព្រះគម្ពីរនៅផ្ទះរៀងៗខ្លួន តើអ្នកបានអានវាទេ? អ្នកនោះឆ្លើយថា ទូលបង្គំមិនបានអានទេ! ខ្ញុំ (ព្រះគ្រីស្ទ)... ទទួលខុសត្រូវក្នុងការផ្ញើព្រះគម្ពីរនោះទៅផ្ទះអ្នក ដើម្បីឲ្យអ្នកអាន អ្នកនោះឆ្លើយថា ប៉ុន្តែ ឱព្រះអម្ចាស់ គឺម្តាយមីងទូលបង្គំគាត់បានឲ្យមកទូលបង្គំទេតើ មិនអីទេ ទោះជាអ្នកនាំសារ

នោះជាអ្នកណាក៏ដោយ គឺខ្ញុំ [ព្រះយេស៊ូវ] បានចាត់ឲ្យគេយកទៅ ឲ្យអ្នក ដែលអ្នកមិនអាចប្រែកែកបានទេ។

រ៉ូម១:២០ «ដ្បិតអ្វីៗរបស់ទ្រង់ ដែលរកមើលមិនឃើញ តាំងពីកំណើតលោកីយមក ទោះទាំងព្រះចេស្តាដ៏នៅអស់កល្បជានិច្ច នឹងនិស្ស័យជាព្រះរបស់ទ្រង់ នោះឃើញច្បាស់វិញ ដោយពិចារណាយល់របស់ទាំងប៉ុន្មាន ដែលទ្រង់បានបង្កើតមក ១២១. ព្រោះកាលគេបានស្គាល់ព្រះ... [ការផ្តន្ទាទោស ត្រូវកើតឡើង ពេលអ្នកបានស្គាល់ព្រះហើយ អ្នកបដិសេធទ្រង់]...នោះគេមិនបានដំកើងទ្រង់ ទុកជាព្រះទេ ក៏មិនដឹងគុណទ្រង់ដែរ គេកើតមានគំនិតឥតប្រយោជន៍វិញ ហើយចិត្តគេដែលឥតយោបល់...» ចូរមើលទៅឯអ្នកវិទ្យាសាស្ត្រសព្វថ្ងៃនេះ តើគេកំពុងធ្វើអ្វី? ខ្ញុំគិតថា គេកំពុងធ្វើរ៉ូបាត ចេញពីកាំព្យូទ័រ ឲ្យទៅជាមនុស្ស «...គេមិនបានដំកើងព្រះទេ... ហើយចិត្តគេ ដែលឥតយោបល់ក៏បានត្រឡប់ជាងងឹតទៅ» (រ៉ូម១:២០-២១) ប៉ុន្តែ គេនិយាយថា គេមានគំនិតភ្លឺស្វាងវិញ វិញ ភាពងងឹតមកពីអារក្សសាតាំង គេថា គេមានពន្លឺ ប៉ុន្តែ គេជាងងឹតទេ។

១២២. «គេអួតខ្លួនថា មានប្រាជ្ញា បានជាគេត្រឡប់ទៅជាល្ងង់ល្ងើវិញ» អូ, វាពិតណាស់ហើយ គេមានប្រាជ្ញា គេបង្កើតឲ្យមានវិទ្យាល័យ មហាវិទ្យាល័យ ស្ថាប័នសិក្សាផ្សេងៗ គេមានគំនិតខ្ពង់ខ្ពស់ គេផ្តល់រង្វាន់ ផ្តល់សញ្ញាប័ត្រ ហើយនឹងប្រាក់កាស នោះជាស្នាដៃរបស់មនុស្សដែលខំប្រឹងធ្វើ វាជាការអស្ចារ្យណាស់ គេមានអំនួតយ៉ាងសំបើម។ ព្រះគម្ពីរសម្តែងថា ១២៣. «គឺគេបំផ្លាស់សិរីល្អនៃព្រះដែលមិនចេះខូច ឲ្យទៅជារូប មើលទៅដូចជាមនុស្ស ដែលតែងតែខូចវិញ ហើយដូចជាសត្វស្លាប សត្វជើង៤ នឹងសត្វលូនវារដែរ ១២៤. ហេតុនោះ បានជាព្រះទ្រង់ប្រគល់គេទៅឯសេចក្តីស្មោកគ្រោកតាមចិត្តគេប្រាថ្នាចង់បាន...»(រ៉ូម ១:១៨-២៤) មានចំណុចមួយ ព្រះអម្ចាស់ទ្រង់បានធ្វើអន្តរាគមន៍នៅក្នុងជីវិតរបស់អ្នកទាំងនោះ គឺព្រះទ្រង់បានប្រគល់គេទៅក្នុងសេចក្តីស្មោកគ្រោករបស់គេ ការទាំងអស់នោះបានកើតឡើងហើយ គឺ(ជម្ងឺអេដស៍AIDS)។ ជាមុនដំបូងតើមានអ្វីប៉ះពាល់ដល់ជីវិតរបស់គេ? ជីវិតរបស់ពួកអ្នកទាំងនោះមានការប៉ះពាល់យ៉ាងខ្លាំងពីព្រោះព្រះអម្ចាស់បានប្រទានឲ្យគេ មានសេចក្តីរំជួលដ៏អាស្រូវ តាមគំនិតចង់បានរបស់គេ។

លោកសាវកប៉ុលសរសេរថា ១២៦. «ហេតុនោះបានជាព្រះទ្រង់ប្រគល់គេ ទៅក្នុងសេចក្តីរំជួលដ៏អាស្រូវបាភយ ដ្បិតទាំងពួកស្រីៗរបស់គេ ក៏បានផ្លាស់ប្រែទំនៀមទំលាប់ពីបវេណីចេញ ឲ្យខុសពីធម្មតា ១២៧. ហើយពួកប្រុសៗ ក៏បែបដូច្នោះដែរ គេបានលះចោលទំនៀមទំលាប់របស់ស្ត្រី ពីបវេណីចេញ ហើយបង្កើតឲ្យមានសេចក្តីសំរើបពេលកលដល់គ្នាទៅវិញទៅមក គឺប្រុសប្រព្រឹត្តនឹងប្រុសៗ ជាការដ៏អាក្រក់ជួជាតិ នោះគេក៏ទទួលរង្វាន់ចំពោះខ្លួនគេដែលសំណំនឹងសេចក្តីកំហុសរបស់ខ្លួន» (រ៉ូម១:២៦-២៧)។ ការនេះបានកើតដល់គេហើយ គឺបានដល់លោកីយទាំងមូលផង គឺជម្ងឺអេដស៍ (AIDS) ជម្ងឺដ៏សាហាវនេះ បានកើតដល់មនុស្សជាច្រើននាក់ហើយ។

លោកសាវកប៉ុល សរសេរបន្តថា ១២៨ «ហើយដោយព្រោះគេមិនចូលនឹងស្គាល់ព្រះសោះ បានជាទ្រង់ប្រគល់គេ ទៅតាមគំនិតចោលម្សៀតវិញ ដើម្បីឲ្យបានសំរេចការដែលគមិនគួរគប្បីធ្វើ» (រ៉ូម១:២៨)។ ដូច្នេះ យើងឃើញមាន បីដង ព្រះបាន «ប្រគល់» ១២៤, ២៦, ២៨ ហើយលើកទី៤ យើងឃើញនៅក្នុងគម្ពីរ ២ថែស្សាឡូនីច២ «...ដោយព្រោះគេមិនព្រមស្រឡាញ់ដល់សេចក្តីពិត... ហេតុនោះបានជាព្រះទ្រង់នឹងឲ្យសេចក្តីខុសឆ្គងមក បណ្តាលឲ្យគេជឿតាមសេចក្តីកុតកវិញ» (២ថែស្សាឡូនីច២:១០-១១)

យើងត្រូវប្រឈមមុខទៅនឹងលោកីយនេះ យ៉ាងខ្លាំង ពីព្រោះលោកីយបានបោះបង់ចោលព្រះដ៏ពិត ដោយគេគិតថា គេមានប្រាជ្ញា គេមិនត្រូវការព្រះទេ! ១កូរិនថូស ១:២១ «ដ្បិតព្រះទ្រង់បានសំរេចតាមប្រាជ្ញានៃទ្រង់ថា មនុស្សលោកនឹងរកស្គាល់ព្រះដោយអាងប្រាជ្ញាខ្លួនមិនបានទេ បានជាព្រះទ្រង់សព្វព្រះហឫទ័យ នឹងជួយសង្គ្រោះអស់អ្នកដែលជឿ ដោយសារសេចក្តីល្ងង់ល្ងើវិញ គឺជាការប្រកាសដំណឹងល្អ» ព្រះអម្ចាស់ទ្រង់ចាត់វិញ្ញាណបរិសុទ្ធទាំង៧របស់ទ្រង់ ឲ្យទៅលើផែនដីដើម្បីនឹងធ្វើការងារជាច្រើន មិនមែនគ្រាន់តែបង្រៀនប៉ុណ្ណោះទេ (វិវរណៈ ៥:៦)

ពេលយើងថ្វាយបង្គំព្រះ នៅថ្ងៃសប្ប័ទ (ថ្ងៃទី៧ ឬថ្ងៃសៅរ៍) យើងមានសេចក្តីអំណរពិតកើតឡើង មិនដូចថ្ងៃឯទៀតនោះទេ ពីព្រោះមានវត្តមានរបស់ព្រះដ៏បរិសុទ្ធនៅថ្ងៃនោះ ហើយជាថ្ងៃដែលព្រះអង្គទ្រង់បានតាំងឡើងសំរាប់ឲ្យយើងរាល់គ្នាបានប្រកបជាមួយនឹងទ្រង់ នឹងរៀនពីផ្លូវ

របស់ទ្រង់ ជាផ្លូវនៃជីវិត។ ឥឡូវនេះយើងកំពុងតែប្រកបជាមួយនឹងព្រះអង្គ តើយើងត្រូវប្រកបជាមួយនឹងព្រះអង្គ យ៉ាងដូចម្ដេចខ្លះ?

- ដោយសេចក្ដីអធិស្ឋាន
- ដោយសិក្សាព្រះបន្ទូលទ្រង់
- ដោយប្រកបជាមួយបងប្អូន
- ប្រកបជាមួយព្រះអង្គ ដោយសារវិញ្ញាណបរិសុទ្ធរបស់ទ្រង់
- ប្រកបជាមួយព្រះអង្គដោយការស្ដាប់បង្គាប់ទ្រង់
- ប្រកបជាមួយព្រះអង្គតាមរយៈការរក្សាថ្ងៃសប្ប័ទ
- ប្រកបជាមួយព្រះអង្គដោយប្រារព្ធធ្វើបុណ្យបរិសុទ្ធទាំងប៉ុន្មានរបស់ទ្រង់

ការរក្សាថ្ងៃសប្ប័ទ គឺជាផ្នែកមួយនៃព្រះគុណរបស់ព្រះ ហេតុនោះហើយ តាមរយៈក្រិត្យវិន័យ យើងរាល់គ្នាបានចំរើនឡើងក្នុងព្រះគុណនៃព្រះ នេះជាការដែលមានសារៈប្រយោជន៍ជ្រាលជ្រៅបំផុតសំរាប់យើង។ លោកីយនេះ កំពុងក្រឡាប់ចាក់ ការពិតកំពុងតែក្រឡាប់ចាក់មែន! ហើយមើលទៅ ដូចជាល្វីល្វើផង។ បើយើងក្រឡេកមើលមកពួកយើងវិញ មានចំនួនតិច ប៉ុន្តែ ព្រះអម្ចាស់យេស៊ូវគ្រីស្ទបានសន្យា ថា «កុំឲ្យខ្លាច ហ្វូងតូចអើយ ព្រោះព្រះវរបិតានៃអ្នករាល់គ្នា ទ្រង់សព្វព្រះហឫទ័យ នឹងប្រទាននគរមកអ្នករាល់គ្នាពិត» (លូកា១២:៣២)។ យើងបង្រៀនព្រះបន្ទូលពិតដល់អស់អ្នកដែលទទួលការត្រាស់ហៅរបស់ព្រះវរបិតា ហើយទ្រង់ទាញនាំគេមកឯព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដើម្បីឲ្យគេអាចទទួលបានសង្គ្រោះពិត។

លោកសាវកប៉ុលសរសេរ ផ្ញើទៅពួកជំនុំ នៅកូរិនថូស ១កូរិនថូស១:២២-២៤ «ពីព្រោះសាសន៍យូដា គេចង់ឃើញក៏ស្កតាង ហើយសាសន៍ក្រេក គេស្វែងរកប្រាជ្ញា ២៣. តែយើងខ្ញុំប្រកាសប្រាប់ពីព្រះគ្រីស្ទដែលទ្រង់ត្រូវឆ្កាងវិញ ជាហេតុនាំឲ្យរវាតចិត្តដល់សាសន៍យូដា នឹងជាសេចក្ដីល្ងង់ល្ងើដល់សាសន៍ក្រេក ២៤. តែព្រះគ្រីស្ទ ទ្រង់ជាព្រះចេស្ដា ហើយជាប្រាជ្ញារបស់ព្រះវិញ ដល់អស់អ្នកណាដែលទ្រង់ហៅ ទាំងសាសន៍យូដា ហើយនឹងសាសន៍ក្រេកផង» យើងរាល់

គ្នា នៅក្នុងពួកអ្នកដែលព្រះអម្ចាស់ប្រទានកម្លាំង នឹងអំណាចព្រះចេស្តារបស់ទ្រង់ ដើម្បីឲ្យយើងអាចប្រឈមមុខ នឹងលោកីយ៍ដ៏អាក្រក់នេះបាន។ លោកសាវកប៉ុល បន្តសរសេរថា ២៥. «ដ្បិតសេចក្តីល្ងង់ល្ងើរបស់ព្រះ... (ព្រះអម្ចាស់ទ្រង់គ្មានភាពល្ងង់ល្ងើទេ) ...នោះមានប្រាជ្ញាលើសជាងមនុស្ស ហើយសេចក្តីកំសោយរបស់ព្រះ ក៏មានកំឡាំងជាងមនុស្សដែរ» ពីព្រោះព្រះគ្មានសេចក្តីល្ងង់ល្ងើណានៅជាមួយនឹងទ្រង់ទាល់តែសោះ ប៉ុន្តែ ព្រះអម្ចាស់ទ្រង់មានសេចក្តីកំសោយនោះ គឺជាព្រះគុណរបស់ទ្រង់ ដែលទ្រង់ទានដល់មនុស្ស នោះមិនមែនជាសេចក្តីកំសោយទេ គឺជាកម្លាំងវិញ ប៉ុន្តែ លោកីយគេរាប់ជាសេចក្តីកំសោយ។ គន្លឹះពាក្យ ១កូរិនថូស១:២៦ «ឱបងប្អូនអើយ អ្នករាល់គ្នាឃើញថា ក្នុងពួកអ្នកដែលទ្រង់បានហៅ មិនសូវមានអ្នកប្រាជ្ញច្រើនខាងសាច់ឈាម ឬច្រើននាក់មានអំណាច នឹងច្រើនអ្នកដែលមានត្រកូលខ្ពស់នោះទេ» យើងអាចនឹងនិយាយបានថា គ្មានម្នាក់សោះ គឺសូន្យ ខ្ញុំគិតថា សាវកប៉ុល មានចិត្តល្អ ដែលបានសរសេរបែបនេះ តើមានអភិបាលខេត្ត ឬព្រឹទ្ធសភា ថ្នាក់ខេត្ត ថ្នាក់ជាតិ ឬមានអ្នកទីប្រឹក្សាក្រុងប៉ុន្មាននាក់? តើមានរដ្ឋាភិបាលសាធារណៈប៉ុន្មាននាក់? ទីប្រឹក្សាឃុំ សង្កាត់ប៉ុន្មាននាក់ នៅក្នុងពួកជំនុំរបស់ព្រះពិត? គឺគ្មានសោះ។ តើនៅក្នុងពួកជំនុំព្រះពិត មានប៉ុន្មាននាក់បានទទួលរង្វាន់ណូបែល? (រង្វាន់អន្តរជាតិ) គឺគ្មានមួយទេ។ យើងទាំងអស់គ្នាមានពរណាស់ បើសិនជាយើងបានទទួលសញ្ញាប័ត្រដំរិះទូទៅ (General Education Diploma, GED) ស្មើនឹងមធ្យមសិក្សាប័ត្រ) ២៧. «ព្រះទ្រង់រើសពួកល្ងង់ល្ងើនៅលោកីយនេះ...» បើមានអ្នកណាម្នាក់ នៅក្នុងលោកីយ គេនិយាយទៅអ្នកថា អ្នកជាមនុស្សល្ងង់ល្ងើ ត្រូវយល់ព្រមជាមួយនឹងគេទៅ ពីព្រោះគេនិយាយត្រូវ! ប៉ុន្តែ ព្រះអម្ចាស់ទ្រង់មិនសព្វព្រះហឫទ័យ ឲ្យយើងនៅតែល្ងង់ល្ងើទៀតទេ «...ដើម្បីនឹងធ្វើឲ្យអ្នកប្រាជ្ញមានសេចក្តីខ្មាសវិញ ទ្រង់បានរើសពួកកំសោយនៅលោកីយនេះ ដើម្បីនឹងធ្វើឲ្យពួកខ្លាំងពូកែមានសេចក្តីខ្មាស ២៨. ហើយទ្រង់បានរើសអ្នកទាបថោកនៅលោកីយនេះ នឹងពួកអ្នកដែលគេមើលងាយព្រមទាំងរបស់ដែលគ្មានផង ដើម្បីនឹងលើកចោលរបស់ដែលមានចេញ» [លើកដំរិះ ប្រាជ្ញារបស់លោកីយនេះចោល] (១កូរិនថូស១:២៧-២៨) គ្រប់ទាំងអស់រាប់ជាគ្មានអ្វីសោះ នៅចំពោះព្រះអម្ចាស់វិញ។

បើលោកីយមិនស្គាល់យើង មិនរាប់អាន ឬមិនទឹកចាំពីយើង នោះកុំឲ្យខ្វល់ខ្វាយ បើអ្នកមានគេមើលងាយ បៀតបៀន ចូរកុំខ្វល់ខ្វាយ ឬមានបញ្ហា ឬមានការសង្កត់សង្កិន ឬលោកីយបដិសេធ នោះអ្នកកុំព្រួយឲ្យសោះ ពីព្រោះព្រះអម្ចាស់ទ្រង់បានត្រាស់ហៅអ្នក តើដើម្បីអ្វី? ដើម្បីឲ្យយើងរាល់គ្នា មានគ្រប់ដំរិះប្រាជ្ញា យោបល់ ខាងឯសេចក្ដីពិត ឲ្យបានធ្វើការល្អគ្រប់មុខ ក្នុងនគរព្រះ។ «ដើម្បីនឹងលើកចោលរបស់ដែលមានចេញ» [គ្រប់ដំរិះប្រាជ្ញារបស់លោកីយ] ហេតុនេះបានជាព្រះអម្ចាស់ទ្រង់ត្រាស់ហៅអ្នក។ ព្រះអម្ចាស់ទ្រង់ធ្វើការដែលមនុស្សមិនអាចធ្វើបាន ព្រះទ្រង់ធ្វើការតាមរយៈ

- ការប្រែចិត្ត
- ការរីកចំរើន
- មានជ័យជំនះ
- ដំរិះប្រាជ្ញា
- ស្អាងកិរិយាប្រព្រឹត្តដូចជាព្រះយេស៊ូវគ្រីស្ទ

ដូច្នេះ ចូរយើងពិចារណា ពីការដែលព្រះអម្ចាស់ទ្រង់ធ្វើ នៅក្នុងជីវិតរបស់យើងរាល់គ្នា ប៉ុន្តែលោកីយ គេមើលមិនឃើញទេ តើហេតុអ្វី? ពីព្រោះការទាំងអស់នោះ ព្រះអម្ចាស់ទ្រង់ធ្វើនៅក្នុងចិត្តយើងរាល់គ្នា ដោយវិញ្ញាណបរិសុទ្ធរបស់ទ្រង់។

លោកសាវកប៉ុល សរសេរថា «ដ្បិតគឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះ...» (អេភេសូរ២:៨) ភាសាក្រេក មានន័យថា អ្នករាល់គ្នាកំពុងបានទទួលសេចក្ដីសង្គ្រោះ ឲ្យរួចពីសាតាំង ហើយឲ្យរួចពីអំពើបាប រ៉ូម៥:១០ «...ប្រាកដជាយើងនឹងបានសង្គ្រោះ ជាមិនខាន...» តើនៅពេលណាដែលយើងបានសង្គ្រោះ? គឺនៅពេលអនាគត! នៅពេលព្រះយេស៊ូវគ្រីស្ទទ្រង់យាងមកកាន់ផែនដីនេះជាលើកទី២ ទ្រង់នឹងប្រោសយើងរាល់គ្នាឲ្យរស់ពីស្លាប់ឡើងវិញ ប្រោសឲ្យរស់ឡើងវិញ ជាវិញ្ញាណ (១ថែស្សាឡូនីច៤:១៣-១៧)។ «...ដោយសារសេចក្ដីជំនឿ ហើយសេចក្ដី

នោះក៏មិនមែនកើតពីអ្នករាល់គ្នាដែរ...» (អេភេសូរ ២:៨) យើងរាល់គ្នាមិនអាចចាប់ផ្តើមសេចក្តីជំនឿចេញពីខ្លួនយើងបានទេ «...មិនមែនកើតពីអ្នករាល់គ្នាដែរ...» ព្រះអម្ចាស់ទ្រង់ប្រទានព្រះគុណរបស់ទ្រង់ ដល់អស់អ្នកណាដែលប្រែចិត្តពីអំពើបាប ទទួលបុណ្យជ្រមុជទឹក ហើយទទួលអំណោយទានជាវិញ្ញាណបរិសុទ្ធរបស់ទ្រង់។ ពួកអ្នកគ្រីស្ទានប្រូតេស្តង់ គេមិនយល់ខនេះ ទាល់តែសោះ ពួកគេដកស្រង់ខនេះ ហើយបង្វែរន័យឲ្យផ្ទុយពីការពិតដោយបង្រៀនមិនឲ្យកាន់តាមបញ្ញត្តិបរិសុទ្ធ នឹងសុចរិតរបស់ព្រះ។ អ្នកគ្រីស្ទាននិកាយប្រូតេស្តង់បង្រៀនថា បើអ្នកមានអារម្មណ៍ក្នុងចិត្ត ឬក្នុងគំនិត គិតថាត្រូវ នោះត្រូវហើយជាមួយនឹងព្រះហើយ ឲ្យតែអ្នកធ្វើចេញពីក្នុងចិត្ត នោះត្រូវហើយ! តើអ្នករាល់គ្នាយល់សេចក្តីនេះ ឬទេ? ខ៨. «... គឺជាអំណោយទានរបស់ព្រះវិញ ខ៩. ក៏មិនមែនដោយការប្រព្រឹត្តដែរ ក្រែងអ្នកណាអួតខ្លួន» (អេភេសូរ២:៨-៩) ការដែលព្រះអម្ចាស់ទ្រង់ធ្វើ មនុស្សមិនអាចមើលឃើញទេ ខ១០. «ដ្បិតយើងរាល់គ្នាជាស្នាដៃដែលទ្រង់បង្កើតក្នុងព្រះគ្រីស្ទយេស៊ូវ សំរាប់ការល្អ...» (អេភេសូរ២:១០) ការរក្សាបញ្ញត្តិ ជាការល្អ ការប្រារព្ធធ្វើបុណ្យបរិសុទ្ធទាំងប៉ុន្មានរបស់ព្រះអម្ចាស់ នោះជាការល្អ សេចក្តីស្រឡាញ់ សេចក្តីជំនឿ សេចក្តីសង្ឃឹម ហើយនឹងការត្រួតត្រាចិត្ត គំនិតខ្លួន ទាំងអស់នេះជាការល្អ ហើយជាផលផ្លែ នៃវិញ្ញាណបរិសុទ្ធរបស់ព្រះផង ខ១០...ដែលព្រះបានរៀបចំជាមុន ឲ្យយើងរាល់គ្នាប្រព្រឹត្តតាម»

តើហេតុអ្វីបានជាព្រះទ្រង់សព្វព្រះហឫទ័យ រៀបចំការនេះ? លោកសាវកប៉ុលសរសេរថា «ប្រយោជន៍កុំឲ្យមនុស្សណាបានអួតខ្លួននៅចំពោះព្រះឡើយ» (១កូរិនថូស១:២៩) ចូរឈប់មួយភ្លែត ហើយគិតសិន តើលោកយ៉ូបសុចរិតឬ? ពេលខ្ញុំអានគម្ពីរយ៉ូប លើកទី១ ខ្ញុំបានគិតថាព្រះខុស យ៉ូបបាននិយាយថា ខ្លួនគាត់សុចរិត (យ៉ូប២៧:៦) លោកយ៉ូបមានអំនួតយ៉ាងសម្បើម។ យ៉ូបជំពូក២៩ លោកយ៉ូបបានមានប្រសាសន៍ថា «ខ្ញុំ» ខ្ញុំធ្វើនេះ ខ្ញុំធ្វើនោះ ខ្ញុំឲ្យនេះ ខ្ញុំឲ្យនោះ ខ្ញុំបានធ្វើការទាំងអស់ ដោយខ្លួនខ្ញុំ លោកយ៉ូបមានអំនួតយ៉ាងខ្លាំងណាស់ លោកគួរតែនិយាយថា ដោយសារព្រះគុណនៃព្រះអម្ចាស់ ខ្ញុំអាចធ្វើគ្រប់ការទាំងអស់នោះបាន សូមសរសើរដំកើង នឹងអរព្រះគុណដល់ព្រះអម្ចាស់។ លោកសាវកប៉ុល បន្តសរសេរ «តែដោយសារព្រះ នោះអ្នករាល់គ្នានៅក្នុង

ព្រះគ្រីស្ទយេស៊ូវ ដែលទ្រង់បានតាំងឡើង...» (១កូរិនថូស១:៣០) ដោយហេតុនេះហើយ បានជាព្រះទ្រង់តាំងយើងឡើង ឲ្យយើងបានទទួលអំណាច ព្រះបេស្កា នឹងកម្លាំង សំរាប់ឲ្យយើងបានទទួលជោគជ័យក្នុងជីវិតបាន។

ខាងក្រោមនេះ ជាការដែលយើងត្រូវតែផ្លាស់ប្រែពី:

- ភាពល្ងីល្ងើ
- ភាពកំសោយ
- កុំឈរលើអ្វីដែលគ្មានសេចក្តីពិត
  ការប្រមាថ
- ធ្វើអ្វីដែលមិនពិត

នេះជាការផ្លាស់ប្រែខាងក្នុងចិត្ត ដូចជាយើងបានស្អាងឡើងក្នុងឥរិយាបទរបស់ព្រះគ្រីស្ទយេស៊ូវ:

- តាមរយៈសេចក្តីស្រឡាញ់របស់ព្រះ
- តាមរយៈបញ្ញត្ត ច្បាប់ របស់ព្រះ
- តាមរយៈព្រះបន្ទូលរបស់ព្រះ
- តាមរយៈការប្រកបជាមួយនឹងព្រះ

លោកសាវកប៉ុល សរសេរថា «តែព្រះគ្រីស្ទ ទ្រង់ជាព្រះបេស្កា ហើយជាប្រាជ្ញារបស់ព្រះវិញ ដល់អស់អ្នកដែលទ្រង់ហៅ ទាំងសាសន៍យូដា ហើយនឹងសាសន៍ក្រេកផង» (១កូរិនថូស ១:២៤) លោកសាវកប៉ុលក៏បន្តសរសេរទៅទៀតថា ២៩. ប្រយោជន៍កុំឲ្យមនុស្សណាបានអួតខ្លួន នៅចំពោះព្រះឡើយ ៣០. តែដោយសារព្រះ នោះអ្នករាល់គ្នានៅក្នុងព្រះគ្រីស្ទយេស៊ូវ ដែលទ្រង់បានតាំងឡើង ទុកជាប្រាជ្ញាដែលមកពីព្រះ ហើយជាសេចក្តីសុចរិត សេចក្តីបរិសុទ្ធ នឹងសេចក្តីប្រោសលោះដល់យើងផង ៣១. ដើម្បីឲ្យបានត្រូវនឹងសេចក្តីដែលចែងទុកមកថា អ្នកណាដែលអួតត្រូវអួតតែពីព្រះអម្ចាស់ប៉ុណ្ណោះ» (១កូរិនថូស១:២៩-៣១)។ កាលណាយើងស្គាល់បទព្រះគម្ពីរច្បាស់

យើងយល់បទព្រះគម្ពីរបានច្រើន នោះប្រាជ្ញារបស់ព្រះក៏ប្រទានមកយើងកាន់តែច្រើនទៀតដែរ គឺជាព្រះហើយដែលមានបន្ទូលឲ្យសរសេរបទព្រះគម្ពីរ មិនមែនយើងអួតពីខ្លួនយើងនោះទេ ពីព្រោះគ្រប់របស់ទាំងអស់ ត្រូវថ្វាយសេចក្ដីសរសើរដំកើងដល់ព្រះអម្ចាស់ ជាព្រះនៃយើងរាល់គ្នាវិញ។ ខ្ញុំសូមប្រាប់អ្នករាល់គ្នាថា តាមរយៈព្រះគុណនៃព្រះ នោះយើងអាចនឹងចំរើនប្រាជ្ញា នឹងការយល់ដឹងពីព្រះកាន់តែច្រើនឡើងថែមទៀតដែរ។

ចូរយើងយល់ តើហេតុអ្វីបានជាព្រះអម្ចាស់ទ្រង់ជ្រើសរើសធ្វើតាមផ្លូវនេះ? ហេតុអ្វីបានជាទ្រង់ធ្វើដូច្នេះ? លោកសាវកប៉ុល សរសេរ ២កូរិនថូស១២:៨-៩ «ខ្ញុំបានសូមអង្វរដល់ព្រះអម្ចាស់៣ដង ឲ្យសេចក្ដីនោះថយចេញពីខ្ញុំ ៩. តែទ្រង់មានបន្ទូលមកខ្ញុំថា គុណរបស់អញល្មមដល់ឯងហើយ ដ្បិតកម្លាំងអញបានពេញខ្នាត ដោយសេចក្ដីកំសោយ ដូច្នេះ ខ្ញុំនឹងស៊ូអួតពីសេចក្ដីកំសោយរបស់ខ្ញុំដោយអំណរជាខ្លាំង ដើម្បីឲ្យព្រះចេស្ដានៃព្រះគ្រីស្ទបានសណ្ឋិតនៅនឹងខ្ញុំ» (ខ៨-៩) បទព្រះគម្ពីរនេះ បានសរសេរថា អារក្សសាតាំងវាកំពុងធ្វើទុក្ខ បៀតបៀនដល់ប៉ុលជាខ្លាំង តាមរយៈទេវតារបស់វា។ តើអារក្សសាតាំង ធ្វើទុក្ខ នឹងបៀតបៀនសាវកប៉ុល ដើម្បីអ្វី? ដើម្បីឲ្យប៉ុលចេះបន្ទាបខ្លួន ពីព្រោះសាវកប៉ុល ពីដើមជាអ្នកមានប្រាជ្ញា ហើយក៏មានអំណាចផង ហេតុនោះហើយបានជាព្រះគ្រីស្ទទ្រង់បង្រៀនគាត់ផ្ទាល់ នៅស្រុកអារ៉ាប់អស់៣ឆ្នាំ (កាឡាទី១:១៧-១៨)។ មានពេល ព្រះទ្រង់ប្រទានឲ្យយើងនូវអ្វីមួយ ឬសេចក្ដីកំសោយណាមួយ ចូរយើងរៀនឲ្យយល់ពីសេចក្ដីកំសោយនោះ ខ្ញុំបានរៀនជាយូរឆ្នាំ ហើយធ្វើជាគ្រូគង្វាលផង។

១) ព្រះទ្រង់ប្រទានឲ្យគ្រប់ៗគ្នាមានសេចក្ដីកំសោយ

២) ព្រះទ្រង់មិនបានយកសេចក្ដីកំសោយនោះចេញពីយើងទេ

ព្រះអម្ចាស់ទ្រង់នឹងជួយយើងឲ្យមានជ័យជំនះលើសេចក្ដីកំសោយនោះវិញ នោះទើបព្រះទ្រង់ដកយកសេចក្ដីនោះចេញពីយើង។ ការទាំងអស់នេះ ចេះតែកើតដល់យើងជាញឹកញាប់ ប្រហែលជានៅជាមួយនឹងយើងខាងសាច់ឈាមរហូតអស់មួយជីវិតរបស់យើងផង។ តើដោយហេតុអ្វី ? ដើម្បី

កុំឲ្យយើងអួតខ្លួន ត្រូវឲ្យយើងចេះសម្លឹងមើលទៅឯព្រះ គឺទ្រង់ហើយ ជាប្រភពនៃកម្លាំង ព្រះពរ នឹងជាសេចក្ដីសង្គ្រោះដល់យើងរាល់គ្នា ព្រមទាំងជួយយើងឲ្យមានជោគជ័យ មិនមែនតែនៅក្នុងបច្ចុប្បន្ននេះប៉ុណ្ណោះទេ គឺសំរាប់ទៅអនាគតផង។ ដោយសារព្រះគុណរបស់ព្រះអង្គទ្រង់បានត្រាស់ហៅយើង នឹងអស់អ្នកដែលទ្រង់បានត្រាស់ហៅ ទោះនៅក្នុងលក្ខណៈណាក៏ដោយព្រះអម្ចាស់ទ្រង់តែងតែជួយយើងជានិច្ច។

លោកសាវកប៉ុល សរសេរថា «...ទ្រង់នឹងតាំងអ្នករាល់គ្នាឲ្យខ្ជាប់ខ្ជួន ដរាបដល់ចុងបំផុត...» (១កូរិនថូស១:៨) តើអ្នកត្រូវធ្វើយ៉ាងដូចម្ដេច នៅពេលមានសេចក្ដីកំសោយ? អ្នកត្រូវទូលអង្វរដល់ព្រះអម្ចាស់ឲ្យអស់អំពីចិត្ត ហើយបន្ទាប់មកព្រះអម្ចាស់ទ្រង់នឹងប្រទានកម្លាំងដល់អ្នក។

សូមយើងមើលទៅឯព្រះអម្ចាស់យេស៊ូវគ្រីស្ទ តើទ្រង់សព្វព្រះហឫទ័យនឹងធ្វើការអ្វីខ្លះ ក្នុងជីវិតរបស់យើងម្នាក់ៗ គឺព្រះអង្គទ្រង់សព្វព្រះហឫទ័យបន្ថែមចំណេះដ៏ខ្ពង់ខ្ពស់ ដល់អស់អ្នកដែលស្ដាប់បង្គាប់ទ្រង់។ ខ្ញុំចង់ឲ្យអ្នកគិតពីព្រះពរ ដែលព្រះប្រទានឲ្យអ្នក ទ្រង់ប្រទានឲ្យអ្នកមានដំរិះប្រាជ្ញាយល់បទព្រះគម្ពីរ អាចប្រែចិត្តបាន ជួយឲ្យអ្នកមានចិត្តខិតខំសិក្សាបទព្រះគម្ពីរ ដើម្បីឲ្យមានគ្រប់ទាំងចំណេះ សំរាប់នឹងធ្វើការល្អគ្រប់មុខ [សោយរាជ្យ] នៅក្នុងនគរព្រះ(វិវរណៈ៥:១០) សូមបងប្អូនយល់ឲ្យបានច្បាស់ ពីការនេះ។

លោកសាវកប៉ុល សរសេរថា «រីឯខ្ញុំ បងប្អូនអើយ កាលខ្ញុំមកឯអ្នករាល់គ្នា នោះមិនបានមកដោយប្រើវោហារ ឬប្រាជ្ញាដ៏ឧត្ដម ដើម្បីនឹងប្រាប់សេចក្ដីបន្ទាល់ពីព្រះដល់អ្នករាល់គ្នាទេ ២. ដ្បិតខ្ញុំបានផ្ដាច់ចិត្តថា នៅក្នុងពួកអ្នករាល់គ្នា នោះខ្ញុំមិនព្រមស្គាល់រឿងអ្វីទៀត ក្រៅពីព្រះយេស៊ូវគ្រីស្ទទេ ហើយគឺដែលទ្រង់ត្រូវឆ្កាងផង ៣. ខ្ញុំក៏បាននៅជាមួយនឹងអ្នករាល់គ្នា ទាំងមានសេចក្ដីកំសោយ គិតភ័យ ហើយញាប់ញ័រជាច្រើនដែរ ៤. ឯពាក្យសំដី នឹងវោហារអធិប្បាយរបស់ខ្ញុំ ក៏មិនមែនដោយពាក្យឧត្តុង្គឧត្តម ដែលពូកែបញ្ចុះបញ្ចូលនោះដែរ គឺដោយការសំដែងចេញជាវិញ្ញាណបរិសុទ្ធរបស់ព្រះ នឹងព្រះចេស្ដាវិញទេតើ ៥. ដើម្បីកុំឲ្យសេចក្ដីជំនឿរបស់អ្នករាល់គ្នាបានតាំងនៅដោយប្រាជ្ញារបស់មនុស្សឡើយ គឺដោយព្រះចេស្ដានៃព្រះវិញ» (១កូរិនថូស២:១-៥)

លោកសាវកប៉ុលបន្តសរសេរទៅទៀត ៦. ប៉ុន្តែ នៅក្នុងចំណោមមនុស្សគ្រប់លក្ខណ៍ នោះយើងខ្ញុំក៏និយាយតាមប្រាជ្ញាដែរ តែមិនមែនតាមប្រាជ្ញារបស់លោកីយនេះ ឬរបស់ពួកចៅហ្វាយនៅលោកីយនេះ ដែលត្រូវសាបសូន្យនោះទេ» (១កូរិនថូស២:៦) អ្នកអាចគិតមើល តើមានអ្វីកើតឡើង? ចូរខំព្យាយាមគិតពីព្រឹត្តិការណ៍ នៃការប្រជុំរបស់អ្នកដឹកនាំពិភពលោក ដែលគេប្រជុំគ្នានៅសាលប្រជុំរបស់អង្គការសហប្រជាជាតិ ដើម្បីដោះស្រាយបញ្ហារបស់ពិភពលោក ហើយជាពិសេសទៅទៀត គេសុទ្ធសឹងតែជាអ្នកមានស្ដុកស្ដម្ភផង ហើយគ្រប់គ្នាមានអំណាច គេអាចនឹងស្នើសុំជាផ្លូវការ ឲ្យទៅទំលាក់គ្រាប់បែកបរមាណូ បំផ្លាញប្រទេសណាមួយក៏បាន។ ចូរអ្នកគិតមើល បើមានអ្នកណាម្នាក់ ហ៊ានឡើងទៅលើវេទិការ នៅសាលប្រជុំរបស់អង្គការសហប្រជាជាតិ ហើយនិយាយថា ព្រះអម្ចាស់លើទាំងអស់ ទ្រង់មានបន្ទូលថា «អ្នកដឹកនាំរបស់លោកីយទាំងអស់គ្នា ជាមនុស្សអសារឥតការ!» ខ្ញុំគិតថា អ្នកនោះត្រូវតែរកច្រកចេញជាប្រញាប់ ពីមុនក្រសួងសន្តិសុខមកដល់ ហើយចាប់ចងអ្នក។ សព្វថ្ងៃនេះ មនុស្សទាំងអស់សុទ្ធតែជាអសារឥតការទេ! ៧ «គឺនិយាយតាមតែប្រាជ្ញានៃព្រះវិញ ជាសេចក្ដីអាថ៌កំបាំងដ៏លាក់ទុក ដែលព្រះបានគិតគូរ តាំងពីមុនអស់ទាំងកល្ប សំរាប់ជាសិរីល្អដល់យើងរាល់គ្នា ៨ គ្មានចៅហ្វាយណាក្នុងលោកីយនេះ បានស្គាល់សេចក្ដីអាថ៌កំបាំងនោះឡើយ បើបានស្គាល់ នោះគេមិនបានឆ្កាងព្រះអម្ចាស់ដ៏មានសិរីល្អទេ» (១កូរិនថូស២:៧-៨) បងប្អូនស្ងួនភ្ងា នេះជារឿងមួយប្លែកយ៉ាងអស្ចារ្យ ដែលមិនអាចជឿបាន ប៉ុន្តែ សំរាប់យើងរាល់គ្នាវិញ យើងយល់ ហើយក៏នឹកចាំជារឿងរហូត។

សាវកប៉ុល បន្តសរសេរថា ៩. «ដូចមានសេចក្ដីចែងទុកមកថា សេចក្ដីដែលភ្នែកមើលមិនឃើញ ត្រចៀកមិនដែលឮ ហើយចិត្តនឹកមិនដែលដល់ គឺសេចក្ដីនោះឯងដែលព្រះបានរៀបចំទុកសំរាប់ពួកអ្នកដែលស្រឡាញ់ទ្រង់» (១កូរិនថូស២:៩) ដោយហេតុនោះហើយ បានជាសេចក្ដីស្រឡាញ់របស់ព្រះ នោះសំខាន់ណាស់ ជាមុនដំបូងអ្នកត្រូវបញ្ជាក់ ខ្លួនយើងថា៖

- អ្នកប្រហែលជាខ្សោយ
- អ្នកប្រហែលជាអសារឥតការ

- អ្នកប្រហែលជាឈឺ
- អ្នកប្រហែលជាចាស់
- អ្នកប្រហែលជាមានបញ្ហារំភើបចិត្ត
- អ្នកប្រហែលជាមានការក្រៀមក្រំក្នុងចិត្ត
- អ្នកប្រហែលជាមានបញ្ហាការងារ

អ្នកប្រហែលជាមានបញ្ហាទាំងអស់ខាងលើនេះ ប៉ុន្តែ បើអ្នកស្រឡាញ់ព្រះអម្ចាស់ អ្នកមានអាចំកំបាំងយ៉ាងអស្ចារ្យ នេះបើអ្នកយល់ពីផែនការរបស់ព្រះអង្គ។ នៅពេលចុងក្រោយនេះ យើងយល់ពីផែនការរបស់ព្រះអម្ចាស់ បានច្រើនជាងពួកជំនុំនៅជំនាន់សតវត្សទី២ នៃគ្រីស្ទសករាជទៅទៀត។

៩. «...គឺសេចក្តីនោះឯងដែលព្រះបានរៀបចំទុក សំរាប់ពួកអ្នកដែលស្រឡាញ់ទ្រង់» ទោះបីយ៉ាងនោះក្តី យើងនៅមើលឃើញតាមកញ្ចក់យ៉ាងស្រអាប់ នៅឡើយទេ។ ១០. ព្រះទ្រង់បានសំដែង ឲ្យយើងរាល់គ្នាឃើញសេចក្តីទាំងនោះ ដោយសារវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ដ្បិតវិញ្ញាណបរិសុទ្ធរបស់ទ្រង់ស្ទង់មើលគ្រប់ទាំងអស់ ព្រមទាំងសេចក្តីជ្រាលជ្រៅនៃព្រះដែរ» នេះជាការមួយដែលខ្ញុំមានបំណងចិត្តចង់ស្គាល់ ចង់យល់ ពីសេចក្តីជ្រាលជ្រៅនៃព្រះ នៅក្នុងបទព្រះគម្ពីរ។ ១១. «ដ្បិតបើមិនមែនជាវិញ្ញាណ ដែលនៅក្នុងខ្លួនមនុស្សទេ នោះតើមានអ្វីនឹងស្គាល់សណ្ឋានមនុស្សនោះបាន ហើយបើមិនមែនជាវិញ្ញាណនៃព្រះ នោះក៏គ្មានអ្នកណាស្គាល់សណ្ឋានព្រះបានដែរ» (១កូរិនថូស២:៩-១១) ដើម្បីរាប់ព្រះពរខាងវិញ្ញាណ ដែលព្រះអម្ចាស់ទ្រង់បានប្រទានមកយើង គឺឲ្យយើងបានយល់បទព្រះគម្ពីរ «ទ្រង់ក៏បានដៅចំណាំយើងរាល់គ្នា ហើយបានប្រទានវិញ្ញាណបរិសុទ្ធរបស់ទ្រង់ មកបញ្ចាំចិត្តយើងរាល់គ្នាផង» (២កូរិនថូស១:២២)

១កូរិនថូស២:១២. «ឯយើងរាល់គ្នា យើងមិនបានទទួលវិញ្ញាណរបស់លោកីយទេ គឺទទួលវិញ្ញាណបរិសុទ្ធដែលមកពីព្រះវិញ ដើម្បីឲ្យបានស្គាល់អស់ទាំងព្រះគុណ ដែលព្រះបានផ្តល់មកយើង ១៣. ហើយយើងក៏និយាយពីសេចក្តីទាំងនោះឯង មិនមែនដោយពាក្យសំដី ដែលប្រាជ្ញាមនុស្សបានបង្រៀនទេ គឺដោយពាក្យសំដី ដែលវិញ្ញាណបរិសុទ្ធរបស់ព្រះបង្រៀនវិញ ព្រម

ទាំងថ្លឹមពន្យល់សេចក្តីខាងឯវិញ្ញាណ ដោយសារសេចក្តីខាងឯវិញ្ញាណផង» (១កូរិនថូស២:១២-១៣) លោកសាវកប៉ុល បានពន្យល់ថា មនុស្សសាមញ្ញខាងសាច់ឈាម មិនអាចយល់បានទេ។

ចូរយើងដឹងថា យើងរាល់គ្នាបានដៅចំណាំ ដោយវិញ្ញាណបរិសុទ្ធរបស់ព្រះ ហើយទ្រង់បានប្រទានឲ្យយើងមានដំរិះប្រាជ្ញា ដើម្បីយល់ពីព្រះរាជបំណងដ៏អាថ៌កំបាំងនៃព្រះ! ចូរយើងគិតពីការនោះ។ បើអ្នកជួបនឹងមនុស្សដែលធ្វើដំណើរតាមផ្លូវ ហើយអ្នកសួរគេថា តើអ្វីទៅជាបំណងព្រះហឫទ័យនៃព្រះ? ខ្ញុំគិតថា អ្នកទាំងនោះគ្មានចម្លើយ ឆ្លើយតបនឹងអ្នកវិញទេ ពីព្រោះគេមិនស្គាល់ពីបំណងព្រះហឫទ័យនៃព្រះទេ។ ព្រះអម្ចាស់ទ្រង់បានបើកសម្តែងពីព្រះហឫទ័យទ្រង់ឲ្យយើងដឹងតាមរយៈការរក្សាថ្ងៃសប្ប័ទ នឹងថ្ងៃបុណ្យបរិសុទ្ធទាំងប៉ុន្មានរបស់ព្រះអង្គ (លេវីវិន័យ២៣) ះជាការដ៏អស្ចារ្យ ដែលព្រះទ្រង់ប្រទានថ្ងៃសប្ប័ទ នឹងថ្ងៃបុណ្យបនរិសុទ្ធទាំងប៉ុន្មានរបស់ទ្រង់មក យើងរាល់គ្នា ដើម្បីឲ្យយើងបានប្រារព្ធធ្វើ នឹងប្រព្រឹត្តតាម ទុកជាថ្ងៃប្រជុំជំនុំបរិសុទ្ធ។ លោកសាវកប៉ុលសរសេរថា «ឲ្យរួមមកក្នុងទ្រង់ ដែលយើងរាល់គ្នាបានកេរ្តិ៍អាករក្នុងទ្រង់ដែរដោយទ្រង់បានដំរូវយើងទុកជាមុន តាមដំរិះសំរេចរបស់ព្រះ ដែលទ្រង់ធ្វើគ្រប់ការទាំងអស់តាមដែលគាប់ព្រះហឫទ័យទ្រង់» (អេភេសូរ១:១១)

ព្រះអម្ចាស់ទ្រង់ត្រាស់ហៅអ្នក ជ្រើសរើសអ្នក ហើយទ្រង់បានដំរូវអ្នកទុកជាមុន «...ដែលទ្រង់ធ្វើការគ្រប់ទាំងអស់ តាមដែលគាប់ព្រះហឫទ័យទ្រង់» ដោយហេតុនេះហើយ បានជាមានអធិស្ឋានជាប្រចាំ «...សូមឲ្យព្រះហឫទ័យទ្រង់បានសំរេច...» (ម៉ាថាយ៦:១០) មិនមែនបំណងតុរបស់យើងរាល់គ្នា បានសំរេចនោះទេ ពីព្រោះព្រះហឫទ័យព្រះអម្ចាស់ នោះធំជាងចិត្តយើងទដងណាស់ ហើយល្អ ក៏«...ទ្រង់គ្រប់លក្ខណ៍» (ម៉ាថាយ ៥:៤៨)។

លោកអ័ប្រាហាំ នឹងសារ៉ា ព្យាយាមបំពេញបំណងព្រះហឫទ័យនៃព្រះ តាមរយៈសាច់ឈាមអរយៈនាងហាការ ជាបាវបំរើស្រីរបស់សារ៉ា ពីស្រុកអេស៊ីព្ទ។ យើងមិនអាចបំពេញផែនការណាងព្រះហឫទ័យរបស់ព្រះដោយចិត្ត នឹងគំនិតរបស់យើងបាននោះទេ។ ដោយសារទង្វើសារ៉ា អ័ប្រាហាំ នឹងហាការ យើងរាល់គ្នាបានជាប់ស្ទះជាមួយនឹងពួកកូនចៅអ៊ីស្មាអែល នឹង

ពូជពង្សរបស់គាត់ អស់ពេលដ៏យូរលង់ៗ អេភេសូរ១:១១. «...ដែលទ្រង់ធ្វើគ្រប់ការទាំងអស់ តាមដែលគាប់ព្រះហឫទ័យទ្រង់ ១១២. ប្រយោជន៍ឲ្យយើងខ្ញុំ ដែលបានទុកចិត្តជឿដល់ព្រះគ្រីស្ទជាមុន បានសំរាប់នឹងសរសើរដល់សិរីល្អនៃទ្រង់ ១១៣. ឯអ្នករាល់គ្នា ក៏បានឮព្រះបន្ទូលនៃសេចក្តីពិត គឺជាដំណឹងល្អពីសេចក្តីសង្គ្រោះរបស់អ្នករាល់គ្នាដោយសារទ្រង់ដែរ ហើយកាលអ្នករាល់គ្នាបានជឿហើយ នោះទ្រង់ក៏ដៅចំណាំដោយវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ដែលបានសន្យា ១១៤. វិញ្ញាណបរិសុទ្ធរបស់ទ្រង់ ជាទីបញ្ចាំចិត្ត ពីដំណើរកេរ្តិ៍អាកររបស់យើងរាល់គ្នា ទាល់តែបានលោះរបស់កំណាន់ ដែលទ្រង់បានទិញទុកឲ្យយើងនោះ សំរាប់ជាសេចក្តីសរសើរដល់សិរីល្អនៃទ្រង់» (អេភេសូរ១:១១-១៤) បងប្អូនអើយ យើងរាល់គ្នាដឹងថា គឺព្រះទ្រង់បានបោះត្រាដៅចំណាំយើងដោយវិញ្ញាណបរិសុទ្ធរបស់ទ្រង់ហើយៗ

តើបំណងព្រះហឫទ័យរបស់ព្រះ ដែលទ្រង់ធ្វើការទាំងអស់នោះ ដើម្បីអ្វី? ដើម្បីឲ្យអស់អ្នកដែលទ្រង់បានត្រាស់ហៅ បានស្គាល់ពីបំណងព្រះហឫទ័យរបស់ព្រះទេៗ អ្នកគ្រីស្ទាននិកាយប្រូតេស្តង់ នឹងនិកាយដទៃទៀត មិនស្គាល់ពីបំណងព្រះហឫទ័យនៃព្រះទេ ពីព្រោះពួកគេមិនរក្សាថ្ងៃសប្ប័ទ ជាថ្ងៃបរិសុទ្ធ ដែលព្រះអម្ចាស់ទ្រង់បានប្រទានពរ ហើយក៏ញែកចេញជាបរិសុទ្ធព្រមទាំងមានវត្តមានរបស់ព្រះអង្គនៅថ្ងៃនោះផង ប៉ុន្តែ ពួកគ្រីស្តបរិស័ទរបស់លោកីយនេះ គេមិនប្រារព្ធធ្វើបុណ្យបរិសុទ្ធទាំងប៉ុន្មានរបស់ព្រះទេ (លេវីវិន័យ២៣) ថ្ងៃបុណ្យទាំងអស់នោះ គឺជាថ្ងៃប្រជុំជំនុំបរិសុទ្ធរបស់ផងព្រះអម្ចាស់ ហើយក៏ជាថ្ងៃសប្ប័ទ សំរាប់ជាទីសំគាល់ «...ត្រូវឲ្យឯងរាល់គ្នាកាន់អស់ទាំងថ្ងៃឈប់សំរាក ...[ថ្ងៃសប្ប័ទ]... របស់អញជាកុំខាន ដ្បិតនោះជាទីសំគាល់ដល់អញហើយនឹងឯងរាល់គ្នា នៅអស់ទាំងដំណតទៅ...» (និក្ខមនំ ៣១:១២-១៧)

ម៉ាថាយ២៥:១៤. «ដ្បិតដំណើរនេះបែបដូចជាមនុស្សម្នាក់ ដែលរៀបនឹងចេញពីស្រុកទៅគាត់ហៅពួកបាវមកប្រគល់របស់ទ្រព្យខ្លួនទុកនឹងគេ ១១៥. បានឲ្យប្រាក់ទៅម្នាក់៥ពាន់ ម្នាក់ទៀត២ពាន់ ហើយអ្នកទីបី១ពាន់ គឺឲ្យគ្រប់គ្នាតាមដំរិះគេរៀងខ្លួន រួចក៏ចេញទៅ ១១៦. នោះអ្នកដែលទទួល៥ពាន់ក៏យកប្រាក់ទៅជួញបានចំណេញ៥ពាន់ទៀត ១១៧. ហើយអ្នកដែលទទួល២ពាន់

គាត់ធ្វើដូច្នោះដែរ ក៏បានចំណេញ២ពាន់ទៀត ១១៨. តែឯអ្នកដែលទទួលតែ១ពាន់ វាទៅជីកដីកប់ប្រាក់របស់ចៅហ្វាយវិញ ១១៩. យូរក្រោយមក ចៅហ្វាយរបស់បាវទាំងនោះត្រឡប់មកវិញ គិតបញ្ជីនឹងគេ ១២០. ចំណែកអ្នកដែលបានទទួល៥ពាន់ ក៏យក៥ពាន់ទៀត មកជំរាបចៅហ្វាយ ថា លោកចៅហ្វាយ លោកបានប្រគល់៥ពាន់មកខ្ញុំ មើល ខ្ញុំបានចំណេញ៥ពាន់ទៀត ១២១.ចៅហ្វាយនិយាយថា ប្រពៃហើយ បាវល្អស្មោះត្រង់អើយ ឯងមានចិត្តស្មោះនឹងត្រួតរបស់បន្តិចនេះ ដូច្នេះ អញនឹងតាំងឲ្យឯងត្រួតលើរបស់ជាច្រើនទៅទៀត ចូរឲ្យឯងប្រកបដោយសេចក្តីអំណររបស់ចៅហ្វាយឯងចុះ ១២២. កាលអ្នកដែលទទួល២ពាន់បានមកដល់ នោះក៏ជំរាបថា លោកចៅហ្វាយ លោកបានប្រគល់២ពាន់មកខ្ញុំ មើល ខ្ញុំបានចំណេញ២ពាន់ទៀត ១២៣. ចៅហ្វាយនិយាយថា ប្រពៃហើយ បាវល្អស្មោះត្រង់អើយ ឯងមានចិត្តស្មោះនឹងត្រួតរបស់បន្តិចនេះ ដូច្នេះ អញនឹងតាំងឲ្យឯងត្រួតលើរបស់ជាច្រើនទៅទៀត ចូរឲ្យឯងប្រកបដោយសេចក្តីអំណររបស់ចៅហ្វាយឯងចុះ ១២៤. ឯអ្នកដែលបានទទួល១ពាន់ វាក៏ចូលមកជំរាបចៅហ្វាយថា លោកចៅហ្វាយ ខ្ញុំដឹងថា លោក ជាមនុស្សតឹងរឹងណាស់ លោកច្រូតនៅកន្លែងដែលមិនបានសាបព្រោះ ហើយប្រមូលនៅកន្លែងដែលមិនបានរោយ ១២៥. ដូច្នេះ ខ្ញុំនឹកខ្លាច ក៏ទៅកប់ប្រាក់១ពាន់នេះទុកក្នុងដី ហ៎ ខ្ញុំសូមប្រគល់របស់លោកជូនលោកវិញ ១២៦. ចៅហ្វាយក៏ឆ្លើយតបថា បាវអាក្រក់ ហើយខ្ជិលច្រអូសអើយ បើឯងដឹងថា អញច្រូតនៅកន្លែងដែលមិនបានសាបព្រោះ ហើយប្រមូលនៅកន្លែងដែលមិនបានរោយ ១២៧. នោះគួរតែឯងបានយកប្រាក់ទៅ ផ្ញើទុកនឹងអ្នកចងការចុះ លុះដល់អញមកវិញ នោះនឹងបានប្រាក់អញ ទាំងដើម ទាំងការផង ១២៨. ដូច្នេះ ចូរដកប្រាក់១ពាន់នោះពីវាចេញ ឲ្យដល់អ្នកដែលមាន១ម៉ឺនវិញ ១២៩. ដ្បិតនឹងឲ្យដល់អស់អ្នកដែលមាន ហើយអ្នកនោះនឹងមានជាបរិបូរឡើង តែអ្នកណាដែលគ្មាន នោះនឹងត្រូវហូតយក ទាំងរបស់អ្វី ដែលអ្នកនោះមានផង» (ម៉ាថាយ២៥:១៤-២៩) ឯអ្នកទី៣ ជាបាវអាក្រក់ ដែលមិនបានបង្កើតផលអ្វីឲ្យចៅហ្វាយគាត់សោះ នោះត្រូវចៅហ្វាយគាត់ដកយកចំណែកនោះមកវិញ។ ១៣០. ឯបាវឥតប្រយោជន៍នោះ ចូរបោះវាចោលទៅឯទីងងឹត ខាងក្រៅទៅ នៅទីនោះនឹងយំ ហើយសង្កៀតធ្មេញ» (ម៉ាថាយ២៥:៣០)

ចំណែកឯអ្នកទី៣ ទទួល១ពាន់ តែមិនបានបង្កើតផលអ្វី ដល់ចៅហ្វាយរបស់ខ្លួនសោះ នោះជាបាវបំរើអាក្រក់ ហើយឥតប្រយោជន៍ នឹងត្រូវបោះចោលទៅក្នុងទីងងឹត ឬបោះទៅក្នុងបឹងភ្លើង ដែលនឹងឆេះអស់ទៅ។ យ៉ាងណាមិញ យើងរាល់គ្នា ជាអ្នកជឿពិត ដែលបានទទួលអំណោយទានជាវិញ្ញាណបរិសុទ្ធរបស់ព្រះ យើងត្រូវតែបង្កើតផលផ្លែ ថ្វាយព្រះ។ ព្រះអម្ចាស់យេស៊ូវគ្រីស្ទទ្រង់មានបន្ទូលថា «មិនមែនអ្នករាល់គ្នាដែលបានរើសខ្ញុំ គឺខ្ញុំទេតើ ដែលរើសអ្នករាល់គ្នាវិញ ទាំងតាំងអ្នករាល់គ្នាឲ្យទៅបង្កើតផល ហើយឲ្យផលរបស់អ្នករាល់គ្នាបាននៅជាប់ផង ដើម្បីឲ្យព្រះវរបិតាបានប្រោសប្រទានឲ្យអ្នករាល់គ្នាបានអ្វីៗ ដែលនឹងសូមពីទ្រង់ ដោយនូវឈ្មោះខ្ញុំ» (យ៉ូហាន១៥:១៦) ការដែលយើងរាល់គ្នាត្រូវធ្វើ គឺប្រែចិត្ត ពីអំពើបាប ជឿព្រះយេស៊ូវគ្រីស្ទ ទទួលបុណ្យជ្រមុជទឹក ហើយទទួលអំណោយទានជាវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ទុកជាកិច្ចចុះសេចក្តីសន្យាសញ្ញាថ្មី (The New Covenant) ជាមួយនឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទ ហើយនឹងបន្តការសិក្សាព្រះគម្ពីរ ដើម្បីឲ្យបានចំរើនឡើងក្នុងព្រះគុណ នឹងជំរិះប្រាជ្ញានៅក្នុងព្រះអម្ចាស់យេស៊ូវគ្រីស្ទ (២ពេត្រុស៣:១៨) ដោយស្តាប់បង្គាប់ រក្សាថ្ងៃសប្ប័ទ នឹងប្រារព្ធធ្វើថ្ងៃបុណ្យបរិសុទ្ធទាំងប៉ុន្មានរបស់ព្រះអង្គ ដោយស្រឡាញ់ព្រះវរបិតា នឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទ ហើយស្រឡាញ់បងប្អូនពួកជំនុំរួមជំនឿ ដោយអធិស្ឋានឥតឈប់ឈរ នឹងចេញទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យ ដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា នឹងវិញ្ញាណបរិសុទ្ធរបស់ព្រះ ហើយនឹងបង្រៀនគេឲ្យកាន់ខ្ជាប់តាមគ្រប់ទាំងសេចក្តីពិត ដែលនៅក្នុងបទព្រះគម្ពីរទាំងមូលផង។

លោកសាវកយ៉ូហាន សរសេរថា «ឯអ្នកណាដែលឈ្នះ ហើយកាន់តាមការអញ ដរាបដល់ចុងបំផុត នោះអញនឹងឲ្យមានអំណាច លើពួកសាសន៍ដទៃ ២៧. អ្នកនោះនឹងឃ្វាលគេដោយដំបងដែក ដូចជាគេបំបែកភាជនៈដីឲ្យខ្ទេចខ្ទី តាមអំណាចដែលអញបានទទួលពីព្រះវរបិតាមក» (វិវរណៈ ២:២៦-២៧) យើងនឹងសោយរាជ្យជាមួយនឹងព្រះគ្រីស្ទ នៅលើផែនដីនេះ ឲ្យតែយើងកាន់ខ្ជាប់តាមព្រះបន្ទូលការទាំងអស់ ដែលទ្រង់បង្គាប់មកយើងរាល់គ្នាចុះ។ យើងត្រូវធ្វើលំ

- សេចក្តីជំនុំជំរះ ដោយសុចរិត
- ដោយសេចក្តីមេត្តាករុណា
- ដោយសេចក្តីស្រឡាញ់
- ដោយចំណេះដឹង
- ដោយមានអំណាចពេញលេញមកពីព្រះ

សេចក្តីទាំងអស់ ខាងលើនេះ ជាសេចក្តី ដែលព្រះអម្ចាស់ទ្រង់បានត្រាស់ហៅ ឲ្យយើងបំពេញ។

លោកសាវកប៉ុល សរសេរថា ៨. «ដែលទ្រង់នឹងតាំងអ្នករាល់គ្នាឲ្យខ្ជាប់ខ្ជួន ដរាបដល់ចុងបំផុត ឲ្យឥតកន្ទែងបន្ទោសបាន ក្នុងថ្ងៃនៃព្រះយេស៊ូវគ្រីស្ទ...[ថ្ងៃដែលព្រះយេស៊ូវគ្រីស្ទយាងមកវិញ]...ជាព្រះអម្ចាស់នៃយើង ៩. ឯព្រះ...[ព្រះវរបិតា]...ដែលបានហៅអ្នករាល់គ្នាមក ឲ្យមានសេចក្តីប្រកបនឹងព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា នោះទ្រង់ស្មោះត្រង់» (១កូរិនថូស១:៨-៩)។ បទព្រះគម្ពីរបានសម្តែងយ៉ាងច្បាស់ថា ព្រះអម្ចាស់ទ្រង់មានបន្ទូលទៅហោរាអេសេគាលថា «អញនេះ គឺយេហូវ៉ា បានចេញវាចាហើយ ការនេះនឹងកើតមក ហើយអញនឹងធ្វើឲ្យសំរេចជាពិត អញមិនព្រមដកថយ ឬត្រាប្រណីឡើយ ក៏មិនដែលប្រែគំនិតដែរ...» (អេសេគាល២៤:១៤) ព្រះអម្ចាស់នៃយើងរាល់គ្នាទ្រង់ជាព្រះដ៏ស្មោះត្រង់ មិនដែលប្រែគំនិតរបស់ព្រះអង្គឡើយ។ លោកសាវកប៉ុល សរសេរថា «បើទុកជាយើងមិនស្មោះត្រង់ក៏ដោយគង់តែទ្រង់នៅស្មោះត្រង់ដដែល ទ្រង់ធ្វើជាមិនស្គាល់ព្រះអង្គទ្រង់មិនបានទេ» (២ធីម៉ូថេ ២:១៣) ព្រះអម្ចាស់ដែលទ្រង់ត្រាស់ហៅយើង ទ្រង់សន្យានឹងប្រោសឲ្យយើងរស់ឡើងវិញ នៅថ្ងៃចុងបំផុត ជាថ្ងៃដែលព្រះយេស៊ូវគ្រីស្ទទ្រង់យាងមកវិញ (យ៉ូហាន៦:៤៤) ហើយនឹងប្រទាននគរមកយើងឲ្យបានសោយរាជ្យជាមួយនឹងព្រះអង្គ នៅផែនដីនេះ (លូកា១២:៣២, វិវរណៈ៥:១០)

យើងរាល់គ្នាដែលមានសេចក្តីសង្ឃឹមដល់សេចក្តីសន្យារបស់ព្រះវរបិតា នឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទ ២. «ពួកស្ងួនភ្ងាអើយ ឥឡូវនេះ យើងរាល់គ្នាជាកូនព្រះហើយ តែដែលយើងរាល់

គ្មានឹងបានទៅជាយ៉ាងណាទៀត នោះមិនទាន់សំដែងមកនៅឡើយ ប៉ុន្តែ យើងដឹងថា កាលណាទ្រង់...[ព្រះយេស៊ូវគ្រីស្ទ]...លេចមក នោះយើងនឹងបានដូចជាទ្រង់ ដ្បិតដែលទ្រង់យ៉ាងណា នោះយើងនឹងឃើញទ្រង់យ៉ាងនោះឯង ៣. អស់អ្នកណាដែលមានសេចក្ដីសង្ឃឹមយ៉ាងនេះដល់ទ្រង់ នោះក៏តែងជំរះសំអាតចិត្តខ្លួន ឲ្យដូចទ្រង់ដែលស្អាតដែរ» (១យ៉ូហាន៣:២-៣)។

## ◉សូមរៀនបន្តទៅមេរៀនជ្រមុជទឹក ទី២ទៀត

កំណត់ចំណាំ៖ បើឃើញសញ្ញានេះ «... មានន័យថា មានពាក្យខ្វះមិនបានចម្លងពីមុន

បើឃើញសញ្ញានេះ ...» មានន័យថា មានពាក្យខ្វះមិនបានចម្លងពីក្រោយសញ្ញា

បើឃើញសញ្ញានេះ ...[ ]... ហើយមានឈ្មោះនៅក្នុងសញ្ញា នោះជាការបញ្ជាក់ឈ្មោះ

ឧទាហរណ៍៖ ខ្ញុំ...[ប៉ុល]...

គម្ពីរយោង

១. ទំនុកដំកើង ២:២-៣
២. ២ថែស្សាឡូនីច២:៤-១២
៣: វិវរណៈ១៩:១៦
៤. រ៉ូម៥:១-៤
៥. ១កូរិនថូស១៥:១៧
៦. ម៉ាថាយ១០:២១-២២
៧. ១កូរិនថូស១១:៨-២១
៨. ហេព្រើរ១១:៦
៩. និក្ខមនំ២០:៨
១០. រ៉ូម៥:៥
១១. ១កូរិនថូស២:១-៦
១២. ១កូរិនថូស១:២១-២៦

១៣. លូកា១២:៣២
១៤. អេភេសូរ៥:៦
១៥. ១កូរិនថូស១២:៩-៣០
១៦. រ៉ូម៥:១-៤
១៧. វិវរណៈ៥:១០
១៨. ១កូរិនថូស ១:២១-២៦
១៩. ១កូរិនថូស ១:២៧-២៨
២០. ម៉ាថាយ៦:១០
២១. ម៉ាថាយ១៥:១៤-៣០
២២. ១កូរិនថូស១:៨-៩
២៣. អេសេគាល២៤:១៤
២៤. ២ធីម៉ូថេ២:១-៣
២៥. ១យ៉ូហាន៣:១-៣

គម្ពីរមិនបានចម្លង

ម៉ាថាយ ២៤:១៣
យ៉ូហាន ៦:៤៤
វិវរណៈ ជំពូក១៧ នឹង១៨
ទំនុកដំកើង ១៩
១ថែស្សាឡូនីច ៤:១៣-១៧
ម៉ាថាយ ៧:២៣
ម៉ាថាយ ១២:៤០
វិវរណៈ៥:៦
២ពេត្រុស៣:១៨

«ចូរខំប្រឹងសិក្សា ...[ព្រះបន្ទូល]...ទុកជាមនុស្សដែលបានល្បង លជាប់ហើយ ជាអ្នកធ្វើការ ដែលមិនត្រូវខ្មាសឡើយ ដោយកាត់ស្រាយព្រះបន្ទូលនៃសេចក្ដីពិតយ៉ាងត្រឹមត្រូវ»
(២ធីម៉ូថេ២:១៥)

«ទូលបង្គំបានកំណត់ចាំព្រះបន្ទូលទ្រង់ទុកនៅក្នុងចិត្ត ប្រយោជន៍កុំឲ្យទូលបង្គំធ្វើបាបនឹងទ្រង់ឡើយ» (ទំនុកដំកើង១១៩:១១)

# ព្រះអម្ចាស់ផ្ទាល់ ត្រាស់ហៅអ្នក

សព្វថ្ងៃនេះយើងកំពុងរស់នៅក្នុងគ្រាចុងបញ្ចប់នៃលោកីយ ជាការរស់នៅជំនាន់ចុងក្រោយរបស់យើងរាល់គ្នា។ យើងរស់នៅក្នុងគ្រាដែលមានព្រឹត្តិការណ៍ជាច្រើនកំពុងកើតឡើង ហើយសេចក្តីទំនាយពិតកំពុងតែត្រូវបានបំពេញ ហើយត្រូវបានសំរេចយ៉ាងពិតប្រាកដ នៅចំពោះមុខយើងរាល់គ្នាផង។ យើងមិនទាន់ដឹងច្បាស់ថា ពេលវេលាណាដែលត្រូវមកដល់នោះទេ ហើយតើយើងនឹងត្រូវរស់នៅដោយរបៀបណា? នេះជារឿងដ៏សំខាន់ ហើយជាគន្លិះដ៏សំខាន់ ពីព្រោះយើងមិនត្រូវឲ្យលោកីយនេះអូសទាញនាំយើងរាល់គ្នា ទៅតាមផ្លូវរបស់គេឡើយ។

យើងរស់នៅក្នុងលោកីយ ប៉ុន្តែយើងមិនមែនជារបស់លោកីយទេ ហើយមានពេលខ្លះវាពិបាកណាស់ ដោយព្រោះយើងនៅមានលក្ខណៈជាសាច់ឈាម ឬជាមនុស្ស ហើយអំពើបាបតែងកើតឡើងដល់យើង ហើយព្រឹត្តិការណ៍នានា ក៏កើតឡើងដល់យើងដែរ ហើយវាធ្វើឲ្យចិត្តយើងទោរទន់ទៅរកភាពធុញទ្រាន់ ដោយការប្រឈមមុខនឹងបញ្ហា ហើយនឹងអ្វីៗទៀត គ្រប់យ៉ាងដែលយើងធ្វើ។ យើងត្រូវតែមានកម្លាំងរបស់ព្រះគ្រីស្ទ នៅក្នុងខ្លួនយើង ព្រោះព្រះគ្រីស្ទទ្រង់ជាកម្លាំង នឹងគឺជាសេចក្តីសង្ឃឹមនៃសិរីល្អ នោះហើយជាអ្វីដែលយើងត្រូវផ្តោតចំពោះ។

សូមមើលទៅគម្ពីរកូល៉ុសជំពូក១ ចូរមើល តើព្រះបានធ្វើអ្វីខ្លះនៅក្នុងជីវិតរបស់យើង? ខ្ញុំគិតថារឿងដ៏សំខាន់បំផុតមួយនេះ ដែលយើងត្រូវយល់ពីរបៀបដែលព្រះអម្ចាស់ធ្វើការនឹងដោះស្រាយបញ្ហានៅក្នុងជីវិតរបស់យើងម្នាក់ៗ ពេលខ្លះវាងាយស្រួលណាស់ក្នុងការគិតថា ព្រះទ្រង់គង់នៅលើបល្ល័ង្ករបស់ព្រះអង្គនៅឯស្ថានសួគ៌ ហើយមិនដឹងថា បល្ល័ង្ករបស់ទ្រង់ស្ថិតនៅឆ្ងាយប៉ុន្មាននោះទេ ដោយវិញ្ញាណបរិសុទ្ធរបស់ព្រះ ជាមួយនឹងព្រះបន្ទូលរបស់ទ្រង់ ហើយជាមួយនឹងអ្វីៗ ដែលព្រះកំពុងធ្វើ យើងបានយល់ថា យើងម្នាក់ៗសុទ្ធតែសំខាន់នៅចំពោះព្រះ! យើងក៏ត្រូវយល់អំពីអ្វីផ្សេងៗទៀតដែរ គឺព្រះទ្រង់មិនបានហៅយើងឱ្យកាន់សាសនា ដើម្បីធ្វើជាមនុស្សល្អនៅក្នុងពិភពលោកនោះទេ! តាមការពិត យើងត្រូវតែធ្វើជាមនុស្សល្អនៅលើលោកីយនោះ ត្រូវហើយ យើងត្រូវឲ្យពន្លឺរបស់យើងភ្លឺ។ ព្រះទ្រង់មិនបានត្រាស់ហៅយើង ឲ្យធ្វើតែការមួយមុខនោះទេ ព្រះអម្ចាស់ទ្រង់ត្រាស់ហៅយើង សំរាប់ការងារដ៏សំខាន់ៗ ដែលយើងត្រូវតែបង្ហាញដល់មនុស្ស គ្រប់សាសន៍ គ្រប់ភាសារ គ្រប់ទីកន្លែង គ្រប់ពេលវេលា នោះជាការដ៏អស្ចារ្យ នឹងជ្រាលជ្រៅបំផុតដែលព្រះអម្ចាស់កំពុងធ្វើ។ នេះគ្រាន់តែជាការបង្ហាញដល់អ្នកពីព្រះអម្ចាស់ដែលទ្រង់កំពុងធ្វើ។ សូមពិនិត្យឡើងវិញ នូវបទគម្ពីរពីរ ឬបី កន្លែង តើយើងបានមកឯព្រះយ៉ាងដូចម្តេច? យ៉ូហាន៦:៤៤ «គ្មានអ្នកណាអាចនឹងមកឯខ្ញុំ...[ព្រះគ្រីស្ទ]... បាន

ទេ លើកតែព្រះវរបិតា ដែលចាត់ខ្ញុំឲ្យមក ទ្រង់ទាញនាំគេប៉ុណ្ណោះ...»ចូរគិតអំពីការនោះ មួយនាទីសិន! ដោយសារខ្ញុំ មិនចង់ឲ្យអ្នករាល់គ្នាមានអារម្មណ៍ថា ព្រះទ្រង់គង់នៅស្ថានសួគ៌ នៅឆ្ងាយពីអ្នក ហើយអ្នកនៅឯផែនដីនេះ តើអ្នកដឹងពីការទាញនាំរបស់ទ្រង់ដោយរបៀបណា? តើអ្នកនឹងបានជាផ្នែកមួយនៃរូបកាយរបស់ព្រះគ្រីស្ទ យ៉ាងដូចម្តេច? គឺព្រះដ៏ជាព្រះវរបិតាបានទាញនាំអ្នក ដោយប្រើវិញ្ញាណបរិសុទ្ធរបស់ទ្រង់ បណ្តាលក្នុងចិត្តរបស់អ្នក ឲ្យអ្នកស្វែងរកសេចក្តីពិត តើការនេះសំខាន់ប៉ុណ្ណា? បងប្អូនអើយ ព្រះដ៏ជាព្រះវរបិតាទ្រង់បានត្រាស់ហៅអ្នក នេះជាការដ៏អស្ចារ្យណាស់! ព្រះអម្ចាស់ទ្រង់បានត្រាស់ហៅអ្នក ទ្រង់ក៏ប្រទានវិញ្ញាណបរិសុទ្ធរបស់ទ្រង់មកអ្នកដែរ។ ដូច្នេះ ព្រះដ៏ជាព្រះវរបិតា នឹងព្រះយេស៊ូវគ្រីស្ទ ទាំងពីរអង្គបានចូលរួមដោយផ្ទាល់នៅក្នុងជីវិតរបស់អ្នក រាល់នាទី រាល់ថ្ងៃ ទោះបីជាអ្នកធ្វើការនៅកន្លែងណាក៏ដោយ ឬអ្នកកំពុងធ្វើការអ្វីក៏ដោយ ទោះជាអ្នកធ្វើអ្វីនៅពេលថ្ងៃ ឬពេលយប់ក្តី ព្រះទ្រង់នៅជាប់ទាក់ទងនឹងជីវិតរបស់អ្នកជារៀងរាល់ពេល រាល់វេលា!

គម្ពីរកូល៉ុស ១:៩ «ហេតុនោះ ចាប់តាំងពីថ្ងៃ ដែលយើងខ្ញុំឮនិយាយ...[នោះជាសេចក្តីរាយការណ៍ពីពួកជំនុំកូល៉ុស-ទៅកាន់សាវកប៉ុល]... នោះយើងខ្ញុំក៏អធិស្ឋានឲ្យអ្នករាល់គ្នាឥតឈប់ឈរ ហើយទូលសូម ឲ្យអ្នករាល់គ្នាបានស្គាល់ព្រះហឫទ័យទ្រង់សព្វគ្រប់ ដោយគ្រប់ទាំងប្រាជ្ញា នឹងចំណេះខាងឯវិញ្ញាណ» នោះហើយជាគោលបំណងដែលព្រះចង់ឲ្យអ្នកមាន ឥឡូវនេះ ប្រសិនបើអ្នកមានការលំបាកក្នុងការសិក្សាព្រះគម្ពីរ សូមគិតអំពីគោលបំណងរបស់ព្រះសំរាប់អ្នកៈ

- អ្នកកំពុងត្រៀមខ្លួនសំរាប់ការងារដ៏អស្ចារ្យបំផុត ដែលមិនធ្លាប់មាន
- អ្នកកំពុងត្រូវបានរៀបចំសំរាប់ជីវិតអស់កល្ប
- អ្នកកំពុងទទួលការអប់រំ នឹងបង្រៀន

ដូច្នេះ អ្នកអាចក្លាយជាកូនប្រុស កូនស្រីរបស់ព្រះអម្ចាស់ ដោយមានគ្រប់ទាំងប្រាជ្ញា នឹងចំណេះ «...ដូចបានថែង ដោយគ្រប់ទាំងប្រាជ្ញា នឹងចំណេះខាងឯវិញ្ញាណ...[ប៉ុន្តែ យើងមានការជាច្រើនត្រូវធ្វើ]... ដើម្បីឲ្យបានដើរបែបគួរនឹងព្រះអម្ចាស់...»(ខ៩-១០) សូមសង្កេតមើលកម្មវិធីខាងក្រោមនេះ តើយើងដើរឲ្យបានបែបគួរនឹងព្រះអម្ចាស់យ៉ាងដូចម្តេច?

- អ្នកដើរដោយជំនឿ ព្រះអង្គបានត្រាស់ហៅអ្នកឲ្យដើរ តាមផ្លូវរបស់ទ្រង់
- អ្នកជឿជាក់ ដោយសេចក្តីសង្ឃឹមថា ព្រះទ្រង់នឹងប្រទានជីវិតអស់កល្បដល់អ្នក
- ព្រះអម្ចាស់ទ្រង់ប្រទានកម្លាំង ដើម្បីឲ្យអ្នកអាចធ្វើអ្វីៗគាប់តាមព្រះហឫទ័យទ្រង់

ហើយអ្នកនឹងដើរឲ្យបែបគួរនឹងព្រះអម្ចាស់ផង ...ទាំងគាប់ចិត្តដល់មនុស្សទាំងអស់ ឲ្យបង្កើយផលល្អក្នុងគ្រប់ការទាំងអស់ ហើយឲ្យស្គាល់ព្រះកាន់តែច្បាស់ឡើង ដោយបានគ្រប់ទាំងព្រះ

ចេស្ដា ចំរើនកម្លាំង  តាមរិទ្ធិបារមីដ៏ឧត្ដមរបស់ទ្រង់ ដើម្បីឲ្យបានចេះទ្រាំទ្រ ហើយអត់ធន់គ្រប់យ៉ាង ដោយអំណរ» (កូល៉ុស១:១០-១១) សូមពិចារណាមើលពីផ្លូវដែលអ្នកកំពុងដើរ  មិនថាជាមានអ្វីកើតឡើងនៅក្នុងជីវិតរបស់អ្នកនោះទេ-ហើយមានការលំបាកខ្លះៗ ពេលអ្នកកំពុងដើរតាមផ្លូវនោះ ឆ្ពោះទៅដល់ទីបញ្ចប់ ដោយអ្នកបន្តកាន់ខ្ជាប់ខ្លួនរហូតដល់ចុងបំផុត។ អ្នកត្រូវឆ្លងកាត់ទុក្ខលំបាក ប៉ុន្តែ ត្រូវចងចាំថា ព្រះទ្រង់គង់ជាមួយអ្នករាល់ៗថ្ងៃ នឹងគ្រប់វិនាទី។

ចូរនឹកចាំ ដោយសារព្រះទ្រង់គង់នៅជាមួយនឹងអ្នករាល់ថ្ងៃ ព្រះទ្រង់រងទុក្ខជាមួយនឹងអ្នក នៅពេលអ្នកមានការរងទុក្ខលំបាក ទ្រង់ប្រទានសេចក្ដីអំណរ សេចក្ដីស្រឡាញ់ នឹងការយល់ដឹងពីព្រះដែលទ្រង់ត្រាស់ហៅយើង ហើយយើងទទួលការត្រាស់ហៅរបស់ទ្រង់ គឺជាការមួយដ៏អស្ចារ្យ!  កូល៉ុស ១:១២ «ព្រមទាំងអរព្រះគុណ ដល់ព្រះវរបិតា ដែលទ្រង់បានប្រោស ឱ្យយើងបានគួរ នឹងទទួលចំណែកកេរ្ដិ៍អាករ...  [យើងបានឮរួចមកហើយថា  យើងមានលក្ខណៈគ្រប់គ្រាន់នឹងទទួលចំណែកក្នុងនគរព្រះ តើអ្នកមិនចង់នៅទីនោះទេឬ?!]...នឹងពួកបរិសុទ្ធនៅទីភ្លឺ» នោះជាការពិត ប៉ុន្តែ តើអ្នកណានឹងផ្ដល់ឲ្យអ្នកមានលក្ខណៈគ្រប់គ្រាន់ នឹងទទួលកេរ្ដិ៍អាករ? គឺជាព្រះ ត្រូវហើយ! យើងមានការងារជាច្រើន  ដែលយើងត្រូវធ្វើ  ហើយយើងត្រូវធ្វើឲ្យបានត្រឹមត្រូវផង ហើយយើងក៏មានកិច្ចការជាច្រើននៅក្នុងជីវិតផ្ទាល់ខ្លួនរបស់យើងដែរ យើងមានកិច្ចការជាច្រើននៅក្នុងគ្រួសាររបស់យើង នឹងកិច្ចការជាច្រើននឹងធ្វើជាមួយនឹងបងប្អូនស្ងួនភ្ងាយើង។  យើងត្រូវមានការរីកចំរើនផ្ទាល់ខ្លួន ហើយនឹងយកជ័យជំនះ។  ព្រះអម្ចាស់មិនបានត្រាស់ហៅយើង  ឲ្យយើងរស់នៅក្នុងសភាពទ្រុឌទ្រោម  ឬក៏ឲ្យផ្លូវជីវិតរបស់យើងនៅទ្រឹងមួយកន្លែងនោះទេ។ ព្រះទ្រង់បានត្រាស់ហៅយើង ឲ្យមានអំណាច ដ៏រំភើប យ៉ាងអស្ចារ្យ ដែលអាចឲ្យយើងធ្វើការថ្វាយទ្រង់បាន។  ការនោះ មិនថាជាការអធិស្ឋានដូចដែលយើងតែងតែមានការអធិស្ឋានសំរាប់អ្នកដែលមានបញ្ហា នឹងការលំបាកក្នុងជីវិត  ព្រមទាំងការប្រោសជំងឺ។

ឥឡូវសូមកត់សម្គាល់: តើទ្រង់ឲ្យយើងបានគួរនឹងទទួលអ្វី? «...ឲ្យយើងបានគួរ នឹងទទួលចំណែកកេរ្ដិ៍អាករ...  តើកេរ្ដិ៍អាករនោះជាអ្វី?

- ក្នុងដំណើរនៃជីវិតរបស់មនុស្សគ្រប់គ្នា  គឺទទួលកេរ្ដិ៍អាករពីឪពុក ម្ដាយដែលស្លាប់ ឬក៏ទទួលកេរ្ដិ៍អាករ ពីមីង ពីពូ ដែលបានស្លាប់ទៅហើយ រាល់ពេលដែលអ្នកទទួលកេរ្ដិ៍អាករពីពួកគាត់ តើនោះមិនមែនជាការពិតទេ ឬអី? វាជាការពិតមែន! តើកេរ្ដិ៍អាករប្រភេទណា ដែលយើងនឹងទទួលពីព្រះអម្ចាស់? យើងនឹងទទួលកេរ្ដិ៍អាករ ដ៏មានអានុភាពមែន!   មិនមែនជាការងាយស្រួលនោះទេ  ពីព្រោះ:
- យើងមានការដែលត្រូវធ្វើ
- យើងមានការដែលត្រូវឆ្លងកាត់

- យើងមានការល្បួងលដែលយើងត្រូវរងទ្រាំ
- យើងមានការដែលយើងត្រូវតែយកជ័យជំនះ
- យើងមានអំពើបាបដែលយើងត្រូវតែប្រែចិត្ត
- យើងមានភាពខ្ជិលច្រអូសដែលយើងត្រូវកំចាត់វាចោល បញ្ហាទាំងអស់នោះ គឺជាការពិត ពីរបៀបដែលជីវិតរបស់យើងត្រូវបានដឹកនាំ «ហើយអស់អ្នកណាដែលវិញ្ញាណបរិសុទ្ធនៃព្រះនាំ... [វិញ្ញាណបរិសុទ្ធនៃព្រះ មិនធ្វើអ្វីឱ្យអ្នក ឬនឹងអូសទាញអ្នកចេញទេ ហើយក៏មិនសង្កត់សង្កិនអ្នកដែរ ទុកឲ្យអ្នកមានសិរីភាពក្នុងការជ្រើសរើស នឹងសំរេចចិត្ត ប៉ុន្តែ វិញ្ញាណបរិសុទ្ធរបស់ព្រះ នឹងនាំអ្នកឲ្យមានសេចក្ដីប្រាថ្នា នឹងបំណងចិត្តស្រឡាញ់ដល់ព្រះអម្ចាស់] ...អ្នកទាំងនោះហើយជាកូនរបស់ព្រះ ១៥. អ្នករាល់គ្នាមិនបានទទួលនិស្ស័យជាបាវបំរើ ឲ្យត្រូវភ័យខ្លាចទៀតឡើយ គឺបានទទួលនិស្ស័យជាកូនវិញ ដោយហេតុនោះ បានជាយើងស្រែកឡើងថា ឱអ័ប្បា ព្រះវរបិតាអើយ» (រ៉ូម៨:១៤-១៥)

សេចក្ដីសន្យារបស់ព្រះជាសេចក្ដីពិត ខ្ញុំបានចាប់ផ្ដើម ដោយព្រះវរបិតាដែលទាញនាំខ្ញុំ សូមឈប់ហើយគិតមួយភ្លែតសិន! ព្រះដ៏ខ្ពង់ខ្ពស់បំផុត គឺព្រះដ៏ជាព្រះវរបិតា ទ្រង់គ្រប់គ្រងលើលោកីយ ទាំងមូលព្រះដ៏ជាព្រះវរបិតា ទ្រង់បានចាត់ព្រះរាជបុត្រារបស់ទ្រង់ឲ្យមកផែនដីនេះ ដើម្បីសុគតលោះបាបរបស់អ្នក ហើយនឹងខ្ញុំ ដើម្បីឲ្យយើងអាចរស់នៅបាន គឺទ្រង់ផ្ទាល់ដែលត្រាស់ហៅអ្នក ដូច្នេះ យើងម្នាក់ៗយល់ពីសេចក្ដីដ៏សំខាន់ នឹងជ្រាលជ្រៅបំផុត សំរាប់ការត្រាស់ហៅដ៏អស្ចារ្យ ហើយយើងអាចហៅទ្រង់ថា ជា «ឱអ័ប្បា» ព្រះវរបិតាអើយ មានកូនរបស់ទ្រង់នៅទីនេះ កូនៗរបស់ព្រះវរបិតា ចូលមកលុតជង្គង់ ហើយទូលថា «ព្រះវរបិតាអើយ» នោះជាគំរូដ៏ល្អ ក្នុងការសរសើរដំកើងដល់ទ្រង់ ១៦. ហើយវិញ្ញាណបរិសុទ្ធរបស់ទ្រង់ក៏ធ្វើបន្ទាល់នឹងវិញ្ញាណយើងថា យើងជាកូនរបស់ព្រះ ១៧. បើសិនណាជាកូនព្រះហើយ នោះយើងក៏បានគ្រងមរដកជាមួយនឹងព្រះគ្រីស្ទផង ...» (ខ ១៦ -១៧)

បងប្អូនស្ងួនភ្ងា នេះគឺជាគម្រោងការណ៍រួមគ្នាមួយដែលមកពីព្រះវរបិតា នឹងព្រះយេស៊ូវគ្រីស្ទ ដើម្បីដោះស្រាយបញ្ហានៅក្នុងជីវិតរបស់អ្នករាល់គ្នាដោយផ្ទាល់ ប្រហែលជាសេចក្ដីនេះនឹងជួយកំចាត់ភាពខ្វះចន្លោះរបស់យើង ពីព្រោះគ្មានលោកគ្រូគង្វាលណាអាចធ្វើឲ្យអំពើបាបចេញពីនរណាម្នាក់បានទេ ឬការអធិប្បាយពីអ្នកណាម្នាក់ អាចបណ្ដេញអំពើបាបពីអ្នកណាបាននោះឡើយ! ប៉ុន្តែតាមរយៈយញ្ញបូជារបស់ព្រះយេស៊ូវគ្រីស្ទ អំណាចនៃវិញ្ញាណបរិសុទ្ធរបស់ទ្រង់ នឹងការបើកសំដែង ព្រោះបទគម្ពីរសរសេរថា៖ «...គ្រាណាដែលឥតមានការបើកសំដែង នោះបណ្ដាជនរមែងត្រូវវិនាស...» (សុភាសិត ២៩:១៨) ហើយការបើកសំដែងមិនមែនមានន័យថា អ្នកត្រូវតែធ្វើចលនានោះទេ ប៉ុន្តែ អ្នកត្រូវផ្ដោតលើអ្វីដែលព្រះកំពុងតែធ្វើនៅក្នុងជីវិតរបស់អ្នក ហើយដោយហេតុអ្វី បានជាព្រះអម្ចាស់ទ្រង់ធ្វើ?

ហេព្រើរ១:១ «ឯព្រះ ដែលពីដើម ទ្រង់មានបន្ទូលនឹងពួកឰយុកោ ដោយពួកហោរា ជាច្រើនដងច្រើនបែប ១២. នៅជាន់ក្រោយបង្អស់នេះ ទ្រង់បានមានបន្ទូលនឹងយើងរាល់គ្នា ដោយសារព្រះរាជបុត្រាវិញ ដែលទ្រង់បានដំរូវឲ្យបានគ្រងរបស់ទាំងអស់ ទុកជាមរដក ...»(១១-២) តើ «គ្រងរបស់ទាំងអស់ មានន័យដូចម្តេច? នេះមានន័យថា ព្រះយេស៊ូវទ្រង់នឹងគ្រប់គ្រងផែនដីទាំងមូល។ ព្រះអម្ចាស់មិនបានបង្កើតលោកីយមក ឲ្យវានៅទំនេរ នោះទេ ទ្រង់បង្កើតលោកីយនេះមក សំរាប់ឲ្យយើងរស់នៅ នឹងប្រើវា! សូមយកឧទាហរណ៍មួយ ប្រសិនបើអ្នកជាម្ចាស់នៃទ្រព្យសម្បត្តិណាមួយ តើទ្រព្យសម្បត្តិនោះជារបស់ផងអ្នកមែនឬទេ? គឺជារបស់អ្នកមែន! អ្នកបានដាក់ឆន្ទៈរបស់អ្នកថា ពេល ខ្ញុំស្លាប់ទៅ ខ្ញុំចង់ផ្តល់ទ្រព្យសម្បត្តិនេះ ឲ្យទៅអ្នកនេះ ឬទៅអ្នកនោះ។ នៅពេលអ្នកស្លាប់ទៅ ពួកគេនឹងទទួលកេរ្តិ៍អាករ ហើយមរដកនឹងក្លាយជារបស់ពួកគេ។ ឥឡូវនេះ សូមអនុវត្តដូចគ្នា ព្រះយេស៊ូវគ្រីស្ទ ទ្រង់នឹងគ្រងមរតកទាំងអស់ គឺផែនដីទាំងមូលអ្នកក៏ដូច្នេះដែរ បើអ្នកមានដីមួយកន្លែង ដីនោះជារបស់ផងអ្នក។ លោកីយទាំងមូលជារបស់ផងព្រះ ដូច្នេះ ព្រះគ្រីស្ទទ្រង់នឹងគ្រប់គ្រងផែនដីនេះ ត្រូវហើយ! ព្រះគ្រីស្ទទ្រង់នឹងទទួលគ្រងមរតក «...ព្រមទាំងបង្កើតលោកីយ ដោយសារព្រះរាជបុត្រានោះដែរ ... [ទ្រង់បានបង្កើតផែនដីឡើង ក្នុងគោលបំណងដើម្បីនឹងត្រាស់ហៅយើង សូមគិតពីការនោះ!] ...គឺទ្រង់ជារស្មីភ្លឺមកពីសិរីល្អនៃព្រះ ហើយជារូបភាពនៃអង្គទ្រង់ ទាំងទ្រទ្រង់គ្រប់របស់ទាំងអស់ដោយសារព្រះបន្ទូលដ៏មានព្រះចេស្តានៃទ្រង់ ហើយក្រោយដែលបានសំអាតអំពើបាប របស់យើងរាល់គ្នាទាំងប៉ុន្មាន នោះក៏គង់នៅខាងស្តាំនៃឫទ្ធានុភាពនៅលើស្ថានដ៏ខ្ពស់ ហើយដែលទ្រង់បានទទួលនាម១ទុកជាមរដក ជានាមដែលប្រសើរជាងនាមរបស់ពួកទេវតាប៉ុណ្ណា នោះទ្រង់ក៏បានត្រឡប់ជាវិសេសជាងពួកទេវតាប៉ុណ្ណោះដែរ» (ហេព្រើរ១:២-៤) ដ្បិតព្រះទ្រង់មិនដែលហៅពួកទេវតាណាមួយជាកូនរបស់ទ្រង់ឡើង។

សូមបើកទៅគម្ពីររ៉ូម៨ ហើយចូរយើងបញ្ចប់ផ្នែក ១១៦ « ...យើងជាកូនរបស់ព្រះ បើសិនណាជាកូនព្រះហើយ នោះយើងក៏បានគ្រងមរដកដែរ គឺជាអ្នកគ្រងមរដកនៃព្រះជាមួយនឹងព្រះគ្រីស្ទផង» [តើអ្នកណាជាអ្នកទទួលគ្រងមរដកទាំងនោះ?] គឺជាអស់អ្នកដែលទទួលការត្រាស់ហៅរបស់ព្រះវរបិតា ហើយទ្រង់ទាញនាំមកឯព្រះយេស៊ូវគ្រីស្ទ អ្នកនោះនឹងទទួលមរតក យ៉ាងពិតប្រាកដ។ ហេតុនេះហើយ បានជាព្រះអង្គមានបន្ទូលថា «អ្នកណាដែលឈ្នះ» [ហើយមានអំណរនៅក្នុងព្រះអម្ចាស់] «...ឲ្យតែយើងទទួលរងទុក្ខជាមួយទ្រង់ចុះ ដើម្បីឲ្យបានដំកើងឡើងជាមួយនឹងទ្រង់ដែរ» (១១៦-១៧)

ដ្បិតនឹងមានពេលខ្លះដែលយើងនឹងត្រូវទទួលរងទុក្ខ ប៉ុន្តែ តើយើងនឹងត្រូវឆ្លងកាត់ការរងទុក្ខនឹងការលំបាកទាំងនេះ យ៉ាងដូចម្តេច? ខ្ញុំនឹងមិនសួរឲ្យនរណាម្នាក់លើកដៃទេ ប្រសិនបើអ្នកមិនធ្លាប់មានការសាកល្បង។ យើងទាំងអស់គ្នានឹងត្រូវរងទុក្ខនៅពេលណាមួយជាមិនខាន ខ្ញុំមានការរងទុក្ខរបស់ខ្ញុំ ហើយអ្នកនឹងមានការរងទុក្ខរបស់អ្នកដែរ ពោះព្រះប្រទានវាមកយើង ព្រះទ្រង់ចង់ដឹងពីអ្វី

ដែលមាននៅក្នុងចិត្តរបស់យើង។ តើយើងនឹងជឿជាក់លើទ្រង់ក្នុងគ្រប់ការទាំងអស់ឬទេ? ឬយើងដូចជាគ្រាប់ពូជដែលព្រោះតាមផ្លូវ ឬព្រោះក្នុងគុម្ពបន្លា នឹងក្នុងអញ្ចាញៗ បើដូច្នេះ តើយើងបោះបង់ចោលសេចក្តីជំនឿឬ? ទេ យើងមិនបោះបង់ចោលទេ! សូមកត់សំគាល់: តើនឹងមានអ្វីកើតឡើង បើយើងទទួលរងទុក្ខជាមួយនឹងព្រះគ្រីស្ទ ដូចព្រះគ្រីស្ទបានរងទុក្ខជំនួសយើងដែរ «ដូច្នេះយើងក៏អាចនឹងលើកដំកើងរួមគ្នាជាមួយនឹងទ្រង់ដែរ» ការរងទុក្ខបច្ចុប្បន្ននេះ មិនស្មើនឹងការទទួលបានសិរីល្អ នៅពេលដែលយើងរាល់គ្នា បានប្រោសឲ្យរស់ពីស្លាប់ឡើងវិញនោះទេ។

ពេលថ្មីនេះ ពួកវិទ្យាសាស្រ្ត បានធ្វើឲ្យប្រសើរឡើងនូវបច្ចេកវិទ្យាដែលពួកគេអាចថតរូបភាពទារកជិត៣សប្តាហ៍ នៅក្នុងផ្ទៃម្តាយបាន ពិតជាការអស្ចារ្យមែនទេ? ហើយពួកគេបានរកឃើញថាទារកមានអាយុ១២សប្តាហ៍ កំពុងចេះកំរើកដៃ ឬកំរើកជើង ឬក៏ហាត់ដើរ ទារកទាំងអស់នោះ ចេះបើកមាត់ ឬបើកភ្នែក ពួកគេញញឹម មានប្រតិកម្ម ប្រសិនបើពួកគេឮសំឡេងរំខានពីខាងក្រៅ ពីព្រោះសំឡេងនោះវាចូលទៅក្នុងពោះម្តាយ ក៏នឹងចូលទៅក្នុងអង្គធាតុអំប្រ៊ីយ៉ុង ដែលបន្ទាប់មកបញ្ជូនសំឡេងនោះទៅដល់ត្រចៀករបស់ទារក ដូច្នេះ ពួកគេឮ! ទារកមានអាយុ៨សប្តាហ៍ បានអភិវឌ្ឍយ៉ាងពេញលេញ ប៉ុន្តែ យើងមិនដែលបានគិតពីវាតាមវិធីនេះទេ បន្ទាប់ពីជីវិតត្រូវបានចាប់កំណើតមកនោះមានអត្ថិភាពដំបូងនៅក្នុងផ្ទៃម្តាយ ហើយក៏ឈានដល់ចំណុចរីកចំរើនមួយ ជីវិតនៅក្នុងស្បូន មើលមិនឃើញ អាចស្តាប់ឮតិចៗ ប៉ុន្តែ ទារកអនុវត្តរាល់មូលដ្ឋានគ្រឹះ ដើម្បីរៀបចំសំរាប់ពេលសំរាលមកក្នុងលោកីយនេះ- ឲ្យបានចាប់ផ្តើមរស់នៅ ដោយមានការចាប់មេដៃជាដើម។ ដូច្នេះ ទារកទទួលបានការអនុវត្តតិចតួចណាស់ សំរាប់ការបៅដោះ។

ឥឡូវនេះនៅពេលទារកកើតមក ពិតជាព្រឹត្តិការណ៍មួយដ៏អស្ចារ្យ ដែលនាំមកនូវជីវិតថ្មី ត្រូវតែដកដង្ហើមដំបូងជារបស់ផងខ្លួន។ រឿងដំបូងរបស់ទារក គឺត្រូវដកដង្ហើមដោយខ្លួនឯង ដែលមិនបានធ្វើពីមុនមកទេ ដូចគ្នានៅពេលយើងរស់ពីស្លាប់ឡើងវិញក៏ដូច្នោះដែរ។ ទារកដែលកើតមកត្រូវតែដកដង្ហើម ត្រូវបៅទឹកដោះ ដើម្បីរស់នៅ។ អ្នកអាចឃើញថា នេះជាជីវិតបណ្តោះអាសន្នរបស់មនុស្សដែលកើតមកនៅលើលោកីយនេះ តើនេះ មិនមែនជាការដ៏អស្ចារ្យទេឬអី? ដែលយើងរាល់គ្នាមានភាពឥតប្រយោជន៍ ពីព្រោះយើងអាចស្លាប់បាន ដោយគ្រាន់តែទះមួយដៃប៉ុណ្ណោះ។ បន្ទាប់ពីព្រះបានត្រាស់ហៅយើង ហើយបើកគំនិតរបស់យើង ទ្រង់ប្រទានឱ្យយើងនូវវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ដើម្បីបង្កើតពូជកូនរបស់ព្រះនៅក្នុងជីវិតរបស់យើង នៅក្នុងស្មារតីនឹងគំនិតរបស់យើង ដើម្បីឲ្យយើងបានជាកូនរបស់ព្រះពិត។ យើងនឹងកើតជាថ្មី នៅពេលព្រះទ្រង់ប្រោសឲ្យយើងរស់ពីស្លាប់ឡើងវិញ រស់ឡើងវិញជាវិញ្ញាណ។ នេះដូចជាការមួយដែលយើងមិនដែលបានធ្វើ ដូចជាទារកមុនពេលកើតពីផ្ទៃម្តាយមកដែរ។ យើងនឹងត្រូវធ្វើការដែលយើងមិនដែលបានធ្លាប់ធ្វើពីមុនមក។

ដូច្នេះ អ្នកអាចនិយាយបានថា មានបីប្រភេទនៃជីវិតរបស់អ្នក៖

- នៅក្នុងស្បូន
- នៅក្នុងលោកីយ
- នឹងកើតជាថ្មីនៅក្នុងនគរព្រះ

ពិតជាការអស្ចារ្យណាស់ មែនទេ?

យើងនឹងត្រូវរងទុក្ខជាច្រើន នៅពេលដែលយើងមើលទៅលើផ្លូវរបស់លោកីយនេះ តើគេកំពុងធ្វើអ្វី? យើងមើលទៅលោកីយ តើពិភពលោកនេះកំពុងដើរទៅមុខយ៉ាងដូចម្ដេច? លោកីយកំពុងតែដើរទៅក្នុងសេចក្ដីស្លាប់ ទៅក្នុងភ្លើងនរក។ សេចក្ដីរងទុក្ខវេទនានឹងមាន ការឈឺចាប់ជាច្រើននឹងកើតឡើង ហើយនឹងមានពេលដែលយើងត្រូវទទួលការប្រមាថមើលងាយ លោកីយវាមិនឲ្យយើងមានពេលវេលា សិក្សាព្រះគម្ពីរ អធិស្ឋាន ដើម្បីមានដំរិះ ប្រាជ្ញា នឹងយកជ័យជំនះលើគ្រប់ការទាំងអស់នោះទេ។

សាវកប៉ុលបន្តសរសេរ «បើសិនណាជាកូនព្រះហើយ នោះយើងក៏បានគ្រងមរដកដែរ គឺជាអ្នកគ្រងមរដកនៃព្រះជាមួយនឹងព្រះគ្រីស្ទផង ឲ្យតែយើងទទួលរងទុក្ខជាមួយនឹងទ្រង់ចុះ ដើម្បីឲ្យបានដំកើងឡើងជាមួយនឹងទ្រង់ដែរ» (រ៉ូម៨:១៧) ដូច្នេះ យើងត្រូវរៀនបំផុសគំនិតរបស់យើងជាមួយនឹង៖

- បំណងប្រាថ្នា ដើម្បីយកជ័យជំនះ
- បំណងប្រាថ្នា ដើម្បីប្រែចិត្ត
- បំណងប្រាថ្នាស្រឡាញ់ដល់ព្រះ
- បំណងប្រាថ្នាដើម្បីផ្លាស់ប្ដូរ
- បំណងប្រាថ្នាចង់រស់នៅក្នុងនគរព្រះ

ប្រសិនបើអ្នកមានសេចក្ដីទាំងនោះ អ្នកនឹងមិនចាំបាច់ព្រួយបារម្ភអំពីភាពខ្វះខាតនោះទេ អ្វីដែលខ្ញុំចង់ឲ្យអ្នកធ្វើនៅថ្ងៃនេះ គឺខ្ញុំចង់រំលឹកដល់អ្នកថា «... ឲ្យដាស់តឿនអំណោយទានរបស់ព្រះ... [វិញ្ញាណបរិសុទ្ធរបស់ព្រះ]...ដែលនៅក្នុងអ្នកដោយខ្ញុំដាក់ដៃលើ» ខ្ញុំចង់ឲ្យអ្នកឃើញនៅក្នុងគំនិតរបស់អ្នក ដូចជាសាវកប៉ុលបានសរសេរទុក៖

- ព្រះអម្ចាស់ផ្ទាល់កំពុងតែទាក់ទងនឹងអ្នក
- ព្រះអម្ចាស់ផ្ទាល់កំពុងតែជួយអ្នក
- ព្រះអម្ចាស់បានប្រទានវិញ្ញាណបរិសុទ្ធរបស់ទ្រង់មកអ្នក
- ព្រះវរបិតាស្រឡាញ់អ្នក

- ព្រះយេស៊ូវគ្រីស្ទស្រឡាញ់អ្នក

ហើយខ្ញុំចង់ឲ្យអ្នកផ្លាស់ប្តូរ ដើម្បីរីកលូតលាស់ នឹងមានជ័យជំនះ ឲ្យបានទទួលព្រះពរដ៏អស្ចារ្យបំផុត ដែលព្រះទ្រង់នឹងប្រទានៗ កូល៉ុស ១:១៣ «ទ្រង់បានប្រោសឲ្យយើងរួចពីអំណាចនៃសេចក្តីងងឹត... ...ដូចដែលខ្ញុំបានរៀបរាប់ប្រាប់មកហើយ... ហើយផ្លាស់យើងមកក្នុងនគររបស់ព្រះរាជបុត្រាស្ងួនភ្ងានៃទ្រង់...យើងទាំងអស់គ្នានឹងនៅក្រោមការដឹកនាំរបស់ព្រះយេស៊ូវគ្រីស្ទ នៅក្នុងនគររបស់ព្រះ នគរព្រះមិនមែននៅទីនេះទេ ពីព្រោះនគរព្រះមិនមែនជាលោកីយនេះទេ នគរព្រះនឹងត្រូវមក នៅពេលខាងមុខ! យើងនឹងក្លាយជាផ្នែកមួយនៃនគរនោះ កូល៉ុស១:២៦ «គឺជាសេចក្តីអាថ៌កំបាំងដែលលាក់ទុកតាំងពីអស់កល្បរៀងរាល់តែដំតមក តែឥឡូវនេះ បានបើកសំដែងឲ្យពួកបរិសុទ្ធទ្រង់ស្គាល់» តាមបំណងព្រះហឫទ័យរបស់ទ្រង់ [គ្រប់អ្វីៗទាំងអស់ដែលអ្នកយល់ គឺមកពីព្រះ] ១២៧.«ព្រះទ្រង់បានសព្វព្រះហឫទ័យ នឹងសំដែងឲ្យពួកបរិសុទ្ធនោះដឹងថា សិរីល្អដ៏បរិបូររបស់សេចក្តីអាថ៌កំបាំងនេះជាយ៉ាងណា ក្នុងពួកសាសន៍ដទៃ គឺថាព្រះគ្រីស្ទទ្រង់សណ្ឋិតនៅក្នុងអ្នករាល់គ្នា ដែលជាទីសង្ឃឹមយ៉ាងឧត្តម» (១២៦-២៧) នោះហើយជាមូលហេតុ ដែលព្រះគ្រីស្ទទ្រង់គង់នៅក្នុងយើង [ដោយវិញ្ញាណបរិសុទ្ធ] មិនចាំទាល់តែយើងបានត្រូវប្រោសឲ្យរស់ពីស្លាប់ឡើងវិញ ហើយសោយរាជ្យជាមួយព្រះគ្រីស្ទ នៅក្នុងនគររបស់ព្រះអង្គនោះទេ ប៉ុន្តែ បច្ចុប្បន្ននេះ គឺទ្រង់សណ្ឋិតនៅក្នុងយើង ដោយវិញ្ញាណបរិសុទ្ធរបស់ទ្រង់ៗ ព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យចង់រស់នៅជាមួយរាស្ត្ររបស់ទ្រង់ នោះគឺជាគោលបំណងដ៏ធំចំបងរបស់ព្រះអង្គៗ យើងមិនត្រូវស្រឡាញ់លោកីយនេះ ទោះជាយើងរស់នៅក្នុងលោកីយក៏ដោយ ប៉ុន្តែយើងមិនមែនជារបស់លោកីយនោះទេៗ

២កូរិនថូស៦:១៤ «កុំឲ្យទឹមនឹមស្រៀក ជាមួយនឹងមនុស្សមិនជឿឡើយ... មានរឿងជាច្រើនដែលយើងត្រូវតែប្រយ័ត្ន មានការជាច្រើនដែលយើងត្រូវធ្វើ យើងត្រូវរស់នៅក្នុងជីវិតរបស់យើង ដោយត្រឹមត្រូវៗ តើសេចក្តីសុចរិត នឹងសេចក្តីទុច្ចរិត ប្រកបជាមួយគ្នាយ៉ាងដូចម្តេចបាន? តើពន្លឺមានទំនាក់ទំនងយ៉ាងណាជាមួយនឹងសេចក្តីងងឹត? ហើយ «តើព្រះគ្រីស្ទ នឹងអារក្សបេលាលត្រូវអ្វីនឹងគ្នា? ឬអ្នកជឿមានចំណែកអ្វីនឹងអ្នកដែលមិនជឿ? តើវិហារនៃព្រះសំណំអ្វីនឹងរូបព្រះ ដ្បិតអ្នករាល់គ្នាជាវិហារនៃព្រះដ៏មានព្រះជន្មរស់ ដូចជាព្រះទ្រង់មានបន្ទូលថា អញនឹងនៅក្នុងគេ ហើយនឹងដើរជាមួយផង...» (១៤-១៦) អ្នកក៏អាចនិយាយបានថា យើងរីករាយជាមួយអ្នកទាំងនោះ ហើយក៏រងទុក្ខជាមួយនឹងគេដែរៗ ព្រះអម្ចាស់ដ៏ជាព្រះវរបិតាបានត្រាស់ហៅយើង តាមរយៈព្រះយេស៊ូវគ្រីស្ទ ដើម្បីប្រទានឲ្យយើងមានទំនាក់ទំនងផ្ទាល់ជាមួយនឹងព្រះអង្គៗ

- តាមរយៈការសិក្សាព្រះគម្ពីរ

- តាមរយៈការអធិស្ឋាន
- តាមរយៈការរស់នៅ នឹងដើរតាមផ្លូវរបស់ព្រះ

នោះជារឿងដ៏អស្ចារ្យ! ហើយនៅក្នុងនោះ ព្រះទ្រង់គង់នៅជាមួយយើង រាល់នាទី រាល់ថ្ងៃ នឹងរាល់ពេលវេលា នឹងគ្រប់កិច្ចការដែលយើងធ្វើ។ នោះជារឿងដ៏អស្ចារ្យ នៅពេលដែលអ្នកយល់ដឹង «អញនឹងនៅក្នុងគេ ហើយនឹងដើរជាមួយផង អញនឹងធ្វើជាព្រះដល់គេ ហើយគេនឹងធ្វើជារាស្ត្រដល់អញ... [ព្រះទ្រង់មានបន្ទូលដល់លោកីយនេះ] ...ហេតុនោះ បានជាព្រះអម្ចាស់ទ្រង់មានបន្ទូលថា ចូរចេញពីកណ្តាលពួកគេទៅ ហើយញែកខ្លួនចេញទៅដោយឡែក នោះអញនឹងទទួលឯងរាល់គ្នា អញនឹងធ្វើជាឪពុកដល់ឯងរាល់គ្នា ហើយឯងរាល់គ្នានឹងធ្វើជាកូនប្រុសកូនស្រីដល់អញ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏មានព្រះចេស្តាបំផុត» (២កូរិនថូស៦:១៦-១៨)

ហេតុនេះហើយ ដែលព្រះអម្ចាស់បានត្រាស់ហៅអ្នក - ព្រះអម្ចាស់ស្រឡាញ់អ្នក ព្រះអង្គសព្វព្រះហឫទ័យនឹងអ្នក ទ្រង់មិនបានហៅអ្នកមាន ឬអ្នកមានអំណាច ឬពួកអ្នកប្រាជ្ញទេ តែព្រះទ្រង់បានហៅយើងរាល់គ្នាវិញ។ ព្រះទ្រង់ក៏មិនបានហៅអ្នកធំ នឹងអស់អ្នកដែលមានឈ្មោះល្បីល្បាញនៅលោកីយនេះទេ គឺព្រះអម្ចាស់បានត្រាស់ហៅអ្នក ហើយនឹងខ្ញុំវិញ សំរាប់គោលបំណងដ៏អស្ចារ្យ លើសពីគំនិតដែលយើងគិត តែលោកីយនេះគេគិតមិនដល់ ពីព្រោះមិនដែលមាននៅក្នុងគំនិតរបស់ពួកគេ ឬក៏ពួកគេមិនដែលបានគិតដល់។ ការទាំងនោះ អាចយល់បានតាមរយៈវិញ្ញាណបរិសុទ្ធរបស់ព្រះដែលទ្រង់ប្រទានមកយើងថា «...ឯងជាកូនអញ អញបានបង្កើតឯងនៅថ្ងៃនេះ...» (ហេព្រើរ១:៥)

សូមមើលទៅក្នុងគម្ពីរអេភេសូរជំពូក១ ហើយសូមមើលពីអ្វីដែលយើងត្រូវធ្វើ មានការមួយដែលខ្ញុំចង់ឲ្យបងប្អូនចងចាំពីព្រះបន្ទូលនេះ ពីព្រោះខ្ញុំដឹង ដោយខ្ញុំមានការពិសោធនៅក្នុងជីវិតរបស់ខ្ញុំ-មានច្រើនដង ហើយអ្នកនឹងត្រូវឆ្លងកាត់ការសាកល្បង ដូចដែលអ្នកកំពុងដើរឆ្លងកាត់ច្រកភ្នំនៃម្លប់សេចក្ដីស្លាប់របស់អ្នក គឺដោយសារជម្ងឺ ឬដោយសារតែការបាត់បង់មនុស្សជាទីស្រឡាញ់ ឬដោយសារការបាត់បង់ការងារ - ឬដោយសារកាលៈទេសៈណាមួយ។

មានពេលខ្លះអ្នកនឹងត្រូវតែស្វែងរកព្រះ ហើយត្រូវយល់ថា បើគ្មានព្រះទេ នោះនឹងគ្មានអ្វីៗទាំងអស់ ហើយទ្រង់នឹងនាំយើងម្នាក់ៗ ទៅដល់ចំណុចដែលយើងត្រូវតែទុកចិត្តលើទ្រង់ចំពោះអ្វីៗទាំងអស់នោះគឺជាសេចក្តីសង្ខេបនៃរាល់ការសាកល្បង នឹងទុក្ខវេទនា ដែលកើតមានដល់យើង ដូចទារកតូច ដែលនៅក្នុងពោះម្តាយ ត្រូវហាត់ហ្វឹកហ្វឺនដើរ បោះមេដៃ កាលណាសំរាលពីផ្ទៃម្តាយមក នោះចេះធ្វើការទាំងអស់នោះ ដូចគ្នានឹងជីវិតរបស់យើង ដែលរស់នៅក្នុងលោកីយនេះដែរ។ យើងត្រូវឆ្លងកាត់ការសាកល្បង ទុក្ខវេទនាជាច្រើន ដែលយើងទទួល ប៉ុន្តែយើងត្រូវតែរៀនពីការទាំងអស់នោះ-

- ដើម្បីដើរជាមួយព្រះគ្រីស្ទ
- ជឿទុកចិត្តលើព្រះបន្ទូល
- ជឿដោយមានសេចក្តីសង្ឃឹម
- រស់នៅក្នុងសេចក្តីស្រឡាញ់

ទាំងអស់នោះហើយជារបៀបដែលយើងរៀនៈ

អេភេសូរ ១:៣ «សូមសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ដែលទ្រង់បានប្រទានពរមកយើងក្នុងព្រះគ្រីស្ទ ដោយគ្រប់ទាំងព្រះពរខាងព្រលឹងវិញ្ញាណនៅស្ថានដ៏ខ្ពស់»

- តើនេះមិនមែនជាព្រះពរពីស្ថានសួគ៌ដែលព្រះវរបិតាបានត្រាស់ហៅយើងរាល់គ្នាទេឬអី?
- តើនេះមិនមែនជាព្រះពរពីជាស្ថានសួគ៌ដែលយើងទទួលវិញ្ញាណបរិសុទ្ធរបស់ព្រះទេឬអី?
- តើនេះមិនមែនជាព្រះពរពីស្ថានសួគ៌ដែលយើងយល់ព្រះបន្ទូលរបស់ព្រះទេឬអី?
- តើនេះមិនមែនជាព្រះអម្ចាស់ទេឬអី ដែលទ្រង់ប្រទានឲ្យយើងមានដំរិះយល់ព្រះបន្ទូល?

គឺមានតែព្រះអង្គមួយប៉ុណ្ណោះដែលប្រទានឲ្យយើងយល់ព្រះបន្ទូលបាន! ត្រូវហើយ! ៤ «តាមដែលទ្រង់បានរើសយើងរាល់គ្នាក្នុងព្រះគ្រីស្ទ...» នេះជាព្រះបន្ទូលដ៏អស្ចារ្យ តើមែនទេ? ពេលយើងដើរកាត់ច្រកភ្នំម្មប់នៃសេចក្តីស្លាប់ យើងត្រូវតែទូលសូមព្រះអម្ចាស់ សូមទ្រង់ប្រទានអំណាច នឹងវិញ្ញាណបរិសុទ្ធរបស់ទ្រង់ជួយយើង ពីព្រោះព្រះទ្រង់បានជ្រើសរើសយើង សំរាប់អង្គទ្រង់។ ខ្ញុំមិនដឹងពីបងប្អូន ឯចំណែកខ្ញុំវិញ ខ្ញុំមានសេចក្តីរំភើបខ្លាំងណាស់! ពីសេចក្តីសន្យាដ៏អស្ចារ្យរបស់ព្រះ...ទ្រង់បានរើសយើង តាំងពីមុនកំណើតលោកីយមក ប្រយោជន៍ឲ្យយើងរាល់គ្នាបានបរិសុទ្ធ ហើយឥតកន្លែងបន្ទោសបាននៅចំពោះទ្រង់ ដោយសេចក្តីស្រឡាញ់» ៥ «ពីព្រោះទ្រង់បានដំរូវយើងរាល់គ្នាទុកជាមុន... [នោះជាផែនការរបស់ទ្រង់ ដែលមានតាំងពីមុនកំណើតលោកីយមកម៉្លេះ]...សំរាប់ឲ្យទ្រង់បានទទួលយើងជាកូន...[ខាងវិញ្ញាណ សូមគិតអំពីការនោះ] ព្រះទ្រង់បរិសុទ្ធ មែនទេ? មែនហើយព្រះទ្រង់បរិសុទ្ធ ដូចទ្រង់មានបន្ទូលទុកនៅក្នុងគម្ពីរលេវីវិន័យ ហើយសាវកពេត្រុសបានសរសេរ ១ពេត្រុស១:១៦ «...ចូរឲ្យឯងរាល់គ្នាបានបរិសុទ្ធ ដ្បិតអញជាបរិសុទ្ធ» ពីព្រោះព្រះគ្មានបាបសោះ [គឺដោយព្រះគុណ នឹងសេចក្តីមេត្តាករុណារបស់ព្រះអង្គ]...អញជាបរិសុទ្ធ...សំរាប់ឲ្យទ្រង់បានទទួលយើងជាកូន ដោយសារព្រះយេស៊ូវគ្រីស្ទ តាមបំណងព្រះហឫទ័យទ្រង់» (អេភេសូរ១:៤-៥) ហេតុនេះហើយ បានជាព្រះអម្ចាស់ទ្រង់ត្រាស់ហៅយើង ដូចពេលដែលយើងចាប់ផ្តើមមានកំណើតនៅក្នុងផ្ទៃម្តាយ ត្រូវបានកំណត់ទុកជាមុនថា បើអ្វីៗគ្រប់យ៉ាងមានដំណើរត្រឹមត្រូវតាមការគួរ ក្នុងរយៈពេលជាង៩ខែ កូនប្រុស ឬកូនស្រីនឹងសំរាល

ចេញពីផ្ទៃរបស់ម្តាយមក នឹងបានជាកូនរបស់គាត់ទាំងពីរនាក់។ ដូចជាព្រះអម្ចាស់ទ្រង់បានដំរូវយើងទុកជាមុនដូច្នេះដែរ ហេតុនោះ បានជាព្រះអម្ចាស់ទ្រង់ត្រាស់ហៅយើង ដូចពេលដែលជីវិតយើងចាប់កំណើតក្នុងផ្ទៃរបស់ម្តាយយើងយ៉ាងដូច្នេះដែរ។

ឥឡូវនេះ ចូរយើងយល់ពីការមួយ តើអ្នកមិនគិតថា ព្រះវរបិតានឹងព្រះយេស៊ូវគ្រីស្ទ ហើយនឹងពួកទេវតាទាំងអស់មានអំណាចនៅលើស្ថានសួគ៌ទេឬអី? ពិតជាមានអំណាច ដោយគ្មានការសង្ស័យ! «ពីព្រោះទ្រង់បានដំរូវយើងរាល់គ្នាទុកជាមុន សំរាប់ឲ្យទ្រង់បានទទួលយើងជាកូន ដោយសារព្រះយេស៊ូវគ្រីស្ទ តាមបំណងព្រះហឫទ័យទ្រង់» (អេភេសូរ១:៥) ព្រះអម្ចាស់ផ្ទាល់ទាក់ទងនៅក្នុងជីវិតរបស់យើង។ ខ្ញុំចង់ប្រាប់អ្នកពីរឿងមួយ ខ្ញុំមិនគិតថាអ្នកដឹងទេ - នៅពេលដែលអ្នកយល់ច្បាស់អំពីរឿងនេះ នោះអ្នកគ្មានលេសថា មិនអធិស្ឋាន ឬមិនសិក្សាព្រះគម្ពីរ ឬមិនព្យាយាមនឹងយកជ័យជំនះនោះទេ ពីព្រោះព្រះទ្រង់នឹងប្រទានពរដល់អ្នកច្រើនជាងនេះទៅទៀត។

សូមកត់សំគាល់ អេភេសូរ១:៦ «ដើម្បីនឹងសរសើរដល់ព្រះគុណដ៏ឧត្តមរបស់ទ្រង់...[ដោយព្រោះយើងមានព្រះគុណរបស់ព្រះ ហើយយើងរស់នៅក្រោមព្រះគុណរបស់ព្រះ]...ដែលបានផ្តល់មកយើងរាល់គ្នាទទេ ក្នុងព្រះរាជបុត្រាស្ងួនភ្ងារបស់ទ្រង់ ហើយយើងបានសេចក្តីប្រោសលោះនៅក្នុងព្រះរាជបុត្រានោះ ដោយសារព្រះលោហិតទ្រង់ គឺជាសេចក្តីប្រោសឲ្យរួចពីទោស តាមព្រះគុណដ៏ធូន់ក្រៃលែងនៃទ្រង់...[ព្រះទ្រង់បានអត់ទោសបាបរបស់យើងដោយសារព្រះគុណរបស់ទ្រង់]... ដែលទ្រង់បានផ្តល់មកយើងជាបរិបូរ ដោយនូវប្រាជ្ញា នឹងដំរិះសព្វគ្រប់...[ម៉្យាងទៀត ព្រះបានបើកសំដែងឲ្យយើងយល់នឹងមានទំនុកទុកចិត្ត ពីការបើកសំដែង ដែលលោកីយមិនយល់]... ព្រមទាំងសំដែង ឲ្យយើងរាល់គ្នាស្គាល់សេចក្តីអាថ៌កំបាំង នៃព្រះហឫទ័យទ្រង់...[ជាគ្រូសាររបស់ព្រះ]... តាមគំនិតដែលទ្រង់បានគិតសំរេច ក្នុងព្រះអង្គទ្រង់ សំរាប់ការកាន់កាប់ត្រួតត្រា ក្នុងកាលដែលពេលពេញកំណត់បានមកដល់ ដើម្បីនឹងបំព្រួមគ្រប់ទាំងអស់ក្នុងព្រះគ្រីស្ទ ទាំងរបស់នៅស្ថានសួគ៌ នឹងរបស់នៅផែនដីផង ឲ្យរួមគ្នាមកក្នុងទ្រង់ ដែលយើងរាល់គ្នាបានកេរ្តិ៍អាករក្នុងទ្រង់ដែរ ដោយទ្រង់បានដំរូវយើងទុកជាមុន តាមដំរិះសំរេចរបស់ព្រះ ដែលទ្រង់ធ្វើគ្រប់ការទាំងអស់ តាមដែលគាប់ព្រះហឫទ័យទ្រង់ ប្រយោជន៍ឲ្យយើងខ្ញុំ ដែលបានទុលចិត្តជឿដល់ព្រះគ្រីស្ទជាមុន បានសំរាប់នឹងសរសើរដល់សិរីល្អទ្រង់» (អេភេសូរ១:៦-១២) គោលបំណងរបស់ព្រះ - នៅពេលដែលអ្នកយល់ដោយវិញ្ញាណបរិសុទ្ធរបស់ទ្រង់គឺ៖

- ដើម្បីជម្រុញឱ្យអ្នកស្រឡាញ់ព្រះឲ្យអស់អំពីចិត្ត អស់អំពីគំនិត អស់អំពីព្រលឹង នឹងអស់អំពីកំឡាំងខ្លួន
- ដើម្បីលើកទឹកចិត្តអ្នក ឱ្យស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង ហើយស្រឡាញ់បងប្អូន ដូចជាព្រះ

គ្រីស្ទ បានស្រឡាញ់យើង

- ដើម្បីជម្រុញយើងឲ្យមានសេចក្ដីប្រាថ្នាចង់ទៅនៅក្នុងនគររបស់ព្រះ

នោះហើយជាមូលហេតុ ដែលព្រះបានត្រាស់ហៅយើង ហើយក៏ជាមូលហេតុ ដែលយើងធ្វើអ្វីៗ ដែលយើងត្រូវធ្វើដែរ។

នេះគឺជាផ្នែកមួយដែលខ្ញុំចូលចិត្តជាងគេបំផុតនៃព្រះគម្ពីរ។ មានបទគម្ពីរជាច្រើនទៀតដែលសំដែងពីផែនការរបស់ព្រះច្រើនជាងនេះទៅទៀត។ នៅពេលដែលយើងឆ្លងកាត់ការនេះ សូមឲ្យយល់ព្រះបន្ទូលនៅក្នុងគម្ពីរអេភេសូរ សាវកប៉ុលសរសេរ «តាមគំនិតសំរេចតាំងពីអស់កល្បរៀងមក ដែលទ្រង់បានគិតស្រេចក្នុងព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើង ហើយក្នុងទ្រង់ យើងរាល់គ្នាក៏មានសេចក្ដីក្លាហាន នឹងច្បាប់ចូលដោយទុកចិត្ត ដោយសារសេចក្ដីជំនឿជឿដល់ទ្រង់ដែរ ហេតុនោះបានជាខ្ញុំសូមអង្វរអ្នករាល់គ្នា កុំឲ្យរសាយចិត្តដោយការដែលខ្ញុំរងទុក្ខលំបាក ជាការដែលមានប្រយោជន៍ដល់អ្នករាល់គ្នានោះឡើយ ដ្បិតការនោះជាសិរីល្អដល់អ្នករាល់គ្នាទេ ដោយហេតុនោះបានជាខ្ញុំលុតជង្គង់ នៅចំពោះព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា» (អេភេសូរ៣:១១-១៤)

នេះជារបៀបដែលសាវកប៉ុលពិនិត្យមើលបញ្ហា នឹងការលំបាកក្នុងជីវិតរបស់គាត់ ហើយក៏ជាវិធីដែលយើងត្រូវពិនិត្យមើលបញ្ហា នឹងការលំបាកដែលកំពុងកើតមាននៅលើលោកីយនេះ ហើយនឹងការដែលយើងប្រឈមមុខនឹងអ្វីៗដែលយើងមិនធ្លាប់រំពឹងគិតពីមុនមក។ ដូច្នេះ សូមយើងចងចាំទុកក្នុងចិត្ត ១៤ «ដោយហេតុនោះបានជាខ្ញុំលុតជង្គង់ នៅចំពោះព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ដែលគ្រប់ទាំងគ្រួនៅស្ថានសួគ៌ ហើយនៅផែនដី មាននាមត្រកូលពីទ្រង់មក... ប្រទានឲ្យអ្នកមានឈ្មោះថ្មី... ដើម្បីឲ្យទ្រង់បានប្រោសប្រទានឲ្យអ្នករាល់គ្នាបានព្រះចេស្ដា ចំរើនកំឡាំងនៃមនុស្សខាងក្នុង ដោយសារវិញ្ញាណបរិសុទ្ធរបស់ទ្រង់ តាមសិរីល្អនៃទ្រង់ដ៏ប្រសើរក្រៃលែង ឲ្យព្រះគ្រីស្ទសណ្ឋិតក្នុងចិត្តអ្នករាល់គ្នា ដោយសារសេចក្ដីជំនឿ ប្រយោជន៍ឲ្យអ្នករាល់គ្នាបានចាក់ឫស ហើយតាំងមាំមួនក្នុងសេចក្ដីស្រឡាញ់ ដើម្បីឲ្យអាចនឹងយល់ ជាមួយនឹងពួកបរិសុទ្ធទាំងអស់គ្នា ពីទទឹង បណ្ដោយ ជំរៅ នឹងកំពស់នៃសេចក្ដីស្រឡាញ់នោះ» (អេភេសូរ៣:១៤-១៨) នោះគឺជាផែនការរបស់ព្រះ បន្ទាប់ពីបានកើតជាថ្មី ដោយព្រះទ្រង់ប្រោសឲ្យរស់ពីស្លាប់ឡើងវិញ ហើយយើងនឹងបានចូលទៅក្នុងនគរព្រះ រស់នៅអស់កល្បតទៅ! ១៩ «ហើយឲ្យបានស្គាល់សេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ទដ៏រកគិតមិនយល់ ប្រយោជន៍ ឲ្យអ្នករាល់គ្នាបានពេញដល់គ្រប់ទាំងសេចក្ដីពោរពេញរបស់ផងព្រះ»។

- នោះជាគោលបំណងរបស់អ្នក!
- នោះជាការត្រាស់ហៅរបស់អ្នក!

- នោះគឺជាមរតករបស់អ្នក!

ហើយនេះក៏អាចថា ជាការជម្រុញអ្នកៈ

- ផ្តល់ឱ្យអ្នកនូវចក្ខុវិស័យ
- ផ្តល់ឲ្យក្តីសង្ឃឹមដល់អ្នក
- ផ្តល់ឱ្យអ្នកនូវការយល់ដឹង

ដូច្នេះ **អ្នកអាចដើរដោយជំនឿ ជឿដោយសង្ឃឹម នឹងរស់នៅដោយសេចក្តីស្រឡាញ់!**

២០ «ឯព្រះដែលទ្រង់អាចនឹងធ្វើ...[មានន័យថាមានអំណាច]...ហួសសន្ធឹកលើសជាងអស់ទាំងសេចក្តីដែលយើងសូម ឬគិតក្តី តាមព្រះចេស្តាដែលបណ្តាលក្នុងយើងរាល់គ្នា នោះសូមឲ្យទ្រង់បានសិរីល្អនៅក្នុងពួកជំនុំ ដោយសារព្រះគ្រីស្ទយេស៊ូវ រហូតដល់គ្រប់ទាំងដំណមនុស្ស នៅអស់កល្បជានិច្ចរៀងរាបតទៅ» អាម៉ែន» (អេភេសូរ៣:២០-២១)

បងប្អូនស្ងួនភ្ងា ព្រះអម្ចាស់ផ្ទាល់ ទ្រង់ចូលរួមក្នុងជីវិតរបស់អ្នក ហើយទ្រង់ស្រឡាញ់អ្នក ទ្រង់មានគោលបំណងសំរាប់ជីវិតរបស់អ្នក ដោយហេតុនោះហើយ បានជាទ្រង់បានត្រាស់ហៅអ្នក។

ដូច្នេះ ចូរចងចាំ នឹងផ្តោតអារម្មណ៍ នឹងចក្ខុវិស័យ នៅក្នុងចិត្តជានិច្ច »

បទគម្ពីរយោង

១. យ៉ូហាន៦:៤៤
២. កូឡុស១:៩-១២
៣. រ៉ូម៨:១៤-១៧
៤. ហេព្រើរ១:១-៤
៥. រ៉ូម៨:១៦-១៨
៦. កូឡុស១:១៣, ២៦-២៧
៧. ២កូរិនថូស ៦:១៤-១៨
៨. អេភេសូរ១:៣-១២
៩. អេភេសូរ៣:១១-២១

បទគម្ពីរ មិនបានចម្លង

១កូរិនថូស៣

១ពេត្រុស១

# ការត្រាស់ហៅរបស់ព្រះអម្ចាស់

សព្វថ្ងៃនេះ ការរស់នៅក្នុងលោកីយរបស់យើង:

- តើមានអ្នកណាម្នាក់នឹងស្វែងរកព្រះឬទេ?
- តើព្រះអម្ចាស់នឹងរកយើងដោយរបៀបណា?
- តើអ្វីដែលផ្តល់ឱ្យអ្នកនូវសិទ្ធិ ថាខ្លួនអ្នកត្រូវ ហើយអ្នកឯទៀតខុស?
- តើអ្វីដែលធ្វើឱ្យអ្នកគិតថា អ្នកមានការពិត ហើយអ្នកឯទៀត គេមិនមានការពិត?
- តើមនុស្សភាគច្រើនគេខុសយ៉ាងដូចម្ដេច?

ព្រះគម្ពីរបង្រៀនឲ្យយើងឃើញថាអារក្សសាតាំងវាកំពុងតែនាំលោកីយទាំងមូលឲ្យវង្វេង ហើយព្រះគម្ពីរបរិសុទ្ធបានប្រាប់យើងថា ដោយព្រោះឪពុក ម្ដាយដើមរបស់មនុស្សយើង មិនស្ដាប់បង្គាប់ព្រះដោយបានបរិភោគផ្លែឈើដឹងខុស នឹងដឹងត្រូវៗ នៅលើលោកីយនេះ ក៏មានការល្អៗជាច្រើន ប៉ុន្តែមិនមែនអ្វីៗទាំងអស់សុទ្ធតែល្អទេ ហើយអ្វីៗដែលល្អនោះ សំរាប់ទុកជាអត្ថប្រយោជន៍ដល់មនុស្ស ដែលព្រះបានបង្កើតមកៗ ចូរចង់ចាំពីអារក្សសាតាំងដែលវាបាននិយាយទៅកាន់ព្រះយេស៊ូវក្នុងពេលវាល្បួងទ្រង់ វានិយាយថា «ដូច្នេះ បើអ្នកក្រាបថ្វាយបង្គំខ្ញុំ...[អារក្ស]... ហើយអារក្សក៏ត្រូវបានគេហៅថា វាជាព្រះនៃលោកីយនេះដែរ» ហើយវាក៏ជាអ្នកដែលធ្វើឲ្យគំនិតរបស់អស់អ្នកដែលមិនជឿសេចក្ដីពិត ទៅជាងងឹតៗ អារក្សវាបាននិយាយទៅកាន់ព្រះយេស៊ូវថា:

- បើអ្នកក្រាបថ្វាយបង្គំខ្ញុំ នោះទាំងអស់នឹងបានជារបស់អ្នក
- តើអ្នកមិនគិតថានោះជាអត្ថប្រយោជន៍ទេឬអី?
- តើមានមនុស្សប៉ុន្មាននាក់ដែលព្យាយាមចង់គ្រប់គ្រងពិភពលោក?
- បច្ចុប្បន្ននេះ មានខ្សែភាពយន្តមួយ សម្ដែងអំពីប្រវត្តិសាស្ត្ររបស់លោកអាឡិចសាន់ឌ័រដ៏អស្ចារ្យ ប៉ុន្តែ លោកបានស្លាប់ហើយ!

តើព្រះអម្ចាស់មានផែនការយ៉ាងដូចម្ដេច? តើព្រះអម្ចាស់សំរេចតាមការសន្យារបស់ទ្រង់ ដែលយើងឃើញនៅក្នុងគម្ពីរម៉ាថាយជំពូក១៦ យ៉ាងដូចម្ដេច? ព្រះយេស៊ូវគ្រីស្ទបានប្រទានសេចក្ដីសន្យានេះ ហើយខ្ញុំនឹងបង្រៀនសេចក្ដីសន្យានេះម្ដងទៀត គឺជាកូនសោដែលព្រះបានប្រទានដល់សាវកពេត្រុស គម្ពីរម៉ាថាយ ១៦:១៣ «កាលព្រះយេស៊ូវ បានយាងមកដល់ក្រវល់ក្រុងសេសារា-ភីលីពហើយ នោះទ្រង់មានបន្ទូលសាកសួរពួកសិស្សថា តើមនុស្សទាំងឡាយ គេថាកូនមនុស្សជាអ្នកណា ពួកសិស្សទូលឆ្លើយថា ខ្លះថាជាយ៉ូហានបាទីស្ទ ខ្លះទៀតថាជាអេលីយ៉ា ហើយខ្លះទៀតថាជាយេរេមា ឬហោរាណាមួយ

ទ្រង់មានបន្ទូលសួរថា ចុះឯអ្នករាល់គ្នាវិញ តើថាខ្ញុំជាអ្នកណា? ស៊ីម៉ូន-ពេត្រុសទូលឆ្លើយថា ទ្រង់ជាព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់ រួចព្រះយេស៊ូវមានបន្ទូលតបថា អ្នកស៊ីម៉ូន កូនយ៉ូណាស់អើយ អ្នកមានពរ ដ្បិតមិនមែនជាសាច់ឈាមដែលសំដែងឲ្យអ្នកស្គាល់ទេ គឺព្រះវរបិតានៃខ្ញុំដែលគង់នៅស្ថានសួគ៌វិញ» (១៣-១៧)។

នេះជាកូនសោទី១ ព្រះអម្ចាស់បង្ហាញអង្គទ្រង់ដល់អ្នកដែលទ្រង់ត្រាស់ហៅ យើងនឹងឃើញពីរបៀបដែលព្រះទ្រង់ធ្វើ ជារឿងដ៏គួរឱ្យភ្ញាក់ផ្អើលមួយ ដែលលោកីយមិនយល់ ពីព្រោះនោះជាការដ៏អស្ចារ្យដែលព្រះកំពុងធ្វើ។

១៨. «ខ្ញុំប្រាប់អ្នកថា អ្នកឈ្មោះពេត្រុស... [ផេត្រូស (ភាសាក្រិក) មានន័យថាថ្មតូច]... ខ្ញុំ...[ព្រះគ្រីស្ទ]...នឹងតាំងពួកជំនុំខ្ញុំនៅលើថ្មដានេះ ... [ផ្ទាំងថ្មដ៏ធំ គឺព្រះគ្រីស្ទ- ដោយហេតុនេះហើយ នៅក្នុងព្រះគម្ពីរបរិសុទ្ធតាមច្បាប់ដើម ខ្ញុំ [ប្រេដ ខលធ័រ Fred Coulter] មានការពន្យល់ពេញលេញអំពីរឿងនោះ។ ការនេះបានប្រាប់យើងយ៉ាងណា - ដូចដែលបានបញ្ជាក់ក្នុងបទគម្ពីរនៅកន្លែងផ្សេងទៀតដែរ - ថាព្រះយេស៊ូវគ្រីស្ទជាក្បាលនៃពួកជំនុំ! តើអ្នកណាជាអ្នកកសាងពួកជំនុំ? គឺព្រះយេស៊ូវគ្រីស្ទ ទ្រង់នឹងបង្កើតពួកជំនុំរបស់ទ្រង់។ យើងនឹងឃើញពីរបៀបដែលទ្រង់ត្រាស់ហៅមនុស្ស នឹងពីរបៀបដែលទ្រង់បង្កើតពួកជំនុំ ហើយខ្ញុំតែងតែអរសប្បាយពេលខ្ញុំកំពុងធ្វើជាគ្រូគង្វាលនៅទីក្រុងសល់ឡេក (Salt Lake, រដ្ឋ Utah) - ខ្ញុំបានធ្វើជាគ្រូគង្វាលនៅក្នុងពួកជំនុំ (Worldwide Church of God, WCG) អស់រយៈពេល ៦ ឆ្នាំ ហើយខ្ញុំចាំបានថា មានពេលមួយមានមនុស្សម្នាក់បានផ្ញើលិខិតទៅ (Pasadena, California ទីចាត់ការកណ្តាល នៃពួកជំនុំ WCG) ដោយនិយាយថា ខ្ញុំចង់ជួបជាមួយគ្រូគង្វាល ដើម្បីនិយាយអំពីពិធីជ្រមុជទឹក នឹងកិច្ចការមួយចំនួនទៀត អ្នកធ្វើការនៅការិយាល័យកណ្តាល នៃពួកជំនុំ ក៏បានផ្ញើលិខិតនោះមកខ្ញុំ ដូច្នេះខ្ញុំ ក៏បានចេញទៅជួបបុរសនោះ បុរសនោះបានប្រាប់ថាខ្លួនគាត់ ឈ្មោះយ៉ូប ហើយប្រហែលជា៥នាទីក្រោយមក ដែលយើងកំពុងតែនិយាយគ្នា នោះមានគេមកគោះទ្វារ គឺព្រឹទ្ធាចារ្យពីរនាក់ មកពីវិហារម័រមិន ចូលមក យ៉ូបជាម្ចាស់ផ្ទះក៏និយាយថា ខ្ញុំបានអញ្ជើញអ្នកមក ពីព្រោះខ្ញុំចង់ឲ្យអ្នកជជែកគ្នា ថា តើព្រះវិហារណាដែលត្រឹមត្រូវ ខ្ញុំនិយាយថា ជាការប្រសើរណាស់ ដែលខ្ញុំ..[ប្រេដ ,Fred]...មិនចាំបាច់និយាយច្រើនទេ ខ្ញុំបានសិក្សាជាច្រើនអំពីគោលលទ្ធិរបស់ម័រមិន នឹងក្រុមម័រមិន គឺលោកយ៉ូសែបស្មីធបានបង្កើតឡើង លោកយ៉ូសែបស្មីធបាននិយាយថា ពួកជំនុំដែលព្រះគ្រីស្ទបង្កើតបានស្លាប់បាត់អស់ទៅហើយ។ លោកយ៉ូសែបស្មីធបានត្រឡប់មករស់នៅរដ្ឋញូវយ៉កវិញ មិនឆ្ងាយប៉ុន្មាន (ប្រហែលជា៥០ម៉ៃ ឬ ៨០គីឡូម៉ែត្រ) ពីវិហារសេវេន (សេវេនដេ Seventh Day) ពីកន្លែងដែលយ៉ូសែបស្មីធប្រកាន់ថា បានទទួលការបើកសម្តែងមកពីព្រះ។

ការសំគាល់ខុសត្តង់ទី១ របស់យ៉ូសែបស្មីធ ព្រះបានលេចមកពីក្រោយខ្នងរបស់គាត់ ព្រះពិតមិនដែលលេចមកពីខាងក្រោយខ្នងរបស់មនុស្សទេ នៅពេលមាននរណាម្នាក់ជួបនឹងព្រះពិត ពួកគេតែងតែក្រាបផ្កាប់មុខចុះដល់ដីនៅចំពោះព្រះ តើមែនឬទេ? គឺពិតមែន!

គឺជាបទគម្ពីរ ហើយខ្ញុំក៏និយាយថា មែនហើយ ឥឡូវនេះ សូមមើលព្រះបន្ទូលរបស់ព្រះយេស៊ូវដែលបានសន្យាថា «...ទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់នឹងមិនដែលឈ្នះពួកជំនុំឡើយ» នៅក្នុងគម្ពីរ King James ភាសាក្រិក ពាក្យ "hades, ហេត" មានន័យថាផ្នូរ...មិនដែលឈ្នះពួកជំនុំឡើយ» ខ្ញុំបានមើលទៅពួក [ម៉ូរមិន] ខ្ញុំបាននិយាយថា ឥឡូវនេះ ខ្ញុំប្រឈមមុខនឹងបញ្ហាមួយ តើព្រះយេស៊ូវកុហក ឬយ៉ូសែបស្មីធកុហក? ព្រះយេស៊ូវមិនដែលកុហកទាល់តែសោះ ខ្ញុំជឿព្រះបន្ទូលរបស់ទ្រង់ ដូច្នេះ អ្វីដែលយ៉ូសែបស្មីធ និយាយមិនមែនជាការពិតទេ ពីព្រោះផ្ទុយនឹងព្រះបន្ទូលរបស់ព្រះ នឹងព្រះយេស៊ូវគ្រីស្ទ ខ្ញុំក៏ក្រោកឡើងចាកចេញទៅ ដោយមិនបន្តនិយាយទៀត។

ដូចដែលយើងបានឃើញនៅក្នុងគម្ពីរដំណឹងល្អ ព្រះយេស៊ូវគ្រីស្ទបានត្រាស់ហៅ នឹងជ្រើសរើសមនុស្ស១២នាក់ ជាសាវក នឹង ពួកសិស្ស១២០នាក់ ដែលប្រជុំជាមួយគ្នានៅបន្ទប់ខាងលើ (កិច្ចការ១:១៥) ចាប់តាំងពីថ្ងៃដែលព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ រហូតដល់ថ្ងៃចុងបញ្ចប់នៃសម័យនេះ [គឺពេលព្រះគ្រីស្ទយាងត្រឡប់មកវិញ] គឺព្រះទ្រង់នឹងធ្វើឲ្យសំរេចគ្រប់ទាំងសេចក្តីដែលបានចែងទុកពីព្រះយេស៊ូវ ទោះក្នុងគម្ពីរក្រិត្យវិន័យ ឬក្នុងគម្ពីរទំនាយរបស់ពួកហោរា ឬក្នុងបទទំនុកដំកើងផង ការទាំងអស់នោះត្រូវតែបានសំរេច តាមសេចក្តីទំនាយ។

សព្វថ្ងៃនេះ យើងមានប្រព័ន្ធផ្សព្វផ្សាយ (អេនធើណិត) ដែលយើងប្រកាសដំណឹងល្អពិតដល់មនុស្សទាំងអស់ គេក៏ឮដំណឹងល្អគ្រប់ៗគ្នា ព្រះយេស៊ូវ «ក៏មានបន្ទូលថា នេះហើយជាសេចក្តីដែលខ្ញុំបានប្រាប់អ្នករាល់គ្នា កាលនៅជាមួយគ្នានៅឡើយ គឺថា ត្រូវតែសំរេចគ្រប់ទាំងសេចក្តីដែលបានចែងទុកពីខ្ញុំ ទោះក្នុងក្រិត្យវិន័យលោកម៉ូសេ ក្នុងទំនាយពួកហោរា ឬក្នុងបទទំនុកដំកើងផង នោះទ្រង់ក៏បើកបំភ្លឺសតិស្មារតីគេ ឲ្យបានយល់ក្នុងបទគម្ពីរ» (លូកា២៤:៤៤-៤៥)

កូនសោសំខាន់ៗ៖

- ព្រះអម្ចាស់បង្ហាញអង្គទ្រង់ផ្ទាល់ដល់យើងម្នាក់ៗ
- ដើម្បីយល់ពីព្រះបន្ទូលរបស់ព្រះគ្រីស្ទ យើងត្រូវតែបើកចិត្ត គំនិត នឹងស្មារតីរបស់យើង

នេះជាសេចក្តីដ៏សំខាន់ណាស់

- ប្រសិនបើយើងធ្វើតាមព្រះបន្ទូលរបស់ព្រះ

- ប្រសិនបើយើងជឿព្រះបន្ទូលរបស់ព្រះ
- ប្រសិនបើយើងរស់នៅដោយសារគ្រប់ទាំងព្រះបន្ទូលរបស់ព្រះ
- ប្រសិនបើយើងមានវិញ្ញាណបរិសុទ្ធរបស់ព្រះ
- ប្រសិនបើចិត្ត នឹងគំនិតរបស់យើង បើកទៅឯបទព្រះគម្ពីរ

បន្ទាប់មកយើងដឹងសេចក្តីជាច្រើន មិនមែនដោយសារយើងជាមនុស្សដ៏អស្ចារ្យ ឬដោយសារយើងជាមនុស្សសំខាន់ នោះទេ! - គឺដោយសារព្រះ ពីព្រោះយើងទទួលការត្រាស់ហៅរបស់ព្រះវិញ ទេតើ!

យើងមិនបានឈរឡើង ហើយប្រកាសថាខ្លួនយើងត្រូវ ហើយលោកីយខុសនោះទេ ហើយយើងនឹងជំនុំជំរះពួកគេនោះទេ គឺព្រះទ្រង់នឹងជំនុំជំរះលោកីយនេះវិញ គឺព្រះទ្រង់មានបន្ទូលថា លោកីយត្រូវបានអារក្សសាតាំងនាំឲ្យវង្វេង ប៉ុន្តែ ព្រះទ្រង់ជាអង្គគ្រប់គ្រងអស់អ្នកដែលទ្រង់បានត្រាស់ហៅវិញ ហើយបើកចិត្តយើង នៅពេលដែលយើងគិតអំពីការត្រាស់ហៅរបស់ទ្រង់ នឹងរបៀបដែលព្រះបានដោះស្រាយបញ្ហានៅក្នុងជីវិតរបស់អ្នក ហើយអ្នកប្រហែលជាគិតអំពីការនោះដែរ។ នៅថ្ងៃណាមួយ អ្នកនឹងគិតអំពីកិច្ចការផ្ទាល់ខ្លួនរបស់អ្នក ហើយបន្ទាប់មកអ្នកនឹងមានការផ្លាស់ប្តូរ - ព្រោះការនោះនឹងកើតមានឡើង មែន!

ដូចពួកសាវ័ក មានការផ្លាស់ប្រែ ដែលមិនធ្លាប់មានពីមុនមកទេ សូមនឹកចាំពីព្រះបន្ទូលរបស់ព្រះយេស៊ូវ «ឱមនុស្សមានជំនឿតិចអើយ យឺតនឹងជឿ ហេតុអ្វីបាជាអ្នកមានចិត្តរឹងរូស បន្ទាប់មកទ្រង់បើកចិត្ត គំនិតឲ្យគេយល់បទគម្ពីរ!

ការផ្លាស់ប្រែ: សព្វថ្ងៃនេះសំខាន់ណាស់ ពីព្រោះមនុស្សជាច្រើនបានអានព្រះគម្ពីរ។ មានពេលមួយខ្ញុំបានទៅឯហ្គូសៀន ដើម្បីចូលរួមធ្វើបុណ្យ ខ្ញុំបានចូលទៅមើលបណ្តាញផ្សព្វផ្សាយ ទូរទស្សន៍មួយនៅទីនោះ អំពីសាសនា ពីព្រោះយើងគ្មានបណ្តាញខ្សែកាបរបស់យើងនៅទីនោះទេ ខ្ញុំក៏ទៅឯប៉ុស្តិ៍ទូរទស្សន៍នោះ ខ្ញុំបានឃើញលោកធាល ស្ទីនលី នៅលើកញ្ចក់ទូរទស្សន៍ កំពុងអធិប្បាយព្រះបន្ទូល លោកមើលបទគម្ពីរមួយហើយ មួយទៀត បទគម្ពីរមួយហើយ មួយទៀត ហើយខ្ញុំក៏និយាយថា "ហេ!" បន្ទាប់លោកបានទៅដល់ទីបញ្ចប់នៃការបង្រៀនរបស់លោក ហើយលោកក៏និយាយថា ឥឡូវនេះ អ្នកត្រូវជឿនៅក្នុងចិត្ត ហើយយាងព្រះយេស៊ូវចូលមកក្នុងជីវិតរបស់អ្នកបានហើយ។ ខ្ញុំមិនអាចយល់បានទេ ហេតុអ្វីបានជាពួកបាទីស្ទដែលធ្លាប់ជឿលើពិធីជ្រមុជទឹក និយាយថាអ្នកមិនចាំបាច់ទទួលបុណ្យជ្រមុជទឹកទៀតទេ! លូកា២៤:៤៦ «ទ្រង់មានបន្ទូលទៅគេថា គឺសេចក្តីនេះហើយ ដែលបានចែងទុកមក គឺថា ព្រះគ្រីស្ទត្រូវរងទុក្ខលំបាក ហើយនៅថ្ងៃទី៣ ទ្រង់នឹងរស់ពីស្លាប់ឡើងវិញ ... [នេះជា

ការដែលព្រះទ្រង់ធ្វើទី១ គឺព្រះទ្រង់ធ្វើការនេះ បន្ទាប់មកព្រះទ្រង់ប្រើអស់អ្នកដែលទ្រង់ជ្រើសរើស ឲ្យធ្វើកិច្ចការនោះដែរ ដោយនៅក្នុងព្រះនាមនៃព្រះអម្ចាស់ អស់អ្នកដែលបានប្រែចិត្តពីអំពើបាប នឹងការអត់ទោសបាប យើងត្រូវតែប្រកាសដំណឹងល្អពិត ដល់គ្រប់អស់ទាំងជាតិសាសន៍ ចាប់ផ្តើមពីក្រុងយេរូសាឡឹមទៅៗ ឥឡូវនេះ យើងកំពុងតែធ្វើទីបន្ទាល់ពីការទាំងអស់ «ហើយត្រូវឲ្យការប្រែចិត្ត នឹងសេចក្តីប្រោសឲ្យរួច បានប្រកាសប្រាប់ដល់អស់ទាំងសាសន៍ ដោយនូវព្រះនាមទ្រង់ ចាប់តាំងពីក្រុងយេរូសាឡឹមទៅ អ្នករាល់គ្នាជាស្មរបន្ទាល់ពីការទាំងនេះ» (លូកា២៤:៤៧-៤៨) រង់ចាំមើល តើការប្រកាសដំណឹងល្អពិតនេះ នឹងបន្តរយៈពេលប៉ុន្មានទៀត?

- ព្រះត្រូវតែបង្ហាញអង្គទ្រង់
- ព្រះត្រូវតែបើកគំនិតរបស់អ្នក ឲ្យយល់ពីបទគម្ពីរ

សូមចងចាំថា នៅពេលដែលព្រះអម្ចាស់ បើកគំនិតរបស់ពួកគេ ឲ្យយល់បទគម្ពីរ ដែលសព្វថ្ងៃនេះត្រូវបានគេហៅថាគម្ពីរសញ្ញាចាស់ - ត្រឹមត្រូវ? គឺច្បាប់ ពួកហោរា នឹងទំនុកដំកើង ពិតជាត្រឹមត្រូវមែន! សូមបើកគម្ពីរកិច្ចការ១:៤ ហើយនេះគឺជាព្រះបន្ទូល ដែលព្រះគ្រីស្ទបានមានបន្ទូលទៅកាន់ពួកសិស្ស «រួចមក កាលបានប្រជុំទាំងអស់គ្នាហើយ នោះទ្រង់ហាមមិនឲ្យគេចេញពីក្រុងយេរូសាឡឹមឡើយ ដោយបន្ទូលថា ត្រូវឲ្យនៅចាំសេចក្តីសន្យានៃព្រះវរបិតា ដែលអ្នករាល់គ្នាបានឮខ្ញុំថ្លែងប្រាប់ហើយ ដ្បិតពិតជាលោកយ៉ូហានបានធ្វើបុណ្យជ្រមុជដោយទឹក ប៉ុន្តែនៅបន្តិចទៀត អ្នករាល់គ្នានឹងទទួលបុណ្យជ្រមុជ ដោយវិញ្ញាណបរិសុទ្ធរបស់ព្រះវិញ»

«ដូច្នេះ កាលពួកសាវកបានប្រជុំគ្នា នោះក៏ទូលសួរថា ព្រះអម្ចាស់អើយ តើនៅគ្រានេះ ឬអី? ដែលទ្រង់នឹងតាំងនគរឲ្យសាសន៍អ៊ីស្រាអែលឡើងវិញនោះ? តែទ្រង់មានបន្ទូលឆ្លើយថា មិនត្រូវឲ្យអ្នករាល់គ្នាដឹងពេល ដឹងកំណត់ ដែលព្រះវរបិតាបានទុកក្នុងអំណាចរបស់ទ្រង់នោះឡើយ ប៉ុន្តែ កាលណាវិញ្ញាណបរិសុទ្ធរបស់ព្រះបានមកសណ្ឋិតលើអ្នករាល់គ្នា នោះអ្នករាល់គ្នានឹងបានព្រះចេស្តាហើយ នឹងធ្វើជាទីបន្ទាល់ពីខ្ញុំ នៅក្រុងយេរូសាឡឹម ព្រមទាំងស្រុកយូដា នឹងស្រុកសាម៉ារីទាំងមូល ហើយរហូតដល់ចុងផែនដីបំផុតផង» (កិច្ចការ១:៤-៨)

យើងនឹងឃើញពីរបៀបដែលព្រះវរបិតា នឹងព្រះយេស៊ូវគ្រីស្ទ មានបន្ទូលថា ទ្រង់នឹងធ្វើការៗ យើងក៏ដឹងដែរថា ទ្រង់មានបន្ទូលទៅនឹងពួកហោរាក្លែងក្លាយ-ត្រូវទេ? គឺត្រូវហើយ! ទ្រង់បន្ទូលថា «កុំឲ្យនរណាម្នាក់បោកបញ្ឆោតអ្នក» - ត្រូវទេ? ទ្រង់បានដាក់ការទាំងអស់នោះមកលើយើង គឺជាភារៈកិច្ចរបស់យើងម្នាក់ៗ ដើម្បីឲ្យចេះបញ្ជាក់ការពិត! ហើយបើយើងធ្វើដូច្នេះ ព្រះនឹងបើកគំនិតស្មារតីរបស់យើងឱ្យយល់ពីសេចក្តីពិត ហើយយើងនឹងឃើញពីរបៀបដែលព្រះទ្រង់ធ្វើ ក្នុងពេលបន្តិចទៀតៗ

នេះជាព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទ «ឯព្រះយេស៊ូវ ទ្រង់យាងមកមានបន្ទូលនឹងគេថា គ្រប់ទាំងអំណាចបានប្រគល់មកខ្ញុំនៅលើស្ថានសួគ៌ ហើយលើផែនដីផង ដូច្នេះ ចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍...[សិស្ស គឺជាអ្នករៀនពីព្រះយេស៊ូគ្រីស្ទ]

ដូចខ្ញុំបាននិយាយជាច្រើនដង ពីគោលដៅ នឹងគោលបំណងរបស់សិស្ស គឺចង់ក្លាយទៅជាគ្រូ ហើយព្រះគ្រីស្ទទ្រង់ជាគ្រូ - តើត្រឹមត្រូវទេ? ត្រឹមត្រូវហើយ! [នោះជាគោលដៅទាំងមូល ហើយក៏ជាគោលបំណងទាំងមូលដែរ] ...ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឱ្យ ដោយនូវព្រះនាមព្រះវរបិតា ... [ពីព្រោះយើងបានទទួលបញ្ញាពីព្រះវរបិតាមក ជាព្រះវរបិតានៃយើង តើមែនឬទេ? មែនហើយ!] ... ហើយពីព្រះរាជបុត្រា ... [ពីព្រោះតាមរយៈយញ្ញបូជារបស់ព្រះយេស៊ូវគ្រីស្ទ ដែលអំពើបាបរបស់យើងបានត្រូវអត់ទោសឲ្យ]... ហើយពីវិញ្ញាណបរិសុទ្ធរបស់ព្រះ ...» (ម៉ាថាយ២៨: ១៨-១៩) បុណ្យជ្រមុជទឹកមិនមែន នៅក្នុងតែព្រះនាមនៃព្រះរាជបុត្រា ឬនៅក្នុងនាមនៃវិញ្ញាណបរិសុទ្ធរបស់ព្រះប៉ុណ្ណោះទេ គឺក្នុងព្រះនាមព្រះវរបិតា នឹងព្រះរាជបុត្រា នឹងវិញ្ញាណបរិសុទ្ធរបស់ព្រះ ពីព្រោះយើងបានទទួលអំណោយទានជាវិញ្ញាណបរិសុទ្ធ ពីព្រះមកតាមរយៈនាមទាំងបីនេះ នាមទាំងបី មានការជាប់ទាក់ទងយ៉ាងជិតស្និត ទោះបីយ៉ាងនេះក៏ដោយ ក៏មិនមែនមានន័យថា ជាព្រះត្រៃឯកនោះទេ។ ប្រសិនបើអ្នកក្រឡេកមើល ពីទស្សនៈបច្ចុប្បន្ននេះ ដូចដែលបានបង្រៀននៅក្នុងវិហារជាច្រើនអ្នកអាចគិតថា នេះជាព្រះត្រៃឯក (ព្រះវរបិតា ព្រះរាជបុត្រា នឹងវិញ្ញាណបរិសុទ្ធ) តាមការពិត មិនមែនទេ! ការនេះបង្ហាញថា ព្រះវរបិតាមានជាប់ទាក់ទងជាមួយព្រះយេស៊ូវគ្រីស្ទជាប់ជានិច្ច ហើយដូចដែលព្រះយេស៊ូវបានមានបន្ទូលនៅក្នុង គម្ពីរកិច្ចការ១:៨ «ប៉ុន្តែ កាលណាវិញ្ញាណបរិសុទ្ធនៃព្រះមកសណ្ឋិតលើអ្នករាល់គ្នា នោះអ្នករាល់គ្នានឹងបានព្រះចេស្តាហើយនឹងធ្វើជាទីបន្ទាល់ពីខ្ញុំ នៅក្រុងយេរូសាឡិមព្រមទាំងស្រុកយូដា នឹងស្រុកសាម៉ារីទាំងមូល ហើយរហូតដល់ចុងផែនដីបំផុតផង» វិញ្ញាណបរិសុទ្ធរបស់ព្រះ នឹងធ្វើការនៅក្នុងជីវិតរបស់អ្នក បើអ្នកមិនមានវិញ្ញាណរបស់ព្រះគ្រីស្ទ នោះអ្នកមិនមែនជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទទេ។ អ្នកមិនមែនជ្រមុជទឹកនៅក្នុងឈ្មោះ នៃអ្នកធ្វើវិធីជ្រមុជទឹកនោះទេ អ្នកធ្វើវិធីជ្រមុជទឹក គ្រាន់តែជាយានប៉ុណ្ណោះ ប៉ុន្តែអ្នកទទួលបុណ្យជមុជទឹក ត្រូវបានទទួលដោយនូវព្រះនាមនៃព្រះវរបិតាវិញ មិនមែនដោយនូវនាមរបស់ពួកជំនុំទេ! ឬជានាមរបស់គ្រូគង្វាលមួយណាម្នាក់ឡើយ! នេះពិតជារឿងដ៏អស្ចារ្យមួយដែលព្រះកំពុងធ្វើ ហើយនៅពេលដែលខ្ញុំកំពុងគិតអំពីរឿងនេះ ខ្ញុំដឹងថាវាពិតជាត្រូវ តាមសៀវភៅប្រវត្តិសាស្ត្រដ៏ល្អមួយដែលសរសេរអំពីប្រវត្តិសាស្ត្រនៃវិហាររបស់ព្រះ មានសៀវភៅប្លែកៗ ហើយល្អៗ ជាច្រើនបានសរសេរឡើង ប៉ុន្តែ អ្នកអាចនឹងដឹងបានខ្លះតាមរយៈសៀវភៅទាំងនោះ ប៉ុន្តែ អ្នកគួរតែសាកល្បងមើល សៀវភៅ sharehare.org ឬ biblesabbath.org ប្រវត្តិសាស្ត្រនៃសាសនា

របស់លោកីយនេះ វាមិនមែនជាប្រវត្តិសាស្ត្រ នៃនគព្រះនោះទេ វាជាប្រវត្តិសាស្ត្រក្លែងក្លាយដែលសរសេរឡើង ដោយពួកហោរាក្លែងក្លាយរបស់លោកីយនេះតែប៉ុណ្ណោះ។

នៅក្នុងគម្ពីរសញ្ញាថ្មីត្រូវបានគេហៅថា «អាថ៌កំបាំងនៃអំពើទុច្ចរិត ឬ អាថ៌កំបាំងនៃការប្រឆាំងច្បាប់» សាវកប៉ុលបានសរសេរថា «ដ្បិតសេចក្តីអាថ៌កំបាំងរបស់ការទទឹងច្បាប់ កំពុងបណ្តាលឡើងឡើងហើយ...»(២ថែស្សាឡូនីច ២:៧) ចាប់តាំងពីថ្ងៃផ្តើមបេសកៈកម្មរបស់សាវកប៉ុល ពីដំណឹងល្អពិត ដូច្នេះ យើងមានប្រព័ន្ធទាំងពីរនេះ ធ្វើការជាមួយគ្នារហូតមកដល់សព្វថ្ងៃនេះ [១ ប្រព័ន្ធអាថ៌កំបាំងនៃអំពើទុច្ចរិត នឹង២ អាថ៌កំបាំងនៃការទទឹងច្បាប់ ឬរំលងក្រិត្យវិន័យ] ម៉ាថាយ២៨:២០ ព្រះយេស៊ូវគ្រីស្ទមានបន្ទូលថា «ហើយបង្រៀនឲ្យគេកាន់តាមគ្រប់ទាំងសេចក្តី ដែលខ្ញុំបានបង្គាប់មកអ្នករាល់គ្នាផង ... [តើនេះជាការសិក្សាគួរឲ្យចាប់អារម្មណ៍មែនទេ? អ្នកអាចសិក្សាព្រះគម្ពីរសញ្ញាថ្មី តើព្រះយេស៊ូវគ្រីស្ទបង្គាប់យ៉ាងណា? អ្នកនឹងឃើញពីថ្ងៃឈប់សំរាក ឬថ្ងៃសប្ប័ទ ដែលព្រះយេស៊ូវបានកាន់ខ្ជាប់ទុកជាគំរូ ដោយមានព្រះបន្ទូលថា ទ្រង់ជាម្ចាស់នៃថ្ងៃឈប់សំរាក មិនមែនគ្រាន់តែមានបន្ទូលតែពីថ្ងៃឈប់សំរាកប៉ុណ្ណោះទេ ទ្រង់ក៏ធ្វើការល្អដោយព្យាបាលជម្ងឺ នឹងបង្រៀនរាល់ថ្ងៃឈប់សំរាក នោះហើយជារបៀបធ្វើការនៅថ្ងៃឈប់សម្រាក] ... ហើយមើល ខ្ញុំក៏នៅជាមួយនឹងអ្នករាល់គ្នាជារាល់ថ្ងៃដែរ រហូតដល់បំផុតកល្ប អាម៉ែន» ឥឡូវនេះ តើព្រះអម្ចាស់ទ្រង់ធ្វើយ៉ាងដូចម្តេច? សូមមើលពីរបៀបដែលព្រះទ្រង់ធ្វើនេះជាការដែលព្រះអម្ចាស់ទ្រង់ធ្វើ ប៉ុន្តែ លោកីយមិនយល់ទេ ពីជាការដែលព្រះអម្ចាស់ទ្រង់ដោះស្រាយបញ្ហាដែលកើត នៅក្នុងជីវិតរបស់យើងម្នាក់ៗ។

យ៉ូហាន១៤:១៥-១៧ យើងនឹងឃើញការចាប់ផ្តើមនៃការនេះ «បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តិរបស់ខ្ញុំចុះ នោះខ្ញុំនឹងទូលសូមដល់ព្រះវរបិតា ហើយទ្រង់នឹងប្រទានជំនួយមួយមកអ្នករាល់គ្នាឲ្យបាននៅជាមួយ រហូតដល់អស់កល្បរៀងទៅ គឺជាវិញ្ញាណនៃសេចក្តីពិត ដែលលោកីយទទួលពុំបានព្រោះមិនឃើញ ហើយមិនស្គាល់សោះ តែអ្នករាល់គ្នាស្គាល់ ដ្បិតនៅជាមួយ ក៏នឹងសណ្ឋិតនៅក្នុងអ្នករាល់គ្នាដែរ» [នេះគឺជាការសន្យាចំពោះអស់អ្នកដែលព្រះអម្ចាស់ត្រាស់ហៅ] ... សូម្បីតែវិញ្ញាណនៃសេចក្តីពិត ... លោកីយមិនស្គាល់(ខ១៥-១៧) នោះហើយ គឺជាកូនសោដែលព្រះដោះស្រាយបញ្ហាជាមួយនឹងអស់អ្នកដែលព្រះទ្រង់ចាប់ផ្តើមត្រាស់ហៅ។ ព្រះអម្ចាស់ទ្រង់មិនគ្រាប់តែធ្វើការក្នុងជីវិតរបស់យើង នឹងក្នុងកាលៈទេសៈ នឹងស្ថានភាពរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែ យើងតែត្រូវយល់ថាវា ជារឿងដ៏សំខាន់មួយ ដែលកើតឡើងនៅពេលព្រះអម្ចាស់ចាប់ផ្តើមហៅយើង។

ដូច្នេះ តើអ្វីជាការពិត? នៅពេលអ្នកចាប់ផ្តើមសួរសំណួរនោះ ហើយចាប់ផ្តើមអានព្រះគម្ពីរ ព្រោះសព្វថ្ងៃនេះ យើងមានព្រះគម្ពីរតាមឯកសារដើមយ៉ាងត្រឹមត្រូវមួយ ដែលជាព្រះពរដ៏អស្ចារ្យ មកពី

ព្រះដ៏អស្ចារ្យនៃយើង។ ហេតុនោះហើយ បានជាមានមនុស្សពុករលួយជាច្រើន ចង់បំផ្លាញព្រះគម្ពីរដ៏ត្រឹមត្រូវមួយនេះ ដោយការពុករលួយរបស់ខ្លួន។ អារក្សសាតាំងវាមិនចង់ឲ្យមនុស្សយល់ព្រះបន្ទូលពិតរបស់ព្រះទេ នោះហើយគឺជាការវាយប្រហាររបស់សាតាំង ដើម្បីមិនឲ្យមនុស្សយល់ព្រះបន្ទូលរបស់ព្រះពិតបាន មែនហើយ! ព្រះអម្ចាស់ទ្រង់មិនត្រូវគេបដិសេធទេ! ហើយព្រះបន្ទូលរបស់ព្រះអម្ចាស់ក៏មិនត្រូវសាបសូន្យឡើយ ពីព្រោះព្រះបន្ទូលរបស់ទ្រង់នឹងស្ថិតនៅអស់កល្បជានិច្ច។ សព្វថ្ងៃនេះយើងបានកែសម្រួលព្រះបន្ទូលពិតតាមឯកសារដើមយ៉ាងត្រឹមត្រូវ គឺជាការពិតដែលអ្នកកំពុងស្វែងរក។ ព្រះយេស៊ូវមានព្រះបន្ទូលថា «...ឯសេចក្តីពិត គឺជាព្រះបន្ទូលរបស់ទ្រង់»(យ៉ូហាន១៧:១៧) ហើយសាវកយ៉ូហានបានសរសេរសំបុត្រទី១-របស់លោក «...គ្មានសេចក្តីភូតភរណាកើតពីសេចក្តីពិតនោះឡើយ» (១យ៉ូហាន២:២១) នៅពេលមាននរណាម្នាក់ចាប់អារម្មណ៍លពីព្រះ ហើយចង់ដឹងអំពីព្រះ នោះព្រះទ្រង់ចាប់ផ្តើមធ្វើការទាក់ទងជាមួយនឹងអ្នកនោះ។ រឿងមួយដែលអ្នកត្រូវប្រឈមមុខ តើអ្នកចង់បានការពិត ឬទេ? ពិតមែន! ហើយប្រសិនបើអ្នកចង់បានការពិត តើបន្ទាប់មកអ្នកនឹងត្រូវធ្វើអ្វី? ប្រសិនបើអ្នកមានព្រះបន្ទូលរបស់ព្រះ ហើយអ្នកសិក្សាព្រះបន្ទូលនោះ ដោយយកចិត្តទុកដាក់ អ្នកចាប់ផ្តើមយល់ពីព្រះបន្ទូលរបស់ព្រះ ហើយបន្ទាប់មកអ្នកមើលទៅឯ «សាសនា» របស់លោកីយនេះ ហើយអ្នកប្រហែលជានិយាយថា «អស្ចារ្យ!» មើលទៅអ្វីៗទាំងអស់របស់សាសនាទាំងនោះ មិនត្រឹមត្រូវទាល់តែសោះ។ សាវកយ៉ូហានសរសេរថា «គឺជាវិញ្ញាណនៃសេចក្តីពិត ដែលលោកីយទទួលពុំបាន ព្រោះមិនឃើញ ហើយមិនស្គាល់សោះ តែអ្នករាល់គ្នាស្គាល់... [នេះគឺជាប្រតិបត្តិការ ដែលមនុស្សមិនអាចធ្វើបាន ហើយក៏មិនដឹងអ្វីដែលកំពុងកើតឡើងផង]...ដ្បិតនៅជាមួយ ក៏នឹងសណ្ឋិតនៅក្នុងអ្នករាល់គ្នាដែរ» (យ៉ូហាន១៤:១៧) នេះជាសេចក្តីពិត! ពេលព្រះអម្ចាស់ទ្រង់ចាប់ផ្តើមទាក់ទងជាមួយនរណាម្នាក់ខាងវិញ្ញាណ ទ្រង់ក៏ប្រទានវិញ្ញាណបរិសុទ្ធរបស់ទ្រង់ មកសណ្ឋិតនៅជាមួយអ្នកនោះ ហើយចាប់ផ្តើមបង្រៀនឲ្យអ្នកនោះយល់ពីសេចក្តីពិត:

- ចាប់ផ្តើមបង្រៀនឲ្យអ្នកស្គាល់ពីអំពើបាប
- ចាប់ផ្តើមបង្រៀនឲ្យអ្នកយល់ពីផ្លូវរបស់មនុស្ស ដែលមើលទៅហាក់ដូចជាត្រឹមត្រូវ ប៉ុន្តែ នាំទៅរកសេចក្តីស្លាប់ទេ

នេះគឺជាគំនិតខាងសាច់ឈាម «ព្រោះគំនិតខាងសាច់ឈាម នោះរមែងទាស់ទទឹងនឹងព្រះ...ហើយក៏អាក្រក់លើសអ្វីៗទាំងអស់...ដ្បិតមិនចុះចូលនឹងក្រិត្យវិន័យរបស់ព្រះទេ ក៏ពុំអាចនឹងចុះចូលបានផង ពួកអ្នកដែលនៅខាងសាច់ឈាម នោះពុំអាចនឹងគាប់ព្រះហឫទ័យដល់ព្រះបានឡើយ តែបើសិនជាវិញ្ញាណបរិសុទ្ធនៃព្រះសណ្ឋិតក្នុងអ្នករាល់គ្នា នោះអ្នករាល់គ្នាមិននៅខាងសាច់ឈាមទៀតទេ គឺនៅខាង

វិញ្ញាណវិញ...» គឺជាវិញ្ញាណបរិសុទ្ធរបស់ព្រះ ដែលនាំឲ្យអ្នករាល់គ្នា ប្រែចិត្ត-បើសិនជាអ្នកបន្តនៅលើផ្លូវនៃសេចក្តីពិតនោះ - ហើយអ្នកនឹងដឹង ថាគឺព្រះដែលកំពុងធ្វើការនោះ។ នេះក៏ជាកូនសោដ៏សំខាន់មួយទៀត។

មានភាពខុសគ្នា កាលណាវិញ្ញាណបរិសុទ្ធរបស់ព្រះចាប់ផ្តើមធ្វើការជាមួយអ្នក នឹងសណ្ឋិតនៅក្នុងអ្នក ហើយវិញ្ញាណបរិសុទ្ធរបស់ព្រះដែលសណ្ឋិតនៅក្នុងអ្នក បានដឹកនាំអ្នកទៅកាន់គ្រប់ទាំងសេចក្តីពិត-បន្ទាប់ពីអ្នកប្រែចិត្តពីអំពើបាប ហើយទទួលពិធីបុណ្យជ្រមុជទឹក - ដើម្បីឱ្យអ្នកមានទំនាក់ទំនងជាមួយនឹងព្រះអង្គ ដែលទ្រង់បានបង្កើតអ្នកដោយវិញ្ញាណបរិសុទ្ធរបស់ទ្រង់។ ឥឡូវនេះ គោលដៅ នឹងគោលបំណងទាំងមូលរបស់អ្នក គឺការរីកចំរើន ផ្លាស់ប្តូរ នឹងអភិវឌ្ឍន៍ នឹងមានជ័យជំនះ សំរាប់ឱ្យបានទទួលការប្រោសឲ្យរស់ពីស្លាប់ឡើងវិញ លើកទីមួយ នឹងបានធ្វើជាកូនរបស់ព្រះអម្ចាស់ យ៉ូហាន ១៤: ១៨ «ខ្ញុំមិនចោលអ្នករាល់គ្នាឲ្យនៅកំព្រាទេ ខ្ញុំនឹងមកឯអ្នករាល់គ្នាវិញ បន្តិចទៀតលោកីយនឹងលែងឃើញខ្ញុំ តែអ្នករាល់គ្នានឹងឃើញខ្ញុំវិញ ហើយដោយព្រោះខ្ញុំរស់ នោះអ្នករាល់គ្នានឹងរស់ដែរ នៅថ្ងៃនោះអ្នករាល់គ្នានឹងដឹងថា ខ្ញុំនៅក្នុងព្រះវរបិតាខ្ញុំ អ្នករាល់គ្នាក៏នៅក្នុងខ្ញុំ ហើយខ្ញុំនៅក្នុងអ្នករាល់គ្នាដែរ» (ខ១៨-២០) នៅពេលដែលព្រះគ្រីស្ទមានព្រះជន្មរស់ឡើងវិញ ពួកសាវក នឹងពួកសិស្សបានឃើញទ្រង់ ពួកគេបានយល់ពីរឿងនោះ រួចព្រះវរបិតាទទួលទ្រង់ឡើងទៅស្ថានសួគ៌វិញ ទៅគង់នៅខាងស្តាំ នៃព្រះវរបិតា តើមែនឬទេ? គឺមែន!

នេះគឺជាគន្លឹះសោ - យើងបានមើលព្រះបន្ទូលនេះជាច្រើនដង ហើយនេះគឺជាមូលដ្ឋានគ្រឹះ ខ២១ «អ្នកណាដែលមានបញ្ញត្តរបស់ខ្ញុំ ហើយកាន់តាម គឺអ្នកនោះហើយដែលស្រឡាញ់ខ្ញុំ ឯអ្នកណាដែលស្រឡាញ់ខ្ញុំ នោះជាទីស្រឡាញ់នៃព្រះវរបិតាខ្ញុំហើយ ខ្ញុំនឹងស្រឡាញ់អ្នកនោះដែរ ក៏នឹងសំដែងខ្លួនឲ្យអ្នកនោះស្គាល់ផង...[ឬសំដែងអង្គទ្រង់ដល់ខ្ញុំ] ...យូដាស (មិនមែនអ៊ីស្ការីយ៉ុតទេ) គាត់ទូលទ្រង់ថា ព្រះអម្ចាស់អើយ តើកើតមានហេតុដូចម្តេច បានជាទ្រង់នឹងសំដែងមកឲ្យយើងខ្ញុំស្គាល់ទ្រង់ តែមិនឲ្យលោកីយស្គាល់ផង ព្រះយេស៊ូវមានបន្ទូលឆ្លើយ បើអ្នកណាស្រឡាញ់ខ្ញុំ អ្នកនោះនឹងកាន់តាមពាក្យខ្ញុំ នោះព្រះវរបិតាខ្ញុំនឹងស្រឡាញ់អ្នកនោះ ហើយយើង...[ព្រះវរបិតា នឹងព្រះរាជបុត្រា]... នឹងមកឯអ្នកនោះ ក៏នឹងតាំងទីលំនៅ នៅជាមួយដែរ» (ខ២១-២៣) នោះជារឿងដ៏សំខាន់ណាស់ដែលត្រូវយល់: «យើង»...[គឺព្រះវរបិតា នឹងព្រះរាជបុត្រា]...នឹងតាំងទីលំនៅ នៅជាមួយ"(ខ២៣) អ្នកនឹងឃើញ ពីន័យនៅក្នុងជីវិតរបស់អ្នក គឺអ្នកមានវិញ្ញាណបរិសុទ្ធរបស់ព្រះសណ្ឋិតនៅក្នុងអ្នក ការនេះសំខាន់ណាស់! អ្នកនឹងត្រូវធ្វើអ្វីៗ ជាមួយនឹងវិញ្ញាណបរិសុទ្ធរបស់ព្រះ ហើយព្រះអម្ចាស់ទ្រង់កំពុងដោះស្រាយ នឹងបង្ហាញព្រះអង្គទ្រង់ដល់អ្នកផ្ទាល់ ប៉ុន្តែ មិនបានបង្ហាញឲ្យលោកីយស្គាល់ទេ ពីព្រោះលោកីយមិនជឿសេចក្តី

ពិត។ ព្រះគម្ពីរសំដែងថា ព្រះអង្គទ្រង់គង់នៅជិតយើងបង្កើយ លើកលែងតែគំនិតគេត្រូវបានបើកឡើង ពុំនោះគេមិនដឹងជាមានការអ្វីកំពុងកើតឡើងនោះទេ។

១២៤ «អ្នកណាដែលមិនស្រឡាញ់ខ្ញុំ នោះមិនកាន់តាមពាក្យខ្ញុំទេ...[មិនកាន់តាមព្រះបន្ទូល]... ឯពាក្យដែលអ្នករាល់គ្នាឮ នោះមិនមែនជាពាក្យខ្ញុំ គឺជាព្រះបន្ទូលរបស់ព្រះវរបិតាដែលទ្រង់ចាត់ឲ្យខ្ញុំមកទេតើ» អ្វីៗទាំងអស់ដែលយើងមាន គឺមកតែពីព្រះដ៏ជាព្រះវរបិតាប៉ុណ្ណោះ។

សូមមើលបទគម្ពីរមួយទៀត គម្ពីរយ៉ូហាន ៦:៤៤ «គ្មានអ្នកណា...[ពីព្រោះព្រះទ្រង់ជាអង្គដែលធ្វើការនោះ] ...អាចនឹងមកឯខ្ញុំ...[ព្រះគ្រីស្ទ]...បានទេ លើកតែព្រះវរបិតា ដែលចាត់ខ្ញុំឲ្យមក ទ្រង់ទាញនាំគេប៉ុណ្ណោះ ហើយខ្ញុំនឹងឲ្យអ្នកនោះរស់ឡើងវិញ នៅថ្ងៃចុងបំផុតដែរ»

ការពិត គឺនៅពេលដែលយើងចាប់ផ្តើមយល់ព្រះបន្ទូលបរិសុទ្ធរបស់ព្រះ នឹងសេចក្តីពិតរបស់ទ្រង់ហើយ យើងនឹងឃើញដូចដែលសាវកប៉ុលសរសេរ «ដូច្នេះ បើគេមិនជឿ ធ្វើដូចម្តេចឲ្យគេអំពាវនាវដល់ព្រះបាន ហើយបើគេមិនបានឮនិយាយ នោះធ្វើដូចម្តេចឲ្យគេជឿដល់ព្រះបាន ហើយធ្វើដូចម្តេចឲ្យគេឮនិយាយបាន បើគ្មានអ្នកណាប្រាប់សោះ» (រ៉ូម១០:១៤) ព្រះអម្ចាស់ទ្រង់ចាត់ឲ្យគេទៅ ហេតុនេះហើយ អស់អ្នកដែលផ្សាយដំណឹងល្អពិត គឺព្រះវរបិតាទ្រង់ចាត់គេឲ្យទៅ ហើយទ្រង់ក៏ទាញនាំអស់អ្នកណាដែលឮដំណឹងល្អពិត! យ៉ូហាន៦:៤៥ «នៅក្នុងគម្ពីរពួកហោរា មានសេចក្តីចែងទុកមកថា ព្រះទ្រង់នឹងបង្រៀនគេទាំងអស់គ្នា ដូច្នេះ អស់អ្នកដែលឮព្រះវរបិតា ហើយបានរៀនពីទ្រង់ នោះក៏មកឯខ្ញុំ» [គឺមកឯព្រះគ្រីស្ទ] គ្រប់សេចក្តីបង្រៀនពិត គឺមកពីព្រះ។ យើងបានបោះពុម្ពព្រះគម្ពីរជាច្រើនភាសា [ព្រះគម្ពីរបរិសុទ្ធ] ប៉ុន្តែ តើមានឥទ្ធិពលអ្វីខ្លះ នៅក្នុងចិត្ត នឹងក្នុងគំនិតរបស់យើង? តើត្រូវធ្វើដូចម្តេច ទើបយើងអាចយល់ព្រះបន្ទូលបាន? លើកតែព្រះអម្ចាស់ផ្ទាល់បង្រៀនយើង? នោះហើយគឺជាការមួយដែលអ្នកអាចជួបប្រទះនៅពេលអ្នកសិក្សាព្រះគម្ពីរ នឹងពេលអ្នកចូលទៅជិតព្រះ ហើយនៅពេលអ្នកចាប់ផ្តើមអធិស្ឋាន។

ខ្ញុំមិនដឹងថា អ្នកបានចងចាំការអធិស្ឋានដំបូងរបស់អ្នកឬទេ? ប៉ុន្តែ ខ្ញុំនៅចាំបានថា ការអធិស្ឋានដំបូងរបស់ខ្ញុំ គឺថា «ព្រះអង្គអើយជួយទូលបង្គំផង» ទូលបង្គំនៅទីនេះ ហើយទូលបង្គំពិតជាត្រូវការទ្រង់ជួយ ពីព្រោះទ្រង់មានបន្ទូលថា «ចូរសូម នោះនឹងឲ្យមកអ្នក ចូររក នោះនឹងឃើញ...» ទូលបង្គំត្រូវការទ្រង់ជួយ...» (ម៉ាថាយ៧:៧) នោះហើយជាវិសាលភាពនៃការអធិស្ឋានរបស់ខ្ញុំ ដែលបង្ហាញពីចំណុចមួយទៀត - ដូច្នេះយើងនឹងបញ្ចូលចំណុចនេះ គឺជាកូនសោទាំងបួនដែលព្រះទ្រង់ប្រើក្នុងជីវិតរបស់មនុស្ស ដើម្បីនាំពួកគេទៅឯះ

- បញ្ហា- ដែលអ្នកមិនអាចដោះស្រាយដោយខ្លួនឯងបាន

- បញ្ហា - យើងជួបប្រទះនូវអ្វីមួយដែលបន្សល់ទុកនូវចំណាប់អារម្មណ៍យូរអង្វែង នឹងពេញមួយជីវិតរបស់អ្នក
- ការសាកល្បង - អ្នកឆ្លងកាត់បទពិសោធន៍ដែលហួសពីសមត្ថភាពរបស់អ្នកក្នុងការដោះស្រាយបញ្ហា ហើយអ្នកដឹងថាអ្នកមិនមានសមត្ថភាពគ្រប់គ្រាន់ ដូច្នេះព្រះទ្រង់ប្រើការទាំងអស់នេះ
- ការល្បួង

ប្រសិនបើអ្នកជួបនឹងបញ្ហា ប៉ះពាល់ផ្លូវចិត្ត ការសាកល្បង នឹងការល្បួងផ្សេងៗ ហើយអ្នកមិនថ្វាយការទាំងអស់នោះដល់ព្រះ - អ្នកបន្ទោសព្រះ នឹងថ្កោលទោសព្រះ - ព្រះអម្ចាស់ទ្រង់នឹងមិនប្រកបជាមួយនឹងអ្នកទេ ពីព្រោះព្រះទ្រង់អនុញ្ញាតឱ្យអ្នកដើរទៅតាមផ្លូវសាច់ឈាមរបស់អ្នក។

ប៉ុន្តែប្រសិនបើអ្នកត្រូវបានផ្តន្ទាទោសដោយសារអំពើអាក្រក់ - អំពើអាក្រក់នឹងអំពើបាបផ្ទាល់ខ្លួននៅក្នុងជីវិតរបស់អ្នក នឹងនៅក្នុងលោកីយ ហើយអ្នកចាប់ផ្តើមយល់ពីលក្ខណៈធម្មជាតិរបស់មនុស្ស នឹងពីចំណុចនៅក្នុងជីវិតរបស់អ្នក ជាច្រើនដង ព្រះនឹងប្រើជំងឺ ឬគ្រោះថ្នាក់ ឬអ្វីៗលើសពីនេះទៅទៀត ដែលអ្នកកំពុងដេកគិតនៅលើគ្រែ ហើយអ្នកថា, ឱព្រះអង្គអើយ ហេតុអ្វីបានជាទូលបង្គំកើតចេញពីពោះម្តាយទូលបង្គំមក?

តើអ្នកមានគោលបំណងនៅក្នុងជីវិតឬទេ? តើអ្នកជានរណា? តើអ្នកនៅឯណា? មែនហើយព្រះអម្ចាស់ទ្រង់ប្រើសំណួរទាំងអស់នេះ តើព្រះទ្រង់ឆ្លើយតបយ៉ាងដូចម្តេច? ព្រះទ្រង់មានបន្ទូលតាមអ្វីៗដែលទ្រង់មាន ព្រះអម្ចាស់ទ្រង់តែងតែប្រើបច្ចេកវិទ្យាដែលមាន ដូចជាម៉ាស៊ីនបោះពុម្ពដែលបង្កើតឡើង ព្រះអម្ចាស់ទ្រង់ប្រើម៉ាស៊ីនបោះពុម្ព! ពិតហើយ ព្រះទ្រង់ប្រើម៉ាស៊ីនបោះពុម្ព! ពេលវិទ្យុបង្កើតឡើង ព្រះទ្រង់ប្រើវិទ្យុ តើមែនឬទេ? មែន! ពេលទូរទស្សន៍បានត្រូវបង្កើតឡើង ព្រះទ្រង់ប្រើទូរទស្សន៍? ត្រូវហើយ! ប៉ុន្តែ តើអ្នកណាជាអ្នកដើរតាមពីក្រោយការកួតកុហកយ៉ាងឆាប់រហ័សនេះ? គឺជាអារក្សសាតាំង! ឥឡូវនេះយើងមានអ៊ិនធឺណែត ហើយព្រះអម្ចាស់ទ្រង់ក៏កំពុងតែប្រើប្រាស់អ៊ិនធឺណេតដែរ។ ដូច្នេះ សាតាំងវាកំពុងតែព្យាយាមលាក់អ្វីៗទាំងអស់ ប៉ុន្តែ អស់អ្នកដែលទទួលការត្រាស់ហៅរបស់ព្រះ ទ្រង់នឹងដឹកនាំអ្នកទាំងនោះ ទៅកន្លែងដែលទ្រង់សព្វព្រះហឫទ័យឲ្យគេទៅ ប្រសិនបើអ្នកធ្វើអ្វីតាមព្រះហឫទ័យទ្រង់ ហើយស្វែងរកសេចក្តីពិត។ ដូច្នេះ យើងនឹងមើលពីរបៀបដែលព្រះទ្រង់ឆ្លើយតប។

ការល្បួង - ប្រហែលជាអ្នកស្ថិតនៅក្រោមការល្បួងដ៏ធំរបស់អារក្សសាតាំង ហើយអ្នកចង់ចេញពីវា ឧទាហរណ៍: ប្រសិនបើអ្នករស់នៅក្នុងក្រុងសាន់ហ្វ្រាន់ស៊ីស្កូ ហើយអ្នកដែលនៅជុំវិញអ្នក គឺជាមនុស្សស្រឡាញ់ភេទដូចគ្នា ហើយអ្នកមានសេចក្តីល្បួងក្នុងការចូលរួមជាមួយពួកគេ ហើយអ្នកស្រែក

រកព្រះ ដើម្បីសូមទ្រង់ជួយអ្នក កុំឲ្យអ្នកចូលរួមជាមួយនឹងគេឡើយព្រះទ្រង់ នឹងឆ្លើយតបនៃការអធិស្ឋាននោះ ដូច្នេះ អ្នកត្រូវស្វែងរកព្រះអម្ចាស់ ដើម្បីនឹងដោះខ្លួនអ្នក ឲ្យរួចចេញពីពួកគេ។

ចូរមើលពីសេចក្តីសន្យាដែលព្រះយេស៊ូវមានបន្ទូល ហើយបន្ទាប់មកមើលពីការដែលទ្រង់បានបំពេញ ម៉ាថាយ៧:៧ «ចូរសូម នោះតែងនឹងឲ្យមកអ្នក...[ប្រាកដណាស់ យើងដឹងថា បើយើងសូមដោយចង់ដឹងការពិត នោះព្រះទ្រង់នឹងប្រទានមកអ្នក]...ចូររក នោះតែងនឹងឃើញ... [យើងត្រូវតែប្រុងប្រៀបគំនិត ដើម្បីយល់ពីចម្លើយរបស់ព្រះអម្ចាស់]...ចូរគោះ នោះតែងនឹងបើកឲ្យអ្នក» យើងនឹងដឹងថា តើព្រះអម្ចាស់ទ្រង់នឹងឆ្លើយតបមកអ្នកយ៉ាងដូចម្តេច? ...ចូរគោះ នោះតែងនឹងបើកឲ្យអ្នក ដ្បិតអស់អ្នកដែលសូម នោះរមែងបាន អ្នកណាដែលរក នោះរមែងឃើញ ហើយនឹងបើកឲ្យអ្នកណាដែលគោះដែរ» [ភាសាក្រេក មានន័យថា បន្តស្វែងរក បន្តសូម បន្តគោះ] (ម៉ាថាយ៧:៧-៨) យើងដឹងថា ព្រះអម្ចាស់ទ្រង់នឹងឆ្លើយតប តាមពេលវេលា នឹងតាមបំណងព្រះហឫទ័យរបស់ទ្រង់។

សូមយើងពិចារណាអំពីរបៀបដែលព្រះទ្រង់ឆ្លើយតប តើព្រះកំពុងរកអ្នកណា? តើទ្រង់នឹងរកពួកគេដោយរបៀបណា? ពិតជាជ្រាលជ្រៅណាស់! ផែនដីនេះមានទំហំធំធេងណាស់ មែនទេ? មានមនុស្សរាប់ពាន់លាននាក់រស់នៅលើផែនដី ខ្ញុំជឿជាក់ ហើយដឹងថា ព្រះប្រាកដជាធ្វើការច្រើនណាស់លើសជាងអ្វីដែលយើងគិតទៅទៀត ឧទាហរណ៍: យើងមានបុរសម្នាក់នៅស្រុកអេស៊ីពួកំពុងស្វែងរកព្រះ គាត់រស់នៅតែឯង! អ្វីដែលគាត់មានគឺព្រះបន្ទូលរបស់ព្រះ គាត់ពិតជាមានកុំព្យូទ័រមួយ គាត់បានភ្ជាប់អ៊ីនធឺណិត មកគេហទំព័ររបស់យើង គាត់បានសួរយើងពីអ្វីដែលត្រូវធ្វើ នេះវាពិតជារឿងមួយដែលគាត់រស់នៅក្នុងសង្គមបែបនេះ គាត់ខ្លាចពីជីវិតរបស់គាត់ណាស់ ប៉ុន្តែ គាត់នៅតែស្វែងរកព្រះ សូមមើលពីរបៀបដែលព្រះបានឆ្លើយតប។

មានមនុស្សជាច្រើនគិតថា អ្នកត្រូវតែមានកន្លែងជាក់លាក់ណាមួយ ដើម្បីថ្វាយបង្គំព្រះ មិនមែនដូចសព្វថ្ងៃនេះទេ! ប៉ុន្តែ អ្នកត្រូវតែមានចិត្តជាក់លាក់ ដើម្បីថ្វាយបង្គំព្រះ ឯទីកន្លែងនោះមិនសំខាន់ទេ។ សាវកយ៉ូហានសរសេរថា «ឯពួកឰយុកោយើងខ្ញុំ បានថ្វាយបង្គំនៅលើភ្នំនេះ... [ជាភ្នំកេរិស៊ីម (ចៅហ្វាយ៩:៧) នៅជិតសាម៉ារី] ... តែពួកលោកថា ក្រុងយេរូសាឡិមជាកន្លែងដែលត្រូវថ្វាយបង្គំវិញ ព្រះយេស៊ូវមានបន្ទូលថា នាងស្រីអើយ ចូរជឿខ្ញុំថា នឹងមានពេលវេលាមក ដែលអ្នករាល់គ្នានឹងមិនថ្វាយបង្គំព្រះវរបិតា នៅលើភ្នំនេះ ឬនៅក្រុងយេរូសាឡិមទេ» (យ៉ូហាន៤:២០-២១)

សព្វថ្ងៃនេះ បើអ្នកធ្វើដំណើរទៅកាន់ទីក្រុងយេរូសាឡិម ហើយអ្នកសរសេរសេចក្តីអធិស្ឋានដាក់លើដុំក្រដាសមួយ ហើយបង់ប្រាក់យ៉ាងច្រើនឲ្យពួកអ្នកដឹកនាំសាសនាយូដានៅទីនោះ ហើយពួកគេនឹងយកក្រដាសរបស់អ្នក ទៅដាក់នៅក្នុងក្រហែងថ្ម ក្នុងជញ្ជាំងនៅក្រុងយេរូសាឡិម នេះហើយជា

មូលហេតុ ដែលធ្វើឲ្យជញ្ជាំងថ្មជិតរលំ ដោយព្រោះគេដាក់ក្រដាសច្រើនពេក។ មានមនុស្សជាច្រើនថា គិតថា គេនឹងទទួលបានចម្លើយពីសេចក្ដីអធិស្ឋាននោះ តាមការពិត គ្មានអ្នកណាម្នាក់ទទួលចម្លើយពីជញ្ជាំងថ្មនោះទេ សូមពិចារណាមើល! តើជញ្ជាំងថ្មចេះឆ្លើយតបនឹង សេចក្ដីអធិស្ឋានឬ? ប៉ុន្ដែ ប្រសិនបើចិត្តអ្នកមិនត្រឹមត្រូវ អ្នកមិនអាចទទួលចម្លើយពីព្រះបានទេ យ៉ូហាន៤:២២ «អ្នករាល់គ្នាមិនដឹងជាខ្លួនថ្វាយបង្គំអ្វីទេ ...[នេះអត្ថបទនៃសេចក្ដីបង្រៀនមួយ មនុស្សភាគច្រើនគេមិនដឹងជាគេថ្វាយបង្គំអ្វីទេ]... ឯយើងវិញ យើងស្គាល់ព្រះដែលយើងថ្វាយបង្គំ ដ្បិតសេចក្ដីសង្គ្រោះកើតមកពីសាសន៍យូដា តែនឹងមានពេលវេលាមក ក៏នៅឥឡូវនេះហើយ នោះពួកអ្នកដែលថ្វាយបង្គំដោយពិតត្រង់ គេនឹងថ្វាយបង្គំព្រះវរបិតា ដោយវិញ្ញាណ នឹងសេចក្ដីពិត...[ត្រូវហើយ យើងនឹងឃើញពីរបៀបដែលព្រះទ្រង់ឆ្លើយតប]...ពីព្រោះព្រះវរបិតា ទ្រង់រកពួកអ្នកទាំងនោះ ឲ្យបានថ្វាយបង្គំទ្រង់...[តើព្រះស្វែងរកយ៉ាងដូចម្ដេច?]... គឺព្រះអង្គទ្រង់ប្រទានវិញ្ញាណបរិសុទ្ធរបស់ទ្រង់មកយើង]... ឯព្រះ ទ្រង់ជាវិញ្ញាណ ហើយដែលអ្នកណាដែលថ្វាយបង្គំទ្រង់ នោះត្រូវតែថ្វាយបង្គំ ដោយវិញ្ញាណ នឹងសេចក្ដីពិតដែរ» (ខ ២២-២៤) ត្រូវហើយ! សូមមើលពីរបៀបដែលព្រះទ្រង់ធ្វើ ប្រសិនបើមានអ្នកណាម្នាក់បាននិយាយថា ឱព្រះអម្ចាស់ សូមជួយជីវិតខ្ញុំផង ខ្ញុំពិតជាចង់ធ្វើឱ្យជីវិតរបស់ខ្ញុំបានគាប់ព្រះហឫទ័យទ្រង់ នោះព្រះអម្ចាស់ទ្រង់ពិតជាស្ដាប់អំពីអ្នកនោះ-មិនថានៅក្នុងកាលៈទេសៈណាក៏ដោយទេ តើព្រះទ្រង់ស្ដាប់សេចក្ដីអធិស្ឋានរបស់អ្នក ឬទេ? ព្រះទ្រង់ពិតជាស្ដាប់សេចក្ដីអធិស្ឋាននោះ ហើយនឹងឆ្លើយតបផង។ សូមមើលការដែលព្រះអង្គទ្រង់ប្រើវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ ដើម្បីបំពេញនូវអ្វីដែលទ្រង់បានសន្យា ដល់អស់អ្នកដែលស្វែងរកការថ្វាយបង្គំទ្រង់ ដោយវិញ្ញាណ នឹងសេចក្ដីពិត។

វិវរណៈ១:៤ «សំបុត្រយ៉ូហានខ្ញុំ ផ្ញើមកពួកជំនុំទាំង៧ នៅស្រុកអាស៊ី សូមឲ្យអ្នករាល់គ្នាបានប្រកបដោយព្រះគុណ នឹងសេចក្ដីសុខសាន្ត អំពីព្រះដ៏គង់នៅ ក៏គង់នៅតាំងតែពីដើម ហើយត្រូវយាងមកទៀត នឹងអំពីវិញ្ញាណបរិសុទ្ធទាំង៧របស់ទ្រង់ ដែលនៅចំពោះបល្ល័ង្កទ្រង់» តើវិញ្ញាណបរិសុទ្ធរបស់ព្រះទាំង៧ជាអ្វី? គឺជាចង្កៀងទាំង៧ (វិវរណៈ៤:៥) តើវិញ្ញាណបរិសុទ្ធទាំង៧នោះជាអ្វីទៀត? គឺជាព្រះនេត្រនៃព្រះ «...ឯភ្នែកទាំងនោះ គឺជាវិញ្ញាណទាំង៧របស់ព្រះ ដែលទ្រង់ចាត់ទៅពេញលើផែនដី« (វិវរណៈ៥:៦)

សូមមើល ម្ដងទៀត គម្ពីរវិវរណៈ៣:១ «ចូរសរសេរផ្ញើទៅទេវតានៃពួកជំនុំ ដែលនៅក្រុងសើដេសថា ព្រះដ៏មានវិញ្ញាណទាំង៧ នឹងផ្កាយទាំង៧ ទ្រង់មានបន្ទូលសេចក្ដីទាំងនេះថា អញស្គាល់ការដែលឯងប្រព្រឹត្តហើយ គឺឯងដែលមានឈ្មោះថារស់ តែឯងស្លាប់ទេ»

ដូច្នេះ វិញ្ញាណបរិសុទ្ធទាំង៧ របស់ព្រះ ត្រូវបានចាត់ឲ្យទៅពេញពាសលើផែនដី អ្នកអាច

ប្រៀបធៀបវិញ្ញាណទាំងនោះ ទៅនឹងភ្នែករបស់មនុស្សយន្ត (រ៉ូបាត robots) ព្រះទ្រង់ចាត់វិញ្ញាណបរិសុទ្ធទាំង៧របស់ទ្រង់ទៅពេញលើផែនដី តើវិញ្ញាណបរិសុទ្ធទាំងនោះធ្វើអ្វី? គឺវិញ្ញាណបរិសុទ្ធទាំងនោះស្វែងរកអស់អ្នកដែលកំពុងតែស្វែងរកព្រះ! ខ្ញុំជឿថា នៅពេលមនុស្សណាម្នាក់ត្រូវបានទាញនាំមកឯព្រះ គឺដោយសារវិញ្ញាណបរិសុទ្ធរបស់ព្រះ ធ្វើការនៅក្នុងចិត្តអ្នកនោះ ហើយនឹងជួយឲ្យអ្នកនោះបន្តដំណើរតាមផ្លូវរបស់ព្រះ ហើយធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គផង បន្ទាប់មក អ្នកនោះនឹងបានចូលរួមក្នុងការងារជាច្រើនរបស់ព្រះគ្រីស្ទ។ គឺព្រះគ្រីស្ទតែមួយព្រះអង្គ ដែលទ្រង់កំពុងតែធ្វើការនោះ តើមែនទេ? គឺមែនហើយ គឺទ្រង់ដែលធ្វើការទាំងអស់នោះ!។

ឯស្នែងទាំងប្រាំពីរ នឹងកូនចៀម នោះប្រៀបទៅនឹងពួកជំនុំទាំងប្រាំពីរ តើត្រូវទេ? ត្រូវហើយ ឯវិញ្ញាណបរិសុទ្ធទាំងប្រាំពីរនោះត្រូវបានចាត់ទៅពេញគ្រប់លើផែនដី។ ចូរយើងបើកទៅគម្ពីរ ចោទិយកថា ៣០:១៩ យើងនឹងរៀនពីគោលការសំខាន់មួយទៀត ពីព្រោះព្រះទ្រង់បានមានបន្ទូលដល់មនុស្សទាំងអស់ថា «អញអាងដល់ស្ថានសួគ៌នឹងផែនដី ឲ្យធ្វើជាបន្ទាល់ទាស់នឹងឯងរាល់គ្នានៅថ្ងៃនេះថា អញបានដាក់សំរេចទាំងជីវិត នឹងសេចក្ដីស្លាប់ ទាំងព្រះពរ នឹងសេចក្ដីបណ្តាសា នៅមុខឯងរាល់គ្នា ដូច្នេះចូររើសយកជីវិតចុះ ដើម្បីឲ្យឯងបានរស់នៅ ព្រមទាំងពូជឯងតរៀងទៅផង» ព្រះអម្ចាស់ទ្រង់ប្រទានសិទ្ធិសេរីភាពឲ្យយើងរាល់គ្នាជ្រើសរើស! ទ្រង់មិនបានបង្ខិតបង្ខំដល់អ្នកណាម្នាក់ឲ្យជឿទ្រង់ឡើយ ព្រះទ្រង់នឹងមិនធ្វើអ្វីមួយគ្រាន់តែជាប្រយោជន៍នៃការធ្វើវានោះទេ បើមិនដូច្នោះ នោះនឹងលុបចោលសិរីភាពក្នុងការជ្រើសរើសហើយ។ សិរីភាពជ្រើសរើស ត្រូវតែនៅជាសិរីភាពជ្រើសរើសដដែល ពីព្រោះយើងមិនមែនជាមនុស្សយន្ត (robots)នោះទេ។ ដូច្នេះព្រះទ្រង់ទុកឲ្យយើងជ្រើសរើស -ប៉ុន្តែ ព្រះព្រះទ្រង់ធ្វើការជាមួយនឹងយើងរាល់គ្នាវិញ។

២របាក្សត្រ ១៥:១ «គ្រានោះ វិញ្ញាណបរិសុទ្ធនៃព្រះក៏មកសណ្ឋិតលើអ័សារា ជាកូនអូដេឌ ហើយលោកចេញទៅទទួលអេសាទូលថា បពិតព្រះករុណាអេសា...[ស្តេចយូដា]... ព្រមទាំងពួកយូដា ពួកបេនយ៉ាមីនទាំងអស់គ្នាអើយ សូមស្តាប់ចុះ កំពុងដែលអ្នករាល់គ្នានៅជាមួយនឹងព្រះយេហូវ៉ា នោះទ្រង់ក៏គង់ជាមួយនឹងអ្នករាល់គ្នារាល់ដែរ ... [នេះជារឿងមានទៅ មានមក] ... បើអ្នករាល់គ្នាស្វែងរកទ្រង់ នោះនឹងរកឃើញពិត តែបើអ្នករាល់គ្នាបោះបង់ចោលទ្រង់វិញ ទ្រង់ក៏នឹងបោះបង់ចោលអ្នករាល់គ្នាដែរ» (ខ១-២)។

នោះគឺជាគោលការមួយដែលយើងអាចអនុវត្តចំពោះមនុស្សគ្រប់រូប នៅលើលោកីយនេះ មិនមែនគ្រាន់តែជាព្រះបន្ទូលនៃសេចក្ដីពិត ដែលព្រះទ្រង់បានធ្វើនោះទេ ប៉ុន្តែ គឺជាការព្យាករណ៍ផងដែរ ពីព្រោះបន្ទាប់មក តើមានអ្វីកើតឡើង? ស្តេចអេសាបានប្រមូលផ្តុំប្រជាជនយូដាទាំងអស់ ហើយពួក

គេបានព្រមព្រៀងគ្នាថា ពួកគេនឹងស្វែងរកព្រះ ហើយពួកគេនឹងធ្វើតាមទ្រង់ ដោយរក្សាបញ្ញត្តរបស់ទ្រង់ ហើយព្រះទ្រង់ក៏ឮសេចក្តីអធិស្ឋានរបស់ពួកគេ ហើយក៏ឆ្លើយតបនឹងសេចក្តីអធិស្ឋាននោះ ក៏ប្រទានឲ្យគេបានឈប់សំរាកពីខ្មាំងសត្រូវដែលនៅព័ទ្ធជុំវិញគេផង។

«ឯនាងម្អាកា ជាព្រះមាតាស្តេចអេសា ទ្រង់ក៏ដកពីដំណែងជាមាតាហ្លួងចេញ ដោយព្រោះព្រះនាងបានធ្វើរូបគួរស្អប់ខ្ពើមទុកជាព្រះ អេសាក៏កាប់រំលំរូបនោះ កិនកំទេចជាផង់ ហើយស្តេចយកទៅដុតចោលនៅត្រង់ជ្រោះកេដ្រុន» (២របាក្សត្រ១៥:១៦)។ បន្ទាប់មកស្តេចអេសា បានមកដល់ចំណុចមួយ ដែលទ្រង់មិនបានធ្វើតាមអ្វីដែលព្រះសព្វព្រះហឫទ័យឲ្យទ្រង់ធ្វើ សូមបើកទៅគម្ពីរ ២របាក្សត្រ ១៦:៧ «នៅវេលានោះ ហាណានី ជាអ្នកមើលឆុត លោកមកឯអេសាជាស្តេចយូដា ទូលថា ដោយព្រោះទ្រង់បានពឹងដល់ស្តេចស៊ីរី មិនបានពឹងដល់ព្រះយេហូវ៉ា ជាព្រះនៃទ្រង់ នោះពួកពលទ័ពរបស់ស្តេចស៊ីរី បានរួចពីកណ្តាប់ព្រះហស្តទ្រង់ហើយ» ដូច្នេះ សេចក្តីទំនាយត្រូវបានសំរេច ដរាបណាទ្រង់នៅជាមួយព្រះអម្ចាស់ ហើយព្រះអម្ចាស់ក៏គង់នៅជាមួយទ្រង់ដែរ ខ៨ «ឯពួកសាសន៍អេធីអូពី នឹងពួកលីប៊ី តើគេមិនមែនជាពួកពលយ៉ាងធំ មានទាំងរទេះចំបាំង នឹងពលសេះសន្ធឹកទេឬអី? ប៉ុន្តែដោយព្រោះទ្រង់បានពឹងដល់ព្រះយេហូវ៉ា បានជាព្រះទ្រង់ប្រគល់គេមកក្នុងកណ្តាប់ព្រះហស្តព្រះករុណាវិញ ដ្បិតព្រះនេត្រ...[វិញ្ញាណបរិសុទ្ធរបស់ព្រះ]...នៃព្រះយេហូវ៉ាចេះតែទតក្រវាត់ នៅគ្រប់លើផែនដីទាំងមូល ដើម្បីនឹងសំដែងព្រះចេស្តា ជួយដល់អ្នកណាដែលមានចិត្តស្មោះត្រង់ចំពោះទ្រង់...»(៨-៩) នោះជាវិញ្ញាណបរិសុទ្ធទាំង៧របស់ព្រះ។ ព្រះអម្ចាស់ទ្រង់មានពួកទេវតារបស់ទ្រង់ដែលកំពុងធ្វើការ នឹងគ្រប់គ្រងអ្វីៗនៅលើផែនដី ហើយទ្រង់ក៏មានព្រះនេត្ររបស់ទ្រង់ គឺជាវិញ្ញាណទាំង៧ ដែលព្រះចាត់ទៅពេញលើផែនដីទាំងមូល ដើម្បីនឹងស្វែងរកអស់អ្នកដែលកំពុងស្វែងរកព្រះ... ព្រះករុណាបានប្រព្រឹត្តបែបឆោតល្ងង់ហើយ ...[មិនប្រែចិត្ត មិនប្រែអាកប្បកិរិយា]...ដ្បិតពីនេះទៅមុខ នឹងចេះតែមានចំបាំងជានិច្ច»(ខ៩)។

សូមអ្នកត្រឡប់មកក្រោយបន្តិចវិញ ហើយអ្នកអាចរិភាគពីជីវិតរបស់ស្តេចដាវីឌ ពីរបៀបដែលស្តេចទ្រង់ធ្វើបានល្អណាស់ រហូតដល់មានទំនាក់ទំនងជាមួយនាងបាតសេបា។ ចាប់តាំងពីពេលនោះមកទ្រង់មានបញ្ហារហូត ព្រះយេហូវ៉ាទ្រង់គង់នៅជាមួយនឹងស្តេច ប៉ុន្តែស្តេចចេះតែមានបញ្ហាជានិច្ច។

យើងអាចពិចារណាតាមវិធីនេះ: ចុះប្រសិនបើអ្នកជាអ្នកឯកកាជ្យម្នាក់ រស់នៅលើភ្នំតែម្នាក់ឯង ហើយអ្នកមានព្រះគម្ពីរមួយក្បាល រួចអ្នកចាប់ផ្តើមស្វែងរកព្រះ ហើយដោយវិញ្ញាណបរិសុទ្ធនៃព្រះអម្ចាស់ទ្រង់ក៏ស្វែងរកអ្នក នោះអ្នកនឹងអាចរកទ្រង់ឃើញ។

សូមមើលរឿងឯទៀតដែលទាក់ទងនឹងរឿងនោះដែរ «ដ្បិតបានហៅមនុស្សជាច្រើន តែរើសបាន

តិចទេ» (ម៉ាថាយ២២:១៤) ហេតុអ្វីបានជាមានមនុស្សតិច ដែលត្រូវបានជ្រើសរើស? ពីព្រោះតិចណាស់បានប្រែចិត្ត! ពីព្រោះពួកគេប្រៀបប្រដូចអំពីអ្នកព្រោះពូជ ការខ្វល់ខ្វាយនឹងទ្រព្យសម្បត្តិរបស់លោកីយនេះ មកខ្ទប់ព្រះបន្ទូលជាប់ មិនឲ្យពូជនោះកើតផលបានឡើយ ដូច្នេះ គេឮព្រះបន្ទូលពិត នៃព្រះ ប៉ុន្តែព្រះបន្ទូលមិនអាចបង្កើតផលបាន អ្នកខ្លះទៀតបានឮព្រះបន្ទូល ហើយមានសេចក្តីអំណរភ្លាម តែព្រះបន្ទូលមិនអាចចាក់ឫសនៅក្នុងអ្នកនោះ ហើយក៏មិននៅជាប់ជាយូរប៉ុន្មានទេ លុះកាលណាកើតមានសេចក្តីទុក្ខលំបាក ឬសេចក្តីបៀតបៀនដោយព្រោះព្រះបន្ទូល នោះគេរសាយចិត្តចេញភ្លាមៗ បន្ទាប់មកក៏មានពូជខ្លះបានធ្លាក់ទៅលើដីល្អដែរ ក៏បានបង្កើតផលផ្លែ ហេតុនេះហើយ បានហៅជាច្រើន តែរើសបានតិចវិញ ពីព្រោះមានមនុស្សតិចណាស់ដែលប្រែចិត្តពីអំពើបាបៗ

នៅពេលមានមនុស្សណាម្នាក់ប្រែចិត្ត ហើយថ្វាយខ្លួនដល់ព្រះ ចូរយើងមើលពីសកម្មភាពរបស់អ្នកនោះ យើងនឹងត្រឡប់មករឿងនេះវិញ ជាមួយនឹងសេចក្តីអធិប្បាយមួយទៀត៖ តើអ្វីទៅដែលហៅថាការគ្រប់គ្រងនៃសេចក្តីស្លាប់ នឹងការគ្រប់គ្រងរបស់វិញ្ញាណបរិសុទ្ធរបស់ព្រះ? ប៉ុន្តែនៅថ្ងៃបុណ្យទី៥០ នៅពេលដែលព្រះបានចាក់បង្ហូរវិញ្ញាណបរិសុទ្ធរបស់ទ្រង់មកលើពួកសាវក នឹងពួក១២០នាក់ដែលនៅជុំគ្នានៅទីនោះ ហើយពួកសាវកក៏បានចាប់ផ្តើមនិយាយ នឹងផ្សព្វផ្សាយដំណាលគ្នា ជាច្រើនភាសា តាមដែលវិញ្ញាណបរិសុទ្ធរបស់ព្រះបណ្តាល តើមានមនុស្សប៉ុន្មានពាន់នាក់ នឹងរាប់ពាន់នាក់ទៀតនៅឯព្រះវិហារ ដែលយើងមិនដឹង? សូមមើលលទ្ធផលបន្ទាប់ពីសាវកពេត្រុស បានបង្រៀនថា ដោយដៃអាក្រក់របស់អ្នករាល់គ្នា បានចាប់ព្រះគ្រីស្ទឆ្កាង ហើយសំឡាប់ទ្រង់ លោកសាវកពេត្រុសបានប្រាប់ពួកគេថា «ដូច្នេះ ចូរឲ្យពួកវង្សអ៊ីស្រាអែលទាំងអស់ដឹងជាប្រាកដថា ព្រះទ្រង់បានលើកព្រះយេស៊ូវនេះ ដែលអ្នករាល់គ្នាបានឆ្កាង ឲ្យទ្រង់ធ្វើជាព្រះអម្ចាស់ ហើយជាព្រះគ្រីស្ទផង» (កិច្ចការ២:៣៦)

កាលណាអ្នកប្រែចិត្តពីអំពើបាប នោះអ្នកនឹងទទួលបាននូវចំណេះដឹង នឹងមានសេចក្តីជំនឿពិតលើសេចក្តីសុគតរបស់ព្រះគ្រីស្ទ សំរាប់លោះយើងរាល់គ្នាចេញពីអំពើបាប ដូច្នេះ យើងទាំងអស់គ្នាមានចំណែកក្នុងការធ្វើគុតព្រះយេស៊ូវគ្រីស្ទដែរៗ

កិច្ចការ២:៣៧-៣៨ «កាលគេបានឮ នោះគេមានសេចក្តីចាក់ចុចក្នុងចិត្ត ក៏សួរពេត្រុស នឹងពួកសាវកឯទៀតថា បងប្អូនអើយ តើយើងខ្ញុំត្រូវធ្វើដូចម្តេច ពេត្រុសឆ្លើយតបថា ចូរអ្នករាល់គ្នាប្រែចិត្តចុះ ហើយទទួលបុណ្យជ្រមុជទឹកទាំងអស់គ្នា ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ ប្រយោជន៍ឲ្យបានរួចពីបាប នោះអ្នករាល់គ្នានឹងទទួលអំណោយទាន ជាវិញ្ញាណបរិសុទ្ធរបស់ព្រះ» (ខ៣៧-៣៨)ៗ ចូរនឹកចាំថា ក្នុងចំណោមមនុស្សជាច្រើន ដែលទទួលបុណ្យជ្រមុជទឹក នៅថ្ងៃនោះ ពិតជាមានអ្នកនៅក្នុងហ្វូងមនុស្សដែលបាននិយាយថា «ចូរឆ្កាងវាទៅ! ចូរឆ្កាងវាទៅ!» នៅពេលដែលព្រះយេស៊ូវត្រូវបានលោកពី

ឡាត់កាត់ទោសទ្រង់ ការដែលកើតឡើងទាំងនោះ បានចាក់ចុចក្នុងចិត្តរបស់សាសន៍យូដា ដូច្នេះ ការប្រែចិត្តរបស់ពួកគេពិតជាជ្រាលជ្រៅណាស់។

ឥឡូវចូរកត់ចំណាំៈ «...នោះអ្នករាល់គ្នានឹងទទួលបានអំណោយទានជាវិញ្ញាណបរិសុទ្ធរបស់ព្រះ ព្រះ...[យើងបានឃើញពីរបៀបដែលវិញ្ញាណបរិសុទ្ធទាំង៧របស់ព្រះធ្វើការ ជាព្រះនេត្ររបស់ព្រះ ដើម្បីនឹងស្ថិតនៅជាមួយអស់អ្នកដែលប្រែចិត្តជឿព្រះយេស៊ូវគ្រីស្ទ។ យើងនឹងឃើញពីផ្នែកផ្សេងទៀត ដែលបានសំរេចដូចដែលព្រះយេស៊ូវមានព្រះបន្ទូលថា វិញ្ញាណបរិសុទ្ធរបស់ព្រះ នឹងនៅជាមួយអ្នក ក៏នឹងនៅក្នុងអ្នកផង។

កិច្ចការ២:៣៩-៤១ «ដ្បិតសេចក្តីសន្យានោះ គឺសន្យាដល់អ្នករាល់គ្នា នឹងកូនចៅអ្នករាល់គ្នាព្រមទាំងអស់អ្នកដែលនៅឆ្ងាយដែរ គឺដល់អស់អ្នកណាដែលព្រះអម្ចាស់ជាព្រះនៃយើងរាល់គ្នា ទ្រង់នឹងហៅ ...[ជាផ្លូវដែលអ្នកជ្រើសរើស ទទួលការត្រាស់ហៅ] ... គាត់ក៏ធ្វើទីបន្ទាល់អស់ពីចិត្ត ហើយទូន្មានដោយពាក្យជាច្រើនទៀតថា ចូរឲ្យអ្នករាល់គ្នាបានសង្គ្រោះ រួចពីពូជដំណវៀចនេះ នោះពួកអ្នកដែលទទួលពាក្យរបស់គាត់ដោយអំណរ ក៏បានទទួលបុណ្យជ្រមុជទឹក ហើយនៅថ្ងៃដដែលនោះ មានប្រហែលជា ៣ពាន់នាក់ថែមកើនឡើងទៀត» (ខ៣៩-៤១)។

យើងមិនដឹងជាមានមនុស្សប៉ុន្មាននាក់នៅក្នុងព្រះវិហារទេ ខ្ញុំប្រាកដជាមាន មនុស្សពី ៣-៤ ម៉ឺននាក់ ដែលជួបជុំនៅក្នុងថ្ងៃបុណ្យទី៥០នោះ ហើយពួកគេទាំងអស់បានឮដូចគ្នាទាំងអស់ ប៉ុន្តែមានតែ ៣ពាន់នាក់ប៉ុណ្ណោះដែលបានប្រែចិត្ត។ នៅពេលយើងក្រឡេកមើលមកក្រុមតូចរបស់យើងវិញ យើងគិតថាមានប្រហែល ៣ពាន់នាក់ - អស្ចារ្យ! នោះជាច្រើននាក់ណាស់ ប៉ុន្តែចំនួន៣ពាន់នាក់ក្នុងចំណោមពួកទាំងមូលនោះ ពិតជាមិនមានច្រើនទេ។ យើងមានរឿងជាច្រើនដែលពាក់ព័ន្ធ នឹងការត្រាស់ហៅរបស់ព្រះ ហើយទ្រង់ជួយឲ្យយើងអាចប្រែចិត្តពីអំពើបាបបាន។ អ្នកអាចកត់សំគាល់នៅក្នុងកំណត់ចំណាំរបស់អ្នកនៅត្រង់នេះថា "...សេចក្តីសប្បុរស...[គឺព្រះគុណ]...នៃព្រះគុណទាញនាំឲ្យអ្នកបានប្រែចិត្ត..." (រ៉ូម២:៤) បើយើងឆ្លើយតបនឹងការត្រាស់ហៅរបស់ព្រះអម្ចាស់។

សូមមើលពីព្រះយេស៊ូវគ្រីស្ទដែលទ្រង់មានបន្ទូលទៅពួកសាវក នៅពេលគេប្រែចិត្ត ហើយទទួល ទទួលបានវិញ្ញាណបរិសុទ្ធរបស់ព្រះ នោះយើងនឹងរីកចំរើននៅក្នុងព្រះគុណ នឹងចំណេះដឹង នឹងសេចក្តីស្រឡាញ់របស់ព្រះ។ បន្ទាប់ពីទទួលពិធីបុណ្យជ្រមុជទឹក នឹងទទួលវិញ្ញាណបរិសុទ្ធរបស់ព្រះ គឺជាការចាប់ផ្តើម បណ្តុះបណ្តាលសំរាប់ជីវិតអស់កល្បជានិច្ច។

នោះជារឿងគួរឱ្យភ្ញាក់ផ្អើលមែនទែន នៅពេលដែលអ្នកគិតអំពីវិធីនោះ - ដែលសព្វថ្ងៃយើងកំពុងហ្វឹកហាត់ដើម្បីទទួលបានជីវិតអស់កល្ប វាជាការអស្ចារ្យណាស់! នេះហើយជាមូលហេតុ ដែល

អ្នកត្រូវបានគេដកចេញពីពួកជឿសាសនា នឹងពីគ្រប់ការល្អទាំងអស់ដែលបានធ្វើ - ពីព្រោះមនុស្សចង់ធ្វើល្អ ហើយគិតថាល្អ ហើយមនុស្សជាច្រើនមានភាពស្មោះទៀងត្រង់ក្នុងលោកីយ-ប៉ុន្តែ ព្រះទ្រង់មិនបានត្រាស់ហៅអស់អ្នកដែលធ្វើការល្អទាំងធ្វើនោះទេ គឺហៅអ្នកមានបាបឲ្យប្រែចិត្ត។

ព្រះអម្ចាស់រៀបចំពេលវេលាសំរាប់ពួកគេ ដូចដែលយើងបានដឹងតាមរយៈថ្ងៃបរិសុទ្ធ សាវកយ៉ូហានសរសេរ យ៉ូហាន១៥:៩ «ខ្ញុំ...[ព្រះគ្រីស្ទ... បានស្រឡាញ់អ្នករាល់គ្នា ដូចជាព្រះវរបិតា ទ្រង់ស្រឡាញ់ខ្ញុំដែរ...» ឥឡូវនេះ យើងមានសេចក្តីស្រឡាញ់មកពីព្រះយេស៊ូវគ្រីស្ទ... ចូរនៅជាប់ក្នុងសេចក្តីស្រឡាញ់របស់ខ្ញុំចុះ» យើងមានសេចក្តីស្រឡាញ់ដែលមកពីព្រះយេស៊ូវគ្រីស្ទ ទ្រង់បានបង្ហាញសេចក្តីស្រឡាញ់ដល់យើង ដោយទ្រង់សុគត នៅលើឈើឆ្កាង សំរាប់ការអត់ទោសបាបរបស់យើង។ សូមកត់ចំណាំគម្ពីរអេសាយជំពូក៥៣ ទំនាយពីព្រះយេស៊ូវគ្រីស្ទ គម្ពីរទំនុកដំកើងជំពូក២២ ស្តេចដាវីឌបានសរសេរអំពីព្រះយេស៊ូវគ្រីស្ទ។ ព្រះយេស៊ូវគ្រីស្ទបានយាងទៅឯឈើឆ្កាង ដោយអំណរដែលនៅខាងមុខទ្រង់ ហើយមើលងាយភាពអាម៉ាស់ - សំរាប់យើង!

នៅក្នុងព្រះគម្ពីរ អស់អ្នកដែលព្រះទ្រង់បានហៅ ទ្រង់មានបន្ទូលថា «...រស់នៅក្នុងសេចក្តីស្រឡាញ់របស់ខ្ញុំ... បើអ្នករាល់គ្នាកាន់តាមបញ្ញត្តិខ្ញុំ នោះនឹងនៅជាប់ក្នុងសេចក្តីស្រឡាញ់របស់ខ្ញុំ ដូចជាខ្ញុំបានកាន់តាមបញ្ញត្តិនៃព្រះវរបិតាខ្ញុំ ហើយក៏នៅជាប់ក្នុងសេចក្តីស្រឡាញ់របស់ទ្រង់ដែរ ខ្ញុំបាននិយាយសេចក្តីទាំងនេះ ប្រាប់ដល់អ្នករាល់គ្នា ដើម្បីឲ្យសេចក្តីអំណររបស់ខ្ញុំ បាននៅជាប់ក្នុងអ្នករាល់គ្នា ហើយឲ្យសេចក្តីអំណររបស់អ្នករាល់គ្នាបានពោរពេញផង» (យ៉ូហាន១៥:៩-១១) នេះជាសេចក្តីទំនាយ តើសេចក្តីអំណរនឹងមកនៅពេលណា? សេចក្តីអំណរនឹងមក នៅពេលព្រះទ្រង់ប្រោសយើងឲ្យរស់ពីស្លាប់ឡើងវិញ ត្រូវហើយ! ទ្រង់បានមានបន្ទូលនៅកន្លែងមួយទៀតថា នៅក្នុងលោកីយតែងតែមានសេចក្តីវេទនា «...ប៉ុន្តែ ត្រូវសង្ឃឹមឡើង ដ្បិតខ្ញុំបានឈ្នះលោកីយហើយ» (យ៉ូហាន១៦:៣៣) ដូច្នេះ នេះជាសេចក្តីអំណរដ៏ពោរពេញ! ឥឡូវនេះ យើងពិតជាមានសេចក្តីអំណរ! ប៉ុន្តែ ដើម្បីឱ្យមានសេចក្តីអំណរដ៏ពេញលេញ គឺនៅពេលដែលយើងបានត្រូវប្រោសឲ្យរស់ពីស្លាប់ឡើងវិញ។

យ៉ូហាន ១៥:១២ «នេះជាសេចក្តីបញ្ញត្តិរបស់ខ្ញុំ គឺឲ្យអ្នករាល់គ្នាស្រឡាញ់ដល់គ្នាទៅវិញ ទៅមក... [នេះគឺជាការលំបាកមែនទេ? ព្រះទ្រង់បានត្រាស់ហៅមនុស្សមកពីគ្រប់សាសន៍ មានលក្ខណៈផ្សេងៗគ្នា ដើម្បីរៀនស្រឡាញ់គ្នាទៅវិញទៅមក យើងអាចនឹងធ្វើបានតាមរយៈវិញ្ញាណបរិសុទ្ធរបស់ព្រះ តែប៉ុណ្ណោះ ហើយត្រូវតែហ្វឹកហ្វឺន នឹងធ្វើ]...គ្មានអ្នកណាមានសេចក្តីស្រឡាញ់ធំជាងនេះ គឺដែលអ្នកណានឹងប្តូរជីវិត ជំនួសពួកសំឡាញ់របស់ខ្លួននោះទេ បើអ្នករាល់គ្នាធ្វើតាមសេចក្តីដែលខ្ញុំបង្គាប់ នោះអ្នករាល់គ្នាជាពួកសំឡាញ់ខ្ញុំហើយ» (១២-១៤)។

ឈប់ហើយគិតអំពីរឿងនេះសិន  អ្នកធ្លាប់គិត ថា ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ ជាអ្នកដឹកនាំផ្ទាល់របស់អ្នក នឹងជាសម្តេចសង្ឃមួយអង្គនៅស្ថានសួគ៌ រង់ចាំជួយអ្នកគ្រប់ពេលវេលា  ហើយទ្រង់ក៏ជាមិត្តសំឡាញ់របស់អ្នកផងដែរ!  មិត្តសំឡាញ់នៅក្នុងព្រះគម្ពីរ គឺជាអស់អ្នកដែលយើងអាចនិយាយបានថា ជាមិត្តសំឡាញ់ពិត – មានន័យថា៖

- ជាម្នាក់ដែលអ្នកអាចជឿទុកចិត្តបាន
- ជាម្នាក់ដែលអ្នកអាចស្រឡាញ់បាន
- ជាម្នាក់ដែលតែងតែគិតពីអ្នក
- ជាម្នាក់ដែលតែងតែជួយអ្នក
- ជាម្នាក់ដែលយកចិត្តទុកដាក់នឹងអ្នក

១១៥ «ខ្ញុំមិនហៅជាអ្នកបំរើទៀត ពីព្រោះអ្នកបំរើគេមិនដឹងជាចៅហ្វាយធ្វើអ្វីទេ គឺខ្ញុំហៅអ្នករាល់គ្នាថាជាសំឡាញ់វិញ ពីព្រោះខ្ញុំបានឲ្យអ្នករាល់គ្នាដឹងគ្រប់ការទាំងអស់ ដែលខ្ញុំឮពីព្រះវរបិតាខ្ញុំមក»

តើព្រះអង្គសព្វព្រះហឫទ័យឲ្យយើងដឹងអ្វីខ្លះ?  តើយើងដឹងពីផែនការនៃសេចក្តីសង្គ្រោះរបស់ព្រះយ៉ាងដូចម្តេច? ព្រះគ្រីស្ទបានបង្ហាញពីផែនការរបស់ព្រះ បើយើងគ្រាន់តែមើលទៅក្នុងលោកីយ ឬរកមើលសៀវភៅទស្សនៈវិជ្ជាផ្សេងៗ ឬសៀវភៅរបស់ «សាសនា» ផ្សេងៗ គ្មាននរណាម្នាក់អាចប្រាប់អ្នកពីអ្វីដែលព្រះកំពុងធ្វើនោះបានទេៗ  សាតាំងវាបានក្លែងបន្លំអ្វីៗគ្រប់យ៉ាងទាំងអស់ តែមនុស្សគេមិនដឹងទេ! ខ្ញុំគិតថាប្រសិនបើអ្នកមើលទៅសាសនាហិណ្ឌូ  អ្នកអាចមើលឃើញការកាន់ច្រឡំយ៉ាងធ្ងន់ធ្ងររបស់គេ ព្រោះគេមិនដឹងពីផែនការរបស់ព្រះអម្ចាស់ទេ  ប្រសិនបើក្មេងប្រុសអាក្រក់  ឬក្មេងស្រីអាក្រក់នោះកើតនៅក្នុងប្រទេសឥណ្ឌា  អ្នកបានចាប់កំណើតមកពីសត្វរុយ  ហើយបន្ទាប់មកអ្នកត្រូវតែខិតខំប្រឹងប្រែងឆ្លងកាត់ គ្រប់កំរិតនៃព្រលឹង    រហូតដល់អ្នកបានកើតមកជាមនុស្សម្តងទៀតៗ   បើអ្នកធ្វើអំពើល្អ នោះអ្នកនឹងបានទៅឯនិព្វានៗ  អ្នកអាចសួរទៅពួកគ្រីស្ទានប្រូតេស្តង់ ឬកាតូលិកថា  តើមានប៉ុន្មាននាក់បានឡើងទៅឋានសួគ៌? តើការនោះកើតឡើងយ៉ាងដូចម្តេច? ព្រះគម្ពីរបានប្រាប់ថា មានសេចក្តីរស់ពីស្លាប់ឡើងវិញ  ព្រះទ្រង់បានមានបន្ទូលសន្យាទុករួចហើយៗ  សូមមើលទៅគម្ពីរយ៉ូហាន ៦:៤៤ៗ

យ៉ូហាន១៥:១៦ «មិនមែនអ្នករាល់គ្នាដែលបានរើសខ្ញុំទេ គឺខ្ញុំ...[ព្រះគ្រីស្ទ]...ទេតើ ដែលរើសអ្នករាល់គ្នាវិញ   ទាំងតាំងអ្នករាល់គ្នាឲ្យទៅបង្កើតផល ហើយឲ្យផលរបស់អ្នករាល់គ្នាបាននៅជាប់ផង ដើម្បីឲ្យព្រះវរបិតាបានប្រោសប្រទានឲ្យអ្នករាល់គ្នាបានអ្វីៗ ដែលនឹងសូមពីទ្រង់ ដោយនូវឈ្មោះខ្ញុំ»

នេះគឺជាការដ៏អស្ចារ្យណាស់ បងប្អូនស្ងួនភ្ងាអើយ  ព្រះទ្រង់សព្វព្រះហឫទ័យឲ្យយើងរាល់គ្នាចងចាំជានិច្ចថា គឺព្រះដ៏ជាព្រះវរបិតា នឹងព្រះយេស៊ូវគ្រីស្ទបានចូលរួមដោយផ្ទាល់អង្គទ្រង់នៅក្នុងជីវិតរបស់

យើង ដោយសារវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ពីព្រោះទ្រង់ស្រឡាញ់យើង។ ហេតុនេះ យើងមិនត្រូវដាក់អ្វីមួយនៅជាកណ្ដាលរវាងយើង ហើយនឹងព្រះអង្គនោះទេ។ អ្នកមានទំនាក់ទំនងផ្ទាល់ជាមួយនឹងព្រះដ៏ជាព្រះវរបិតា នឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទ! នោះគឺជាសេចក្ដីសន្យាដ៏អស្ចារ្យរបស់ព្រះ!

សូមមើលទៅឯវិញ្ញាណបរិសុទ្ធរបស់ព្រះ ដែលយើងបានទទួលដោយការអធិស្ឋានដាក់ដៃលើ នៅពេលអ្នកងើបពីក្នុងទឹកមកវិញ ហើយអ្នកបានទទួលអំណោយទានជាវិញ្ញាណបរិសុទ្ធនៃព្រះមកសណ្ឋិតនៅក្នុងអ្នក ដើម្បីឲ្យបានប្រកបនឹងវិញ្ញាណរបស់អ្នក នោះហៅថា ការចាប់ផ្ដើមមានកំណើតនៃវិញ្ញាណបរិសុទ្ធរបស់ព្រះ គឺអ្នកចាប់ផ្ដើមមានកំណើតថ្មីពីព្រះមក។

ដូចពេលដែលយើងចាប់កំណើតក្នុងពោះម្ដាយរបស់យើង ខាងសាច់ឈាមដំបូងជាយ៉ាងណា ហើយឪពុកយើងជាអ្នកឲ្យកំណើតយើង ម្ដាយយើងពរពោះដាង៩ខែ ហើយសំរាលយើងចេញមក ដូចគ្នាជាមួយនឹងវិញ្ញាណបរិសុទ្ធរបស់ព្រះដែរ ដែលស្ថិតនៅក្នុងយើង ហើយនឹងកំណើតថ្មីរបស់យើងដែរ។

សាវកប៉ុលបានដាស់តឿនយើង «...ដើម្បីឲ្យយើងបានដើរក្នុងជីវិតបែបថ្មី ដូចជាព្រះគ្រីស្ទបានរស់ពីស្លាប់ឡើងវិញ...» (រ៉ូម៦:៤) ការដើរក្នុងជីវិតបែបថ្មី មិនរង់ចាំដល់ពេលយើងត្រូវបានប្រោសឲ្យរស់ពីស្លាប់ឡើងវិញនោះទេ ការដើរក្នុងជីវិតបែបថ្មី គឺដើរតាមផ្លូវរបស់ព្រះ។ ការដើរក្នុងជីវិតបែបថ្មី មានការកាន់ច្រឡំជាច្រើនណាស់ នៅលើលោកីយនេះ ដោយព្រោះគេមិនជឿព្រះបន្ទូលរបស់ព្រះ។

ចូរមើលទៅគ្រប់ការទាំងអស់រួមគ្នា ដោយសារវិញ្ញាណបរិសុទ្ធរបស់ព្រះបណ្ដាល សូមបើកទៅគម្ពីររ៉ូមជំពូក៨ ខ្ញុំគ្រាន់តែចង់រំលឹកអ្នក ពីអ្វីដែលយើងបានអាននៅគម្ពីរយ៉ូហាន ជំពូក១៤ ព្រះយេស៊ូវបានមានបន្ទូលថា «បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តរបស់ខ្ញុំចុះ នោះខ្ញុំនឹងទូលសូមដល់ព្រះវរបិតាខ្ញុំ ហើយទ្រង់នឹងប្រទានជំនួយ១ មកអ្នករាល់គ្នា ឲ្យបាននៅជាមួយ អស់កល្បជានិច្ចទៅ គឺជាវិញ្ញា-ណនៃសេចក្ដីពិត ដែលលោកីយទទួលពុំបាន ព្រោះមិនឃើញ ហើយមិនស្គាល់សោះ តែអ្នករាល់គ្នាស្គាល់ ដ្បិតនៅជាមួយ ក៏នឹងសណ្ឋិតនៅក្នុងអ្នករាល់គ្នាដែរ ព្រះយេស៊ូវមានបន្ទូលឆ្លើយថា បើអ្នកណាណាស្រឡាញ់ខ្ញុំ អ្នកនោះនឹងកាន់តាមពាក្យខ្ញុំ នោះព្រះវរបិតាខ្ញុំនឹងស្រឡាញ់អ្នកនោះ ហើយយើង...[គឺព្រះវរបិតា នឹងព្រះរាជបុត្រា]...នឹងមកឯអ្នកនោះ ក៏នឹងតាំងទីលំនៅ នៅជាមួយដែរ» (យ៉ូហាន១៤:១៥, ២៣) នេះមានន័យថា ព្រះអម្ចាស់ទ្រង់រស់នៅក្នុងអ្នក ដោយសារវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ដូចដែលយើងនឹងឃើញក្នុងពេលបន្តិចទៀតនេះ ដោយព្រះអម្ចាស់ទ្រង់នឹងប្រទានវិញ្ញាណបរិសុទ្ធមកយើង។

រ៉ូម៨:៦ នៅក្នុងខនេះ បានបញ្ជាក់បន្ថែមទៀត ពីរបៀបរស់នៅរបស់លោកីយ «ដ្បិតគំនិតខាងសាច់ឈាមនោះ គឺជាសេចក្ដីស្លាប់ទទេ...» [មានផ្លូវមួយដែលមើលទៅដូចជាត្រឹមត្រូវល្អ ដល់មនុស្ស តែចុងបំផុតនៃផ្លូវនោះ គឺជាសេចក្ដីស្លាប់ សុភាសិត១៦:២៥]...ឯគំនិតនៃវិញ្ញាណបរិសុទ្ធរបស់ព្រះ នោះ

ទើបជាជីវិត នឹងសេចក្តីសុខសាន្តវិញ ព្រោះគំនិតខាងសាច់ឈាម នោះរមែងទាស់ទទឹងនឹងព្រះ... [នៅពេលមួយនោះ យើងទាំងអស់គ្នាជាសត្រូវរបស់ព្រះ មែនឬទេ? មែន!]... ដ្បិតមិនចុះចូលនឹងក្រិត្យវិន័យរបស់ព្រះទេ ក៏ពុំអាចនឹងចុះចូលបានផង ពួកអ្នកដែលនៅខាងសាច់ឈាម នោះពុំអាចនឹងគាប់ព្រះហឫទ័យដល់ព្រះបានឡើយ តែបើសិនជាវិញ្ញាណបរិសុទ្ធនៃព្រះសណ្ឋិតក្នុងខ្លួនអ្នករាល់គ្នា នោះអ្នករាល់គ្នាមិននៅខាងសាច់ឈាមទៀតទេ គឺនៅខាងវិញ្ញាណវិញ ប៉ុន្តែ បើអ្នកណាគ្មានវិញ្ញាណរបស់ព្រះគ្រីស្ទ អ្នកនោះមិនមែនជារបស់ផងទ្រង់ទេ» (រ៉ូម៨:៦-៩)។

ព្រះយេស៊ូវគ្រីស្ទបានមានបន្ទូលថា «វិញ្ញាណនៃសេចក្តីពិត នឹងនៅជាមួយអ្នក ក៏នឹងស្ថិតនៅក្នុងអ្នក តើត្រូវទេ? ត្រូវហើយ! ការនោះកើតឡើងនៅពេលអ្នកទទួលបុណ្យជ្រមុជទឹក នឹងការអធិស្ឋានដាក់ដៃលើ ព្រះដ៏ជាព្រះវរបិតាទ្រង់សព្វព្រះហឫទ័យបង្កើតយើងឡើង ជាកូនប្រុស កូនស្រីរបស់ព្រះអង្គ ដោយមានវិញ្ញាណបរិសុទ្ធនៃព្រះវរបិតា នឹងវិញ្ញាណបរិសុទ្ធរបស់ព្រះយេស៊ូវគ្រីស្ទ នឹងគំនិតរបស់ព្រះយេស៊ូវគ្រីស្ទ ឋិតនៅក្នុងជីវិតយើងផង!

សូមទៅមើលទៅឯកំណើតរបស់សាច់ឈាមម្តងទៀត តាមពិត ទារកកើតមកត្រូវលូតលាស់ នឹងអភិវឌ្ឍន៍ ហើយទារកបានធ្វើអ្វីៗគ្រប់យ៉ាង ពេលនៅក្នុងស្បូនរបស់ម្តាយ ដើម្បីរៀបចំខ្លួនឱ្យបានរួចរាល់សំរាប់សំរាលចេញមក ដូចជាការជញ្ជក់មេដៃ បើកភ្នែក ញញឹម យំ ដេក អនុវត្តដើរដោយទាត់ជើង នឹងរំកិលដៃ នឹងអស់ទាំងអវៈយវៈរបស់វាផ្សេងៗទៀត ហើយម្តាយក៏ដឹងថា ទារកកំពុងកំរើកនៅក្នុងពោះ ម្តាយក៏ដឹងដែរ ថាកូនរបស់នាងកំពុងតែមានចលនានៅក្នុងពោះរបស់នាង ទារកបានត្រៀមខ្លួនដើម្បីនឹងសំរាល ឯម្តាយមានអារម្មណ៍ថា នាងកំពុងពរទឹកមួយថាំងធំ នៅក្នុងពោះនាង ទារកបានសម្រូតក្បាលចុះមកផ្នែកខាងក្រោម រៀបចំកើតចេញពីផ្ទៃម្តាយ បន្ទាប់ពីទារកកើតមកភ្លាម ទារកត្រូវដកដង្ហើមដោយខ្លួនឯង នឹងបន្តដកដង្ហើមពេញមួយជីវិតរបស់គាត់។ ព្រះបានដាក់ខ្យល់ដង្ហើមនៅក្នុងទារកនោះដោយស្ម័គ្រចិត្តរហូតដល់ថ្ងៃស្លាប់ នេះតើមិនមែនជារឿងដ៏អស្ចារ្យទេ ឬអ្វី? ឥឡូវនេះ ដូចគ្នានៅពេលយើងរស់ពីស្លាប់ឡើងវិញ នៅពេលដែលយើងបានកើតជាថ្មីចេញពីផ្នូរមក ភ្លាមៗនោះអ្វីៗទាំងអស់ខុសគ្នាទាំងស្រុង មែនទេ? មែនហើយ យើងនឹងកើតជាវិញ្ញាណ ប៉ុន្តែ ដូចជាទារកនៅក្នុងផ្ទៃ ត្រូវត្រៀមសំរាប់ជីវិតខាងសាច់ឈាមដែរ ដូច្នេះ នៅពេលព្រះអម្ចាស់ទ្រង់ត្រាស់ហៅយើង ហើយទ្រង់ប្រទានវិញ្ញាណបរិសុទ្ធរបស់ទ្រង់មកយើង ហើយវិញ្ញាណបរិសុទ្ធនោះកំពុងតែស្ថិតនៅក្នុងខ្លួនយើង ដើម្បីរៀបចំឱ្យយើងកើតជាថ្មី គឺប្រោសឲ្យយើងរស់ពីស្លាប់ឡើងវិញ ទៅជាវិញ្ញាណ។

យើងនឹងឃើញមានលក្ខណៈពីរ (២) គឺជាវិញ្ញាណបរិសុទ្ធដែលមកអំពីព្រះយេស៊ូវគ្រីស្ទ នឹងវិញ្ញាណបរិសុទ្ធដែលមកអំពីព្រះវរបិតា។ សូមមើលគម្ពីរ រ៉ូម៨:៩ «តែបើសិនជាវិញ្ញាណបរិសុទ្ធនៃព្រះ

សណ្ឋិតក្នុងខ្លួនអ្នករាល់គ្នា នោះអ្នករាល់គ្នាមិននៅខាងសាច់ឈាមទៀតទេ គឺនៅខាងវិញ្ញាណវិញ ប៉ុន្តែ បើអ្នកណាគ្មានវិញ្ញាណរបស់ព្រះគ្រីស្ទ អ្នកនោះមិនមែនជារបស់ទ្រង់ទេ» មានការមួយទៀត ដែលលោកីយមើលមិនឃើញ ព្រះទ្រង់ទតឃើញវិញ! ពីព្រោះព្រះទ្រង់ជ្រាបគ្រប់ទាំងអស់! ព្រះអម្ចាស់ទ្រង់ប្រទានវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ដល់អស់អ្នកដែលបានប្រែចិត្តពីអំពើបាប ជឿព្រះយេស៊ូវគ្រីស្ទ ហើយទទួលបុណ្យជ្រមុជទឹក ៖១០ «ហើយបើសិនជាព្រះគ្រីស្ទសណ្ឋិតក្នុងអ្នករាល់គ្នា ...[យើងត្រូវរីកចំរើនក្នុងគំនិតរបស់ព្រះគ្រីស្ទ]... នោះរូបសាច់បានស្លាប់ ដោយព្រោះអំពើបាបមែន តែវិញ្ញាណមានជីវិតវិញ ដោយព្រោះសេចក្ដីសុចរិតរបស់ព្រះ មួយទៀត បើវិញ្ញាណបរិសុទ្ធនៃព្រះអង្គ ដែលបានប្រោសឲ្យព្រះគ្រីស្ទរស់ពីស្លាប់ឡើងវិញ សណ្ឋិតក្នុងខ្លួនអ្នករាល់គ្នា នោះព្រះអង្គ...[ព្រះវរបិតា]...នោះឯង ដែលបានប្រោសឲ្យព្រះគ្រីស្ទរស់ពីស្លាប់ឡើងវិញ ទ្រង់នឹងប្រោសរូបកាយនៃអ្នករាល់គ្នា ដែលទៀងតែស្លាប់ ឲ្យមានជីវិតឡើងវិញ ដោយសារវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ដែលសណ្ឋិតនៅក្នុងអ្នករាល់គ្នា» (៖១០-១១) ព្រះបន្ទូលនេះ គួរឲ្យចាប់អារម្មណ៍ណាស់ មែនទេ? គឺមែន! តើសំដៅទៅលើអ្វី? នេះគឺសំដៅទៅលើវិញ្ញាណបរិសុទ្ធរបស់ព្រះវរបិតា ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ តើត្រឹមត្រូវទេ? គឺត្រឹមត្រូវហើយ! សូមមើលទៅបទគម្ពីរមួយផ្សេងទៀត គម្ពីររ៉ូមជំពូក៦ ហើយមើលពីអត្ថន័យនៃពិធីបុណ្យជ្រមុជទឹក ដើម្បីឲ្យយើងអាចឈានដល់ចំណុចនៃការទទួលវិញ្ញាណបរិសុទ្ធរបស់ព្រះបាន តើហេតុអ្វីបានជាព្រះទ្រង់ធ្វើតាមរបៀបនេះ? ព្រះទ្រង់មានបន្ទូលនៅកន្លែងផ្សេងទៀតថា «...អញចូលចិត្តឲ្យឯងបានត្រជាក់ ឬក្តៅក្តី» (វិវរណៈ៣:១៥-១៦) ម្យ៉ាងទៀត មនុស្សនៅលោកីយនេះ គេមានចិត្តព្រងើយកន្តើយណាស់ ហេតុនេះហើយ បានជាព្រះអម្ចាស់ទ្រង់មិនបានត្រាស់ហៅពួកអ្នកទាំងនោះ ហើយព្រះទ្រង់ក៏មិនទាក់ទងជាមួយនឹងពួកគេដែរ ពីព្រោះព្រះទ្រង់នឹងដោះស្រាយបញ្ហាជាមួយពួកគេ នៅថ្ងៃដ៏ធំអស្ចារ្យចុងក្រោយវិញ។

រ៉ូម៦:១ «ដូច្នេះ តើយើងនឹងថាដូចម្ដេច តើត្រូវឲ្យយើងចេះតែប្រព្រឹត្តអំពើបាបទៅទៀត ដើម្បីឲ្យព្រះគុណបានចំរើនឡើង ឬអី? ទេ មិនត្រូវឡើយ ធ្វើដូចម្ដេចឲ្យយើងដែលស្លាប់ខាងឯអំពើបាបហើយ បានរស់នៅក្នុងអំពើបាបទៀតបាន» បុណ្យជ្រមុជទឹក គឺជានិមិត្តរូបនៃសេចក្ដីស្លាប់ ខាងអំពើបាប! យើងដឹងថាសេចក្ដីស្លាប់នេះ គ្រាន់តែជានិមិត្តរូបនៃសេចក្ដីស្លាប់ប៉ុណ្ណោះទេ ខ្ញុំតែងតែលើកអ្នកទទួលជ្រមុជទឹក គ្រប់គ្នាចេញពីទឹក បើសិនជាអ្នកនៅក្នុងទឹកយូរបន្តិច នោះ អ្នកអាចនឹងស្លាប់បាន... តើអ្នករាល់គ្នាមិនដឹងទេ ឬអី ថា យើងទាំងប៉ុន្មានដែលបានទទួលជ្រមុជក្នុងព្រះយេស៊ូវគ្រីស្ទ នោះគឺបានទទួលជ្រមុជក្នុងសេចក្ដីសុគតនៃទ្រង់ដែរ ដូច្នេះ យើងបានត្រូវកប់ជាមួយនឹងទ្រង់ហើយ ដោយទទួលជ្រមុជក្នុងសេចក្ដីស្លាប់ ដើម្បីឲ្យយើងបានដើរក្នុងជីវិតបែបថ្មី ដូចជាព្រះគ្រីស្ទបានរស់ពីស្លាប់ឡើងវិញ

ដោយសារសិរីល្អនៃព្រះវរបិតាដែរ» (រ៉ូម៦:១-៤) បន្ទាប់ពីបានទទួលបុណ្យជ្រមុជទឹក ជីវិតរបស់អ្នករាល់គ្នាត្រូវតែផ្លាស់ប្រែ យើងត្រូវរស់នៅក្នុងជីវិតបែបថ្មី។

- ឥឡូវនេះ យើងបានប្រែចិត្តជឿ
- ឥឡូវនេះ យើងដើរតាមផ្លូវរបស់ព្រះអម្ចាស់
- ឥឡូវនេះ យើងរក្សាបញ្ញត្តិរបស់ព្រះអម្ចាស់
- ឥឡូវនេះ យើងស្រឡាញ់ព្រះអម្ចាស់
- ឥឡូវនេះ យើងទុកចិត្តលើព្រះអម្ចាស់
- ឥឡូវនេះ យើងជឿព្រះអម្ចាស់
- ឥឡូវនេះ យើងដើរដោយជំនឿ

រ៉ូម៦:៥ «ដ្បិតបើយើងបានជាប់ជាមួយនឹងទ្រង់ ក្នុងការដែលជាគំរូពីសេចក្តីសុគតរបស់ទ្រង់ ...[ប្រសិនបើយើងបានចូលរួមក្នុងសេចក្តីសុគតរបស់ព្រះយេស៊ូវ [ក្នុងការជ្រមុជទឹក]...» សូមចងចាំបទគម្ពីរដែលព្រះយេស៊ូវបានមានបន្ទូលថា «បើអ្នកណាមកឯខ្ញុំ ដោយមិនបានលះអាល័យពីឪពុកម្តាយ ប្រពន្ធកូន បងប្អូនប្រុសស្រី នឹងជីវិតខ្លួនឯងផង អ្នកនោះនឹងធ្វើជាសិស្សខ្ញុំមិនបានទេ ហើយអ្នកណាដែលមិនផ្ទុកឈើឆ្កាងខ្លួន មកតាមខ្ញុំ នោះក៏ធ្វើជាសិស្សខ្ញុំមិនបានដែរ» (លូកា១៤:២៦-២៧) នោះបង្ហាញពីរបៀបដែលយើងចូលរួមក្នុងសេចក្តីសុគតរបស់ព្រះយេស៊ូវគ្រីស្ទ នឹងពីរបៀបដែលព្រះយេស៊ូវគ្រីស្ទលះបង់ផ្ទាល់អង្គទ្រង់ នឹងយកមកអនុវត្តន៍នៅក្នុងជីវិតរបស់យើងម្នាក់ៗ។

៦៥"...នោះក៏នឹងបានជាប់ក្នុងសេចក្តីរស់ឡើងវិញរបស់ទ្រង់ដែរ...[នេះជាសេចក្តីសង្ឃឹមរបស់យើងរាល់គ្នានៅពេលខាងមុខ] ...ដោយដឹងសេចក្តីនេះថា មនុស្សចាស់របស់យើង បានត្រូវឆ្កាងជាមួយនឹងទ្រង់ហើយ ដើម្បីឲ្យតួអំពើបាបបានត្រូវសូន្យទៅ...[ពេលយើងងើបពីក្នុងទឹកមកវិញ យើងមានការងារដែលត្រូវធ្វើ គឺត្រូវចំរើនឡើងក្នុងព្រះគុណ ហើយក្នុងការស្គាល់ដល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង ដែលទ្រង់បានបំផ្លាញអំពើបាបឲ្យសូន្យទៅ ដើម្បីឲ្យយើងមានជ័យជំនះលើអំពើបាប នឹងលើលក្ខណៈធម្មជាតិរបស់មនុស្ស]...ដូចការរស់ឡើងវិញរបស់ទ្រង់ដែរ ... [នោះជាសេចក្តីសង្ឃឹមដែលយើងរាល់គ្នាកំពុងទន្ទឹងរង់ចាំ]... ប្រយោជន៍កុំឲ្យយើងនៅបំរើអំពើបាបទៀតឡើយ» បទនេះ មិនបានចែងថា អ្នកឈប់ធ្វើបាបទៀតទេ អ្នកមិនត្រូវធ្វើជាបាវបំរើរបស់អំពើបាប ក៏កុំឲ្យអំពើបាបត្រួតត្រាលើអ្នកដែរ]... ដ្បិតអ្នកណាដែលស្លាប់នោះក៏បានរាប់ជាសុចរិតរួចពីបាបហើយ បើសិនជាយើងស្លាប់ជាមួយនឹងព្រះគ្រីស្ទ នោះយើងជឿថា យើងនឹងរស់ជាមួយនឹងទ្រង់ដែរ» (រ៉ូម៦:៥-៨) នោះហើយជាការ

ដែលយើងរាល់គ្នាកំពុងតែទន្ទឹងរង់ចាំ។

សូមបើកទៅគម្ពីរអេភេសូរជំពូក១ ហើយមើលពីរបៀបដែលលោកសាវកប៉ុល សរសេរទៅពួកជំនុំអេភេសូរ ភីលីព និងកូល៉ុស គឺជាបទគម្ពីរទាំងអស់នោះហើយ ដែលព្រះអម្ចាស់បានបណ្តាលឲ្យសាវកប៉ុលសរសេរ ទុកសំរាប់យើងរាល់គ្នា ដើម្បីឲ្យយើងទាំងរាល់គ្នាអាចចូលទៅជិតព្រះបាន ហើយអាចទទួលបានភាពពេញលេញនៃអំណាចវិញ្ញាណបរិសុទ្ធរបស់ទ្រង់។ ប៉ុន្តែ សូមមើលបទគម្ពីរដែលព្រះអម្ចាស់មានបន្ទូលតាមរយៈសាវកប៉ុលៈ

អេភេសូរ១:៣ «សូមសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ដែលទ្រង់បានប្រទានពរមកយើងក្នុងព្រះគ្រីស្ទ ដោយគ្រប់ទាំងព្រះពរខាងព្រលឹងវិញ្ញាណ នៅស្ថានដ៏ខ្ពស់ តាមដែលទ្រង់បានរើសយើងរាល់គ្នាក្នុងព្រះគ្រីស្ទ...[ដើម្បីទទួលបានវិញ្ញាណបរិសុទ្ធរបស់ទ្រង់]... តាំងពីមុនកំណើតលោកីយមក ប្រយោជន៍ឲ្យយើងរាល់គ្នាបានបរិសុទ្ធ ហើយឥតកន្លែងបន្ទោសបាននៅចំពោះទ្រង់ ដោយសេចក្តីស្រឡាញ់» (ខ៣-៤) អរព្រះគុណដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង ដែលបានប្រទានពរដល់យើង គ្រប់ទាំងព្រះពរនៅស្ថានបរមសុខ ជាមួយនឹងព្រះគ្រីស្ទផង។ ពេលទទួលបានវិញ្ញាណវិសុទ្ធរបស់ព្រះ នោះគឺជាព្រះពរដែលមកអំពីព្រះ នឹងចំណេះដឹង អំពីសេចក្តីពិតរបស់ព្រះ។ ព្រះទ្រង់ប្រទានពរឲ្យយើងយល់ដឹងពីសេចក្តីអាថ៌កំបាំង ឲ្យយើងយល់ដឹងអំពីទំនាយរបស់ទ្រង់ តើនេះមិនមែនជាព្រះពររបស់ព្រះទេ ឬអី? ត្រូវហើយ! ទាំងអស់នោះជាព្រះពររបស់ព្រះ ដែលយើងត្រូវការ នឹងត្រូវដឹងៈ

- ព្រះអម្ចាស់បានត្រាស់ហៅយើង ពីព្រោះយើងជាមនុស្សកំសោយនៅលោកីយនេះ
- ព្រះអម្ចាស់បានត្រាស់ហៅយើង ពីព្រោះយើងជាមនុស្សល្ងង់ល្ងើនៅលោកីយនេះ

តាមពិត តើយើងជាអ្នកណា នៅក្នុងលោកីយនេះ? យើងរាល់គ្នាជាអ្នកទទួលការត្រាស់ហៅរបស់ព្រះ ហើយព្រះបានជ្រើសរើសយើងតាមព្រះហឫទ័យរបស់ទ្រង់។ ព្រះទ្រង់នឹងធ្វើការដ៏អស្ចារ្យយ៉ាងសំខាន់បំផុត! ទ្រង់នឹងយកអ្វីៗដែលលោកីយបដិសេធ ហើយទ្រង់នឹងបំផ្លាស់បំប្រែពួកអ្នកដែលទ្រង់បានត្រាស់ហៅ ដោយសារវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ហើយបង្រៀនពួកអ្នកទាំងនោះ ដោយព្រះបន្ទូលរបស់ទ្រង់ ដូច្នេះ អ្នកអាចនឹងមានចំណេះសំរាប់គ្រប់គ្រង ហើយនឹងសោយរាជ្យនៅលើផែនដីនេះ ជាមួយនឹងព្រះយេស៊ូវគ្រីស្ទ នេះជាការមួយដ៏អស្ចារ្យ ពិតមែន! ពួកអ្នកទាំងអស់នោះជាផលដំបូង នៅក្នុងគ្រួសារនៃព្រះដ៏ជាព្រះវរបិតា ដោយទទួលការត្រាស់ហៅដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គ។ «...គ្រប់ទាំងប្រទានពរខាងព្រលឹងវិញ្ញាណនៅស្ថានដ៏ខ្ពស់ ...[គឺពីស្ថានសួគ៌ វិញ្ញាណបរិសុទ្ធរបស់ព្រះនៃស្ថានសួគ៌ គឺមកពីព្រះនៃស្ថានសួគ៌ រួមទាំងព្រះបន្ទូលរបស់ទ្រង់ផង] ...តាមដែលទ្រង់បានរើសយើងរាល់គ្នាក្នុងព្រះគ្រីស្ទ តាំង

ពីមុនកំណើតលោកីយមក ប្រយោជន៍ឲ្យយើងរាល់គ្នាបានបរិសុទ្ធហើយឥតកន្លែងបន្ទោសបាននៅចំពោះទ្រង់ ដោយសេចក្តីស្រឡាញ់ ពីព្រោះទ្រង់បានដំរូវយើងរាល់គ្នាទុកជាមុន សំរាប់ឲ្យទ្រង់បានទទួលយើងជាកូនដោយសារព្រះយេស៊ូវគ្រីស្ទ តាមបំណងព្រះហឫទ័យទ្រង់» (អេភេសូរ១:៣-៥)

យើងរាល់គ្នាអាចហៅព្រះអង្គថាជា «ព្រះវរបិតារបស់យើង» ចំពោះខ្ញុំ [Fred] ដរាបណាខ្ញុំនៅតែអធិប្បាយ នឹងបង្រៀនសេចក្តីពិត វាជារឿងដ៏អស្ចារ្យលើសលប់សំរាប់ខ្ញុំ ពិតជាព្រះពរដ៏អស្ចារ្យ! ឥឡូវនេះ ទ្រង់មានបន្ទូលឲ្យយើងរាល់គ្នា បានស្គាល់ពីបំណងព្រះហឫទ័យរបស់ព្រះអង្គ។

អេភេសូរ១:១៣ «ឯអ្នករាល់គ្នា ក៏បានឮព្រះបន្ទូលនៃសេចក្តីពិត...» ដូច្នេះ ចូរយើងត្រឡប់ទៅឯកន្លែងដែលយើងបានចាប់ផ្តើម៖

- ព្រះបន្ទូលរបស់ព្រះ
- ព្រះបន្ទូលនៃសេចក្តីពិត

តើព្រះចាប់ផ្តើមត្រាស់ហៅអ្នកយ៉ាងដូចម្តេច?

- តាមរយៈការបង្ហាញអ្នកពីសេចក្តីពិត
- តាមរយៈការផ្តល់ចំណេះដឹងដល់អ្នក

« ... គឺជាដំណឹងល្អពីសេចក្តីសង្គ្រោះរបស់អ្នករាល់គ្នាដោយសារទ្រង់ដែរ» [មានបទគម្ពីរផ្សេងទៀតបង្ហាញពីការទទួលបុណ្យជ្រមុជទឹក] ... ហើយកាលអ្នករាល់គ្នាបានជឿហើយ នោះទ្រង់ក៏ដៅចំណាំដោយវិញ្ញាណបរិសុទ្ធរបស់ទ្រង់ដែលបានសន្យា»(ខ១៣) ជាវិញ្ញាណបរិសុទ្ធដែលមកពីព្រះដ៏ជាព្រះវរបិតា ហើយទ្រង់ប្រទានដល់អស់អ្នកដែលប្រែចិត្តពីអំពើបាប ទទួលបុណ្យជ្រមុជទឹក នេះហើយការត្រាស់ហៅរបស់ព្រះដ៏ជាព្រះវរបិតា ដើម្បីឲ្យយើងរាល់គ្នាបានធ្វើជាកូនប្រុស-ស្រីរបស់ព្រះអង្គ ហើយក៏ប្រទានឱ្យយើងមានគំនិតរបស់ព្រះយេស៊ូវគ្រីស្ទផងដែរ «ត្រូវតែមានគំនិត គិតដូចជាព្រះគ្រីស្ទយេស៊ូវវិញ» (ភីលីព២:៥)

យើងត្រូវបានញែកចេញពីលោកីយ យើងមិនមែនជារបស់លោកីយទៀតទេ បើយើងនិយាយខាងវិញ្ញាណ លោកីយគេមិនយល់ទេ ពីព្រោះគេមើលមិនឃើញ ហើយពួកគេក៏មិនយល់ពីការដែលព្រះកំពុងធ្វើនៅក្នុងជីវិតរបស់យើងរាល់គ្នាបានដែរ - លើកលែងតែពួកគេគត់សំគាល់ថា យើងជាអ្នករក្សាថ្ងៃឈប់សំរាក ឬថ្ងៃសប្ប័ទ ហើយពួកគេក៏មិនយល់ ថាយើងកំពុងតែធ្វើអ្វីដែរ យើងធ្វើការទាំងអស់នោះ ដើម្បីជួយពួកគេ ឲ្យស្គាល់ព្រះពិត ដែលគ្រប់របស់សព្វសារពើបានកើតមកដោយសារទ្រង់ ពីព្រោះយើងស្រឡាញ់ពួកគេ ហើយពួកគេក៏ជាអ្នកជិតខាងរបស់យើងផងដែរ។ ទោះជាយើងធ្វើយ៉ាងណាក្តី ពួកលោកីយគេនៅតែមិនយល់ ពីព្រោះយើងរាល់គ្នាបានធ្វើដោយអំណាចនៃវិញ្ញាណបរិសុទ្ធ

របស់ព្រះ ដែលព្រះទ្រង់បានបោះត្រាចំណាំយើងរាល់គ្នា។

អេភេសូរ១:១៤ «...ពីដំណើរកេរ្តិ៍អាកររបស់យើងរាល់គ្នា...» ម្យ៉ាងទៀត នេះជាសេចក្តីធានាពីកេរ្តិ៍អាករដែលព្រះបានទិញទុកឲ្យយើង ដែលយើងនឹងទទួលនៅពេលព្រះទ្រង់ប្រោសឲ្យយើងរស់ពីស្លាប់ឡើងវិញ បើសិនជាយើងនៅតែមានជំនឿស្មោះត្រង់ រហូតដល់ចុងបំផុត «តែអ្នកណាដែលកាន់ខ្ជាប់ដរាបដល់ចុងបំផុតវិញ អ្នកនោះនឹងបានសង្គ្រោះ» (ម៉ាថាយ២៤:១៣) ព្រះទ្រង់ប្រទានអ្វីៗគ្រប់យ៉ាងសំរាប់យើង ឲ្យយើងអាចធ្វើគ្រប់ការល្អទាំងអស់បាន។

- ដោយមិនគិតពីការបៀតបៀន
- ដោយមិនគិតពីការលំបាក
- ដោយមិនគិតពីរង់ទុក្ខ ក្នុងការតស៊ូ

ដែលយើងរាល់គ្នាធ្លាប់បានឆ្លងកាត់ការទាំងអស់នោះហើយ។

នៅពេលដែលមនុស្សគ្រប់គ្នាបានបោះបង់ចោលអ្នក ហើយលោកីយស្អប់អ្នក ហើយគ្មាននរណាម្នាក់យកចិត្តទុកដាក់ចំពោះអ្នក ហើយគ្មាននរណាម្នាក់ស្រឡាញ់អ្នក ហើយអ្នកមានអារម្មណ៍ឯកោ ហើយអ្នកត្រូវកាត់ផ្តាច់ពីលោកីយ ហើយអ្វីៗទាំងអស់ គឺវេទនា ហើយអ្នកប្រឈមមុខគ្រប់ការអាក្រក់ទាំងអស់ សូមអ្នកនឹកចាំថា ព្រះទ្រង់ស្រឡាញ់អ្នក! ហើយអ្នកត្រូវដឹងថា ទ្រង់បានប្រទានវិញ្ញាណបរិសុទ្ធរបស់ទ្រង់ដល់អ្នក ១១៤ «...ពីដំណើរកេរ្តិ៍អាកររបស់យើងរាល់គ្នា ទាល់តែបានលោះរបស់កំណាន់ ដែលទ្រង់បានទិញទុកឲ្យយើងនោះ ...[យើងត្រូវបានទិញដោយព្រះលោហិតរបស់ព្រះយេស៊ូវគ្រីស្ទ ដើម្បីឲ្យបានទទួលជីវិតអស់កល្ប ជាកេរ្តិ៍អាករ]... សំរាប់ជាសេចក្តីសរសើរដល់សិរីល្អនៃទ្រង់» (ខ ១៤) ។

នៅក្នុងបទព្រះគម្ពីរឯទៀត ដែលយើងត្រូវរៀន បទគម្ពីរនោះនឹងបង្រៀនយើង ពីអ្វីដែលយើងត្រូវធ្វើ។ សូមមើលទៅគម្ពីរអេភេសូរជំពូក២ សូមមើលពីអ្វីដែលព្រះអម្ចាស់ទ្រង់នឹងធ្វើជាមួយយើង តាមរយៈការហ្វឹកហ្វឺន ដើម្បីឲ្យបានរីកចំរើនក្នុងព្រះគុណ នឹងចំណេះដឹង៖

- តាមរយៈការអធិស្ឋាន
- តាមរយៈការសិក្សាព្រះគម្ពីរ
- តាមរយៈការប្រកបជាមួយបងប្អូនរួមសេចក្តីជំនឿ

មើលតាមវិធីនេះ ចូរក្រឡេកមើលទៅថ្ងៃឈប់សំរាក នឹងគ្រប់ថ្ងៃបុណ្យបរិសុទ្ធ - នេះជាផ្លូវដែលខ្ញុំព្យាយាមក្នុងការរៀបចំ សំរាប់ការបង្រៀន នឹងអធិប្បាយ។ នេះជាឱកាស សំរាប់ចំណេះដឹង ក្នុងការ

សិក្សាពីផ្លូវរបស់ព្រះអម្ចាស់ សំរាប់ជីវិតអស់កល្បជានិច្ច។ នេះមានន័យថា នៅពេលដែលយើងអនុវត្តន៍តាមព្រះបន្ទូលរបស់ព្រះនៅក្នុងជីវិតរបស់យើង ដោយមានវិញ្ញាណបរិសុទ្ធនៃព្រះបិតនៅក្នុងជីវិតរបស់យើងផង នោះយើងនឹងអភិវឌ្ឍន៍គំនិតរបស់ព្រះយេស៊ូវគ្រីស្ទ។ យើងអាចយល់បានថា ព្រះអម្ចាស់ទ្រង់នឹងប្រទានឱ្យយើងបានដូចជារូបអង្គទ្រង់ នៅពេលដែលយើងបានត្រូវប្រោសឲ្យរស់ពីស្លាប់ឡើងវិញ។

ការរក្សាថ្ងៃឈប់សំរាក នឹងថ្ងៃបុណ្យបរិសុទ្ធទាំងប៉ុន្មានរបស់ព្រះ នោះជាថ្ងៃដ៏សំខាន់ ហើយមានអត្ថន័យយ៉ាងជ្រាលជ្រៅ នឹងសំខាន់បំផុត ដែលយើងរាល់គ្នាត្រូវតែកាន់ឲ្យបានខ្ជាប់ខ្ជួន ត្រូវហើយ! យើងត្រូវតែខិតខំប្រឹងសិក្សាព្រះបន្ទូល យើងត្រូវការអ្នកបង្រៀនពីសេចក្តីពិត នឹងអធិប្បាយពីសេចក្តីពិត! ខ្ញុំ [Fred] ត្រូវការអ្នកបង្រៀនពីសេចក្តីពិត ខ្ញុំនឹងដាក់ខ្លួនខ្ញុំជួយគេ ហើយសូមដល់ព្រះអម្ចាស់ទ្រង់ជួយខ្ញុំ ដើម្បីឲ្យខ្ញុំបានលើកទឹកចិត្តអ្នកទាំងនោះ ឲ្យស្គាល់ព្រះបន្ទូលរបស់ទ្រង់ ដែលខ្ញុំអាចនឹងបង្រៀនអ្នក។

ដូច្នេះ សូមអ្នកមើលទៅឯសាសនារបស់លោកីយនេះ នឹងពីសិទ្ធិអំណាច នឹងការគ្រប់គ្រងលើអ្វីៗទាំងអស់ដែលពួកគេមាន ប៉ុន្តែ គេមិនធ្វើតាមព្រះហឫទ័យនៃព្រះទេ ហើយពួកគេក៏នៅឆ្ងាយពីអ្វីដែលព្រះទ្រង់សព្វព្រះទ័យចង់បានផង។ ព្រះទ្រង់មានរង្វាន់ដ៏ធំសំរាប់យើង! នេះហើយជាមូលហេតុដែលព្រះទ្រង់ត្រាស់ហៅយើង។

ឥឡូវនេះ សូមកត់សំគាល់ពីអ្វីដែលព្រះទ្រង់នឹងធ្វើនៅក្នុងពួកជំនុំអេភេសូរ ២:៨ «ដ្បិតគឺដោយព្រះគុណដែលអ្នករាល់គ្នាបានសង្គ្រោះ ...[ដោយព្រះគុណ សេចក្តីមេត្តាករុណា សេចក្តីស្រឡាញ់ របស់ព្រះ ដែលទ្រង់បានត្រាស់ហៅ អត់ទោសបាប ជួយឲ្យអាចប្រែចិត្ត ប្រទានវិញ្ញាណបរិសុទ្ធរបស់ទ្រង់មកយើង ទាំងអស់នេះ គឺនៅក្នុងព្រះគុណ]... ដោយសារសេចក្តីជំនឿ ហើយសេចក្តីនោះក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ» (៦៨)

ដូច្នេះ មានមនុស្សជាច្រើនបានចោទប្រកាន់យើង ថាយើងរក្សាបញ្ញត្តិរបស់ព្រះ ព្យាយាមប្រព្រឹត្តតាមបញ្ញត្តិ ដើម្បីទទួលបានសេចក្តីសង្គ្រោះ។ គ្មានផ្លូវណាដែលអ្នកអាចទទួលបានសេចក្តីសង្គ្រោះនោះទេ-សេចក្តីសង្គ្រោះ គឺជាអំណោយទានរបស់ព្រះ ដែលប្រទានមកមនុស្សដោយសារព្រះគុណទ្រង់។ យើងរក្សាបញ្ញត្តិរបស់ព្រះ ដើម្បីឲ្យយើងអាចមានគំនិតរបស់ព្រះយេស៊ូវគ្រីស្ទ យើងរក្សាថ្ងៃឈប់សំរាក ឬថ្ងៃសប្ប័ទ នឹងថ្ងៃបុណ្យបរិសុទ្ធ ដើម្បីទទួលការអប់រំខាងវិញ្ញាណ ឲ្យបានត្រឡប់ជាកូនប្រុស-ស្រីរបស់ទ្រង់... ក៏មិនមែនដោយការប្រព្រឹត្តដែរ ... [យើងមានការងារត្រូវធ្វើ] ... ក្រែងអ្នកណាអួតខ្លួន» [នេះមិនមែនមានការប្រកួតប្រជែងនៅពេលមានជីវិតរស់ឡើងវិញនោះទេ ខ្ញុំគឺជាមនុស្សដែលបានរកឃើញព្រះគ្រីស្ទមុនគេ ប្រសិនបើអ្នកមិនជឿ សូមអ្នកត្រឡប់ទៅសិក្សាគម្ពីរយ៉ូបវិញ]...ដ្បិតយើងរាល់គ្នា

ជាស្នាដៃ...[យើងជាស្នាព្រះហស្តរបស់ព្រះ]...ដែលបានបង្កើតឡើងនៅក្នុងព្រះគ្រីស្ទយេស៊ូវ ... [ព្រះគ្រីស្ទស្ថិតនៅក្នុងយើង ដោយវិញ្ញាណរបស់ទ្រង់ ទាំងប្រទានគំនិតរបស់ទ្រង់មកយើងផង]...សំរាប់ការល្អ...» (អេភេសូរ២: ៩-១០) ។

- សេចក្តីស្រឡាញ់ សេចក្តីជំនឿ សេចក្តីសុខ សេចក្តីសង្ឃឹម សេចក្តីអំណរ នឹងការបេះត្រួតត្រាចិត្ត
- «អំពើល្អ» ការរក្សាបទបញ្ញត្តិរបស់ព្រះ ដូចដែលទ្រង់បានបង្គាប់
- «អំពើល្អ» ការស្រឡាញ់អ្នកជិតខាង ដូចខ្លួនឯង
- « អំពើល្អ» ការស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង ដូចជាព្រះគ្រីស្ទបានស្រឡាញ់យើង

« ...ដែលទ្រង់បង្កើតក្នុងព្រះគ្រីស្ទយេស៊ូវ ... [បន្ទាប់ពីអ្នកបានទទួលវិញ្ញាណបរិសុទ្ធ ពីព្រះដ៏ជាព្រះវរបិតា ហើយវិញ្ញាណបរិសុទ្ធរបស់ទ្រង់កំពុងធ្វើការក្នុងអ្នក ដើម្បីបង្កើតអ្នកនៅក្នុងព្រះគ្រីស្ទ នឹងរៀបចំអ្នកសំរាប់ការរស់ពីស្លាប់ឡើងវិញ]...សំរាប់ការល្អ ដែលព្រះបានរៀបចំជាមុន ឲ្យយើងរាល់គ្នាប្រព្រឹត្តតាម» (១១០) នោះហើយជារបៀបដែលព្រះទ្រង់ធ្វើការ ពិតជារឿងដ៏អស្ចារ្យណាស់ មែនទេ? មែនហើយ!

## សូមបន្តសិក្សា ទៅមេរៀនជ្រមុជទឹក ទី៤ បន្ថែមទៀត!

បទគម្ពីរដកស្រង់ពីព្រះគម្ពីរបរិសុទ្ធ ឆ្នាំ១៩៥៤, ១៩៦២

បទគម្ពីរយោង:

១. ម៉ាថាយ ១៦:១៣-១៨
២. លូកា ២៤:៤៤-៤៨
៣. កិច្ចការ ១:៤-៨
៤. ម៉ាថាយ ២៨:១៨-២០
៥. ២ថែស្សាឡូនីច ២:៧
៦. យ៉ូហាន ១៤:១៥-២៤
៧. យ៉ូហាន ១៧:១៧
៨. ១យ៉ូហាន ២:២១-២៤
៩. យ៉ូហាន ៦:៤៤-៤៥
១០. រ៉ូម ១០:១៤
១១. ម៉ាថាយ ៧:៧-៨
១២. ហោហ្វាយ ៩:៧-៨
១៣. យ៉ូហាន ៤:២០-២៤
១៤. វិវរណៈ ១:៤
១៥. វិវរណៈ ៣:១
១៦. ចោទិយកថា ៣០:១៩
១៧. វិវរណៈ ៤:៥
១៨. វិវរណៈ ៥:៦
១៩. ២របាក្សត្រ ១៥:១២-១៦
២០. ២របាក្សត្រ ១៦:៧-៩

២១. ម៉ាថាយ ២២:១៤
២២. រ៉ូម ៦:៤
២៣. សុភាសិត ១៦:២៥
២៤. កិច្ចការ ២:៣៦-៤១
២៥. យ៉ូហាន ១៥:៩-១៦
២៦. រ៉ូម ៨:៦-១១
២៧. វិវរណៈ ៣:១៥-១៦
២៨. រ៉ូម ៦:-១៥
២៩. លូកា ១៤:២៦-២៧
៣០. រ៉ូម ៦:៥-៨
៣១. ភីលីព ២:៥
៣២. ម៉ាថាយ ២៤:១៣-១៤
៣៣. អេភេសូរ ១:៣-៥, ១៣-១៤
៣៤. អេភេសូរ ២:៨-១០, ១៣-១៤

បទគម្ពីរមិនបានចម្លង:

ម៉ាថាយ ២២
រ៉ូម ២
ទំនុកដំកើង ២២
អេសាយ ៥៣
យ៉ូហាន ២

# មើលការត្រាស់ហៅរបស់អ្នក

សព្វថ្ងៃនេះ មនុស្សជាច្រើនកំពុងតែសួរ តើពិភពលោកមានបញ្ហាអ្វីខ្លះ? បញ្ហារបស់ពិភពលោក គឺការបង្ហាត់បង្រៀនដោយគ្មានស្តង់ដារត្រឹមត្រូវ អ្នកមិនត្រូវបង្រៀនអ្វីដែលគ្មានតម្លៃនោះទេ។ ឥឡូវយើងត្រូវមានការអប់រំឲ្យប្រសើរជាងពីមុន បើមិនដូច្នោះទេ អ្នកមិនអាចបង្រៀនដោយគ្មានស្តង់ដារត្រឹមត្រូវនោះបានឡើយ។ អ្នកមិនអាចបង្រៀនអ្វីដោយគ្មានតម្លៃទេ ឯសាលារៀនរដ្ឋ ត្រូវតែបង្រៀនអ្វីដែលមានតម្លៃសំរាប់សិស្ស នឹងនិស្សិត គ្រូមិនអាចនិយាយទៅកាន់សិស្សថា អ្វីដែលត្រឹមត្រូវ នោះខុសទេ ហើយអ្វីដែលខុស នោះទើបត្រឹមត្រូវវិញ។ អ្នកក៏មិនអាចធ្វើអ្វីនៅក្នុងសង្គមបានទេ ពីព្រោះសង្គមបានបានឈានទៅដល់ចំណុច ដែលនិយាយថា ការដែលត្រឹមត្រូវនោះវាខុសទេ ហើយអ្វីដែលខុស នោះទើបត្រឹមត្រូវវិញ។ អស់អ្នកដែលធ្វើខុស នឹងអស់អ្នកដែលធ្វើការអាក្រក់ នោះអ្នកមិនអាចថ្កោលទោសគេបានទេ។ សូមបើកទៅគម្ពីរអេសាយជំពូក៥ ពីព្រោះព្រះទ្រង់មានបន្ទូល អំពីពេលវេលា ហើយនឹងទំទាយអំពីគ្រាដូចដែលយើងរស់នៅសព្វថ្ងៃនេះ ជាហេតុដែលបណ្តាលឱ្យមានការលំបាកជាច្រើន សូម្បីតែពួកអ្នកដែលព្រះបានត្រាស់ហៅ ក៏មានការលំបាកណាស់ដែរ គម្ពីរអេសាយ៥:២០ «វេទនាដល់ពួកអ្នក ដែលរាប់សេចក្តីអាក្រក់ថា ជាល្អ ហើយសេចក្តីល្អថាជាអាក្រក់វិញ...» វាពិតណាស់ យើងដឹងថា គឺជាអ្នកដឹកនាំ នឹងអ្នកដឹកនាំគ្រប់ប្រភេទ ទាំងអស់ដែលបានប្រព្រឹត្តិការនោះ។ ឥឡូវនេះ អ្នកមានមនុស្សជាច្រើនកំពុងចំរើនឡើងនៅក្នុងសង្គម ពីជំនាន់មួយ ទៅជំនាន់មួយទៀត មានរហូតដល់ទៅ៣ នឹង២ ហើយ៥ ជំនាន់ផង ដែលមិនស្គាល់អ្វីទាំងអស់ អំពីព្រះពិត។ វាជារឿងគួរឱ្យហួសចិត្ត ពីព្រោះព្រះគម្ពីរត្រូវបានបោះពុម្ពផ្សាយ លើសច្រើនជាងសៀវភៅ ឯទៀត។ ហើយក៏មានការសិក្សាដ៏ច្រើនបំផុតនៅលើលោកីយនេះ ប៉ុន្តែ មនុស្សគេបដិសេធព្រះ ដោយព្រោះអ្នកដឹកនាំ របស់លោកីយនេះ គម្ពីរអេសាយ៣:១២ «ឯរាស្ត្ររបស់អញ គឺជាកូនក្មេងដែលសង្កត់សង្កិនគេ ...»គ្រប់ពេលវេលានៅក្នុងប្រវត្តិសាស្ត្រ គឺវាជាការពិតជាងពេលណាៗទាំងអស់ ហេតុអ្វី? ពីព្រោះគ្រូបង្រៀនសិស្សថា ឪពុក-ម្តាយ គឺជាសត្រូវ ហើយឪពុកម្តាយជាអ្នកខុស! កម្មវិធីសិក្សាទាំងមូល ជាល្ខោន នឹងទស្សនៈវិជ្ជារបស់សាលា គឺយើង [គ្រូ] ត្រូវតែជួយសង្គ្រោះកុមារពីឪពុកម្តាយរបស់ពួកគេ «ដូច្នេះ ឪពុកម្តាយគ្មានការចូលរួមជាមួយគ្រូ នឹងសាលារៀនទេ ពួកគ្រូៗ និយាយទៅឪពុក-ម្តាយថា សូមអញ្ជើញមកចូលរួមគ្នាជាមួយ PTA [Parents Teachers Association, សមាគមមាតាបិតា នឹងគ្រូ] យើងចង់ស្តាប់អ្នក ប៉ុន្តែ ពួកគ្រូបង្រៀនទាំងអស់នោះ មិនដែលស្តាប់ ហើយមិនដែលធ្វើតាមការសូមរបស់មាតាបិតាសិស្សនោះទេ ពីពីព្រោះពួកស្រីៗ ជាអ្នកដឹកនាំ «...ហើយគឺជាពួកស្រីៗ ដែលមានអំណាចត្រួតត្រាលើគេ...» នោះជាការពិត គ្មានអ្វីធ្វើឲ្យធុញថប់ លើសជាងស្ត្រីត្រួតត្រាលើបុរសនោះទេ «... ឱរាស្ត្ររបស់អញអើយ ពួកអ្នកនាំ

មុខឯង គេនាំឲ្យវង្វេងក៏បំផ្លាញផ្លូវដែលឯងដើរដែរ» (១១២)

គឺជាអ្នកដឹកនាំ គ្រូបង្រៀន អ្នកនយោបាយ និងជាពិសេសអ្នកដឹកនាំសាសនាទាំងអស់ ដែលនាំឲ្យវង្វេង! គម្ពីរអេសាយ៥:២០ «វេទនាដល់ពួកអ្នក ដែលរាប់សេចក្ដីអាក្រក់ថាជាល្អ ហើយសេចក្ដីល្អ ថាជាអាក្រក់វិញ ជាពួកអ្នកដែលយកសេចក្ដីងងឹតជាពន្លឺ ហើយយកពន្លឺជាងងឹត ក៏យកសេចក្ដីជូរចត់ជាផ្អែម ហើយយកផ្អែមជាជូរចត់វិញ វេទនាដល់ពួកអ្នកដែលរាប់ខ្លួនថា ជាមានប្រាជ្ញា ហើយស្មានថាខ្លួនគេមានគំនិតស្រួច វេទនាដល់ពួកអ្នកដែលប៉ិនប្រសប់នឹងផឹកស្រាទំពាំងបាយជូរ នឹងអ្នកដែលខ្លាំងពូកែ ក្នុងការលាយគ្រឿងស្រវឹង» (ខ ២០-២២)

គោលការដូចគ្នានេះ អាចអនុវត្តន៍ចំពោះគ្រឿងញៀន ហើយពួកគេនៅតែព្យាយាមធ្វើឱ្យគ្រឿងញៀន មានភាពស្របច្បាប់ ហើយអ្នកអាចស្រមៃឃើញថា តើនឹងមានអ្វីកើតឡើងចំពោះសង្គមនេះៗ យើងកំពុងរងការបៀតបៀន ហើយអ្នកខ្លះទៀត ហៅថាជាសង្គ្រាមវប្បធម៌ ពិតហើយ នេះវាលើសជាងសង្គ្រាមវប្បធម៌ទៅទៀត គឺអារក្សសាតាំងវាកំពុងដើរក្រវែល ស្វែងរកអ្នកដែលវាអាចនឹងត្របាក់លេបបាន ហើយយើងរាល់គ្នាដែលជារាស្ត្ររបស់ព្រះ ត្រូវតែរស់នៅក្នុងលោកីយដ៏សែនអាក្រក់នេះ យើងត្រូវតែរកផ្លូវយ៉ាងដូចម្ដេច ដើម្បីឲ្យយើងអាចរស់នៅបាន?

ខ្ញុំសូមនិយាយថា «ស្រាខ្លាំងមានជាតិអាល់កុលច្រើន» កុំគិតថាពួកគេមិនដឹងពីគ្រឿនញៀនដែលហៅថាអាភៀននោះ ប្រហែលជាពួកគេមិនដឹងអំពីអ្វី ដែលយើងហៅថា «ហេរ៉ូអ៊ីន» ដែលមានសព្វថ្ងៃនេះទេៗ ពីដំនាន់ដើមពួកគេមិនមានសម្ភារៈចម្រាញ់វា ដូចដែលបានធ្វើសព្វថ្ងៃនេះទេ ប៉ុន្តែ ពួកគេពិតជាមានកញ្ឆាៗ កញ្ឆាវាជាគ្រឿងញៀនមួយប្រភេទ ចាស់ជាងគ្រឿងញៀនឯទៀតៗ នៅក្នុងប្រវត្តិសាស្ត្រដែលមនុស្សជក់ៗ តើអ្នកគិតថាប្រជាជននៅអាស៊ីអាគ្នេយ៍ គ្រាន់តែដាំដំណាំដើមអាភៀន ឲ្យរីកលូតលាស់រហូតដល់មានថ្ងៃមួយ ស្រាប់តែមាននរណាម្នាក់សំរេចថា ត្រូវដកអាភៀនចេញ! អាភៀនវាមានអាយុអស់ជាច្រើនសតវត្សរ៍មកហើយ វាអាចមានកំឡាំងជាងថ្នាំ ដទៃទៀតៗ តើអ្នកគិតថាការលោកលន់ចង់បានគ្រឿងញៀនដោយមនុស្សខាងសាច់ឈាម សព្វថ្ងៃនេះ តើមានភាពខុសប្លែកគ្នា ពីមនុស្សខាងសាច់ឈាមពីសម័យនោះមុនឬទេ? ពិបាកយល់ណាស់! គឺពិតជាពិបាកនឹងយល់ណាស់!

អេសាយ៥:២៣-២៤ «ជាពួកអ្នកដែលស៊ីសំណូក... [សូមឲ្យអ្នកគ្រាន់តែក្រឡេកមើលទៅឯរដ្ឋសភា តៅក្រម ក្រុមអ្នកដឹកនាំសង្គម]... ដើម្បីរាប់មនុស្សអាក្រក់ថាជាសុចរិតវិញ ហើយដកសេចក្ដីសុចរិតរបស់មនុស្សសុចរិតចេញ ហេតុដូច្នោះ បែបដូចជាអណ្ដាតភ្លើងឆេះបន្សុសជញ្ជ្រាំង ហើយស្មៅក្រៀមស្រុតចុះក្នុងភ្លើងយ៉ាងណា នោះឫសរបស់អ្នកទាំងនោះ នឹងបានដូចជាអ្វីដែលពុករលួយ ហើយផ្ការបស់គេនឹងហុយឡើង ដូចជាធូលីយ៉ាងនោះដែរ ដ្បិតគេបានលះចោលបញ្ញត្តច្បាប់របស់ព្រះយេហូវ៉ានៃពួក

ពលបរិវារ ព្រមទាំងមើលងាយចំពោះព្រះបន្ទូលរបស់ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែលផង» (ខ២៣-២៤)។ សូម្បីតែមនុស្សដែលចង់ធ្វើល្អ ក៏មិនដឹងថាពិតជាមានតម្លៃ នឹងធ្វើល្អដែរនោះទេ បន្ទាប់មក គេដូចជាត្រីដែលឡើងតាមខ្សែទឹក ដោយមិនដឹងថាមានទឹកសែសសល់តិចតួចណាស់ សំរាប់រស់នៅ ពីព្រោះទឹកទាំងអស់នោះ នឹងហូរចុះទៅយ៉ាងរហ័ស ដោយមិនមាននៅសល់ទៀតឡើយ។

ឥឡូវនេះ នឹងមិនមានការផ្លាស់ប្តូរនៅក្នុងសង្គមទេ ទាល់តែមានការផ្លាស់ប្តូរអ្វីៗ ដែលខ្ញុំទើបតែបានអាននៅខាងលើនេះ។ កាលណាសង្គមគ្រប់គ្រងដោយច្បាប់របស់ព្រះ ហើយអ្នកដឹងពិតប្រាកដថា វានឹងមិនកើតឡើងនៅក្នុងជីវិតរបស់យើងនេះទេ ការនោះនឹងកើតមានឡើង នៅពេលដែលព្រះយេស៊ូវគ្រីស្ទយាងត្រឡប់មកផែនដីនេះវិញ! គ្មានចលនានយោបាយ គ្មានអង្គការសាសនាណាមួយមានអំណាចនឹងផ្លាស់ប្តូរអ្វី ដែលព្រះបានដាក់ព្រះហស្តរបស់ទ្រង់ធ្វើនោះទេ! ការនោះនឹងកើតឡើងតាមផែនការរបស់ទ្រង់ បើយើងក្រឡេកមើលជុំវិញ យើងឃើញថាសង្គមទាំងអស់កាន់តែយ៉ាប់យ៉ឺនៗទៅ។

សូមបើកទៅគម្ពីររ៉ូមជំពូក១ ហើយយើងនឹងឃើញម្តងទៀត ពីការរំលឹកឡើងវិញ នៅពេលដែលសង្គមណាមួយបដិសេធព្រះ សង្គមនោះបានប្រគល់ខ្លួនទៅឱ្យអាកំណាច ហើយអ្វីៗ ទាំងអស់នឹងកើតឡើង តាមផែនការរបស់វា។ សូមក្រឡេកមើលទៅសហភាពសូវៀត ពួកគេបានប្រកាសថា ពួកគេនឹងនាំមកនូវអេកូឡូស៊ីនិយម (បរិស្ថានវិទ្យា) ដែលជាឈ្មោះដ៏មានឥទ្ធិពលមួយទៀតសំរាប់លទ្ធិកុម្មុយនិស្តនឹងដល់មនុស្សគ្រប់គ្នានៅសហភាពសូវៀត។ ពួកគេនឹងនាំមកនូវទ្រព្យសម្បត្តិ ពួកគេនឹងនាំឲ្យកម្មករទាំងអស់ធ្វើការជាមួយគ្នា ហើយយើងនឹងមានសង្គមនិយមដ៏អស្ចារ្យមួយ។ ពួកគេកំពុងទទួលទោសពីការបដិសេធព្រះ ពួកគេទទួលទោសមែន ពីព្រោះគ្មានប្រជាជាតិណាអាចរស់រាន ហើយចំរើនបាននៅពេលដែលពួកគេបដិសេធព្រះនោះទេ! ព្រះទ្រង់មានបន្ទូលប្រាប់ថា «មានពរហើយនគរណាដែលយកព្រះយេហូវ៉ាទុកជាព្រះរបស់ខ្លួន...» សូម្បីតែលោកហ្គ្រូបាឆូវ (ប្រធានាធិបតី សហភាពសូវៀត) ត្រូវតែដោះមួក ហើយឱនក្បាលនៅត្រង់ជើងរបស់សម្តេចប៉ាប របស់កាតូលិក ហើយទទួលស្គាល់ថា សូម្បីតែគ្រីស្ទសាសនាក្លែងក្លាយរបស់រ៉ូម៉ាំងកាតូលិក ដែលមិនជឿលើព្រះពិតសោះ នោះប្រសើរជាងអ្វីដែលពួកគេមាននៅសហភាពសូវៀតទៅទៀត បន្ទាប់មកមានរដ្ឋប្រហារផ្តាច់ព្រ័ត្រចុងក្រោយលើពួកសូវៀតជាឧប្បត្តិហេតុ នៃការបដិសេធព្រះ។ សហភាពសូវៀតកំពុងតែធ្លាក់ចុះ គ្រប់ប្រជាជាតិទាំងអស់ ក៏ស្ថិតក្នុងកម្រិតដូចគ្នានៃការបែកបាក់ នឹងការចុះខ្សោយ ដោយសារតែរឿងដូចគ្នា [បដិសេធព្រះ] នៅសហរដ្ឋអាមេរិក នឹងសង្គមលោកខាងលិច ដែលមានចំណេះដឹង អំពីព្រះ តើពួកយើងកំពុងធ្វើអ្វីហ្នឹង?

- យើងកំពុងបដិសេធព្រះ!
- យើងកំពុងបែរខ្នងទៅឯព្រះ!

- យើងកំពុងតែដើរថយក្រោយ!

នេះជាដើមហេតុនៃអ្វីៗទាំងអស់ គម្ពីររ៉ូម១:១៨ «ពីព្រោះសេចក្ដីក្រោធរបស់ព្រះ បានសំដែងមកពីស្ថានសួគ៌ ទាស់នឹងគ្រប់ទាំងសេចក្ដីទមិលល្មើស...[ភាពមិនគោរពព្រះ នឹងអស់ទាំងទទួលការកែតម្រង់ ការខ្លះត្រូវដាក់ទណ្ឌកម្ម ការខ្លះទៀតត្រូវទទួលសេចក្ដីក្រោធ! ឥឡូវនេះគ្រាន់តែបង្ហាញឲ្យអ្នកឃើញ-នៅពេលបន្តិចទៀត ខ្ញុំនឹងនិយាយ នៅពេលយើងចូលទៅក្នុងសេចក្ដីបង្រៀនបោកបញ្ឆោត នៃគំនិតរបស់មនុស្ស ការពិតមួយដែលគួរឱ្យចាប់អារម្មណ៍ណាស់ ពីការដែលទើបតែបានកើតឡើង នៅពេលថ្មីៗនេះ] ...នឹងសេចក្ដីទុច្ចរិតរបស់មនុស្ស ដែលគេបង្ខាំងសេចក្ដីពិត ដោយសេចក្ដីទុច្ចរិត... សេចក្ដីដ៏សំខាន់ណាស់ សំរាប់អស់អ្នក ដែលស្គាល់ព្រះគម្ពីរ ពេលយើងឮសេចក្ដីពិត! តើសេចក្ដីពិតនោះមាននៅក្នុងចិត្ត ក្នុងគំនិតរបស់អ្នកយ៉ាងដូចម្ដេច? ព្រះបន្ទូលរបស់ព្រះគឺជាសេចក្ដីពិត! ព្រះយេស៊ូវទ្រង់មានបន្ទូលថា «... ឯសេចក្ដីពិត គឺជាព្រះបន្ទូលរបស់ទ្រង់» ព្រះយេស៊ូវក៏មានបន្ទូលថា ទ្រង់ជាសេចក្ដីពិត ទ្រង់ជាផ្លូវ ពួកគេបង្ខាំងព្រះបន្ទូលរបស់ព្រះដោយសេចក្ដីទុច្ចរិត... ព្រោះការអ្វីដែលអាចនឹងស្គាល់ពីព្រះបាន នោះបានសំដែងមកក្នុងពួកគេហើយ ដោយព្រះទ្រង់សំដែងការនោះ ឲ្យគេឃើញជាក់ ដ្បិតអ្វីៗរបស់ទ្រង់ដែលរកមើលមិនឃើញ តាំងពីកំណើតលោកីយមក ទោះទាំងព្រះចេស្ដា ដ៏នៅអស់កល្បជានិច្ច នឹងនិស្ស័យជាព្រះរបស់ទ្រង់ នោះឃើញច្បាស់វិញ ដោយពិចារណាយល់របស់ទាំងប៉ុន្មានដែលទ្រង់បានបង្កើតមក» ពួកគេ «...បង្ខាំងសេចក្ដីពិតដោយសេចក្ដីទុច្ចរិត» (ខ១៨) «ពីព្រោះការអ្វីដែលអាចនឹងស្គាល់ពីព្រះបាន... [ព្រះបានសម្ដែង នឹងបានបង្ហាញ]...នោះបានសំដែងមកក្នុងពួកគេហើយ... [គ្រប់របស់ទាំងអស់ដែលព្រះទ្រង់បង្កើត]...ឃើញ តាំងពីកំណើតលោកីយមក ទោះទាំងព្រះចេស្ដាដ៏នៅអស់កល្បជានិច្ច នឹងនិស្ស័យជាព្រះរបស់ទ្រង់ នោះឃើញច្បាស់វិញ ដោយពិចារណា យល់របស់ទាំងប៉ុន្មានដែលទ្រង់បានបង្កើតមក» (ខ១៩-២០)។ ខ្ញុំតែងតែត្រូវពួកអ្នកតារាវិទូទាំងនោះ ផាត់ចេញ ពួកគេកំពុងតែព្យាយាមដូចជាមនុស្សឆ្កួត បានដាក់ឧបករណ៍ជាច្រើននៅលើមេឃ ដូចជាកែវយឺត [កែវពង្រីកឲ្យធំ] ធំជាងមុន នឹងល្អប្រសើរជាងមុន ដើម្បីមើលឲ្យឃើញអ្វីៗនៅលើមេឃ គេបានរកឃើញតារាមានរាប់ពាន់លាន ហើយគេសំឡឹងមើលទៅលើមេឃ រួចប្រកាសថា ពួកគេបានរកឃើញចំណុចកណ្ដាលនៃពិភពលោក តែខ្ញុំសង្ស័យថា ពួកគេមិនដឹងហេតុអ្វី បានជាមានតារា រាប់ពានលាន នៅលើមេឃនោះទេ គឺព្រះទ្រង់បានបង្ហាញពួកគេ ពីភាពអស្ចារ្យនៃការបង្កបង្កើតរបស់សព្វសារពើ នឹងសិរីរុងរឿងរបស់ទ្រង់ ប៉ុន្តែ ពួកគេធ្វើប្រងើយកន្តើយ មិនអើពើពីការទាំងនោះទេ ដូច្នេះ ការផ្ដន្ទាទោសនឹងកើតមានឡើងដល់ពួកគេ ហើយចុងបំផុតនឹងដល់សង្គម ការទាំងនេះបង្ហាញថា «ទោះទាំងព្រះចេស្ដាដ៏នៅអស់កល្បជានិច្ច នឹងនិស្ស័យជាព្រះរបស់ទ្រង់នោះបានឃើញច្បាស់...» ដូច្នេះ ពួកគេគ្មានលេសនឹងគេចវេសបានឡើយ។ នៅពេលពេលខ្ញុំមានការសិក្សា ខ្ញុំត្រូវបានគេបង្រៀនពីទ្រឹស្ដី នៃការវិវត្តន៍នេះដែរ។

ព្រះទ្រង់នឹងប្រាប់គេថា ពួកគេគួរតែដឹងនៅពេលគេក្រឡេកមើលទៅលើមេឃ ឃើញផ្កាយ ទាំងអស់នោះ ហើយគេបានឃើញភពទាំងនោះហើយ គេបានឃើញរបស់ដ៏អស្ចារ្យទាំងអស់នោះ ដែលគេមើលឃើញជាមួយនឹងបច្ចេកវិទ្យាដែលគេមាន ១២១ «ព្រោះកាលគេបានស្គាល់ព្រះ នោះគេមិនបានដំកើងទ្រង់ ទុកជាព្រះទេ...[ព្រះត្រូវតែបានទទួលការសរសើរដំកើង នឹងទទួលសិរីល្អ ពីព្រោះទ្រង់ជាព្រះដែលបង្កើតរបស់សព្វសារពើ]... ក៏មិនដឹងគុណទ្រង់ដែរ គេកើតមានគំនិតឥតប្រយោជន៍វិញ ហើយចិត្តគេដែលឥតយោបល់ ក៏បានត្រឡប់ជាងងឹតទៅ»

- នៅពេលដែលគេមិនស្គាល់ព្រះ
- នៅពេលគេមិនលើកតម្កើងសិរីរុងរឿងរបស់ព្រះ
- នៅពេលដែលគេមិនអរគុណព្រះ
- នៅពេលដែលគេមិនថ្វាយសិរីរុងរឿងដល់ព្រះ

ដើម្បីយល់ពីការទាំងអស់នេះ អ្នកចាំបាច់ត្រូវតែដឹងអំពីបទបញ្ញត្តិរបស់ព្រះអម្ចាស់ បញ្ញត្តរបស់ព្រះអម្ចាស់នឹងជួយអ្នកឲ្យយល់ពីចរិយាល្អ ហើយអាចនឹងទទួលស្គាល់ព្រះបាន ហើយបន្ទាប់មកអ្នកនឹងមិនមានការលំបាកច្រើនមកលើខ្លួនអ្នកទេ។ ប៉ុន្តែ នៅពេលដែលមនុស្សបដិសេធព្រះ ហើយបដិសេធព្រះបន្ទូលរបស់ព្រះ នឹងមានសេចក្តីងងឹតកើតឡើង នេះគឺជាគោលការនយោបាយរបស់លោកីយនាពេលបច្ចុប្បន្ននេះ។ ដូច្នេះ ពួកគេបានទទួលការផ្តន្ទាទោសមួយ បន្ថែមលើការផ្តន្ទាទោសមួយទៀតទៅលើសង្គមទាំងមូលដែរ គម្ពីររ៉ូម១:២២ «គេអួតខ្លួនថា មានប្រាជ្ញា បានជាគេត្រឡប់ទៅជាល្ងង់ល្ងើវិញ គឺគេបំផ្លាញសិរីល្អនៃព្រះដែលមិនចេះខូច ឲ្យទៅជារូប មើលទៅដូចជាមនុស្ស ដែលតែងតែខូចវិញ ហើយដូចជាសត្វស្លាប សត្វជើងបួន នឹងសត្វលូនវារ»(១២២-២៣)។ សព្វថ្ងៃនេះ យើងមានអ្វីៗទាំងអស់ ដើម្បីជួយសង្គ្រោះសត្វពាហនៈ ប៉ុន្តែ គេបានសំឡាប់ទារកដោយពន្លូតកូនវិញ គឺគេនាំឲ្យមានសេចក្តីវិនាសទាំងស្រុង ធ្វើឲ្យសង្គមក្រឡាប់ចាក់ ចិត្តល្ងង់ល្ងើ ហើយឆោតល្ងង់ ឥតតម្លៃ ឥតប្រយោជន៍ នឹងល្ងង់ខ្លៅ តើវានឹងដឹកនាំគេនៅឯណា? ព្រះអម្ចាស់ទ្រង់នឹងធ្វើការណាមួយ ការនោះមិនមែនគ្រាន់តែកើតឡើង ដើម្បីឲ្យគ្រាន់តែកើតឡើងនោះទេ ប៉ុន្តែ មានចំណុចមួយ ដែលព្រះបានធ្វើអន្តរាគមន៍ ហើយទ្រង់បណ្តាលឱ្យមានអ្វីមួយកើតឡើង គឺព្រះទ្រង់បានប្រទានឱ្យពួកគេទទួលអំពើអាក្រក់ ជារបស់ផងគេ ១២៤ «ហេតុនោះបានជាព្រះទ្រង់ប្រគល់គេទៅឯសេចក្តីស្មោកគ្រោក តាមចិត្តចិត្តគេប្រាថ្នាចង់បាន ឲ្យបានបង្អាប់ដល់រូបកាយគេទៅវិញទៅមក» នៅពេលយើងបដិសេធព្រះ នោះយើងនឹងប្រឈមមុខទៅនឹងអំពើអាក្រក់ ហើយនឹងការវង្វេងស្មារតី ពីផ្លូវភេទ ដោយប្រុសរួមភេទ នឹងប្រុស ហើយវាងមនុស្សស្រីដូចគ្នា នេះហើយជាកត្តាចុះថោក នៃគុណធម៌នៅ ក្នុងសង្គមមនុស្ស

១២៥ «គេបានផ្លាស់សេចក្តីពិតនៃព្រះ ឲ្យទៅជាសេចក្តីកុតករវិញ... [ពិតណាស់ លោកគ្រូបង្រៀនព្រះគម្ពីរ ជាអ្នកប្តូរសេចក្តីពិតរបស់ព្រះទៅជាសេចកក្តីកុតករ គេបង្រៀន ថាអ្នកមិនចាំបាច់កាន់តាមសេចក្តីពិតទៀតទេ គេ [គ្រូគង្វាល] បង្រៀនថា ព្រះនៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺខុសពីព្រះដែលយើងមានសព្វថ្ងៃនេះ នេះគឺជាការកុហកទាំងស្រុង!]... ក៏គោរពខ្លាច ហើយគោរពបូជាដល់របស់ដែលកើតមក ជាជាងដល់ព្រះ ដែលបង្កើតរបស់ទាំងនោះមក ជាព្រះដែលមានព្រះពរអស់កល្បជានិច្ច អាម៉ែន ដោយហេតុនោះ បានជាព្រះទ្រង់ប្រគល់គេ ទៅក្នុងសេចក្តីរំជួលដ៏អាស្រូវបាវាយ ដ្បិតទាំងពួកស្ត្រីៗរបស់គេ ក៏បានផ្លាស់ប្រែទំនៀមទំលាប់ពីបវេណីចេញ ឲ្យខុសពីធម្មតា ហើយពួកប្រុសៗក៏បែបដូច្នោះដែរ គេបានលះចោលទំនៀមទំលាប់របស់ស្ត្រីពីបវេណីចេញ ហើយបង្កើតឲ្យមានសេចក្តីសំរើបពោលពល ដល់គ្នាទៅវិញទៅមក គឺពួកប្រុសប្រព្រឹត្តនឹងប្រុសៗ ជាការអាក្រក់ជួជាតិនោះ គេក៏ទទួលរង្វាន់ចំពោះខ្លួនគេ ដែលសំណាំនឹងសេចក្តីកំហុសរបស់ខ្លួន» (១២៥-២៧) កំហុសចុងក្រោយរបស់គេ គឺជម្ងឺអេដស៍ ជម្ងឺអេដស៍បានកើតឡើង ដោយសារអ្នកដឹកនាំសាសនាទាំងអស់នោះៗ តើមានបងប្អូនប៉ុន្មាននាក់បានឮ ពីពួកជំនុំប្រេសប៊ីធើរៀន គេពិភាក្សាគ្នា ហើយបានបោះឆ្នោតសំរេចបដិសេធ បោះបង់ចោលបញ្ហារបស់ព្រះទាំងអស់? តើមាននរណាម្នាក់បានឮការផ្សាយព័ត៌មាននេះឬទេ? វិហារប្រេសប៊ីធើរៀន បាននិយាយថា «យើងត្រូវតែបោះបង់ចោលរាល់ស្តង់ដារចាស់ទាំងនេះចេញ យើងមិនអាចថ្កោលទោសការស្រឡាញ់ភេទដូចគ្នាបានទេ យើងក៏មិនអាចថ្កោលទោសការរួមភេទ មុនរៀបការបានដែរ យើងមិនអាចថ្កោលទោសការសម្រេចកាមដោយខ្លួនឯងបានទេ គ្មានអ្វីណាមួយដែលអាចត្រូវបានថ្កោលទោសទាល់តែសោះ ពីព្រោះយើងរស់នៅក្នុងយុគសម័យដែលមានពន្លឺភ្លឺស្វាង នេះជាការដោះស្រាយបញ្ហារបស់ពួកសាសនា ក្រុមអាពិស្កូប៉ាលលាន [Episcopalians, Church of England ពួកជំនុំអាពិស្កូប៉ាលលាន នៃប្រទេសអង់គ្លេស] ពួកគេបានធ្វើការនោះហើយៗ

ខ្ញុំបានអានផ្នែកអត្ថបទមួយរបស់ទស្សនាវដ្តីថៃមស៍ នៅទំព័រសាសនា មានបូជាចារ្យម្នាក់បានចាក់ប្រេងតាំងអ្នកស្រឡាញ់ភេទដូចគ្នា ហើយរៀបមង្គលការឲ្យប្រុស ស្រឡាញ់ប្រុសពីរនាក់ ហើយប្រុសស្រឡាញ់ប្រុសគ្នាឯង និយាថា នេះជារឿងកំណើតព្រហ្មចារី [គេវង្វេងស្មារតី] វាជារឿងដ៏អាក្រក់ជួជាតិៗ ដូច្នេះ យើងឃើញការពិត ពីពួកអ្នកដែលធ្វើពុតជាមេដឹកនាំសាសនា ដឹកនាំមនុស្សក្នុងសង្គមទៅរកផ្លូវហិនវិនាស ផ្លូវវេទនាទាំងស្រុងនៃសង្គម ហើយអ្នកអាចចុះបញ្ជាំងពីអ្វីៗទាំងអស់នៅលើលោកីយនេះបាន មិនមែនត្រឹមតែវិធីដែលពួកគេនិយាយប៉ុណ្ណោះទេ ប៉ុន្តែគេបានធ្វើតាមគំនិតរបស់គេ ដោយរួមភេទជាមួយមនុស្ស មានភេទដូចគ្នា គេមានសីលធម៌ផ្លូវភេទរបស់ពួកគេ បទដ្ឋានសីលធម៌របស់ពួកគេ គឺអ្វីៗទាំងអស់ គេធ្វើតាមគំនិតវង្វេងរបស់ពួកគេៗ អ្នកអាចឃើញរឿងនោះ តាមកញ្ចក់ទូរទស្សន៍ អ្នកអាចឮរឿងនោះ នៅក្នុងខ្សែភាពយន្ត ហើយរឿងទាំងអស់នេះ គឺជាលទ្ធផលរបស់ព្រះ ដែលព្រះ

ទ្រង់ប្រគល់ពួកគេ ទៅឯការទាំងអស់នោះតាមចិត្តចង់បានរបស់ពួកគេ នោះហើយជាការផ្តន្ទាទោស! នោះគឺជាសេចក្តីក្រោធរបស់ព្រះ ដែលទ្រង់បានបើកសម្តែងពីលើមេឃ - ដោយមានបន្ទូលថា ១២៨ «ហើយដោយព្រោះគេមិនចូលចិត្តនឹងស្គាល់ដល់ព្រះសោះ បានជាទ្រង់ប្រគល់គេទៅតាមគំនិតចោលម្សៀតវិញ...» តើគំនិតចោលម្សៀតនោះជាអ្វី? គឺជាគំនិតដែលមិនអាចគិតតាមសេចក្តីត្រឹមត្រូវបាន! ...» ខ្ញុំសូមឲ្យអ្នករាល់គ្នា ធ្វើឧទាហរណ៍ជាក់ស្តែង: ពីអ្នកស្រឡាញ់ភេទដូចគ្នា- គ្រួគង្វាលទាំងប្រុស ទាំងស្រី ដូចពួកអ្នកដែលខ្ញុំបាននិយាយពីក្រុមជំនុំ អេពិស្កូលប៉ុលាន ពួកអ្នកជឿ នៅប្រទេសអង់គ្លេស [Episcopalians Church of England] នឹងពួកប្រែសបេតធើរាន [Presbyterian] ហើយនឹងអ្នកដឹកនាំគ្រីស្តសាសនា នឹងសាសនាផ្សេងៗទៀតទាំងអស់ ដែលចូលរួមធ្វើការទាំងអស់នោះ ហើយពួកចៅក្រម តុលាការ ប្រព័ន្ធប៉ូលីស គណៈបក្សនយោបាយ ពួកអ្នកទាំងអស់នោះ គេមិនអាចគិតបានទេ! ពួកគេក៏មិនអាចវែកញែកបានដែរ! ឥឡូវនេះគ្រាន់តែផ្តល់ឧទាហរណ៍ដល់អ្នក ប៉ូលីសបានវាយបុរសម្នាក់ឈ្មោះ Rodney King ស្លាប់ ជាការបង្ហាញពីអ្វី ដែលពួកមានអំណាចបានធ្វើ ខ្ញុំមិនយល់ស្របតាមប៉ូលីស ដែលវាយលោកRodney King ឲ្យស្លាប់នោះទេ ខ្ញុំក៏មិនមែននិយាយថា ការនោះត្រឹមត្រូវទេ ប៉ុន្តែ គ្រាន់តែបង្ហាញអ្នកពីភាពវង្វេងស្មារតីរបស់មនុស្សនៅក្នុងកាលៈទេសៈដូចគ្នាៗ មូលហេតុដែលប៉ូលីសទាំងនេះជួបបញ្ហា គឺដោយសារតែបុរសម្នាក់បានឈរនៅលើយ៉រ មានកាមេរ៉ាទូរទស្សន៍ ហើយបានថតរឿងទាំងមូលដែលបង្ហាញក័ស្តុតាងពិតប្រាកដ នៅគ្រប់នាទីទាំងអស់ៗ ជាការប្រសើរណាស់ កាលពីយប់មិញប៉ូលីសបានរឹបអូសយកម៉ាស៊ីនថតទូរទស្សន៍នោះ ពីចោរដែលវាប្លន់ នឹងលួចពីគេ ពួកគេបានថតរឿងទាំងអស់នេះ តាមវីដេអូ ចោរវាបានបង្ហាញពីពេលវេលា ថ្ងៃ នឹងខែ បង្ហាញពីអ្នកដែលវាបានវាយនឹងប្លន់ គឺជាពួកស្បែកខ្មៅ ប្លន់ពួកស្បែកសៗ សូមទាយលមើល តើមេធាវីការពារដើមចោទបាននិយាយអ្វីខ្លះ? មេធាវីនោះបាននិយាយតាមភាពវង្វេងស្មារតី នៃការវែកញែករបស់គេ ប្រសិនបើមេធាវីដែលការពារប៉ូលីសជាចុងចោទ ដែលបានវាយបុរសនោះ មេធាវីនោះនិយាយ នឹងបង្ហាញឱ្យឃើញពីការសន្និដ្ឋាននូវអ្វីៗ ដែលប៉ូលីសបានធ្វើខុសដែរ ត្រឡប់មកវិញ មេធាវីមិនដូចគ្នាទេ មានមេធាវីសំរាប់ការពារខាងចុងចោទ ហើយមួយទៀតសំរាប់ធ្វើការខាងដើមចោទ ប៉ុន្តែ អ្នកដឹងថាមេធាវីមានលក្ខណៈបែបណាហើយ ក្នុងករណីយដែលក្រុមចោរទាំងនេះ បានកត់ត្រាដោយដៃរបស់ពួកគេផ្ទាល់ ពួកគេបានកត់ត្រាបទឧក្រិដ្ឋផ្ទាល់ខ្លួនរបស់ពួកគេ ដោយអួតអំពីបទសម្ភាសន៍នោះ ក្រោយមកបាននិយាយថា យើងមិនគួរប្រើវីដេអូនេះទេ ពីព្រោះវាបញ្ចាំង បង្ហាញនៅលើកញ្ចក់ទូរទស្សន៍ហើយ វាជាការរើសអើងប្រឆាំងនឹងចុងចោទ ពួកគេមិនមានខួរក្បាល ឲ្យដឹងថា កាមេរ៉ាមិនអាចកុហកបានទេ ពីព្រោះកាមេរ៉ាវាថតយកចលនារូបភាព វាអាចកត់ត្រានូវអ្វី ដែលមនុស្សបានធ្វើៗ អ្នកអាចមើលឃើញពីភាពវង្វេងស្មារតីក្នុងគំនិតគេ ពីករណីយពីរ ដែលស្ទើរតែដូចគ្នា អ្នកអាចយកហេតុផលដូចគ្នា គឺហេតុផលមួយ

ដោះសារ នឹងហេតុផលមួយទៀតចោទសួរ- មនុស្សឥឡូវនេះ មិនដឹងខាងណាខុស ឬខាងណាត្រូវទេ គេរាប់ស្តាំថាឆ្វេង ហើយឆ្វេង ថាជាស្តាំវិញ នេះហើយជារបៀបដែលមនុស្សគិតសព្វថ្ងៃនេះ ហេតុនេះបានជាព្រះទ្រង់ប្រគល់ពួកគេទៅក្នុងសេចក្តីនោះឯង!

នេះជាលទ្ធផលដែលកើតឡើង បន្ទាប់ពីពួកគេត្រូវបានប្រគល់ទៅក្នុងសេចក្តីទុច្ចរិត នឹងការវែកញែកដោយមានស្មារតីវង្វេង ១២៩ «ជាមនុស្សមានពេញដោយសេចក្តីទុច្ចរិតគ្រប់យ៉ាង...[រាល់អំពើទុច្ចរិត អំពើអសីលធម៌ផ្លូវភេទ អំពើលោភលន់ ការស្អប់ខ្ពើម ការច្រណែនឈ្នានីស ឃាតកម្ម ការឈ្លោះប្រកែកគ្នា វង្វេងស្មារតី គំនិតអាក្រក់ ការនិយាយខ្សឹបខ្សៀវគ្នា]...គឺសេចក្តីកំផិត សេចក្តីកំណាច សេចក្តីលោភ នឹងសេចក្តីព្យាបាទ ក៏មានសេចក្តីឈ្នានីស នឹងការកាប់សំឡាប់ ឈ្លោះប្រកែក កិច្ចកល គំនិតខិលខូចដំពោរពេញផង» (រ៉ូម១:២៩) សព្វថ្ងៃនេះ តើប្រជាជនមិនត្រូវបានគេសាកល្បង នៅក្នុងរឿងផ្សេងៗទេឬអី? ដូចពីជីវប្រវត្តិរបស់លោករីហ្គែន [Reagans] នាងយេតទីឃីលី ដោយគ្មានការអនុញ្ញាត ហើយរាយការណ៍ថា នាងបាននិយាយជាមួយលោកប្រធានាធិបតី រីហ្គែន នាងយេតទីឃីលី បានអះអាងថា នាងបានសម្ភាសន៍ជាមួយនឹងលោកប្រធានាធិបតី Reagans នេះជាការបោកបញ្ឆោតបំភ្លើសទាំងស្រុង! នេះហើយជាអំពើអាក្រក់ដែលកំពុងកើតឡើងនៅក្នុងលោកីយសព្វថ្ងៃនេះ។

១៣០ «ជាមនុស្សចែចូវ បេះបួយ ស្អប់ព្រះ ព្រហើនឈ្លានពាន មានៈកាន់ខ្លួន អួតអាង ជាមេបង្កើតការអាក្រក់ ហើយមិនស្តាប់បង្គាប់តាមឪពុកម្តាយ ឥតយោបល់ មានចិត្តមិនទៀង មិនចេះស្រឡាញ់តាមធម្មតា ក៏ឥតមានសេចក្តីមេត្តាករុណាសោះ គេក៏ស្គាល់សេចក្តីជំនុំជំរះដ៏សុចរិតរបស់ព្រះថា អស់អ្នកដែលប្រព្រឹត្តការយ៉ាងដូច្នោះ នោះគួរនឹងស្លាប់ហើយ...[នេះជាគោលលទ្ធិសញ្ញាថ្មី ដែលចែងថាអស់អ្នកដែលប្រព្រឹត្តយ៉ាងដូច្នោះ នោះគួរនឹងស្លាប់ហើយ] ...ប៉ុន្តែគេមិនគ្រាន់តែប្រព្រឹត្តយ៉ាងនោះប៉ុណ្ណោះ គឺគេចូលចិត្តយល់ព្រមនឹងអស់អ្នកណា ដែលប្រព្រឹត្តិដូច្នោះផងដែរ» (១៣០-៣២)។

នៅក្នុងការទាំងអស់នេះ យើងមានអ្នកកាន់សាសនាជាច្រើននាក់ ដែលប្រព្រឹត្តការនោះ តើមែនឬទេ? យើងមានពួកអ្នកផ្សព្វផ្សាយដំណឹងល្អ នឹងគ្រូបង្ហាត់បង្រៀនព្រះបន្ទូល តែព្រះយេស៊ូវបានមានបន្ទូលប្រាប់យើង នឹងអ្នកអធិប្បាយប្រភេទនេះ នឹងត្រូវកើតមានឡើង ម៉ាថាយ៧:១៥ ព្រះយេស៊ូវមានបន្ទូលព្រមានថា «ចូរប្រយ័ត្ននឹងពួកគ្រូក្លែងក្លាយ...» មានហោរាក្លែងក្លាយ បានតាំងខ្លួនដូចជាហោរាពិតទៀតផង ពួកគេក៏ធ្វើសកម្មភាពពីសេចក្តីមិនពិត ពួកគេក៏កំពុងតែប្រាប់មនុស្សជាច្រើនឲ្យធ្វើតាមសេចក្តីមិនពិត នឹងគំនិតខុសឆ្គងរបស់ពួកគេ មិនត្រឹមតែនៅក្នុងន័យសាសនាមួយប៉ុណ្ណោះទេ គឺនៅពេលដែលអ្នកចូលទៅកាន់ជាប់តាមសាសនាណាមួយ ដែលមិនមានសេចក្តីពិត ហើយហៅថា «ជំនឿសាសនា» ដូចដែលមនុស្សទាំងអស់បានដឹង ពីជីវិតរបស់អ្នកទាំងអស់នោះ នឹងត្រូវប្រឈមមុខជាមួយនឹងព្រះពិត។ ប៉ុន្តែ មានអ្នកធ្វើពុតជាអ្នកកាន់សាសនាជាច្រើននាក់ ដែលយកសាសនា ជារបររកស៊ី

វិញ។ ១៥«...ដែលគេមកឯអ្នករាល់គ្នា ដោយពាក់រោមចៀមបំប្លែងខ្លួន តែខាងក្នុងរបស់គេ ជាឆ្កែចចកដែលឆ្មក់ស៊ីវិញ អ្នករាល់គ្នានឹងស្គាល់គេបាន ដោយសារផលគេបង្កើត តើដែលបេះផ្លែទំពាំងបាយជូរពីគុម្ពបន្លា ឬផ្លែល្វាពីដំបងយក្សឬទេ? ដូច្នេះ អស់ទាំងដើមឈើល្អ តែងមានផ្លែល្អ ឯដើមអាក្រក់ក៏តែងមានផ្លែអាក្រក់ដែរ ធម្មតាដើមឈើល្អ មិនដែលបញ្ចេញផលអាក្រក់បានទេ ហើយដើមដែលអាក្រក់ ក៏ពុំអាចនឹងបញ្ចេញផលផ្លែល្អបានដែរ អស់ទាំងដើមឈើណា ដែលមិនកើតផលផ្លែល្អ នោះត្រូវតែកាប់បោះចោលទៅក្នុងភ្លើងចេញ ដូច្នេះ អ្នករាល់គ្នានឹងស្គាល់គេបាន គឺដោយសារផលគេបង្កើត» ១៥-២០)។ នេះមានន័យថា គឺដោយសារតែជីវិតរស់នៅរបស់ពួកគេ នឹងដោយសេចក្តីជំនឿរបស់ពួកគេ មានគ្រីស្ទានជាច្រើននាក់បានធ្វើតាមគំរូខ្សែភាពយន្តពីហូលីវូដ យកគំរូពីទូរទស្សន៍ យកពីអក្សរសិល្ប៍ នឹងពីពត៌មានផ្សេងៗ។ យើងត្រូវតែការពារខ្លួន ពីរឿងទាំងអស់នេះ វាពិតជាពិបាកសំរាប់យើង ដែលរស់នៅក្នុងលោកីយនេះណាស់ មែនឬទេ? នេះខ្ញុំមានន័យថា វាជារឿងមួយដែលយើងរាល់គ្នាកំពុងប្រឈមមុខជាមួយ ហើយយើងឃើញថា អ្វីៗនៅលោកីយនេះ ខុសទាំងអស់ ហើយបើមើលទៅឯសាសនាវិញខុសទាំងអស់ ប៉ុន្តែ តើយើងត្រូវធ្វើយ៉ាងដូចម្តេច? យើងត្រូវតែសួរសំណួរ ដល់ខ្លួនយើង! ២១ «មិនមែនអស់អ្នកណាដែលគ្រាន់តែនិយាយមកខ្ញុំ...[ព្រះយេស៊ូវ]...ថា ឱព្រះអម្ចាស់ៗអើយ ដែលនឹងចូលទៅក្នុងនគរស្ថានសួគ៌នោះទេ គឺជាអស់អ្នកដែលធ្វើតាមព្រះហឫទ័យនៃព្រះវរបិតា ដែលគង់នៅស្ថានសួគ៌វិញទេតើ...[មានអ្នកធ្វើពើ ជាអ្នកកាន់សាសនាច្រើននាក់ណាស់]...នៅថ្ងៃនោះ នឹងមានមនុស្សជាច្រើន...[អ្នកកាន់សាសនាច្រើននាក់ណាស់]...និយាយមកខ្ញុំថា ឱព្រះអម្ចាស់ៗអើយ តើយើងខ្ញុំមិនបានទាយដោយនូវព្រះនាមទ្រង់ ហើយដេញអារក្សដោយនូវព្រះនាមទ្រង់ ព្រមទាំងធ្វើការឫទ្ធិបារមីជាច្រើន ដោយនូវព្រះនាមទ្រង់ទេឬអី? នោះខ្ញុំ...[ព្រះគ្រីស្ទ]... នឹងនិយាយដោយត្រង់ថា អញមិនដែលបានស្គាល់ឯងរាល់គ្នាទេ នៃពួកទទឹងច្បាប់...[រំលងបញ្ញត្តិ ]...អើយ ចូរថយចេញពីអញទៅ» (២១-២៣) នៅក្នុងភាសាក្រិកថា «អាណូម៉ូស» ដែលមានន័យថា ប្រឆាំងនឹងច្បាប់។

តើសាវកយ៉ូហានបានសរសេរពាក្យខ្លះ អំពីអ្នកធ្វើពុតជាអ្នកដឹកនាំសាសនាទាំងនេះ? មានអ្នកធ្វើពុតជាអ្នកជឿសាសនាជាច្រើននាក់! សូមបើកទៅគម្ពីរ ១យ៉ូហានជំពូក២ សូមយើងមើលពីរបៀបដែលយើងអាចវិនិច្ឆ័យរឿងទាំងនេះ នឹងពីរបៀបដែលយើងអាចចាប់ផ្តើមការពារខ្លួនយើង ពីរឿងប្រភេទនេះដែរ សូមអ្នកគិតអំពីរឿងនេះ មួយនាទីសិន៖ តើយើងរងផលប៉ះពាល់ដោយព្រោះលោកីយ ដែលយើងរស់នៅមែនឬទេ? មែន! សូមក្រឡេកមើលពីឡុតនឹងគ្រួសាររបស់គាត់ ដែលរស់នៅក្រុងសូដុំម តើគ្រួសាររបស់ឡុតរងផលប៉ះពាល់ពីបញ្ហានេះដែរ ឬទេ? តើឡុតបានរងផលប៉ះពាល់អ្វីខ្លះ? គាត់រងផលប៉ះពាល់យ៉ាងខ្លាំង! គម្ពីរ ២ពេត្រុសជំពូក២ សាវកពេត្រុសសរសេរថា ព្រះទ្រង់មានព្រះហឫទ័យអាក់អន់ ដោយព្រោះមនុស្សចេះតែបន្តប្រព្រឹត្តអំពើបាបជានិច្ចរាល់ថ្ងៃ «ហើយបើទ្រង់បានបញ្ឆេះក្រុងសូដុំម

នឹងក្រុងកូម៉ូរ៉ាឲ្យទៅជាផេះ ទាំងកាត់ទោសឲ្យត្រូវវិនាសសាបសូន្យទៅ ទុកជាគំរូដល់ពួកមនុស្សតទៅមុខ ដែលគិតរស់នៅដោយសេចក្តីទមិលល្មើស តែបានប្រោសលោកឡុត ជាអ្នកសុចរិតឲ្យរួចវិញ ដែលលោកមានចិត្តព្រួយលំបាក ដោយព្រោះកិរិយាខូចអាក្រក់របស់មនុស្សទទឹងច្បាប់ទាំងនោះ ដ្បិតអ្នកសុចរិតនោះ ដែលនៅជាមួយនឹងគេ ក៏កើតទុក្ខក្នុងចិត្តសុចរិតរបស់លោករាល់តែថ្ងៃ ដោយបានឮ ហើយឃើញការទទឹងច្បាប់ ដែលគេប្រព្រឹត្តធ្វើ» (២ពេត្រុស២:៦-៨) ប៉ុន្តែ សូមនឹកចាំពីការដែលបានកើតឡើងនៅពេលដែលអ័ប្រាហាំធ្វើអន្តរាគមន៍ ដើម្បីព្យាយាមនឹងជួយឡុត ព្រះបាទមានបន្ទូលថា បើមានមនុស្សតែដប់នាក់ប៉ុណ្ណោះនៅក្រុងសូដុំម ទ្រង់នឹងសង្គ្រោះទីក្រុងទាំងមូលដោយយល់ដល់ពួកមនុស្សសុចរិតទាំងដប់នាក់ៗ «ដល់ពេលព្រលប់ នោះទេវតាទាំង២ក៏ទៅដល់ក្រុងសូដុំម...» (លោកុប្បត្តិ១៩:១) នៅពេលដែលទេវតាបានមកដល់មាត់ទ្វារក្រុងសូដុំម ឡុតជាមនុស្សសុចរិត ក៏អញ្ជើញទេវតាទៅឯផ្ទះរបស់លោកៗ ពួកអ្នកស្រឡាញ់ភេទដូចគ្នាក្នុងក្រុងទាំងអស់ ក៏បានមកឯឡុត ព្យាយាមចាប់ពួកទេវតាទាំងនេះ ដើម្បីបំពេញបំណងចិត្តនៅពេលរាត្រីរបស់ពួកគេ តែឡុតបានចេញទៅក្រៅហើយ ថែមទាំងបានផ្តល់កូនស្រីពីរនាក់របស់គាត់ទៅឲ្យគេ ដើម្បីឲ្យគេប្រព្រឹត្តនឹងនាងតាមតែចិត្តគេ «កាលមិនទាន់ដេកនៅឡើយ នោះពួកមនុស្សទាំងឡាយ ទាំងក្មេងទាំងចាស់នៅក្នុងក្រុងសូដុំមគេមកឡោមព័ទ្ធផ្ទះ គឺជាមនុស្សទាំងអស់ពីគ្រប់ក្នុងទីក្រុង គេហៅឡុតសួរថា មនុស្សដែលចូលមកក្នុងផ្ទះឯងអម្បាញ់នេះ តើនៅឯណា ចូរឯងនាំវាចេញមកឯយើង ឲ្យយើងបានស្គាល់ផង» (លោកុប្បត្តិ១៩:៤-៥) ដូច្នេះ ពួកទេវតាបានធ្វើឲ្យមនុស្សទាំងអស់ ដែលនៅត្រង់មាត់ទ្វារនោះខ្វាក់ភ្នែកទៅទាំងតូចទាំងធំ បន្ទាប់មក តើមានអ្វីកើតឡើង ដល់ប្រពន្ធឡុត? នឹងកូនស្រីទាំង២នាក់ បាននាំគ្នាភៀសខ្លួន «ឯប្រពន្ធឡុតក៏បែរមើលទៅក្រោយវិញ នោះស្រាប់តែទៅជាបង្គោលអំបិលទៅ» (លោកុប្បត្តិ១៩:២៦) ហើយឡុតមិនចង់ទៅលើភ្នំទេ ដូច្នេះ ពួកទេវតានិយាយថា «មើលន៏ មានទីក្រុង១នុះ ស្ថិតនៅជិតបង្កើយ ហើយក៏តូចផង ឬមិនតូចទេ នោះល្មមនឹងរត់ទៅឲ្យរួចបាន សូមឲ្យខ្ញុំរត់ទៅឯណោះវិញ នោះខ្ញុំនឹងបានរួចជីវិតហើយ ទេវតាក៏ឆ្លើយថា មើលអញបានព្រមតាមឯងក្នុងការនេះដែរ ឯទីក្រុង១ដែលឯងនិយាយនោះ អញមិនបំផ្លាញទេ... ដូច្នេះ ទីក្រុងនោះបានហៅឈ្មោះថាសូអារ» (លោកុប្បត្តិ១៩:២០-២២) តើពួកគេទៅណាទៀត? ខ៣០ ឯឡុតព្រមទាំងកូនស្រីទាំង២ ក៏ចេញពីសូអារឡើងទៅឯភ្នំវិញ ដ្បិតគាត់មិនហ៊ានទៅក្នុងក្រុងសូអារទេ គាត់ក៏នៅក្នុងរអាងភ្នំជាមួយនឹងកូនស្រី របស់គាត់ទាំង២ទៅៗ បន្ទាប់មកមានអ្វីកើតឡើងទៀត? ខ៣១ ចំណែកនាងបងនិយាយទៅកាន់ប្អូនថា ឪពុកយើងគាត់ចាស់ហើយ គ្មានប្រុសណានៅគ្រប់ក្នុងស្រុកនេះ នឹងចូលមកឯយើងតាមបវេណីផែនដីទេ ខ៣២ បើដូច្នេះ ចូរយើងបំផឹកស្រាឪពុកយើង ហើយទៅដេកជាមួយនឹងគាត់ទៅ ដើម្បីឲ្យបានតពូជឲ្យឪពុកយើងវិញ ខ៣៣ នោះគេក៏បំផឹកស្រាឪពុកគេនៅយប់នោះឯង រួចនាងបងទៅដេកជាមួយនឹងឪពុកខ្លួនទៅ តែគាត់ឥតមានដឹង ជាកាលនាងដេកឬ

កាលនាងក្រោកឡើយ ៣២ លុះថ្ងៃស្អែកទៀត នាងបងនិយាយទៅប្អូនថា មើលយប់មិញអញបានដេកជាមួយនឹងលោកឪពុក យប់នេះចូរយើងបំផឹកស្រាគាត់ទៀត រួចឲ្យឯងចូលទៅដេកជាមួយនឹងគាត់ម្តង ដើម្បីឲ្យយើងបានតពូជរបស់ឪពុកយើង ៣៥ គេក៏បំផឹកស្រាឪពុកគេនៅយប់នោះទៀត នោះនាងប្អូនក៏ក្រោកឡើងទៅដេកជាមួយនឹងឪពុកទៅ តែគាត់ឥតដឹងជាកាលនាងដេក ឬកាលនាងក្រោកឡើយ ៣៦ ដូច្នេះ កូនស្រីរបស់ឡុតទាំង២ ក៏មានទំងន់នឹងឪពុកខ្លួន ៣៧ នាងបងបង្កើតបានកូនប្រុស១ នាងឲ្យឈ្មោះថា ម៉ូអាប់ គឺអ្នកនោះហើយដែលជាឪពុកនៃសាសន៍ម៉ូអាប់ ដរាបដល់សព្វថ្ងៃនេះ ៣៨ ហើយនាងប្អូនក៏បង្កើតបានកូនប្រុស១ដែរ នាងឲ្យឈ្មោះថាបេន-អាំមី គឺអ្នកនោះហើយដែលជាឪពុកនៃពួកកូនចៅអាំម៉ូនដរាបដល់សព្វថ្ងៃនេះ» (លោកុប្បត្តិ១៩:៣០-៣៨) [សព្វថ្ងៃនេះហៅថាប្រទេសយ័ដាន់ នៅមជ្ឈឹមបូព៌ា] តើសង្គមដែលនៅជុំវិញយើង មានឥទ្ធិពលលើយើងដែរ ឬទេ? ពិតជាមាន! ដោយសង្ឃឹមថា មិនបះពាល់ដល់មនុស្សខ្លាំងហួសកំរិតពេកនោះទេ។ ប៉ុន្តែ មានការណែនាំមួយដែលអាចឲ្យយើងដឹងបាន ទោះជាតាមពាក្យសំដី ដែលយើងរាល់គ្នាឮពីមនុស្ស ឬដោយឮផ្ទាល់ តាមវិទ្យុ តាមទូរទស្សន៍ ឬតាមការថតចម្លងសម្លេងផ្សេងៗ ឬឮដោយសារមិត្តភក្តិ ឬតាមមនុស្សដែលយើងស្គាល់ក្តី សេចក្តីដំណឹងនោះ យើងត្រូវតែវិនិច្ឆ័យ តាមបទព្រះគម្ពីរ ១យ៉ូហាន២:៣-៤ «យើងរាល់គ្នាដឹងថា យើងស្គាល់ទ្រង់...[ព្រះយេស៊ូវ]... ដោយសារសេចក្តីនេះ គឺដោយយើងកាន់តាមបញ្ញត្តរបស់ទ្រង់ អ្នកណាដែលថា បានស្គាល់ទ្រង់ តែមិនកាន់តាមបញ្ញត្តទ្រង់ទេ អ្នកនោះឈ្មោះថាជាអ្នកកុហក ហើយសេចក្តីពិតមិននៅក្នុងអ្នកនោះឡើយ» (ខ៣-៤)នោះជាមូលដ្ឋានគ្រឹះ សំរាប់អ្នកជឿពិត ដើម្បីរក្សានូវសុចរិតភាព។ មានពេលខ្លះអ្នកមិនចាំបាច់ធ្វើយចំពោះមនុស្សទាំងនេះទេ ពេលខ្លះអ្នកត្រូវតែជាមនុស្សឆ្មើងឆ្មៃចំពោះពួកគេ ពីព្រោះគ្មានអ្វីដែលអាចធ្វើឲ្យពួកគេយល់បានទេ យើងត្រូវតែស្អប់អំពើបាបគ្រប់យ៉ាងរបស់គេ ម្យ៉ាងវិញទៀត ដើម្បីកុំឲ្យរឿងនេះធ្លាក់មកលើអ្នក នឹងចូលក្នុងជីវិតរបស់អ្នក នោះអ្នកត្រូវតែរឹងមាំនៅចំពោះពួកគេ។ មានវិធីតែមួយគត់ ដើម្បីកំចាត់ពួកគេ គឺត្រូវធ្វើដូចព្រះយេស៊ូវបានធ្វើ ដោយបន្ទោសពួកគេ នៅចំពោះមុខ ខ្ញុំមិនមែននិយាយឲ្យអ្នក ចេញមុខដេរប្រមាថគេទេ សូមមេត្តាកុំយល់ច្រឡំ ឲ្យសោះ។ លោកអ័ប្រាហាំបានរស់នៅក្នុងសង្គមស្រដៀងគ្នា ដូចយើងដែរ មែនទេ? គឺមែន! សូមត្រឡប់ទៅក្រោយបន្តិច ដូច្នេះ ប្រសិនបើអ្នកមានអារម្មណ៍ ថាអ្នកនៅតែម្នាក់ឯង! លោកអ័ប្រាហាំក៏នៅតែម្នាក់ឯងដែរ ព្រះទ្រង់បានយាងចុះមក «មានបន្ទូល នឹងអាប់រ៉ាម ...[គឺអ័ប្រាហាំ]... ថា ចូរឯង ចេញពីស្រុក ពីញាតិសន្តាន នឹងពីផ្ទះឪពុកឯង ទៅនៅឯស្រុកដែលអញនឹងបង្ហាញឯងចុះ អញនឹងបង្កើតនគរមួយយ៉ាងធំពីឯង អញនឹងឲ្យពរដល់ឯង ទាំងលើកឈ្មោះឯងជាធំផង ឯងនឹងបានធ្វើជាទីបញ្ចេញពរដល់មនុស្សទាំងឡាយ អញនឹងឲ្យពរដល់អស់អ្នកណាដែលឲ្យពរឯង ហើយនឹងដាក់បណ្តាសាដល់អស់អ្នកណាដែលផ្តាសាឯង គ្រប់ទាំងគ្រួនៅផែនដីនឹងបានពរដោយសារឯង អាប់រ៉ាម

ក៏ចេញទៅ ដូចជាព្រះយេហូវ៉ាបានបង្គាប់ ...នាំគ្នាចេញពីទីនោះ ដើម្បីទៅស្រុកកាណាន...»(លោកុប្បត្តិ១២) មែនហើយ ខ្ញុំមិនចង់ចូលជ្រៅទៅក្នុងរឿងរបស់លោកអ័ប្រាហាំទេ ដូច្នេះ តើលោកអ័ប្រាហាំនៅតែម្នាក់ឬ? តើលោកអ័ប្រាហាំមិនបានទទួលភាពទន់ខ្សោយរបស់គាត់ទេឬអី? ត្រូវហើយ គឺគាត់មានភាពទន់ខ្សោយ សូមទឹកចាំពីពេលដែលអ័ប្រាហាំបានចូលទៅក្នុងប្រទេសអេហ្ស៊ីប «នោះគាត់បាននិយាយទៅសារ៉ាជាប្រពន្ធថាមើល អញដឹងថាឯងជាស្ត្រីមានរូបស្រស់ល្អ... (ទោះនាងចាស់ហើយក្តី)... កាលណាពួកសាសន៍អេស៊ីព្ទឃើញឯង នោះក្រែងគេនឹងនិយាយពីឯងថាជាប្រពន្ធអញ រួចគេនឹងសំឡាប់អញទៅ ហើយទុក ឲ្យឯងរស់នៅវិញ ដូច្នេះ ចូរឯងប្រាប់គេថា ឯងជាប្អូនអញទេ ដើម្បីឲ្យគេបានប្រព្រឹត្តល្អនឹងអញដោយព្រោះឯង ហើយឲ្យអញមានជីវិតរស់នៅដោយសារឯងផង» (លោកុប្បត្តិ១២:១០-១៣)

មើលការដែលបានកើតឡើង នៅលោកុប្បត្តិ១២:១៨-១៩ «រួចផារ៉ោនទ្រង់ហៅអាប់រ៉ាម... [អ័ប្រាហាំ]...មកសួរថា តើឯងបានធ្វើអ្វីដល់អញដូច្នេះ ហេតុអ្វី បានជាឯងមិនបានប្រាប់អញដោយត្រង់ថា នាងជាប្រពន្ធឯង ម្តេចក៏ឯងថាជាប្អូនវិញ ដើម្បីបើកឱកាសឲ្យអញបានយកនាងមកធ្វើជាប្រពន្ធ ដូច្នេះ នេះនែ ប្រពន្ធឯងហើយ ចូរយកនាងទៅវិញឥឡូវ ហើយចេញទៅចុះ» (១១៨-១៩) បន្ទាប់មកយើងបានមកដល់ពេលប្រហែលជា១២ឆ្នាំ ដែលអ័ប្រាហាំត្រៀមនឹងទទួលមរតក ពីព្រោះព្រះទ្រង់មានបន្ទូលថា «... គឺជាម្នាក់ដែលនឹងកើតពីឯងមកវិញទេតើ ដែលត្រូវស៊ីមរដករបស់ឯងនោះ» (លោកុប្បត្តិ១៥:៤) សារ៉ាយប្រពន្ធអាប់រ៉ាមមិនមានកូនទេ លោកុប្បត្តិ១៦:២ «ដូច្នេះសារ៉ាក៏និយាយទៅអាប់រ៉ាមថា មើល ព្រះយេហូវ៉ាទ្រង់បង្ខាំងមិនឲ្យខ្ញុំមានកូនទេ ហេតុនោះ សូមអ្នកអញ្ជើញចូលទៅឯបាវស្រីរបស់ខ្ញុំចុះ ប្រហែលជាខ្ញុំបានកូនដោយសារវា អាប់រ៉ាមក៏ស្តាប់តាម រួចសារ៉ាយប្រពន្ធអាប់រ៉ាមក៏ឲ្យហាការជាសាសន៍អេស៊ីព្ទ បាវខ្លួន ទៅធ្វើជាប្រពន្ធរបស់ប្តីទៅ...» នាងហាការបង្កើតបានកូនប្រុស១ ដែលត្រូវឲ្យឈ្មោះថា អ៊ីសម៉ាអែល...» ១១២ វានឹងបានដូចជាលាព្រៃនៅកណ្តាលមនុស្ស ដៃវានឹងបានទាស់នឹងមនុស្សទាំងអស់ ហើយដៃមនុស្សទាំងអស់ នឹងបានទាស់នឹងវាដែរ...» ដូច្នេះ យើងមានបញ្ហាអារ៉ាប់នឹង អ៊ីស្រាអែល ចាប់តាំងពីថ្ងៃនោះរហូតមកដល់ឥឡូវនេះ។ យើងឃើញសង្គម នឹងព្រឹត្តិការណ៍នៅជុំវិញយើង ពិតជាជះឥទ្ធិពលដល់យើងមែន! ប៉ុន្តែ យើងតែត្រូវរស់នៅក្នុងលោកីយនេះ នឹងរក្សាភាពស្អាតស្អំរបស់យើង នឹងរក្សាភាពត្រឹមត្រូវជាមួយនឹងព្រះអម្ចាស់របស់យើង។ សូមឲ្យយើងមើលពីរបៀបដែលយើងអាចរក្សាគំនិតរបស់យើង ហើយយល់ពីអ្វីដែលយើងត្រូវធ្វើ សូមបើកទៅគម្ពីរលូកា ៥:៣២ នេះហើយជាការពិតទាំងស្រុង សំរាប់អ្នកធ្វើពុតជាអ្នកដឹកនាំសាសនា «ខ្ញុំមិនបានមកហៅពួកមនុស្សសុចរិតទេ គឺមកហៅតែមនុស្សមានបាប ឲ្យគេប្រែចិត្តវិញទេតើ» ដូច្នេះ កុំឲ្យមានអារម្មណ៍ថា

អ្នកបានធ្វើអាក្រក់ហួសល្បត់ ដែលអ្នកមិនអាចប្រែចិត្តបាន ហើយថាព្រះទ្រង់នឹងបោះបង់ចោលអ្នកទៅឆ្ងាយ ប្រសិនបើអ្នកមានអារម្មណ៍ ថាអ្នកមានកំហុស ឬអ្នកត្រូវគេវាយដោយព្រោះ អ្នកបានធ្វើអ្វីដែលអ្នកមិនគួរធ្វើ ប៉ុន្តែ ព្រះទ្រង់បាន «...ហៅមនុស្សមានបាប ឲ្យប្រែចិត្ត...» នេះហើយ ដែលអ្នកត្រូវចង់ចាំថា ព្រះទ្រង់ស្គាល់ ទ្រង់យល់ ហើយទ្រង់ជ្រាបគ្រប់ការទាំងអស់។ តើព្រះទ្រង់បានធ្វើអ្វីខ្លះ ដើម្បីនាំយើងចេញពីការរឹករររបស់លោកីយនេះ? ហើយនឹងជួយយើងឲ្យរួចផុតពីលោកីយដ៏អាក្រក់នេះផង។ យើងនៅក្នុងលោកីយ ហើយអ្វីៗមិនទៅតាមផ្លូវដែលយើងគិតនោះទេ តើយើងត្រូវធ្វើយ៉ាងណា? សូមបើកទៅគម្ពីររ៉ូមជំពូក៥ យើងនឹងឃើញ ពីការដែលព្រះទ្រង់បានធ្វើ មុនពេលដែលយើងរាល់គ្នាគិតមានពេលខ្លះ យើងហាក់ដូចជាត្រូវបានគ្របដណ្ដប់ជាមួយនឹងរបៀបនៃលោកីយនេះ ពេលខ្លះទៀតយើងអាចឃ្លាតឆ្ងាយពីរបៀបរបស់លោកីយនេះ ដោយចូលទៅក្នុងបន្ទប់ ហើយបិទទ្វារពីខាងក្រោយយើង នោះយើងនឹងមានអារម្មណ៍ធូរស្រាលជាច្រើន ដោយសេចក្ដីអធិស្ឋាន ការសិក្សាព្រះគម្ពីរ នឹងធ្វើការអ្វីដែលយើងត្រូវការ - នោះវាជា រពិត។

រ៉ូម៥:៦ «ដ្បិតកាលយើងនៅខ្សោយនៅឡើយ... [យើងដូចជាមនុស្សនៅលើលោកីយនេះដែរ យើងមិនអាចគ្រប់គ្រងលើអ្វីដែលយើងកំពុងធ្វើបានទេ យើងមិនដឹងខុស ហើយមិនដឹងត្រូវ យើងមិនយល់ពីអ្វីដែលអាក្រក់ យើងមិនយល់អំពីព្រះ នឹងពីអ្វីៗដែលទ្រង់ធ្វើទេ ហើយយើងពិតជាមិនបានយល់ ពីអ្វីដែលព្រះយេស៊ូវគ្រីស្ទបានធ្វើសំរាប់យើងរាល់គ្នានោះដែរ យើងក៏មិនបានយល់ពីអ្វីដែលព្រះវរបិតាទ្រង់បានធ្វើសំរាប់យើងតាមរយៈព្រះយេស៊ូគ្រីស្ទនោះទេ] ...លុះដល់កំណត់ហើយ នោះព្រះគ្រីស្ទទ្រង់បានសុគតជំនួសមនុស្សទមិលល្មើស ៧ កម្រនឹងមានអ្នកណាព្រមស្លាប់ជំនួសមនុស្សសុចរិតណាស់ ប៉ុន្តែប្រហែលជាមានអ្នកខ្លះហ៊ានស្លាប់ជំនួសមនុស្សល្អដែរទេដឹង ៨ តែឯព្រះ ទ្រង់សំដែងសេចក្ដីស្រឡាញ់របស់ទ្រង់ ដល់យើងរាល់គ្នាឲ្យឃើញច្បាស់ ដោយព្រះគ្រីស្ទបានសុគតជំនួសយើងរាល់គ្នា នោះគឺក្នុងកាលដែលយើងនៅមានបាបនៅឡើយផង ៩ ដូច្នេះ ដែលបានរាប់ជាសុចរិតដោយសារព្រះលោហិតទ្រង់ នោះប្រាកដជាយើងនឹងបានរួចចេញពីសេចក្ដីក្រោធដោយសារទ្រង់ ជាមិនខានលើសទៅទៀត ១០ ដ្បិតកាលយើងជាខ្មាំងសត្រូវ ...[ខ្មាំងសត្រូវរបស់ព្រះ នឹងខ្មាំងសត្រូវនៃសេចក្ដីសុចរិត]... បើយើងបានជាមេត្រីនឹងព្រះវិញទៅហើយ ដោយព្រោះព្រះរាជបុត្រាទ្រង់សុគតដូច្នេះ ដែលយើងបានជាមេត្រីហើយ នោះប្រាកដជាយើងនឹងបានសង្គ្រោះ ជាមិនខានលើសទៅទៀត ដោយទ្រង់មានព្រះជន្មរស់ឡើងវិញ» (រ៉ូម៦:៥-១០) ពីព្រោះព្រះគ្រីស្ទទ្រង់មានព្រះជន្មរស់នោះជាសេចក្ដីដែលសំខាន់បំផុត!

សូមបើកទៅគម្ពីរម៉ាថាយ ២២:១៤ នេះជាខដែលលើកទឹកចិត្ត ប្រសិនបើយើងយល់ឲ្យបានត្រឹមត្រូវ ខ្ញុំគិតថាយើងអាចយល់បាន៖ «ដ្បិតបានហៅមនុស្សជាច្រើន តែរើសបានតិចទេ» តើហេតុអ្វី

បានជារើសបានតិច? ពីព្រោះមានមនុស្សតិចណាស់ដែលបានប្រែចិត្ត! ព្រះទ្រង់រើសអ្នកដែលប្រែចិត្ត ហើយទទួលការទ្រង់បានត្រាស់ហៅរបស់ព្រះ។ សេចក្តីមេត្តាករុណា នឹងព្រះគុណរបស់ទ្រង់ បាននាំឱ្យយើងប្រែចិត្ត ហើយយើងឃើញពីសេចក្តីស្រឡាញ់ដែលព្រះអម្ចាស់មានចំពោះយើង។ សូមយើងវិលត្រឡប់ទៅឯការត្រាស់ហៅ ជាថ្មីវិញម្តងទៀត ខ្ញុំចង់ផ្តោតលើការត្រាស់ហៅ ពីព្រោះយើងអាចរស់នៅលើលោកីយនេះបាន ដោយសារការត្រាស់ហៅរបស់ព្រះអម្ចាស់។ យើងម្នាក់ៗ បានឃើញព្រឹត្តិការណ៍ដែលនៅជុំវិញយើង ប្រឆាំងនឹងយើង ហើយមានពេលខ្លះ បណ្តាលឱ្យយើងធ្លាក់ទឹកចិត្ត នឹងអស់សង្ឃឹម ហើយក៏ធ្វើឱ្យយើងឆ្ងល់ថា តើហេតុអ្វីបានជាខ្ញុំឆ្លងកាត់រឿងទាំងអស់នេះ? ខ្ញុំចង់ឲ្យអ្នកផ្តោតអារម្មណ៍លើព្រះបន្ទូលនេះ «ដ្បិតបានហៅមនុស្សជាច្រើន តែរើសបានតិចទេ» សូមយើងពិចារណាមើល តើការត្រាស់ហៅរបស់ព្រះ មានប្រយោជន៍អ្វីខ្លះសំរាប់យើង! អ្នកធ្លាក់ទឹកចិត្ត អ្នកអស់ម៉ាំងអ្នកធុញទ្រាន់នឹងការប្រយុទ្ធប្រឆាំងនឹងលោកីយ នឹងអំពើបាប នឹងអំពើទុច្ចរិត ហើយនឹងអំពើពុករលួយគ្រប់ជាន់ថ្នាក់ នៅក្នុងពួកអ្នកដឹកនាំរបស់លោកីយនេះ។ ពេលខ្លះខ្ញុំចង់តែវាយកំទេចទូរទស្សន៍របស់ខ្ញុំចោលទេ ពីព្រោះវាមិនដែលមានកម្មវិធីណាល្អម្តងសោះ។ កិច្ចការដែលកើតឡើងរបស់លោកីយនេះពិតជាមិនឲ្យគួរជឿបាន ពីព្រោះវាសំរាប់តែបំផ្លាញគំនិតរបស់អ្នកតែប៉ុណ្ណោះ គម្ពីរយ៉ូហាន ៦:៤៤ ចូរផ្តោតទៅលើការត្រាស់ហៅរបស់ព្រះ «គ្មានអ្នកណាអាចនឹងមកឯខ្ញុំ...[ព្រះគ្រីស្ទ]...បានទេ លើកតែព្រះវរបិតាដែលចាត់ឲ្យខ្ញុំឲ្យមក ទ្រង់ទាញនាំគេប៉ុណ្ណោះ ហើយខ្ញុំនឹងឲ្យអ្នកនោះរស់ឡើងវិញនៅថ្ងៃចុងបំផុត» តើព្រះទ្រង់ត្រាស់ហៅអ្នក ឲ្យអ្នកមានជោគជ័យ ឬឲ្យអ្នកបរាជ័យទេ? ព្រះអម្ចាស់ទ្រង់ត្រាស់ហៅអ្នក ទ្រង់ចង់ឲ្យអ្នកមានជោគជ័យ! ព្រះអម្ចាស់ទ្រង់ជាព្រះដែលគ្រប់គ្រងលោកីយ បានត្រាស់ហៅអ្នក ពីព្រោះអ្នកនឹងត្រូវគ្រប់គ្រងលោកីយនេះ ជាមួយទ្រង់ ហេតុនោះហើយ បានជាព្រះវរបិតាទ្រង់ ធ្វើសកម្មភាព នៅក្នុងជីវិតរបស់អ្នក ហើយជ្រើសរើសអ្នក! ដូច្នេះ មិនមានអ្វីអាចយកជ័យជំនះលើអ្នកបានឡើយ ពីព្រោះព្រះទ្រង់បានជ្រើសរើសអ្នក! អ្នកមិនអាចនិយាយថា ខ្ញុំជាមនុស្សដ៏សំខាន់បំផុតនៅលើផែនដីនេះទេ អ្នកមិនត្រូវអួតពីខ្លួនអ្នកនោះទេ គឺជាព្រះអម្ចាស់ទ្រង់បានត្រាស់ហៅអ្នកវិញ អ្នកគឺជារបស់ផងទ្រង់!។ ឥឡូវសូមអ្នកផ្តោតលើការត្រាស់ហៅនេះ សូមបើកទៅគម្ពីរ ១កូរិនថូសជំពូក ១ ហើយមើល តើព្រះអម្ចាស់បានធ្វើអ្វីខ្លះសំរាប់យើង? ព្រះទ្រង់បានត្រាស់ហៅយើង តាមរយៈព្រះគុណរបស់ទ្រង់ ១កូរិនថូស១:៣ «សូមឲ្យអ្នករាល់គ្នាបានប្រកបដោយនូវព្រះគុណ នឹងសេចក្តីសុខសាន្ត ...» ព្រះគុណ នោះសំខាន់បំផុត ដែលអ្នកអាចពិចារណា ហើយនឹកចាំថា ព្រះគុណរបស់ព្រះចំពោះអ្នក មានន័យថា:

- ព្រះអម្ចាស់បានត្រាស់ហៅអ្នក
- ព្រះអម្ចាស់ដឹងថាអ្នកជានរណា

- ព្រះអម្ចាស់ស្គាល់សេចក្តីកំសោយរបស់អ្នក
- ព្រះអម្ចាស់នឹងមិនថ្កោលទោសអ្នកចំពោះសេចក្តីកំសោយទេ

អ្នកត្រូវតែប្រែចិត្ត ហើយវិលមករកព្រះវិញ ហើយផ្តោតលើការត្រាស់ហៅរបស់អ្នក នោះជាការដ៏សំខាន់បំផុត ប្រសិនបើអ្នកធ្លាក់ទឹកចិត្ត នឹងខ្សោយ សូមផ្តោតលើការហៅរបស់ព្រះ ដើម្បីកុំឲ្យអ្នកមានអំនួត ប៉ុន្តែ ឲ្យអ្នកបានបន្ទាបខ្លួន ដើម្បីនឹងលើកសរសើរដំកើងដល់ព្រះអម្ចាស់ ពីការដ៏អស្ចារ្យរបស់ព្រះដែលទ្រង់បានត្រាស់ហៅ ហើយទ្រង់បានធ្វើការសំរាប់អ្នក ២៣ «...អំពីព្រះដ៏ជាព្រះវរបិតានៃយើងរាល់គ្នា នឹងពីព្រះអម្ចាស់យេស៊ូវគ្រីស្ទផង ៤ អរព្រះគុណដល់ព្រះនៃខ្ញុំ អំពីដំណើរអ្នករាល់គ្នា ជាដរាបដោយព្រោះព្រះគុណនៃព្រះ ដែលបានផ្តល់មកអ្នករាល់គ្នាក្នុងព្រះគ្រីស្ទយេស៊ូវ ៥ ព្រោះអ្នករាល់គ្នាបានចំរើនឡើងគ្រប់ជំពូក ដោយសារទ្រង់ គឺក្នុងគ្រប់ទាំងពាក្យ សំដី នឹងចំណេះទាំងអស់ដែរ ៦ តាមដែលសេចក្តីបន្ទាល់ពីព្រះគ្រីស្ទបានបញ្ជាក់ក្នុងពួកអ្នករាល់គ្នា ៧ ដល់ម្ល៉េះបានជាអ្នករាល់គ្នាមិនចាញ់គេខាងឯអំណោយទានណាមួយឡើយ ទាំងចាំទំរាំព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នាលេចមកផង ៨ ដែលទ្រង់នឹងតាំងអ្នករាល់គ្នាឲ្យខ្ជាប់ខ្ជួន ដរាបដល់ចុងបំផុត ឲ្យបានឥតកន្លែងបន្ទោសបាន ក្នុងថ្ងៃនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង ៩ ឯព្រះដែលបានហៅអ្នករាល់គ្នាមក ឲ្យមានសេចក្តីប្រកបនឹងព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង នោះទ្រង់ស្មោះត្រង់» (១កូរិនថូស១:២-៩) ប្រសិនបើខ្ញុំត្រូវតែរស់នៅដល់ថ្ងៃនោះ ព្រះអម្ចាស់ទ្រង់នឹងផ្តល់កម្លាំងឱ្យខ្ញុំ ដើម្បីឲ្យខ្ញុំអាចនឹងទ្រាំទ្របានដល់ចុងបញ្ចប់។

- ព្រះអម្ចាស់ទ្រង់នឹងមិនចាកចោលអ្នក ឲ្យអ្នកនៅតែឯងទេ
- ព្រះអម្ចាស់ទ្រង់នឹងមិនបដិសេធអ្នកទេ
- ព្រះអម្ចាស់ទ្រង់នឹងមិនបោះបង់ចោលអ្នកទេ

ប្រសិនបើអ្នកផ្តោតចំពោះការត្រាស់ហៅរបស់អ្នក នេះជាព្រះបន្ទូលដែលលើកទឹកចិត្តដ៏អស្ចារ្យ!

មានកិច្ចការជាច្រើនដែលយើងអាចសិក្សាបាន ប៉ុន្តែ ខ្ញុំចង់ផ្តោតអារម្មណ៍លើការត្រាស់ហៅរបស់យើង ហើយយើងត្រូវតែចងចាំថា ព្រះយេស៊ូវបានយាងមក ដើម្បីហៅមនុស្សមានបាប ឲ្យប្រែចិត្ត! ជាការពិតណាស់ យើងទាំងអស់គ្នាសុទ្ធតែជាមនុស្សមានបាប ហើយបានធ្វើបាបជាបន្តបន្ទាប់គ្រប់ពេលវេលា ពីព្រោះយើងមិនទាន់បានគ្រប់លក្ខណ៍នៅឡើយ។ មានផ្លូវមួយដែលយើងត្រូវផ្តោតអារម្មណ៍ លើការត្រាស់ហៅរបស់យើង ដូចជាយើងនឹងឃើញក្នុងពេលបន្តិចទៀតនេះ! ១កូរិនថូស១:២៦ «ឱបងប្អូនអើយ អ្នករាល់គ្នាឃើញថា ក្នុងពួកអ្នកដែលទ្រង់បានហៅ មិនសូវមានអ្នកប្រាជ្ញច្រើនខាងសាច់ឈាម ឬច្រើននាក់មានអំណាច នឹងច្រើនអ្នកដែលមានត្រកូលខ្ពស់នោះទេ ព្រះទ្រង់បានរើសពួកល្ងង់ល្ងើនៅ

លោកីយនេះ ដើម្បីនឹងធ្វើឲ្យអ្នកប្រាជ្ញមានសេចក្ដីខ្មាសវិញ... អ្នកបានឃើញថា វាជាការពិតណាស់ ពួកអ្នកប្រាជ្ញរបស់លោកីយនេះ គេមិនដឹងអ្វីទាំងអស់... ទ្រង់បានរើសពួកកំសោយនៅលោកីយនេះ ដើម្បីនឹងធ្វើឲ្យពួកខ្លាំងពូកែមានសេចក្ដីខ្មាស» (១២៦-២៧) ត្រូវហើយ យើងខ្សោយខាងសាច់ឈាម តើព្រះយេស៊ូវមានបន្ទូលយ៉ាងដូចម្ដេច? «...ឯវិញ្ញាណក៏ប្រុងជាស្រេចមែន តែសាច់ឈាមខ្សោយទេ» (ម៉ាថាយ២៦:៤១) តើសាវកប៉ុលបានសរសេរយ៉ាងដូចម្ដេច? «ខ្ញុំមិនប្រព្រឹត្តការល្អ ដែលខ្ញុំចង់ធ្វើនោះទេ តែការអាក្រក់ដែលខ្ញុំមិនចង់ធ្វើ នោះបែរជាខ្ញុំធ្វើវិញ» (រ៉ូម៧:១៩) ដូច្នេះ សាវកប៉ុល គាត់មានការប្រយុទ្ធនឹងអំពើបាបជាបន្តបន្ទាប់គ្នា ហើយយើងក៏ខ្សោយដែរ!

- តើព្រះអម្ចាស់ទ្រង់ជ្រាបការនោះឬទេ?
- តើយើងខ្សោយមែនឬទេ?
- តើព្រះអម្ចាស់ទ្រង់យល់ឬទេ?

មានអ្នកខ្លះមានចំណុចខ្សោយខុសៗគ្នា អ្នកខ្លះមានភាពទន់ខ្សោយខាងរាងកាយ អ្នកខ្លះមានចំណុចខ្សោយខាងលក្ខណៈ ដូចលោកអ័ប្រាហាំដែរឬ គាត់មានភាពទន់ខ្សោយ នឹងមិនយល់ពីការដែលគាត់ធ្វើដោយមិនបានគិតឲ្យបានត្រឹមត្រូវ អ៊ីសាកជាកូនក៏ធ្វើដូចគ្នាដែរ ដូច្នេះហើយ វាកើតមានឡើងនៅក្នុងគ្រួសារទាំងមូលរបស់កូនចៅលោកអ័ប្រាហាំៗ សូមយើងក្រឡេកមើល ទៅគ្រួសាររបស់យ៉ាកុប តើមានអ្វីកើតឡើងដល់យ៉ាកុប? អ្នកបានដឹងរឿងទាំងមូលស្រាប់ហើយ យ៉ាកុបគាត់មានជីវភាពលំបាក គាត់លំបាកណាស់ជាមួយនឹងប្រពន្ធរបស់គាត់ទាំងពីរនាក់ ហើយនឹងប្រពន្ធចុងពីរនាក់ទៀត ហើយវេទនាណាស់ទៅទៀត ដោយព្រោះកូនទាំង១២នាក់ ហើយនឹងពីរបៀបដែលកូនៗ របស់គាត់បានធ្វើចំពោះគាត់! យើងនឹងមើលពីការដែលពួកកូនៗរបស់យ៉ាកុបទាំងនោះ បានធ្វើដល់យ៉ូសែបៗ ពួកកូនយ៉ាកុបបានធ្វើពុតដាក់យ៉ាកុបអស់១៧ឆ្នាំ! ឲ្យយ៉ាកុបគិតថា យ៉ូសែបកូនប្រុសគាត់បានស្លាប់ហើយ លោកយ៉ាកុបតែងតែចេញទៅក្រៅ ហើយអង្គុយនៅក្រោមដើមឈើ ជាមួយនឹងអាវរបស់យ៉ូសែប ដែលប្រឡាក់ដោយឈាមពពែមកដាក់លើភ្លៅនោះ ហើយពោលថា «កូនរបស់អញបានស្លាប់ហើយ» បន្ទាប់មកអ្នកដឹងថា ព្រះទ្រង់បានផ្លាស់ប្រែរឿងនោះ ឲ្យទៅជាល្អវិញ ដូច្នេះ នោះវាជារឿងកំសោយរបស់មនុស្ស!

១កូរិនថូស១:២៨-៣០ «ហើយទ្រង់បានរើសអ្នកទាបថោកនៅលោកីយនេះ នឹងពួកអ្នកដែលគេមើលងាយ ព្រមទាំងរបស់ដែលគ្មានផង ដើម្បីនឹងលើកចោលរបស់ដែលមានចេញ ប្រយោជន៍កុំឲ្យមនុស្សណាបានអួតខ្លួន នៅចំពោះព្រះឡើយ តែដោយសារព្រះ នោះអ្នករាល់គ្នានៅក្នុងព្រះគ្រីស្ទ

យេស៊ូវ ដែលទ្រង់បានតាំងឡើង ទុកជាប្រាជ្ញាដែលមកពីព្រះ ហើយជាសេចក្តីសុចរិត សេចក្តីបរិសុទ្ធ នឹងសេចក្តីប្រោសលោះដល់យើងផង» (ខ២៨-៣០) ការនោះឯងដែលព្រះអម្ចាស់ទ្រង់កំពុងធ្វើសំរាប់យើងរាល់គ្នា។

ពេលខ្លះខ្ញុំគិតថាប្រសិនបើយើងរៀនមេរៀននៃការរស់នៅក្នុងលោកិយដ៏អាក្រក់នេះ - មិនមែនមានន័យថា យើងចូលរួមធ្វើអ្វីៗ ដែលលោកិយធ្វើនោះទេ ប៉ុន្តែ យើងនៅតែរងឥទ្ធិពលពីលោកិយនេះ - ប្រសិនបើយើងអនុញ្ញាតឲ្យអ្វីៗ មានឥទ្ធិពលមកលើអ្នក នោះអ្នកត្រូវតែស្វែងរកព្រះ អ្នកនឹងឃើញការត្រាស់ហៅរបស់អ្នក ហើយអ្នកនឹងឃើញនូវអ្វីៗ ដែលព្រះទ្រង់បានធ្វើសំរាប់អ្នក។

- អ្នកអាចនឹងធ្វងរួចពីការរបស់លោកិយនេះ
- អ្នកអាចទប់ទល់នឹងអ្វីដែលកំពុងកើតមានឡើង
- អ្នកអាចដឹងថា អ្នកមានសង្ឃឹមចំពោះការទាំងអស់

ហើយនឹងមានថ្ងៃមកដល់ ដែលព្រះអម្ចាស់ទ្រង់នឹងផ្លាស់ប្តូរអ្វីៗទាំងអស់នោះ រួមទាំងពួកមនុស្សគ្រប់គ្នាទាំងអស់ផង។

ឥឡូវនេះ ចូរយើងផ្តោតចំពោះលើរឿងមួយ ដែលសាវកប៉ុលបានសរសេរយ៉ាងច្បាស់ថា ព្រះអម្ចាស់បានត្រាស់ហៅមនុស្សមានបាប ឲ្យប្រែចិត្ត (១កូរិនថូស៦:៩-១១) «តើមិនដឹងថា ពួកទុច្ចរិតមិនដែលបានគ្រងនគរព្រះទុកជាមរដកទេឬអី កុំច្រឡំឡើយ ដ្បិតពួកមនុស្សកំផិត ពួកថ្វាយបង្គំរូបព្រះ ពួកសហាយស្មន់ ពួកអ្នកសំរេចកិច្ចដោយខ្លួនឯង ពួកលេងកូនជំង ពួកចោរ ពួកមនុស្សលោភ ពួកប្រមឹក ពួកត្មះតិះដៀល នឹងពួកប្លន់កំហែង នោះមិនដែលបានគ្រងនគរព្រះទុកជាមរដកឡើយ» (ខ៩-១១) ប៉ុន្តែ អ្នករាល់គ្នាបានលាងសំអាត ដោយព្រះលោហិតដ៏បរិសុទ្ធនៃព្រះយេស៊ូវគ្រីស្ទវិញ។ យើងត្រូវគិត នឹងត្រូវធ្វើ តបទៅនឹងសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់យ៉ាងដូចម្តេច? ម៉ាកុស១២ នេះជាចំណុចដ៏សំខាន់ ដែលយើងត្រូវធ្វើ គឺរក្សាគំនិតរបស់យើងលើការត្រាស់ហៅ យើងមិនមើលទៅឯព្រឹត្តិការណ៍ ដែលនៅជុំវិញយើងនោះទេ ប្រសិនបើសេដ្ឋកិច្ចនៅតែបន្តធ្លាក់ចុះ ប្រទេសនានា នឹងប្រឈមមុខការខ្វះស្បៀង អសន្តិសុខ នឹងកើនឡើង។ យើងមិនត្រូវខ្វាយនៅចំពោះស្ថានភាពទាំងនោះទេ ហើយស្ថានភាពទាំងនោះ ក៏មិនមែនជាកត្តាចំបង នៅក្នុងជីវិតរបស់យើងដែរ យើងត្រូវតែផ្តោតទៅលើការត្រាស់ហៅរបស់ព្រះអម្ចាស់។

ម៉ាកុស១២:៣០ «ហើយឯងត្រូវស្រឡាញ់ ដល់ព្រះអម្ចាស់ ជាព្រះនៃឯង ឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង អស់អំពីគំនិត ហើយអស់អំពីកំឡាំងនៃឯង» នេះជាកូនសោដ៏សំខាន់ ដែលអ្នកត្រូវយល់។ សេចក្តីសង្គ្រោះមិនមែនអាស្រ័យលើស្ថានភាពនៅជុំវិញយើងនោះទេ!

- គិតពីការត្រាស់ហៅរបស់យើង
- គិតពីអ្វីដែលព្រះបានធ្វើ ដើម្បីនឹងត្រាស់ហៅយើង
- គិតពីអ្វីដែលព្រះបានផ្តល់ផ្តង់យើង

សិក្សាអំពីអត្ថបទនេះ! អធិស្ឋានពីអត្ថបទនេះ! ហើយត្រូវធ្វើដូចដែលយើងត្រូវធ្វើ នាំអស់ទាំងគំនិត ដើម្បីឲ្យបានស្តាប់បង្គាប់តាមព្រះយេស៊ូវគ្រីស្ទ ធ្វើគ្រប់ការល្អ ហើយដកអំពើអាក្រក់ចេញតាមរយៈអំណាច នៃវិញ្ញាណបរិសុទ្ធរបស់ព្រះយេស៊ូវគ្រីស្ទ ហើយទ្រង់ក៏មានបន្ទូលថា ខ៣១ ឯបញ្ញត្តទី២ ក៏បែបដូចគ្នា គឺថា ត្រូវឲ្យស្រឡាញ់អ្នកជិតខាងដូចឯងខ្លួន» ពិតណាស់ បងប្អូនស្ងួនភ្ងា យើងត្រូវស្រឡាញ់គ្នា ដូចព្រះគ្រីស្ទបានស្រឡាញ់យើង -នេះជាការដ៏សំខាន់ណាស់ ជាពិសេស ការជួបជុំគ្នានៅថ្ងៃសប្ប័ទ ជាមួយរាស្ត្ររបស់ព្រះ ជាការដែលមានទំនង ដោយការប្រកបគ្នា ក្នុងសេចក្តីស្រឡាញ់ៗ ព្រះអម្ចាស់ទ្រង់នឹងយកព្រះហឫទ័យទុកនឹងអ្នក ប៉ុន្តែ បើអ្នកមិនស្រឡាញ់ព្រះអង្គ ហើយអ្នកមិនស្រឡាញ់អ្នកជិតខាងខ្លួននោះទេ អ្វីៗទាំងអស់ពិតជាគ្មានន័យអ្វីឡើយៗ នេះហើយជាមូលហេតុ ដែលយើងត្រូវតែផ្តោតចំពោះពីព្រោះអ្វីៗដែលខ្ញុំកំពុងនិយាយនេះ គឺការថែរក្សា នឹងការពារខ្លួនរបស់អ្នក នៅក្នុងលោកីយនេះ ដែលអ្នកត្រូវការ មិនមែនកើតមកពីខ្លួនអ្នកទេ គឺមកអំពីព្រះអម្ចាស់វិញ ដែលពេញដោយសេចក្តីស្រឡាញ់ ហើយត្រូវឲ្យយើងស្រឡាញ់ព្រះអម្ចាស់តាមរបៀបនេះៈ

- អស់អំពីចិត្ត
- អស់ពីអំពីព្រលឹង
- អស់អំពីគំនិត
- ហើយអស់អំពីកម្លាំងនៃឯង

យើងដឹងថាលោកីយនេះ កំពុងតែដុនដាបទៅៗ ផេទនា នឹងអំពើពុករលួយ កាន់តែចំរើនច្រើនឡើង ដែលធ្វើឲ្យលោកីយនេះ កាន់តែយ៉ាប់យ៉ឺនៗទៅ គ្មានអ្វីអាចឃាត់ឃាំងបានឡើយៗ ខ្ញុំក៏បានប្រាប់ទៅអស់អ្នកដែលកំពុងព្យាយាមបញ្ឈប់ការរំលូតកូន នឹងជួយសង្គ្រោះទារកនៅក្នុងផ្ទៃម្តាយ- តើការរំលូតកូនបានចាប់ផ្តើមនៅកន្លែងណា? តើនៅក្នុងគ្លីនិក? ឬក្នុងគំនិតរបស់បុគ្គលដែលពាក់ព័ន្ធ? គឺនៅក្នុងគំនិតរបស់បុគ្គលដែលពាក់ព័ន្ធ នោះហើយជាមូលហេតុ ដែលខ្ញុំបាននិយាយពីមុន ប្រសិនបើថ្នាំការពារការរំលូតកូនរបស់បារាំងមាននៅលើទីផ្សារ នោះការរំលូតកូនមិនមែនជាសំណួរទៀតទេៗ ការរំលូតកូនក្លាយជាការសម្រេចចិត្តរបស់ស្ត្រីម្នាក់ៗ រហូតមកដល់សព្វថ្ងៃនេះ! រស់នៅក្នុងលោកីយ ដែលយកការល្អ ថាជាអាក្រក់ ហើយយកការអាក្រក់ ហៅថាល្អៗ គ្មានការអ្វីដែលយើងអាចនឹងធ្វើបានឡើយ

ដើម្បីផ្លាស់ប្តូរស្ថានការណ៍របស់លោកីយនេះបានទេ អ្នកប្រហែលជាអាចជួយដល់មនុស្សម្នាក់បាន ប៉ុន្តែ អ្នកមិនអាចផ្លាស់ប្តូរលោកីយបានទេ ពីព្រោះព្រះយេស៊ូវមាន បន្ទូលថា «...នគរខ្ញុំមិនមែនត្រូវខាងលោកីយនេះទេ...» (យ៉ូហាន១៨:៣៦) ហេតុនេះហើយ ប្រសិនបើអ្នកផ្តោតចិត្ត គំនិត លើលោកីយនេះ នោះអ្នកនឹងធ្លាក់ទឹកចិត្ត ហើយនឹងអស់សង្ឃឹម។

សូមយើងមើលទៅ គម្ពីរ១កូរិនថូសជំពូក២ នោះយើងនឹងឃើញពីជ័យជំនះ នឹងអំណោយទានដ៏អស្ចារ្យដែលព្រះបានប្រទានដល់យើង ឲ្យយើងបានផ្តោតលើការត្រាស់ហៅរបស់ទ្រង់។ បងប្អូនអើយ សូមមើលការត្រាសរហៅរបស់អ្នក តើការត្រាស់ហៅនេះជាអ្វី ដែលយើងត្រូវមើល? ជាការមួយដែលមានតែព្រះទេ ដែលអាចផ្តល់ឱ្យយើង បើយើងបែរទៅរកព្រះអង្គ ដោយសេចក្តីស្រឡាញ់ដល់ទ្រង់ នោះទ្រង់នឹងផ្គត់ផ្គង់អ្វីៗដែលយើងត្រូវការ។

១កូរិនថូស២:៩ «ដូចមានសេចក្តីចែងទុកមកថា សេចក្តីដែលភ្នែកមិនដែលឃើញ ត្រចៀកមិនដែលឮ ហើយចិត្តនឹកមិនដែលដល់ គឺសេចក្តីនោះឯងដែលព្រះបានរៀបចំទុក សំរាប់ពួកអ្នកដែលស្រឡាញ់ទ្រង់... [កំណត់ចំណាំ គន្លិះពាក្យ: សំរាប់ពួកអ្នកដែលស្រឡាញ់ទ្រង់ តើត្រូវឲ្យយើងស្រឡាញ់ព្រះដូចម្តេច? គឺត្រូវឲ្យស្រឡាញ់ព្រះអម្ចាស់ ឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង អស់អំពីគំនិត ហើយអស់អំពីកំឡាំងនៃឯង]... ព្រះទ្រង់បានសំដែង ឲ្យយើងរាល់គ្នាឃើញសេចក្តីទាំងនោះ ដោយសារវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ដ្បិតវិញ្ញាណបរិសុទ្ធនៃទ្រង់ស្ទង់មើលគ្រប់ទាំងអស់ ព្រមទាំងសេចក្តីជ្រាលជ្រៅនៃព្រះផង» (២៩-១០) ពីព្រោះព្រះទ្រង់បាន ត្រាស់ហៅយើង ហើយប្រទានវិញ្ញាណបរិសុទ្ធរបស់ទ្រង់មកយើង។

- ពីព្រោះទ្រង់បានត្រាស់ហៅយើង
- ប្រទានវិញ្ញាណបរិសុទ្ធរបស់ទ្រង់មកយើង
- ប្រទានដំរិះប្រាជ្ញា នឹងការយល់ដឹងមកយើង

ព្រះអម្ចាស់បានប្រទានដល់យើងនូវចំណេះដឹង ខាងឯសេចក្តីពិត។

នៅបច្ចុប្បន្ននេះ លោកីយកំពុងតែប្រឈមមុខនឹងបញ្ហាច្រើនណាស់ យើងមានការព្រួយបារម្ភយ៉ាងខ្លាំង ដោយព្រោះយើងរស់នៅក្នុងលោកីយនេះ ដែលធ្វើឱ្យយើងភ្លេចគិតពីការត្រាស់ហៅរបស់យើងហើយធ្វើឲ្យយើងមិនឆ្លើយតបទៅព្រះ តាមរបៀបដែលយើងត្រូវធ្វើនោះទេ។ ដូច្នេះ យើងឲ្យត្រូវស្រឡាញ់ដល់ព្រះអម្ចាស់ ជាព្រះនៃយើង ឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង អស់អំពីគំនិត ហើយអស់អំពីកំឡាំងឯង តើមែនឬទេ? មែនហើយ! «...ដ្បិតវិញ្ញាណបរិសុទ្ធនៃទ្រង់ស្ទង់មើលគ្រប់ទាំងអស់ព្រមទាំងសេចក្តីជ្រាលជ្រាលជ្រៅនៃព្រះដែរ ដ្បិតបើមិនមែនជាវិញ្ញាណ ដែលនៅក្នុងខ្លួនមនុស្សទេ នោះ

នោះតើនឹងមានអ្វីនឹងស្គាល់សណ្ដានមនុស្សនោះបាន ហើយបើមិនមែនជាវិញ្ញាណនៃព្រះ នោះក៏គ្មានអ្នកណាស្គាល់សណ្ដានព្រះបានដែរ» (១០-១១) ព្រះទ្រង់បានត្រាស់ហៅអ្នក **ផ្ដោតលើការត្រាស់ហៅនោះ!** អ្វីក៏ដោយដែលជាបន្ទុកនាំឱ្យអ្នកធ្លាក់ចុះ មិនថាកាលៈទេសៈណាក៏ដោយ ក្នុងលោកីយដែលរំខានអ្នក មានបញ្ហាអ្វីក៏ដោយ អ្នកត្រូវស្វែងរកព្រះ! ប្រសិនបើអ្នកបានធ្វើបាប អ្នកត្រូវតែប្រែចិត្តពីអំពើបាបនោះ ហើយព្រះអម្ចាស់ទ្រង់នឹងអត់ទោសបាបឲ្យអ្នក ប្រសិនបើអ្នកមិនព្រមប្រែចិត្ត នោះអ្នកបានបន្តប្រព្រឹត្តអំពើបាបដែលមិនអាចអត់ទោសឲ្យបាន ពីព្រោះអ្នកមិនបានប្រែចិត្ត។

- តើព្រះអម្ចាស់បានអត់ទោសឲ្យសូលពីបទសម្លាប់គ្រីស្ទានឬទេ? ព្រះទ្រង់បានអត់ទោសបាបឲ្យសុល!
- តើព្រះយេស៊ូវបានអត់ទោសឲ្យស្រីសំផឹងដែលបានលាងជើងទ្រង់ដោយទឹកភ្នែកនឹងសក់របស់នាងទេ? ទ្រង់បានអត់ទោសឲ្យ!
- តើព្រះយេស៊ូវបានអត់ទោសឲ្យបុរសស្វិតដៃមែនឬទេ? គឺមែន!
- តើព្រះយេស៊ូវបានអនុញ្ញាតឲ្យស្ត្រីដែលគេចោទប្រកាន់ពីការមិនពិត ឲ្យរួចខ្លួន ឬទេ?

តើព្រះយេស៊ូវបានព្យាបាលបុរសពិការភ្នែក ដែលមិនបានធ្វើបាបឲ្យជាមែនទេ? គឺមែន! ១២ «ឯយើងរាល់គ្នា យើងមិនបានទទួលវិញ្ញាណរបស់លោកីយទេ គឺទទួលវិញ្ញាណដែលមកពីព្រះវិញ ដើម្បីឲ្យបានស្គាល់អស់ទាំងព្រះគុណ ដែលព្រះបានផ្ដល់មកយើង... [អ្នកមិនអាចចំណេញបានព្រះគុណ អ្នកមិនអាចទទួលបានដោយប្រការណាទេ គឺព្រះទ្រង់បានប្រទានមកអ្នកដោយសទ្ធា]... ហើយយើងក៏និយាយពីសេចក្ដីទាំងនោះឯង មិនមែនដោយពាក្យសំដី ដែលប្រាជ្ញាមនុស្សបានបង្រៀនទេ គឺដោយពាក្យសំដី ដែលវិញ្ញាណបរិសុទ្ធរបស់ព្រះបង្រៀនវិញ ព្រមទាំងផ្ទឹមពន្យល់សេចក្ដីខាងឯវិញ្ញាណដោយសារសេចក្ដីខាងវិញ្ញាណផង ប៉ុន្តែ មនុស្សខាងសាច់ឈាម គេមិនទទួលសេចក្ដីខាងឯវិញ្ញាណនៃព្រះទេ ពីព្រោះជាសេចក្ដីល្ងង់ល្ងើដល់គេ ក៏រកស្គាល់មិនបានដែរ ដ្បិតត្រូវឯសេចក្ដីទាំងនោះ ត្រូវពិចារណាយល់ខាងវិញ្ញាណវិញ» (១២-១២) នោះហើយជាមូលហេតុដែលលោកីយ បានធ្វើឲ្យគ្រីស្ទានមានសេចក្ដីសៅហ្មង ពីព្រោះលោកីយគេមិនទទួលសេចក្ដីពិត ខាងឯវិញ្ញាណទេ អ្វីៗដែលយើងត្រូវធ្វើ គឺការអធិស្ឋាន ដូចដែលព្រះយេស៊ូវបានអធិស្ឋាន «ទូលបង្គំមិនសូមឲ្យយកគេចេញពីលោកីយទេ គឺសូមឲ្យទ្រង់រក្សាគេ ឲ្យរួចពីសេចក្ដីអាក្រក់វិញ» (យ៉ូហាន១៧:១៥) យើងត្រូវតែអធិស្ឋាន ដូចដែលព្រះយេស៊ូវបានអធិស្ឋាន «...ពីព្រោះពួកគេជាមនុស្សល្ងីល្ងើ» សូមបើកទៅគម្ពីរអេភេសូរជំពូក២ ចូរយើងផ្ដោតលើសេចក្ដីស្រឡាញ់ ដែលព្រះអម្ចាស់ទ្រង់មានចំពោះយើង បទគម្ពីរទាំងនេះ គឺជាមូលដ្ឋានដែលយើងបានសិក្សាពីមុន ប៉ុន្តែ រឿងដែលខ្ញុំចង់ផ្ដោតលើ គឺគ្មានអ្វីអាចរារាំងអ្នក មិនឲ្យព្រះអង្គជួយ

អ្នក នោះគ្មានទេ ប្រសិនបើអ្នកថ្វាយអស់ទាំងបន្ទុក ការលំបាក នឹងបញ្ហារបស់លោកីយដែលនៅជុំវិញអ្នកដល់ព្រះ នោះព្រះទ្រង់អាចនឹងជួយអ្នកបាន។

អេភេសូរ២:២ «ជាការដែលអ្នករាល់គ្នាបានប្រព្រឹត្ត តាមរបៀបលោកីយនេះ គឺតាមមេគ្រប់គ្រងរាជ្យលើអាកាស ជាវិញ្ញាណ ដែលសព្វថ្ងៃនេះ បណ្តាលមកក្នុងពួកមនុស្សរឹងចចេស... [ហើយឥឡូវនេះ កំពុងតែចំរើនអំណាចកាន់តែខ្លាំងឡើងថែមទៀត ហើយបង្កើត ឲ្យមានមធ្យោបាយកាន់តែច្រើនឡើងៗ ដើម្បីព្យាយាមនឹងទាក់ទាញពួកអ្នកដែលជាគ្រីស្ទានពិត ឲ្យបោះបង់ចោលសេចក្តីជំនឿទៅតាមពួកគេ] ...យើងរាល់គ្នាទាំងអស់ក៏បានប្រព្រឹត្តក្នុងពួកនោះពីដើមដែរ ដោយសេចក្តីប៉ងប្រាថ្នារបស់ សាច់ឈាមយើង ទាំងប្រព្រឹត្តសេចក្តីដែលសាច់ឈាម នឹងគំនិតយើងចង់បានផង ហើយតាមកំណើតយើង នោះយើងជាមនុស្សជាប់ក្នុងសេចក្តីខ្ញាល់ ដូចជាមនុស្សឯទៀតដែរ ប៉ុន្តែ ព្រះដែលទ្រង់មានសេចក្តីមេត្តាករុណាដ៏លើសលប់ ដោយព្រោះសេចក្តីស្រឡាញ់ជាខ្លាំង... [អ្នកកំពុងត្រូវបានសង្គ្រោះដោយសារព្រះគុណ ដែលទ្រង់មានដល់យើង]...ដែលទ្រង់មានដល់យើងរាល់គ្នា ក្នុងកាលដែលយើងនៅស្លាប់ក្នុងការរំលងនៅឡើយ នោះទ្រង់បានប្រោសឲ្យយើងរាល់គ្នាបានរស់ ជាមួយនឹងព្រះគ្រីស្ទ គឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះ» (អេភេសូរ២:២-៥) នោះហើយជាកិច្ចដែលយើងត្រូវផ្តោតលើ៖

- សេចក្តីស្រឡាញ់របស់យើងចំពោះព្រះ
- សេចក្តីស្រឡាញ់របស់ព្រះចំពោះយើង
- ព្រះអម្ចាស់ទ្រង់ត្រាស់ហៅយើង
- ការឆ្លើយតបរបស់យើងទៅព្រះ

**នោះជាការដែលសំខាន់!**

២ពេត្រុស ៣:១៨ «ចូរឲ្យអ្នករាល់គ្នាចំរើនឡើងក្នុងព្រះគុណ ហើយក្នុងការស្គាល់...[ចំណេះដឹង]..ដល់ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ ជាព្រះអង្គសង្គ្រោះនៃយើងរាល់គ្នា...» [ការនេះដែលយើងត្រូវធ្វើខាងវិញ្ញាណ ហើយក៏ជាការដែលលើកទឹកចិត្តផងដែរ!] បងប្អូនអើយ ហេតុអ្វីបានជាយើងមានថ្ងៃឈប់សំរាក ឬថ្ងៃសប្ប័ទ ជារៀងរាល់ចុងសប្តាហ៍? ខ្ញុំពិតជាអរគុណដល់ព្រះអម្ចាស់ខ្លាំងណាស់ សំរាប់ថ្ងៃឈប់សំរាក ឬថ្ងៃសប្ប័ទ។ ថ្ងៃឈប់សំរាករបស់ព្រះ ជាថ្ងៃបរិសុទ្ធ នៅលើផែនដីនេះ បើគ្មានថ្ងៃឈប់សំរាក ឬថ្ងៃសប្ប័ទទេ តើមនុស្សយើងនឹងត្រូវទៅជាយ៉ាងណា? មនុស្សពិតជានឹងមិនមានកម្លាំង ឬមានសមត្ថភាព ទាំងខាងស្មារតី ឬខាងវិញ្ញាណ ដើម្បីទប់ទល់ នឹងប្រយុទ្ធ ប្រឆាំងនឹងលោកីយនេះ ដែលពោរពេញដោយអំពើអាក្រក់ នឹងសេចក្តីទុច្ចរិតគ្រប់យ៉ាង។ ថ្ងៃឈប់សំរាក នៅចុងសប្តាហ៍ ដូចជាកោះមួយបរិសុទ្ធរបស់យើង បានឈប់សំរាកពីកិច្ចការនឿយហត់របស់លោកីយនេះរាល់គ្នា បើមិនដូច្នោះ យើង

នឹងគ្មានកម្លាំង ដូចមនុស្សដទៃទៀត ដែលនៅលើលោកីយនេះដែរ។

២ពេត្រុស១:១០ «ដូច្នេះ បងប្អូនអើយ គួរឲ្យអ្នករាល់គ្នាមានចិត្តឧស្សាហ៍វិញ ដើម្បីនឹងធ្វើឲ្យដំណើរដែលទ្រង់ហៅ ហើយរើសតាំងអ្នករាល់គ្នា...[រើសតាំង គួរតែជា «ការជ្រើសរើស» ... ព្រះទ្រង់បានរើសអ្នក ឯអ្នកមិនបានជ្រើសរើសព្រះទេ គឺព្រះជ្រើសរើសអ្នកវិញទេតើ] ... បានពិតប្រាកដឡើង បើប្រព្រឹត្តដូច្នោះ នោះអ្នករាល់គ្នាមិនដែលជំពប់ឡើយ» (១១០) បងប្អូនអើយ មិនដែលបរាជ័យទេ! សូមចងចាំពីសាវកប៉ុលបានសរសេរថា «ហេតុនោះបានជាខ្ញុំទូន្មាន ឲ្យសំដែងសេចក្តីស្រឡាញ់ ដល់អ្នកនោះឲ្យជាក់លាក់» (២កូរិនថូស២:៨) នេះហើយជាការដែលយើងត្រូវធ្វើ - ផ្តោតអារម្មណ៍ម្តងទៀត ទៅលើការត្រាស់ហៅរបស់ព្រះអម្ចាស់។

សូមមើលទៅ ២ពេត្រុស១:២ «សូមឲ្យព្រះគុណ នឹងសេចក្តីសុខសាន្ត បានចំរើនដល់អ្នករាល់គ្នាឲ្យបានស្គាល់ព្រះ...[ព្រះវរបិតា]... នឹងព្រះយេស៊ូវ ជាព្រះអម្ចាស់នៃយើង»

- តើស្គាល់តាមរបៀបណា? គឺតាមរយវិញ្ញាណបរិសុទ្ធ!
- តើស្គាល់តាមរបៀបណា? តាមរយសេចក្តីស្រឡាញ់!
- តើស្គាល់តាមរបៀបណា? គឺដោយស្តាប់បង្គាប់ព្រះអម្ចាស់!
- តើស្គាល់តាមរបៀបណា? ដោយការឆ្លើយតបទៅទ្រង់ ដោយអនុញ្ញាតឲ្យវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ជួយយើង ដើម្បីមិនឲ្យយើងតាមលោកីយ ឲ្យវាមានឱកាសបំផ្លាញយើងឡើយ!

១៣ «ដ្បិតព្រះចេស្តានៃព្រះបានផ្តល់ឲ្យយើងរាល់គ្នាមានគ្រប់របស់ទាំងអស់ ...[ខាងឯជីវិត នឹងខាងសេចក្តីគោរពប្រតិបត្តិដល់ព្រះ គ្រប់សេចក្តីត្រូវការរបស់អ្នក គឺមាននៅក្នុងព្រះគម្ពីរ ហើយសេចក្តីត្រូវការខាងជីវិត នឹងអំណាច ព្រះចេស្តារបស់ព្រះ ដោយសារវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ដែលជួយឲ្យអ្នករស់នៅផ្ទុយស្រឡះពីលោកីយនេះ តាមរយៈព្រះយេស៊ូវគ្រីស្ទ] ...ខាងឯជីវិត នឹងសេចក្តីគោរពប្រតិបត្តិដល់ព្រះ ដោយយើងបានស្គាល់ព្រះអង្គ ដែលទ្រង់ហៅយើងរាល់គ្នាមក ដោយសារសិរីល្អ នឹងសគុណរបស់ទ្រ ង់ ដែលដោយសារសេចក្តីទាំងនោះ ទ្រង់បានប្រទានសេចក្តីសន្យាដ៏ធំបំផុត ហើយវិសេសផង មកយើងរាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាបានចំណែកជានិស្ស័យនៃព្រះ ...ដោយបានរួចពីសេចក្តីពុករលួយនៅក្នុងលោកីយនេះ ដែលកើតអំពីសេចក្តីប៉ងប្រាថ្នា» (២ពេត្រុស១: ២-៤)

ហេតុអ្វីបានជាទ្រង់មានបន្ទូលពីសេចក្តីសន្យាដ៏អស្ចារ្យ តើសេចក្តីសន្យានោះមានតម្លៃឬទេ? តើនេះជាសេចក្តីដែលហួសពីចំណេះដឹង នឹងការរំពឹងទុករបស់យើងឬ? សូមនឹកចាំពីលោកពេត្រុសគឺជាម្នាក់ក្នុងចំណោមអ្នក ដែលបានទៅឯភ្នំជាមួយព្រះយេស៊ូវ ហើយបានឃើញការផ្លាស់ប្រែទ្រង់ទ្រាយ

របស់ព្រះយេស៊ូវផ្ទាល់ភ្នែក ហើយក្រោយមកទៀត គាត់មានសេចក្ដីចេះឆ្លុលនៅក្នុងគំនិតរបស់គាត់ ដែលសាវកយ៉ូហានសរសេរថា «ភ្នែកបានឃើញ ហើយដៃបានប៉ះពាល់ ខាងឯព្រះបន្ទូលនៃជីវិត» ទាំងអស់នេះ គឺជាការសន្យាដ៏អស្ចារ្យ នឹងមានតម្លៃលើសពីអ្វីដែលបានចែងទុក ២៤ «...ទ្រង់បានប្រទានសេចក្ដីសន្យាដ៏ធំបំផុត...» ដោយសារសេចក្ដីសន្យានោះ អ្នកត្រូវតែគិត ហើយត្រូវតែផ្ដោតចំពោះសេចក្ដីសន្យានោះ ពីព្រោះជីវិតខាងសាច់ឈាមកំពុងតែកន្លងទៅ ហើយយើងមិនមានអំណាចអាចឃាត់វាបានទេ។ ប្រសិនបើយើងទទួលបានជីវិតខាងសាច់ឈាម រស់នៅបានយូរបន្តិច នោះគឺជាសេចក្ដីមេត្តាករុណារបស់ព្រះហើយ។

ឥឡូវនេះ យើងបានទទួលវិញ្ញាណបរិសុទ្ធរបស់ព្រះហើយ វិញ្ញាណនោះនឹងជួយរំលឹកយើង សាវកប៉ុលបានសរសេររំលឹកយើង ថា «...ខ្ញុំរំលឹកដល់អ្នក ឲ្យដាស់តឿនអំណោយទានរបស់ព្រះ...» (២ធីម៉ូថេ១:៦) តើវិញ្ញាណបរិសុទ្ធរបស់ព្រះជួយរំលឹកយើងយ៉ាងដូចម្ដេចខ្លះ? គឺឲ្យយើងផ្ដោតលើការត្រាស់ហៅដែលព្រះបានប្រទានមកយើង! ហើយបន្ទាប់មកយើងត្រូវដើរតាមជំហានទាំងនោះ ដូចដែលយើងបានឃើញស្រាប់ «...យើងមាននិស្ស័យជាព្រះ ... [យើងដឹងថាអ្វីដែលសំខាន់បំផុត គឺយើងត្រូវបានប្រោសឲ្យរស់ពីស្លាប់ឡើងវិញ ដើម្បីនឹងចូលទៅក្នុងនគររបស់ព្រះ តើត្រឹមត្រូវទេ? គឺត្រឹមត្រូវ! ដូច្នេះ យើងអាចរួចផុតពីសេចក្ដីប៉ងប្រាថ្នារបស់លោកីយនេះ។ នៅថ្ងៃសប្ប័ទ ជាថ្ងៃដែលយើងចំណាយពេលវេលានៅចំពោះព្រះអម្ចាស់ នឹងប្រកបជាមួយបងប្អូន តើត្រូវទេ? គឺត្រូវ! ថ្ងៃសប្ប័ទ ជាថ្ងៃបរិសុទ្ធ ដែលមានវត្តមានរបស់ព្រះដ៏បរិសុទ្ធនៅថ្ងៃនោះ ហើយទ្រង់ក៏ប្រទានពរ ទាំងញែកចេញជាបរិសុទ្ធ។

១ពេត្រុស១:៥ «គឺឲ្យយើងរាល់គ្នា ដែលព្រះចេស្ដានៃព្រះកំពុងតែថែរក្សា ដោយសារសេចក្ដីជំនឿ... [នេះជាជំហ៊ាន]...សំរាប់ឲ្យបានសេចក្ដីសង្គ្រោះ ...[ធ្វើអ្វីដែលត្រឹមត្រូវ បន្ថែមចំណេះដឹង ឲ្យបានចេះត្រួតត្រាចិត្ត គំនិត ឲ្យចេះអត់សង្កត់ចិត្ត ឲ្យសេចក្ដីអត់សង្កត់ចិត្តបានខ្ជាប់ខ្ជួន ឲ្យសេចក្ដីខ្ជាប់ខ្ជួនបានចេះគោរពប្រតិបត្តិដល់ព្រះ ឲ្យសេចក្ដីគោរពប្រតិបត្តិ បានចេះរាប់អានគ្នាជាបងប្អូន ហើយឲ្យសេចក្ដីរាប់អានគ្នាបានសេចក្ដីស្រឡាញ់ថែមទៀត]... ដែលប្រុងប្រៀបនឹងសំដែងមកនៅជាន់ក្រោយបង្អស់នោះ អ្នករាល់គ្នាក៏មានសេចក្ដីអំណរជាខ្លាំង ក្នុងសេចក្ដីសង្គ្រោះនោះ ទោះបើសព្វថ្ងៃនេះត្រូវរងទុក្ខព្រួយជាយូរបន្តិច ដោយកើតមានសេចក្ដីល្បួងផ្សេងៗក៏ដោយ ដើម្បីឲ្យការសាកលសេចក្ដីជំនឿនៃអ្នករាល់គ្នា ដ៏វិសេសជាងមាសដែលតែងតែខូច ទោះបើបានសាកនឹងភ្លើងក៏ដោយ នោះបានឃើញសំរាប់ជាសេចក្ដីសរសើរ កេរ្តិ៍ឈ្មោះ នឹងសិរីល្អ ក្នុងកាលដែលព្រះយេស៊ូវគ្រីស្ទទ្រង់លេចមក» (ខ៥-៧) យ៉ាងនេះឯង ដើម្បីនឹងធ្វើឲ្យដំណើរដែលទ្រង់ហៅ ហើយរើសតាំងអ្នករាល់គ្នាបានពិតប្រាកដឡើង។

ឥឡូវនេះ សូមមើលទៅ គម្ពីរ១យ៉ូហានជំពូក៣ យើងបាននិយាយអំពីរឿងនេះ ពីមុនមកហើយ ប៉ុន្តែ ខ្ញុំចង់អានម្តងទៀត កត់ទុកក្នុងកំណត់ត្រា ដើម្បីឲ្យយើងបានដឹងជាក់ កង ១យ៉ូហាន៣:១ «មើល ... [យកចិត្តទុកដាក់ ហើយស្វែងយល់] ...សេចក្តីស្រឡាញ់យ៉ាងណាហ្ន៎ ដែលព្រះវរបិតាបានផ្តល់មកយើងរាល់គ្នា ឲ្យយើងបានហៅថាជាកូនរបស់ព្រះដូច្នេះ... [កូនរបស់ទ្រង់ផ្ទាល់]... គឺដោយហេតុនោះបានជាលោកីយមិនស្គាល់យើងទេ ពីព្រោះមិនស្គាល់ទ្រង់ដែរ ពួកស្ងួនភ្ងាអើយ ឥឡូវនេះ យើងរាល់គ្នាជាកូនព្រះហើយ តែដែលយើងរាល់គ្នានឹងបានទៅជាយ៉ាងណាទៀត នោះមិនទាន់សំដែងមកនៅឡើយ ប៉ុន្តែ យើងដឹងថា កាលណាទ្រង់លេចមក នោះយើងនឹងបានដូចជាទ្រង់ ដ្បិតដែលទ្រង់យ៉ាងណា នោះយើងនឹងឃើញទ្រង់យ៉ាងនោះឯង» (១យ៉ូហាន៣:១-២)

នេះជាបទគម្ពីរដែលត្រូវមើល - មែនទេ? យើងមិនចាំបាច់ព្រួយបារម្ភអំពីសាច់ឈាមទេ យើងក៏មិនចាំបាច់ព្រួយបារម្ភអំពីលោកីយ នឹងពីអ្វីៗដែលកំពុងកើតឡើងនោះឡើយៗ ពីព្រោះព្រះទ្រង់ជ្រាបអ្វីៗដែលមាននៅក្នុងលោកីយ ហើយព្រះទ្រង់នឹងធ្វើតាមពេលវេលាកំណត់ នឹងតាមកម្មវិធីរបស់ទ្រង់ គឺដោយសារព្រះហើយ ទើបយើងអាចរស់នៅក្នុងលោកីយនេះបាន ដូច្នេះ យើងត្រូវផ្តោតលើការត្រាស់ហៅ នឹងលើសេចក្តីសន្យារបស់ព្រះ ១យ៉ូហាន៣:៣ «អស់អ្នកណាដែលមានសេចក្តីសង្ឃឹមយ៉ាងនេះដល់ទ្រង់ នោះក៏តែងជំរះសំអាតចិត្តខ្លួន ឲ្យដូចទ្រង់ដែលស្អាតដែរ» តើព្រះយេស៊ូវបានអធិស្ឋាន ទូលសូមដល់ព្រះវរបិតាយ៉ាងម៉េចខ្លះ? ព្រះយេស៊ូវទ្រង់បានអធិស្ឋានទូលសូមដល់ព្រះវរបិតា «...ឱព្រះវរបិតាដ៏បរិសុទ្ធអើយ ឯពួកអ្នកដែលទ្រង់បានប្រទានមកទូលបង្គំ នោះសូមទ្រង់រក្សាគេដោយព្រះនាមទ្រង់ផង ដើម្បីឲ្យគេបានរួមគ្នាតែមួយ ដូចជាយើងដែរ» (យ៉ូហាន១៧:១១) ព្រះបន្ទូលនេះពិតជាអស្ចារ្យមែន!

គម្ពីរអេភេសូរជំពូក៣ គឺជាបទគម្ពីរមួយដែលមានការលើកទឹកចិត្តយ៉ាងធំបំផុត នៅក្នុងព្រះគម្ពីរបរិសុទ្ធ ហើយខ្ញុំគិតថា ជាបទគម្ពីរមួយដ៏អស្ចារ្យ នឹងអស្ចារ្យបំផុត នៅក្នុងព្រះគម្ពីរបរិសុទ្ធ ដែលយើងត្រូវតែផ្តោតចំពោះៗ

អេភេសូរ ១:១៧ សេចក្តីអធិស្ឋានរបស់សាវកប៉ុល លោកបានអធិស្ឋាន ឲ្យយើងរាល់គ្នាបានរួចពីបាបដោយសារព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទ ហើយឲ្យបានជារបស់ផងទ្រង់ តាមបំណងព្រហ្មទ័យទ្រង់ «ដើម្បីនឹងសូមឲ្យព្រះនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង គឺជាព្រះវរបិតាដ៏មានសិរីល្អ បានប្រទានឲ្យអ្នករាល់គ្នាបានវិញ្ញាណបរិសុទ្ធ ដែលប្រោសឲ្យមានប្រាជ្ញា ហើយក៏បើកសំដែង ឲ្យដឹងពីដំណើរស្គាល់ទ្រង់ ដើម្បីឲ្យភ្នែកចិត្តរបស់អ្នករាល់គ្នា បានភ្លឺឡើង ប្រយោជន៍ឲ្យបានដឹងថា ដែលទ្រង់ហៅអ្នករាល់គ្នា នោះមានសេចក្តីសង្ឃឹមជាយ៉ាងណា ហើយដឹងថា សិរីល្អដ៏ប្រសើរក្រៃលែងនៃមរដកទ្រង់ ក្នុងពួកបរិសុទ្ធជាយ៉ាងណាផង» (ខ១៧-១៨)

នោះហើយជាសេចក្តីសង្ឃឹមដែលយើងមាន ដោយ «យើងដឹងថា កាលណាទ្រង់លេចមក នោះយើងនឹងបានដូចជាទ្រង់» ហើយយើងនឹងបានជាកូនរបស់ទ្រង់ គឺយើងនឹងធ្វើអ្វីៗ ដូចដែលទ្រង់ធ្វើដែរ ពីព្រោះយើងនឹងឃើញទ្រង់ដូចជាទ្រង់ដែរៗ នេះជាការដែលយើងត្រូវផ្តោតលើ ដើម្បីឲ្យគំនិតរបស់យើងត្រូវបានបំផុសឡើង ប្រយោជន៍ឲ្យបានទប់ទល់ទៅនឹងលោកីយ នឹងគ្រប់អំពើអាក្រក់ទាំងអស់ ហើយព្រះអម្ចាស់ទ្រង់នឹងដោះស្រាយគ្រប់ការអាក្រក់ទាំងអស់នោះៗ ចំណែកយើង ត្រូវធ្វើការអ្វី ដែលយើងត្រូវធ្វើៗ

សូមមើល ១១៨ ដែលត្រូវធ្វើ «...ដែលទ្រង់ហៅអ្នករាល់គ្នា នោះមានសេចក្តីសង្ឃឹមជាយ៉ាងណាណា ហើយថា សិរីល្អដ៏ប្រសើរក្រៃលែងនៃមរដកទ្រង់ ក្នុងពួកបរិសុទ្ធជាយ៉ាងណាផង ហើយថាព្រះចេស្តាដ៏ខ្លាំងលើសលន់របស់ទ្រង់ដល់យើងរាល់គ្នាដែលជឿជាយ៉ាងណាដែរ តាមដែលកំឡាំងទ្រង់ដ៏មានឫទ្ធិបានពូកែនឹងធ្វើ» (១១៨-១៩)ៗ

ដូចដែលបងប្អូនទាំងអស់គ្នាធ្លាប់បានឮខ្ញុំ បង្រៀនពីមុនមកហើយថា ខ្ញុំចូលចិត្តបំផុតព្រះបន្ទូលដែលនៅក្នុងគម្ពីរអេភេសូរជាងបទគម្ពីរឯទៀតៗ នេះគឺជាផ្នែកដែលបំផុសគំនិត នឹងលើកស្ទួយបំផុតក្នុងគម្ពីរសញ្ញាថ្មីទាំងមូល-តាមគំនិត នឹងបទពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្ញុំ នៅពេលខ្ញុំមានបញ្ហា ហើយពេលខ្ញុំជួបការលំបាក នេះគឺជាបទគម្ពីរ ដែលតែងតែឲ្យខ្ញុំបែរទៅឯព្រះ ហើយនោះមិនមែនជាខ្ញុំទេ គឺជាព្រះវិញ ដែលទ្រង់បណ្តាលៗ

អេភេសូរ៣:១២ «ដោយហេតុនោះបានជាខ្ញុំលុតជង្គង់ នៅចំពោះព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើងរាល់គ្នា ដែលគ្រប់ទាំងគ្រួនៅស្ថានសួគ៌ ហើយនៅផែនដី មាននាមត្រកូលពីទ្រង់មក...[ដោយសារវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ដែលនៅក្នុងយើងរាល់គ្នាបាន ឃាត់ឃាំងការអាក្រក់របស់លោកីយដែលនៅជុំវិញយើង ហើយឲ្យយើងផ្តោតចិត្ត គំនិត របស់យើងទៅលើការត្រាស់ហៅរបស់យើង]...ដោយសារវិញ្ញាណបរិសុទ្ធរបស់ទ្រង់ តាមសិរីល្អនៃទ្រង់ដ៏ប្រសើរក្រៃលែង ...[ព្រះទ្រង់គង់ក្នុងយើងដោយសារព្រះគ្រីស្ទ]...ឲ្យព្រះគ្រីស្ទបានសណ្ឋិតក្នុងចិត្តអ្នករាល់គ្នា ដោយសារសេចក្តីជំនឿ ប្រយោជន៍ឲ្យអ្នករាល់គ្នាបានចាក់ឫស ហើយតាំងមាំមួនក្នុងសេចក្តីស្រឡាញ់ ដើម្បីឲ្យអាចនឹងយល់ ជាមួយនឹងពួកបរិសុទ្ធទាំងអស់គ្នា ពីទទឹង បណ្តោយ ជំរៅ នឹងកំពស់នៃសេចក្តីស្រឡាញ់នោះ» (១១២-១៨)

ដូច្នេះ ត្រូវឲ្យយើងស្រឡាញ់ដល់ព្រះអម្ចាស់នៃយើង «ឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង អស់អំពីគំនិត ហើយអស់អំពីកំឡាំងឯង» (ម៉ាកុស១២:៣០)

សាវកប៉ុលបានសរសេរថា «ដើម្បីឲ្យអាចនឹងយល់ ជាមួយពួកបរិសុទ្ធទាំងអស់គ្នា ពីទទឹង

បណ្ដោយ នឹងកំពស់នៃសេចក្ដីស្រឡាញ់នោះ ...[ចំណេះដឹង នៃផែនការរបស់ព្រះ នឹងការត្រាស់ហៅរបស់ព្រះ] ...ហើយឲ្យបានស្គាល់សេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ទដ៏រកគិតមិនយល់ ប្រយោជន៍ឲ្យអ្នករាល់គ្នាបានពេញដល់គ្រប់ទាំងសេចក្ដីពោរពេញរបស់ផងព្រះ»( អេភេសូរ៣:១៨-១៩)

ឥឡូវនេះ ខ្ញុំដឹងថា វិញ្ញាណបរិសុទ្ធរបស់ព្រះដែលនៅក្នុងចិត្ត នឹងក្នុងគំនិតរបស់អ្នក នឹងជួយរាំងលោកីយ ហើយដកយកអស់ទាំងអំពើអាក្រក់ទាំងអស់ចេញពីអ្នក ហើយបង្រួបបង្រួមចិត្តអ្នក គំនិត នឹងវិញ្ញាណអ្នក ជាមួយព្រះអម្ចាស់ ដែលទ្រង់ប្រទានដល់អ្នក ហើយអ្នកក៏ដឹងដែរថា បានកើតឡើងដល់អ្នក ដូចដែលបានកើតឡើងដល់ខ្ញុំដែរ។

ខាងក្រោមនេះជាកូនសោ ២៦០ «ឯព្រះដែលទ្រង់អាចនឹងធ្វើហួសសន្ធឹក... [សេចក្ដីដែលភ្នែកមិនដែលឃើញ ត្រចៀកមិនដែលឮ ហើយចិត្តនឹកមិនដែលដល់ គឺសេចក្ដីនោះឯងដែលព្រះបានរៀបចំទុក សំរាប់ពួកអ្នកដែលស្រឡាញ់ទ្រង់]...លើសជាងអស់ទាំងសេចក្ដីដែលយើងសូម ឬគិតក្ដី តាមព្រះចេស្ដា ដែលបណ្ដាលក្នុងយើងរាល់គ្នា នោះសូមឲ្យទ្រង់បានសិរីល្អ នៅក្នុងពួកជំនុំ ដោយសារព្រះគ្រីស្ទយេស៊ូវ រហូតដល់គ្រប់ទាំងដំណមនុស្ស នៅអស់កល្បជានិច្ចរៀងរាបតទៅ» អាម៉ែន ( ២០-២១)

ឱ បងប្អូនស្ងួនភ្ងាអើយ យើងអាចរស់នៅលើលោកីយនេះបាន ដោយផ្ដោតលើការត្រាស់របស់ព្រះអម្ចាស់នៃយើង។

បទគម្ពីរយោង

១. អេសាយ៥:២០
២. អេសាយ៣:១២
៣. អេសាយ៥:២០-២៤
៤. រ៉ូម ១:១៨-៣២
៥. ម៉ាថាយ៧:១៥-២៣
៦. ១យ៉ូហាន២:៣-៤
៧. ១កូរិនថូស ២:៩-១៤
៨. រ៉ូម៥:៦-១០
៩. ម៉ាថាយ២២:១៤
១០. យ៉ូហាន៦:៤៤
១១. ២ពេត្រុស៣:១៨
១២. ២ពេត្រុស១:១០; ២-៧
១៣. ១យ៉ូហាន៣:១
១៤. ១កូរិនថូស១:៣-៩; ២៦-៣០
១៥. ១កូរិនថូស៦:៩-១១
១៦. លូកា៥:៣២
១៧. អេភេសូរ២:២-៥
១៨. អេភេសូរ១:១៧-១៩
១៩. អេភេសូរ៣:១៤-២១

ព្រះយេស៊ូវមានបន្ទូលថា «...មនុស្សមិនមែនរស់ ដោយសារតែនំប៉័ង...[ឬបាយ]...ប៉ុណ្ណោះទេ
គឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋព្រះមកដែរ»

ម៉ាថាយ៤:៤

"It is written, 'Man shall not live by bread alone, but by every word that proceeds out of the mouth of God."

**Matthew 4:4, AFV.**

«ចូរខំប្រឹងសិក្សា ទុកជាមនុស្សដែលល្បងលជាប់ ជាអ្នកធ្វើការ ដែលមិនត្រូវខ្មាសឡើយ
ដោយកាត់ស្រាយ ព្រះបន្ទូលនៃសេចក្តីពិតយ៉ាងត្រឹមត្រូវ»

២ធីម៉ូថេ២:១៥

"Diligently *study* to show yourself approved unto God, a workman who does not *need to be* ashamed, rightly dividing the Word of the truth;"

2 Timothy 2:15, AFV.

«គឺជាវិញ្ញាណដែលឲ្យមានជីវិត រូបសាច់គ្មានប្រយោជន៍អ្វីទេ ឯពាក្យដែលខ្ញុំនិយាយនឹងអ្នក
រាល់គ្នា នោះត្រូវខាងវិញ្ញាណ នឹងជីវិតវិញ»

យ៉ូហាន៦:៦៣

"It is the Spirit that gives life; the flesh profits nothing. The words that I speak to you, *they* are spirit and *they* are life."

**John 6:63, AFV.**

# ក្រិត្យវិន័យ១០ប្រការ

នោះព្រះទ្រង់មានបន្ទូលនូវពាក្យទាំងនេះថា អញនេះគឺយេហូវ៉ា ជាព្រះនៃឯង ដែលបាននាំឯងចេញពីផ្ទះពួកបាវបំរើនៅស្រុកអេស៊ីព្ទមក

១. កុំឲ្យមានព្រះឯណាទៀតនៅចំពោះអញឲ្យសោះ

២. កុំឲ្យឆ្លាក់ធ្វើរូបណាសំរាប់ឯងឲ្យសោះ ក៏កុំឲ្យធ្វើរូបណាឲ្យដូចជាអ្វីនៅស្ថានសួគ៌ខាងលើ ឬនៅផែនដីខាងក្រោម ឬនៅក្នុងទឹកដែលទាបជាងដីផង ក៏កុំឲ្យក្រាបសំពះនៅចំពោះរបស់ទាំងនោះ ឬគោរពប្រតិបត្តិតាមនោះឡើយ ដ្បិតអញដែលជាយេហូវ៉ា ជាព្រះនៃឯង អញមានសេចក្តីប្រចណ្ឌ ក៏ទំលាក់ការទុច្ចរិតរបស់ឪពុកទៅលើកូនចៅរហូតដល់ ៣ ហើយ៤ដំណផង ចំពោះអស់អ្នកណាដែលស្អប់អញ តែអញផ្តល់សេចក្តីសប្បុរស ដល់ទាំងពាន់ដំណ នៃពួកអ្នកដែលស្រឡាញ់ ហើយកាន់តាមបញ្ញត្តិរបស់អញទាំងប៉ុន្មានវិញ

៣. កុំឲ្យចេញព្រះនាមរបស់ព្រះយេហូវ៉ា ជាព្រះនៃឯង ជាអសារឥតការឡើយ ដ្បិតព្រះយេហូវ៉ាទ្រង់នឹងមិនរាប់ជាឥតទោសដល់អ្នកណា ដែលចេញព្រះនាមទ្រង់ ជាអសារឥតការនោះទេ

៤. ចូរឲ្យនឹកចាំពីថ្ងៃឈប់សំរាក ដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ ក្នុងរវាង៦ថ្ងៃ នោះត្រូវឲ្យឯងធ្វើអស់ទាំងការរបស់ឯងចុះ តែឯថ្ងៃទី៧ នោះគឺជាថ្ងៃឈប់សំរាកថ្វាយព្រះយេហូវ៉ាជាព្រះនៃឯងវិញ នៅថ្ងៃនោះមិនត្រូវធ្វើអ្វីឲ្យសោះ ទោះខ្លួនឯងឬកូនប្រុសកូនស្រីឯងក្តី ទោះបាវប្រុស ឬបាវស្រីឯងក្តី ទោះសត្វរបស់ឯង ឬអ្នកដទៃ ដែលនៅផ្ទះឯងក្តី ដ្បិតក្នុង៦ថ្ងៃព្រះយេហូវ៉ាទ្រង់បានធ្វើផ្ទៃមេឃ ផែនដី ហើយនឹងសមុទ្រ ព្រមទាំងរបស់សព្វសារពើនៅស្ថានទាំងនោះដែរ រួចដល់ថ្ងៃទី៧ ទ្រង់ឈប់សំរាក ហេតុនោះបានជាព្រះយេហូវ៉ាទ្រង់បានប្រទានពរដល់ថ្ងៃឈប់សំរាក ហើយក៏ញែកចេញជាបរិសុទ្ធ

៥. ចូរឲ្យគោរពប្រតិបត្តិដល់ឪពុកម្តាយ ដើម្បីឲ្យបានអាយុវែងនៅក្នុងស្រុក ដែលព្រះយេហូវ៉ា ជាព្រះនៃឯងទ្រង់ប្រទានឲ្យ

៦. កុំឲ្យសំឡាប់មនុស្សឲ្យសោះ

៧. កុំឲ្យផិតគ្នាឲ្យសោះ

៨. កុំឲ្យលួចប្លន់ឲ្យសោះ

៩. កុំឲ្យធ្វើជាទីបន្ទាល់ក្លែង ទាស់នឹងអ្នកជិតខាងខ្លួនឲ្យសោះ

១០. កុំឲ្យលោភចង់បានផ្ទះអ្នកជិតខាងខ្លួនឲ្យសោះ ក៏កុំឲ្យលោភចង់បានប្រពន្ធកូនគេ ឬបាវប្រុសបាវស្រីគេក្តី ឬគោ លា ឬរបស់អ្វីផងអ្នកជិតខាងខ្លួនឲ្យសោះ